ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# ឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ (កម្រិតទី២) នៃយុទ្ធសាស្ត្រ ស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាន

២០១៧

រចនាទំព័រដោយ៖ © UNICEF Cambodia/2017/Youra Soeum and Nova

គំនូរ និងរូបភាព៖ © Save the Children
© Ministry of Women's Affairs

រាល់ការផលិតឡើងវិញនូវផ្នែកណាមួយនៃឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ ( កម្រិតទី ២ ) នៃយុទ្ធសាស្រ្តស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាននេះ ចាំបាច់ត្រូវមានការអនុញ្ញាត។

**សូមទំនាក់ទំនង៖**
ក្រុមការងារបច្ចេកទេសស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននៃក្រសួងកិច្ចការនារី

**អាសយដ្ឋាន៖**
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ( +៨៥៥ ) ២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨

រាជធានីភ្នំពេញ ឆ្នាំ២០១៧

# អារម្ភកថា

យុទ្ធសាស្រ្ត " ការចិញ្ចឹមកូនបែបវិជ្ជមាន " ឆ្នាំ២០១៧-២០២១ បានអភិវឌ្ឍឡើងដោយផ្អែកតាមយុទ្ធសាស្ត្រទី១ ស្តីពីការទប់ស្កាត់បឋម ត្រង់ចំណុចគ្រួសារ និងកូនៗ នៃផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្រ្តី ទី២ ( ២០១៤-២០១៨ ) ដោយមានការសម្របសម្រួលពីក្រសួងកិច្ចការនារី និងចូលរួមផ្តល់បច្ចេកទេស និងយោបល់កែលម្អ ពីក្រុមការងារបច្ចេកទេសថ្នាក់ជាតិ រួមមានក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដោយផ្តោតទៅលើឧបករណ៍ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំនួន ៣ កម្រិតផ្សេងៗគ្នា។ ឧបករណ៍ផ្សព្វផ្សាយសកល ( កម្រិតទី១ ) នៃយុទ្ធសាស្រ្ត ស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាន បានរៀបចំរួចរាល់ ដោយមានការឯកភាព និងចុះហត្ថលេខាទទួលស្គាល់ពីថ្នាក់ដឹកនាំក្រសួងកិច្ចការនារី។

ជាមោទនភាពមួយថ្មីបន្ថែមទៀតរបស់នាយកដ្ឋានស្ត្រី និងការអប់រំ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមរបស់ក្រសួងកិច្ចការនារី ដែលបានរៀបចំឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ ( កម្រិតទី២ ) នៃយុទ្ធសាស្រ្តស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាន។ កន្លងមកនៅប្រទេសកម្ពុជាកុមារ ដែលមានអាយុចាប់ពី0 ដល់ក្រោម ១៨ឆ្នាំ ទទួលរងផលអវិជ្ជមានជាច្រើនពីសំណាក់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងពីអ្នកដែលរស់នៅជុំវិញខ្លួនដូចជា ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ ឬការមិនយកចិត្តទុកដាក់។ ទង្វើទាំងអស់នេះអាចបណ្តាលមកពីមូលហេតុជាច្រើនដូចជា ទម្លាប់ ឥរិយាបថ និងការប្រព្រឹត្តរបស់សង្គម ដែលបានអនុវត្តតៗគ្នាជាយូរយាណាស់មកហើយ ដោយសារកង្វះខាតការយល់ដឹងអំពីសិទ្ធិកុមារ និងភាពក្រីក្រ។ កត្តាទាំងនេះ អាចញ៉ាំងឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនធំធ្លាប់សម្តែងឡើងនូវសកម្មភាពមិនសមរម្យទៅលើកុមារដូចជា ការគំរាមកំហែង មិនអើពើ ឬមិនយកចិត្តទុកដាក់ មិនឱ្យតម្លៃ និងមិនផ្តល់ភាពកក់ក្តៅលើកុមារ ឬអាចបញ្ជូនកុមារទៅរស់នៅឆ្ងាយពីគ្រួសារ ឬក្នុងមណ្ឌលថែទាំ។

ឯកសារនេះ មានគោលបំណងបង្កើនចំណេះដឹង និងលើកកម្ពស់ការយល់ដឹងអំពី ការចិញ្ចឹមកូនបែបវិជ្ជមាន និងផ្លាស់ប្តូរទម្លាប់ ឥរិយាបថ និងការប្រព្រឹត្តរបស់គ្រួសារ និងសង្គម ដែលគាំទ្រដល់ការចិញ្ចឹមកូន ដែលបានអនុវត្តដោយការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ និងអំពើហិង្សា ព្រមទាំងលើកកម្ពស់ឥរិយាបថស្វែងរកជំនួយ ឆន្ទៈ និងចំណាប់អារម្មណ៍ចំពោះកិច្ចគាំទ្រដល់ការចិញ្ចឹមកូនបែបវិជ្ជមាន។ ក្នុងនោះក៏ត្រូវកំណត់រកឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលត្រូវការការគាំទ្របន្ថែមសម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ មន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្តគ្រប់លំដាប់ថ្នាក់ដែលធ្វើការងារពាក់ព័ន្ធនឹងកុមារគប្បីចូលរួមបង្កើនចំណេះដឹងមូលដ្ឋាន និងលើកកម្ពស់ការចិញ្ចឹមកូនបែបវិជ្ជមានឱ្យមាននិរន្តរភាព និងជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហ៊ូ~សាមិត្ត

# សេចក្តីថ្លែងអំណរគុណ

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) និងអង្គការ Save the Children ចំពោះកិច្ចគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស ដ៏ថ្លៃថ្លាតាមរយៈដំណើរការអភិវឌ្ឍ ឧបករណ៍បណ្តុះបណ្តាល កំណត់គោលដៅ (កម្រិតទី២) នៃយុទ្ធសាស្ត្រស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននេះ។ សូមថ្លែងអំណរគុណចំពោះ ជំនួយហិរញ្ញវត្ថុរបស់ទីភ្នាក់ងារជំនួយអាមេរិក (USAID) និងទីភ្នាក់ងារសម្រាប់កិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍វេស្ស តាមរយៈ Save the Children Norway។

សូមថ្លែងអំណរគុណជាពិសេសចំពោះ **លោកជំទាវ ហ៊ូ សាមិត្ថ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី **លោកជំទាវ ទេស ច័ន្ទសារឿន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី **លោកជំទាវ ញាណ សុចិត្រា** អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមក្រសួងកិច្ចការនារី ដែលតែងតែផ្តល់ការគាំទ្រ សម្របសម្រួល លើកទឹកចិត្ត និងផ្តល់អនុសាសន៍ក្នុងការរៀបចំ និងអភិវឌ្ឍឧបករណ៍បណ្តុះបណ្តាល កំណត់គោលដៅ (កម្រិតទី២) នៃយុទ្ធសាស្ត្រស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននេះ។

សូមថ្លែងអំណរគុណផងដែរចំពោះក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) និងអង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា (ICS-SP) ដែលបានចូលរួមផ្តល់ជាបច្ចេកទេសក្នុងការរៀបចំ និងកែសម្រួលឧបករណ៍បណ្តុះបណ្តាល កំណត់គោលដៅ (កម្រិតទី២) នៃយុទ្ធសាស្ត្រស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននេះកន្លងមក។ ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់រួមមាន៖

## ក្រសួងកិច្ចការនារី

- **លោក ម៉ែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម
- **លោកស្រី នុំ បូផារី** ប្រធាននាយកដ្ឋានស្ត្រី និងការអប់រំ
- **លោកស្រី តែ ដាលីន** អនុប្រធាននាយកដ្ឋានស្ត្រី និងការអប់រំ
- **លោកស្រី ជិន ទិត្យទីនី** ប្រធានការិយាល័យអប់រំកុមារតូច
- **កញ្ញា គឹម សុខ័ណ្ឌរី** ប្រធានការិយាល័យលើកកម្ពស់ការអប់រំស្ត្រី និងកុមារី
- **លោកស្រី សឿង សុខចំរើន** អនុប្រធានការិយាល័យអប់រំសុខុមាលភាពសង្គម
- **កញ្ញា អ៊ុក ច័ន្ទស៊ីថា** អនុប្រធានការិយាល័យអប់រំកុមារតូច

## ក្រសួងព័ត៌មាន

- **លោកស្រី នង ធូក** អគ្គនាយករងទូរទស្សន៍ជាតិកម្ពុជា

## ក្រសួងមហាផ្ទៃ

- **លោក មិន ស៊ីថា** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- **លោក សារូ រដ្ឋជាតិ** អនុប្រធានការិយាល័យផែនការ ក្រុង ស្រុក ឃុំ សង្កាត់

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- លោកស្រី វ៉ាន់ កញ្ញា អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ
- លោកស្រី ស៊ាន ប៉ូលីន អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម
- លោកស្រី ជា សុមាលី ប្រធានការិយាល័យ
- លោក កែវ សុម៉ែ ប្រធានការិយាល័យ

## ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- លោកស្រី រស់ ដារី ប្រធានការិយាល័យ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- លោកស្រី ពេជ្រ ស្គាសិរី អនុប្រធាននាយកដ្ឋានពេទ្យការងារ

## ក្រសួងអប់រំ យុវជន និងកីឡា

- លោកស្រី រស់ សេដ្ឋា ប្រធានការិយាល័យនាយកដ្ឋានអប់រំកុមារតូច
- លោកស្រី ថោង ច័ន្ទឆដា អនុប្រធានការិយាល័យនាយកដ្ឋានអប់រំកុមារតូច
- លោកស្រី អ៊ាម ផារីរ័ត្ន មន្ត្រីនាយកដ្ឋានបឋមសិក្សា
- លោកស្រី ស៊ឹង សុវណ្ណ មន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## ក្រសួងសុខាភិបាល

- លោកស្រី ស្វាយ សារី មន្ត្រីកម្មវិធីជាតិអាហារូបត្ថម្ភ

## អង្គការបុគ្គាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា (ICS-SP)

- លោក ឆាយ វីរ៉ូឌីន នាយក
- លោកស្រី ប៊ូ មករា បុគ្គលិកបណ្តុះបណ្តាល

## អង្គការសេវាសង្គមកិច្ចកម្ពុជា (SSC)

- លោក អ៊ុក ប៊ុនធឿន ប្រធានកម្មវិធីបណ្តុះបណ្តាល

## អង្គការយូនីសេហ្វ

- លោក រតនៈ ជីវិត មន្ត្រីឯកទេសផ្នែកកិច្ចការពារកុមារ

## អង្គការ Save the Children

- លោកស្រី លន់ បរមី ប្រធានកម្មវិធីការការពារកុមារ
- លោក អេង ហុក មន្ត្រីកម្មវិធីការការពារកុមារ

# មាតិកា


**សេចក្តីផ្តើម**..........១

**វគ្គទី១ ជំនួបដំបូង**..........៣

**វគ្គទី២**..........១៩

មេរៀនទី១៖ ការការពារកុមារ

**វគ្គទី៣**..........៥១

មេរៀនទី២៖ សុខុមាលភាពឪពុកម្តាយ

**វគ្គទី៤**..........៨១

មេរៀនទី៣៖ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ

**វគ្គទី៥**..........៩៧

មេរៀនទី៤៖ កាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន

**វគ្គទី៦**..........១៤៥

មេរៀនទី៥៖ របៀបនៃការចិញ្ចឹមកូន

**វគ្គទី៧**..........១៦១

មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (១)

**វគ្គទី៨**..........១៨៧

មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (២)

**វគ្គទី៩**..........២៣៩

មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៣)

**វគ្គទី១០**..........២៦៧

មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៤)

**វគ្គទី១១**..........២៨៩

មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៥)

**វគ្គទី១២ ជំនួបចុងក្រោយ**..........៣០៧

# សេចក្តីផ្តើម

ឪពុកម្តាយគ្រប់រូបតែងតែចង់បាននូវអ្វីៗដែលល្អសម្រាប់កូនៗរបស់ខ្លួន។ ពួកគាត់សង្ឃឹមថានៅពេលដែលកូនៗធំឡើង ពួកគេនឹងមានសុខភាពល្អ សប្បាយរីករាយ មានទំនុកចិត្តក្នុងខ្លួន មានចំណេះដឹង និងជំនាញសម្រាប់បង្កើត និងឧបត្ថម្ភគ្រួសារ ព្រមទាំងបន្តនូវប្រពៃណី និងវប្បធម៌របស់ពួកគាត់។

ការចិញ្ចឹមកូនមិនមែនជាកិច្ចការសាមញ្ញនោះទេ គឺទាមទារឱ្យមានភាពអត់ធ្មត់ ការគ្រប់គ្រងអារម្មណ៍ គោលដៅជាក់លាក់ និងការផ្តល់ក្តីស្រឡាញ់ដោយឥតលក្ខខណ្ឌ រួមទាំងជំនាញក្នុងការដោះស្រាយបញ្ហាទៀតផង។ ឪពុកម្តាយមួយចំនួន ធំធាត់ក្នុងគ្រួសារដែលមានស្ថានភាពងាយរងគ្រោះ និងមិនមានសុភមង្គលពិតប្រាកដ ពួកគាត់នឹងមិនមានចំណេះដឹង និងជំនាញក្នុងការចិញ្ចឹមកូនឱ្យបានល្អនោះទេ។

ក្រសួងកិច្ចការនារីបានបង្កើត **ឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ** (**កម្រិតទី២**) នេះឡើងដើម្បីបង្កើនចំណេះដឹងដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំពីវិធីក្នុង**ការចិញ្ចឹមកូនបែបវិជ្ជមាន** ។

ឧបករណ៍នេះ បានបង្ហាញនូវខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ ងាយស្រួលក្នុងការទទួលយក និងប្រើប្រាស់ ហើយកូន ឬកុមាររបស់ពួកគាត់ក៏ចូលចិត្តរបៀបនៃការប្រៀនប្រដៅកូនបែបនេះដែរ ដោយសារតែពួកគាត់មានអារម្មណ៍ថា ទទួលបានក្តីស្រឡាញ់ពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងអាចរៀនសូត្រឱ្យក្លាយជាកូន ឬកុមារដែលមានអាកប្បកិរិយា និងការប្រព្រឹត្តល្អ ។
- កាត់បន្ថយទំហំគ្រោះថ្នាក់ និងការឈឺចាប់ដែលកូន ឬកុមារខ្លះទទួលបានដោយសារតែឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំធ្លាប់ប្រើអំពើយង់ឃ្នង និងឈឺចាប់ ក្នុងគោលបំណងចិញ្ចឹមពួកគាត់ឱ្យក្លាយជាមនុស្សល្អ។ កូន ឬកុមារដែលត្រូវបានចិញ្ចឹមដោយមិនមានហិង្សា គឺអាចមានការលូតលាស់ និងអភិវឌ្ឍរាងកាយ អារម្មណ៍ និងសតិបញ្ញាបានល្អ ហើយនៅពេលដែលពួកគេធំឡើង គឺអាចមានអាកប្បកិរិយាល្អ មានទំនាក់ទំនងល្អក្នុងសង្គម និងអាចដោះស្រាយបញ្ហាដោយអហិង្សា។ ឧបករណ៍នេះគឺសម្រាប់បណ្តុះបណ្តាលដល់ក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានកូន ឬកុមារនៅក្នុងបន្ទុកហើយងាយរងគ្រោះ ឬរងគ្រោះដោយសារការរំលោភបំពាន និងអំពើហិង្សា។

ក្រុមឪពុកម្តាយ ដែលមានសមាជិកចូលរួមចន្លោះពី ១៥ ទៅ ២៥នាក់ ទាំងបុរស និងស្ត្រី នៅក្នុងសហគមន៍នឹងត្រូវបានអញ្ជើញឱ្យជួបជុំគ្នាជាទៀងទាត់ដើម្បីស្តាប់ មើល និងរៀនសូត្រអំពីផ្នែកផ្សេងៗ នៃការចិញ្ចឹមកូនបែបវិជ្ជមាន។ អ្នកស្ម័គ្រចិត្តដែលទទួលការបណ្តុះបណ្តាលទាំងខ្លឹមសារ និងវិធីសាស្ត្រសម្របសម្រួល នឹងសម្របសម្រួលអំពីមេរៀននានា ដោយប្រើការពិភាក្សាជាដៃគូ ឬក្រុមតូច ការប្រមូលផ្តុំគំនិត សំណួរ ចម្លើយ និងការប្រើបដាផ្ទាំងធំៗ ដើម្បីបណ្តុះបណ្តាល។ ការជួបជុំគ្នានេះមានរយៈពេលប្រហែល ១២០ ទៅ ១៦០នាទី ដោយបានបញ្ចូលម៉ោងសម្រាប់អ្នកចូលរួមសួរសំណួរ និងឆ្លុះបញ្ចាំងអំពីបទពិសោធន៍របស់ខ្លួនកាលពីនៅជាកុមារភាព និងពេលក្លាយជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។

**ឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ (កម្រិតទី២)** ត្រូវបានរៀបចំឡើងជា ៦ មេរៀន និងចែកចេញជា ១២វគ្គតៗគ្នា មានន័យថា អ្នកសម្របសម្រួលត្រូវលើកយកមេរៀនតាមលំដាប់លំដោយ សម្រាប់យកទៅបណ្តុះបណ្តាលដល់ក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលបានជ្រើសរើស ហើយពួកគាត់នឹងត្រូវចូលរួមចាប់តាំងពីវគ្គដំបូងរហូតដល់វគ្គបញ្ចប់ផងដែរ ។

វគ្គទាំង១២ នៅក្នុងឧបករណ៍បណ្តុះបណ្តាលកំណត់គោលដៅ (កម្រិតទី២) នេះរួមមាន៖

**វគ្គទី១** ជំនួបដំបូង

**វគ្គទី២** ការការពារកុមារ

**វគ្គទី៣** សុខុមាលភាពរបស់ឪពុកម្តាយ

**វគ្គទី៤** ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ

**វគ្គទី៥** កាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន

**វគ្គទី៦** របៀបនៃការចិញ្ចឹមកូន

**វគ្គទី៧** ការប្រៀនប្រដៅកូនបែបវិជ្ជមាន (១)៖ គោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់

**វគ្គទី៨** ការប្រៀនប្រដៅកូនបែបវិជ្ជមាន (២)៖ យល់អំពីការគិត និងអារម្មណ៍
(កុមារអាយុចន្លោះពី ០ឆ្នាំ ដល់ ១២ឆ្នាំ)

**វគ្គទី៩** ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៣)៖ យល់អំពីការគិត និងអារម្មណ៍
(កុមារអាយុចន្លោះពី ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ)

**វគ្គទី១០** ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៤)៖ ដោះស្រាយបញ្ហា
(កុមារអាយុចន្លោះពី ០ឆ្នាំដល់ ១២ឆ្នាំ)

**វគ្គទី១១** ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៥)៖ ដោះស្រាយបញ្ហា
(កុមារអាយុចន្លោះពី ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ)

**វគ្គទី១២** ជំនួបចុងក្រោយ

# វគ្គទី១
# ជំនួបដំបូង

## សេចក្ដីផ្ដើម

ការយល់ដឹងពីគោលបំណងទូលំទូលាយ និងខ្លឹមសាររបស់កម្មវិធីនៃការចិញ្ចឹមកូនបែបវិជ្ជមាន នឹងជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការសម្រេចចិត្តក្នុងការចូលរួមកម្មវិធីនេះដោយពេញចិត្ត និងរីករាយ។

ជាទូទៅឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកូន ឬកុមារ តែងតែជួបជុំគ្នាទៅតាមឱកាស ឬកម្មវិធីផ្សេងៗក្នុងជីវិតប្រចាំថ្ងៃ។ ការជួបជុំគ្នានេះ ហាក់បីដូចជាមិនសូវបានលើកយករបៀប ឬបទពិសោធន៍ទាក់ទងនឹងការចិញ្ចឹមកូនមកចែករំលែក ឬរិះរកមធ្យោបាយនានាដើម្បីគាំទ្រ និងដោះស្រាយបញ្ហាដែលពួកគាត់តែងជួបប្រទះក្នុងការចិញ្ចឹមកូន។ ដូច្នេះហើយ វគ្គនេះនឹងជួយដល់អ្នកសម្របសម្រួល និងក្រុមទាំងមូលកសាងនូវទំនាក់ទំនងជិតស្និទ្ធដោយរីករាយនៅក្នុងការបង្កើតគោលការណ៍រួមគ្នា ការចែករំលែកនូវបទពិសោធន៍នានាអំពីការចិញ្ចឹមកូន ការរស់នៅប្រចាំថ្ងៃ ព្រមទាំងគោលបំណង និងខ្លឹមសារយ៉ាងទូលំទូលាយរបស់កម្មវិធីនៃការចិញ្ចឹមកូនបែបវិជ្ជមានដែលជាការរំពឹងទុករបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដែលបានចូលរួមក្នុងកម្មវិធីចាប់ពីវគ្គដំបូងរហូតដល់វគ្គបញ្ចប់។

| គោលបំណង | នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាចៈ<br>• កសាងទំនាក់ទំនង និងមានការទុកចិត្តគ្នាទៅវិញទៅមកប្រកបដោយភាពរីករាយ និងកក់ក្ដៅ<br>• បញ្ជាក់យ៉ាងច្បាស់ពីគោលបំណងនៃការចិញ្ចឹមកូនបែបវិជ្ជមាន និងធ្វើការសម្រេចចិត្តចូលរួមក្នុងកម្មវិធីតាំងពីវគ្គដំបូងរហូតដល់វគ្គបញ្ចប់<br>• ចែករំលែក និងឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួនទៅវិញទៅមកដែលទាក់ទងទៅនឹងការចិញ្ចឹមកូនកន្លងមក<br>• បង្កើតគោលការណ៍ក្រុម និងអនុវត្តសម្រាប់វគ្គបន្តបន្ទាប់។ |
|---|---|

| | |
|---|---|
| **រយៈពេល** | **១៣០ នាទី** |
| **សម្ភារៈដែលត្រូវការ** | • ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ<br>• កម្រាលសម្រាប់អ្នកចូលរួមអង្គុយ<br>• ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ<br>• គោលបំណងវគ្គដែលបានសរសេរលើក្រដាសផ្ទាំងធំ<br>• ឯកសារលំហាត់សាកល្បងមុនវគ្គ |

## ខ្លឹមសារលម្អិត

### ១. ទស្សនទានទាក់ទងការចិញ្ចឹមកូន ឬកុមារ

ការផ្ដល់នូវការយកចិត្តទុកដាក់ ការថែទាំ ការការពារ ការផ្ដល់ក្ដីស្រឡាញ់ ការផ្ដល់ចំណីអាហារ និងការអប់រំប្រៀនប្រដៅកូន ឬកុមារ គេហៅថា កាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារ។ នៅពេលដែលលោកអ្នកមានបំណងចង់បានកូន នោះលោកអ្នកចាប់ផ្ដើមមានការពាក់ព័ន្ធទៅនឹងកាតព្វកិច្ចនៃការចិញ្ចឹមកូនរួចជាស្រេចទៅហើយ (កាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានតាំងពីមុនកូនកើតមកម្លេះ)។ កាតព្វកិច្ចនៃការចិញ្ចឹមកូនរួមមាន ការបំពេញតម្រូវការមូលដ្ឋានមានដូចជា ផ្ដល់អាហារដែលមានជីវជាតិគ្រប់គ្រាន់ ផ្ដល់ទីជម្រកដែលមានសុវត្ថិភាព សម្លៀកបំពាក់សមរម្យ ការថែទាំសុខភាព អនាម័យ ផ្ដល់នូវក្ដីស្រឡាញ់ ភាពកក់ក្ដៅ និងការអប់រំជាដើម។ កាតព្វកិច្ចទាំងនេះទាមទារឱ្យមានការអត់ធ្មត់ និងជំនាញក្នុងការចិញ្ចឹមកូន មានន័យថា ឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំអាចផ្ដល់ការថែរក្សា គ្រប់គ្រង បណ្ដុះបណ្ដាលឱ្យកូនស្គាល់គុណតម្លៃដែលមានប្រយោជន៍ដូចជា ការប្រៀនប្រដៅបែបវិជ្ជមាន ការគោរពខ្លួនឯង និងអ្នកដទៃ និងការបង្កើតឱ្យមានបរិយាកាសប្រាស្រ័យទាក់ទងទូលំទូលាយ និងមានសុវត្ថិភាពសម្រាប់កូនៗ ឬកុមារ។

នៅក្នុងប្រទេសកម្ពុជា ទស្សនៈអំពីពាក្យថា "គ្រួសារ" គឺរាប់តាំងពីគ្រួសារផ្ទាល់ខ្លួន រួមបញ្ចូលទាំងជីដូនជីតា សាច់ញាតិ និងគ្រួសារធម៌ជាដើម។ កុមារមួយចំនួនធំមិនបានមើលថែដោយផ្ទាល់ពីឪពុកម្ដាយទេ គឺពួកគេត្រូវបានចិញ្ចឹម ឬមើលថែដោយជីដូនជីតា ឬសាច់ញាតិ។ ការចិញ្ចឹមបីបាច់កូន និងជីវិតជាកុមារភាពរបស់កុមារ អាចទទួលរងឥទ្ធិពលខ្លាំងពីវប្បធម៌ ព្រឹត្តិការណ៍ ឬរឿងរ៉ាវដែលកើតមានក្នុងជីវិត និងកត្តាបរិបទដទៃទៀតផងដែរ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប តែងតែចង់ឱ្យកូនរបស់ខ្លួនមានអនាគតល្អ ប៉ុន្តែជួនកាលគោលបំណងរបស់ពួកគាត់អាចមិនបានសម្រេចដូចអ្វីដែលពួកគាត់រំពឹងទុកនោះទេ ទាំងនេះអាចបណ្ដាលមកពីកត្តាជំណារពូជ គ្រួសារ និងសង្គមរស់នៅដោយសារតែពួកគាត់ខ្វះចំណេះដឹង ខ្វះជំនាញ ខ្វះលទ្ធភាពឬសមត្ថភាពដែលអាចជួយដល់កូនៗឱ្យក្លាយទៅជាមនុស្សដែលពួកគាត់ចង់បានយ៉ាងពិតប្រាកដ។

ឧទាហរណ៍៖ ទង្វើមួយចំនួនរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលប្រៀនប្រដៅកូន ឬកុមារដោយជេរ វាយ ប្រមាថ ស្តីបន្ទោស សំឡុត ដាក់ទណ្ឌកម្ម ឬដាក់ងារផ្សេងៗ អាចធ្វើឱ្យកូនៗមានអារម្មណ៍ថា ពួកគេមិនបានទទួលនូវសេចក្តីស្រឡាញ់ និងភាពកក់ក្តៅពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនោះទេ តែផ្ទុយទៅវិញ កូនៗ ឬកុមារបានទទួលនូវការឈឺចាប់ គុំគួន រឹងរូស អស់សង្ឃឹម ឬយកគំរូតាមទៅវិញទេ។ ដូចនេះ ការលើកទឹកចិត្តដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យឆ្លុះបញ្ចាំងអំពីបទពិសោធន៍ដែលបានជួបប្រទះ និងការប្រព្រឹត្តកន្លងមក ព្រមទាំងស្វែងយល់ពីផលប៉ះពាល់ដែលអាចកើតមានចំពោះកូន ឬកុមារ គឺជាមធ្យោបាយមួយដែលជួយឱ្យពួកគាត់អាចរៀន និងយល់ពីរបៀបដែលធ្វើឱ្យប្រសើរដល់ការចិញ្ចឹមកូនប្រកបដោយការពេញចិត្ត ឬស្របតាមបំណងដែលពួកគាត់ចង់បាន។

## ២. រចនាសម្ព័ន្ធ និងរយៈពេលសិក្សានៃកម្មវិធី

ការជួបគ្នារបស់ក្រុមឪពុកម្តាយ គឺអាស្រ័យទៅលើការយល់ព្រម និងឯកភាពរបស់ក្រុម ថាតើក្រុមនឹងជួបគ្នារៀងរាល់សប្តាហ៍ ឬពីរសប្តាហ៍ម្តង ឬមួយខែម្តង។ ហើយពេលវេលានៃការប្រជុំក្នុងវគ្គនីមួយៗមានរយៈពេលចន្លោះពី ១២០ ទៅដល់ ១៥០នាទី ហើយពេលសិក្សានៅក្នុងកម្មវិធីត្រូវបានរៀបចំជារចនាសម្ព័ន្ធដូចៗគ្នារួមមាន៖ ការស្វាគមន៍ ការកសាងក្រុម ការរំឭកមេរៀនចាស់ ការចាប់ផ្តើមមេរៀនថ្មី និងការឆ្លុះបញ្ចាំង។ កម្មវិធីទាំងមូលមាន ៦មេរៀន ដែលមានវត្ថុបំណងដូចខាងក្រោម៖

**មេរៀនទី ១៖ ការការពារកុមារ**

**គោលបំណង**

- កំណត់បានពីប្រភេទផ្សេងៗនៃអំពើហិង្សា និងការរំលោភបំពានលើកុមារ
- រៀបរាប់បានពីផលប៉ះពាល់នៃការរំលោភបំពានលើកុមារ
- កំណត់បាននូវឥរិយាបថដែលគួរធ្វើ និងមិនគួរធ្វើ ដើម្បីការពារកុមារពីការរំលោភបំពាន
- បង្កើនការយកចិត្តទុកដាក់ដល់កុមារដែលមានតម្រូវការពិសេស និងកុមារដែលមានពិការភាព។

**មេរៀនទី ២៖ សុខុមាលភាពឪពុកម្តាយ**

**គោលបំណង**

- ឆ្លុះបញ្ចាំងពីស្ថានភាពទូទៅនៃសុខុមាលភាពរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ
- កំណត់បាននូវភាពតានតឹងចិត្ត ព្រមទាំងវិធីសាស្ត្រដែលអាចបន្ធូរភាពតានតឹងចិត្តរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ
- កំណត់បាននូវភាពតានតឹងចិត្ត ព្រមទាំងវិធីសាស្ត្រដែលអាចបន្ធូរភាពតានតឹងចិត្តរបស់កុមារ
- ធ្វើការប្រាស្រ័យទាក់ទងជាមួយកូន ឬកុមារឱ្យមានប្រសិទ្ធភាព។

## មេរៀនទី ៣៖ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ

### គោលបំណង

- រៀបរាប់ពីហេតុផលនិងសារៈសំខាន់នៃការប្រាស្រ័យទាក់ទងក្នុងរង្វង់គ្រួសារ
- កត់សម្គាល់ និងយល់ពីអត្ថន័យនៃការប្រាស្រ័យទាក់ទងតាមរយៈកាយវិការ និងការនិយាយ
- ឆ្លុះបញ្ចាំងពីកម្រិតនៃការប្រាស្រ័យទាក់ទងក្នុងរង្វង់ក្រុមគ្រួសាររបស់ខ្លួន
- បង្ហាញពីការស្ដាប់ដោយយកចិត្តទុកដាក់ និងលើកទឹកចិត្តកូន ឬកុមារឱ្យមានជំនាញប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព។

## មេរៀនទី ៤៖ កាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កូន

### គោលបំណង

- វិភាគបាននូវអាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ
- លើកកម្ពស់ទម្លាប់ល្អ ឬរបៀបនៃការចិញ្ចឹមកូន ឬកុមារ និងផ្លាស់ប្ដូរនូវអាកប្បកិរិយាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ
- ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បំពេញកាតព្វកិច្ច និងគាំទ្រដល់កូន ឬកុមារ ដើម្បីឱ្យពួកគេមានការលូតលាស់ និងអភិវឌ្ឍបានល្អ
- បង្កើនការយកចិត្តទុកដាក់ដល់កូន ឬកុមារ ដែលមានតម្រូវការពិសេស និងកុមារដែលមានពិការភាព។

## មេរៀនទី ៥៖ របៀបនៃការចិញ្ចឹមកូន

### គោលបំណង

- កំណត់ពីអត្ថន័យ នៃការចិញ្ចឹមកូនបែបវិជ្ជមាន និងស្វែងយល់ពីរបៀបផ្សេងៗគ្នានៃការចិញ្ចឹមកូន
- វិភាគនូវអាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ ហើយបន្តអនុវត្តនូវអាកប្បកិរិយាដែលគួរធ្វើ និងផ្លាស់ប្ដូរនូវអាកប្បកិរិយាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ
- ស្វែងយល់ពីភាពខុសគ្នារវាងការដាក់ទណ្ឌកម្ម និងការអនុវត្តវិន័យ។

## មេរៀនទី ៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន

### គោលបំណង

- កំណត់ និងវិភាគអំពីចំណុចដែលត្រូវផ្សារភ្ជាប់រវាងគោលដៅរយៈពេលខ្លី និងគោលដៅយូរអង្វែង។
- ស្វែងយល់ពីការគិត និងអារម្មណ៍របស់កុមារ តាមរយៈការលូតលាស់ និងអភិវឌ្ឍរបស់កុមារដែលមានអាយុពី ០ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ
- ទទួលស្គាល់ពីសារៈសំខាន់នៃការផ្តល់ដែនកំណត់ និងអនុវត្តនូវវិធីនានាដែលមានប្រសិទ្ធភាពក្នុងការផ្តល់ដែនកំណត់សម្រាប់កូន
- ទទួលស្គាល់អំពីការគិត និងអារម្មណ៍នានា ដែលបណ្តាលឱ្យកូន ឬកុមារមានអាកប្បកិរិយាប្រឆាំងនឹងអ្វីៗដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបានរំពឹងទុក
- ទទួលស្គាល់ពីមូលហេតុនានានៃអាកប្បកិរិយាដែលពិបាកៗ តាមរយៈការអនុវត្តចំណេះដឹងនៃការលូតលាស់ និងអភិវឌ្ឍកុមារ
- ទទួលស្គាល់ថាកូនឬកុមារមានអាកប្បកិរិយាពិបាកនានាទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ហើយថែមទាំងរកឱ្យឃើញនូវមូលហេតុនៃអាកប្បកិរិយានោះ ដើម្បីជួយគាំទ្រដល់កូន ឬកុមារ រួមទាំងជួយឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងអារម្មណ៍ដែលប្រតិកម្មក្នុងខ្លួនផងដែរ
- ហាត់អនុវត្តដោះស្រាយបញ្ហាជាមួយកូន ឬកុមារដែលមានអាយុពី ០ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដោយប្រើគោលការណ៍សំខាន់ៗទាំង៥ និងធាតុផ្សំទាំង៤ នៃការចិញ្ចឹមកូនបែបវិជ្ជមាន។

## ៣. លក្ខខណ្ឌនៃការចូលរួម

- សមាជិកជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកូន ឬកុមារ នឹងត្រូវបានចងក្រងជាក្រុមៗនៅតាមភូមិ ឬសហគមន៍ ដើម្បីចូលរួមប្រជុំជាទៀងទាត់ដូចដែលបានកំណត់ និងឯកភាពពីអ្នកទាំងអស់គ្នា
- ក្រុមឪពុកម្តាយមួយក្រុមៗអាចមានចំនួនពី ១៥ ទៅ ២៥នាក់
- សមាជិកថ្មីមិនអនុញ្ញាតិឱ្យចូលរួម បន្ទាប់ពីការប្រជុំ បានចាប់ផ្តើមម្តង ឬពីរដងរួចហើយ
- អ្នកចូលរួមអាចប្តូរសមាជិកក្នុងគ្រួសារចូលរួមបាន តែត្រូវធានាថាគាត់បានចែករំលែកអ្វីដែលបានពិភាក្សាពីការប្រជុំ ជាមួយសមាជិកគ្រួសារ ដើម្បីអាចឱ្យគាត់តាមដាន និងទទួលបានចំណេះដឹងពេញលេញ។

# លំហាត់សាកល្បងមុនវគ្គ
# សម្រាប់ក្រុមឪពុកម្ដាយ (Pre-Test)
# (បំពេញក្នុងជំនួបដំបូង)

## លេខសម្គាល់៖..............................

កាលបរិច្ឆេទ ៖ ថ្ងៃទី............ខែ............ឆ្នាំ............

ទីកន្លែង ៖ ភូមិ....................ឃុំ....................

ស្រុក.......................ខេត្ត....................................

# គោលការណ៍ណែនាំ

មុននឹងចាប់ផ្ដើមមេរៀនយើងនឹងធ្វើលំហាត់មួយ ហើយលំហាត់នេះគឺគ្រាន់តែចង់ដឹងថា តើលោកអ្នកមានចំណេះដឹង ឬបទពិសោធន៍អ្វីខ្លះ ហើយត្រូវការអ្វីបន្ថែមទៀតដើម្បីជួយលោកអ្នកក្នុងការចិញ្ចឹមបីបាច់កូនឱ្យមានការលូតលាស់បានល្អ។ ចម្លើយរបស់លោកអ្នកនឹងត្រូវរក្សាការសម្ងាត់ សូមលោកអ្នកធ្វើការបំពេញតាមបទពិសោធន៍រស់នៅប្រចាំថ្ងៃរបស់លោកអ្នក។

សម្គាល់៖សូមគូសសញ្ញា (√) នៅក្នុងប្រអប់ចម្លើយទាំងឡាយណាដែលលោកអ្នកយល់ថាត្រឹមត្រូវ។

**១- តើឪពុកម្តាយត្រូវធ្វើអ្វីខ្លះសម្រាប់កូន ឬកុមារ?**

- ☐ ចុះសំបុត្រកំណើត និងបញ្ជូនកូនទៅរៀន
- ☐ ផ្តល់អាហារដែលមានជីវជាតិគ្រប់គ្រាន់
- ☐ វាយ ដើម្បីប្រៀនប្រដៅចំពោះកូនដែលមិនស្តាប់បង្គាប់
- ☐ ផ្តល់ភាពកក់ក្តៅ ក្តីស្រឡាញ់ និងធ្វើជាគំរូល្អ

**២- តើកូន ឬកុមារមានភារកិច្ចធ្វើអ្វីខ្លះនៅក្នុងគ្រួសារ?**

- ☐ ជួយធ្វើការងារផ្ទះ និងខិតខំរៀនសូត្រ
- ☐ លេង និងធ្វើសកម្មភាពតាមអ្វីដែលខ្លួនចង់ធ្វើ
- ☐ ប្រាប់ឪពុកម្តាយពេលមានទុក្ខកង្វល់
- ☐ ស្តាប់ និងធ្វើតាមដំបូន្មានល្អៗ ពីឪពុកម្តាយដើម្បីការពារខ្លួន

**៣- តើធ្វើយ៉ាងណាទើបដឹងថា មនុស្សម្នាក់កំពុងស្តាប់ដោយយកចិត្តទុកដាក់?**

- ☐ មើលមុខ ងក់ក្បាល បន្ទរពាក្យ សួរបញ្ជាក់
- ☐ សួរសំណួរត្រូវតាមសាច់រឿង
- ☐ សង្ខេបសាច់រឿងបាន
- ☐ ធ្វើការបណ្តើរ ស្តាប់បណ្តើរ

## ៤- តើការប្រាស្រ័យទាក់ទងក្នុងគ្រួសារ មានសារៈសំខាន់អ្វីខ្លះ ?

- ☐ ស្ដាប់បង្គាប់ និងធ្វើតាម ទោះបីមិនពេញចិត្តក៏ដោយ
- ☐ ទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក
- ☐ អាចស្វែងរកដំណោះស្រាយតាមតម្រូវការ
- ☐ ការពារកូនពីការរំលោភបំពានផ្សេងៗ និងការពារខ្លួន

## ៥- តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថាជាការរំលោភបំពានលើកុមារ ?

- ☐ វាយកូនដើម្បីឱ្យកូនស្ដាប់ដំបូន្មាន
- ☐ ប៉ះពាល់ប្រដាប់ភេទកុមារ ពេលលាងសម្អាត
- ☐ ចាប់បង្ខំ ឬរំលោភផ្លូវភេទកុមារ
- ☐ ទុកកុមារតូចឱ្យនៅផ្ទះតែម្នាក់ឯង

## ៦- តើការរំលោភបំពានកុមារ មានផលប៉ះពាល់អ្វីខ្លះ ?

- ☐ ចេះប្រុងប្រយ័ត្ន និងមានការអត់ធ្មត់
- ☐ ភ័យខ្លាច និងយល់សប្ដិអាក្រក់
- ☐ រាងកាយលូតលាស់មិនបានល្អ និងអាចពិការភាព
- ☐ រៀនមិនចេះ និងមិនចូលសាលា

**៧- តើឪពុកម្ដាយគួរធ្វើអ្វីខ្លះ ដើម្បីការពារកូនពីការរំលោភបំពាន ?**

- [ ] ណែនាំពីរបៀបការពារខ្លួន និងប្រាប់ពីល្បិចឆបោករបស់ជនខិលខូច
- [ ] ស្ដាប់កូន ឬកុមារឱ្យបានច្រើន
- [ ] ចាក់សោរកូនក្នុងផ្ទះ ជាជាងយកទៅផ្ញើសាច់ញាតិ
- [ ] ទុកវត្ថុអាចបង្កគ្រោះថ្នាក់ឱ្យផុតពីដៃកូន

**៨- នៅពេលដែលលោកអ្នកមានអារម្មណ៍មិនសប្បាយចិត្ត ឬតានតឹងចិត្ត តើលោកអ្នកធ្លាប់បានធ្វើអ្វីខ្លះ ?**

- [ ] ដកដង្ហើមឱ្យវែងៗ
- [ ] ដាំដំណាំ ឬធ្វើការងារផ្ទះផ្សេងៗ
- [ ] ជជែកលេងជាមួយអ្នកដទៃ
- [ ] ផឹកស្រា ឬជក់បារី

**៩- នៅពេលដែលកូន ឬកុមារមានអាកប្បកិរិយាមិនល្អ តើលោកអ្នកធ្លាប់បានធ្វើអ្វីខ្លះ ?**

- [ ] សម្លុត និងវាយកូន
- [ ] សួរ និងស្ដាប់ពីហេតុផល
- [ ] ពិភាក្សាជាមួយកូនដើម្បីរកដំណោះស្រាយ
- [ ] នាំកូនធ្វើសកម្មភាពផ្សេងៗ ដើម្បីបន្ធូរអារម្មណ៍

## ១០- តើសកម្មភាពអ្វីខ្លះដែលបង្ហាញថា ជាការផ្តល់ភាពកក់ក្តៅដល់កូន ?

- [ ] វាយ ហើយលួងលោមតាមក្រោយ
- [ ] នៅក្បែរកូននៅពេលដែលកូនត្រូវការ
- [ ] ស្តាប់កូននិយាយដោយយកចិត្តទុកដាក់
- [ ] ចំណាយពេលលេងជាមួយកូន

## ១១- តើការផ្តល់ភាពកក់ក្តៅមានសារៈសំខាន់អ្វីខ្លះ ?

- [ ] បង្កើនភាពស្និទ្ធស្នាលរវាងឪពុកម្តាយនឹងកូន
- [ ] កាត់បន្ថយជម្លោះ ឬអំពើហិង្សាក្នុងគ្រួសារ
- [ ] កូនមានទំនុកចិត្តក្នុងការប្រាប់រឿងកង្វល់របស់ខ្លួន
- [ ] ឪពុកម្តាយមានអាទិភាពក្នុងការសម្រេចចិត្តធ្វើអ្វីមួយ

## ១២- ពេលកូន ឬកុមារឈានចូលវ័យជំទង់ តើពួកគេមានការប្រែប្រួលអ្វីខ្លះ ?

- [ ] កុមារី (មានរដូវ ដើមទ្រូង និងត្រគៀករីកធំ) កុមារា (ប្តូរសំឡេង មានទឹកកាម ស្មារីកធំ)
- [ ] អារម្មណ៍ឆេវឆាវ និងមិនសូវស្តាប់បង្គាប់
- [ ] ចាប់អារម្មណ៍ជាមួយមិត្តភក្តិច្រើនជាងគ្រួសារ
- [ ] ចូលចិត្តធ្វើការងារផ្ទះ

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន៖

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (២០នាទី) | ▪ អ្នកសម្របសម្រួលរួមទាំងដៃគូ ធ្វើការណែនាំខ្លួនបន្ទាប់មកស្នើសុំអ្នកចូលរួមលេងល្បែងណែនាំខ្លួន ដើម្បីកសាងទំនាក់ទំនង និងទំនុកចិត្តលើគ្នាបន្ថែមទៀតតាមរយៈសកម្មភាពដូចខាងក្រោម៖<br>☞ ឱ្យអ្នកចូលរួមឈរជាក្រុមតាមចំនួនកូន (ក្រុមអ្នកមិនទាន់មានកូន កូន១ កូន២ កូន៣ ។ល។ បើមានអ្នកមិនទាន់រៀបការឈរជាមួយក្រុមមិនទាន់រៀបការ)<br>☞ ឈរជាជួរតាមលំដាប់អាយុពីតិចជាងគេទៅច្រើនជាងគេតាមក្រុមខាងលើ។ បន្ទាប់មក ស្នើសុំឱ្យអ្នកចូលរួមធ្វើការណែនាំខ្លួនម្តងម្នាក់ៗ ដោយប្រាប់អំពីឈ្មោះ ទីកន្លែងរស់នៅ មុខរបរ និងអ្វីដែលគាត់ចូលចិត្តបំផុត<br>▪ ស្នើសុំអ្នកចូលរួមឱ្យអង្គុយតាមកន្លែងរៀងៗខ្លួនវិញរួចបន្តសកម្មភាពបន្ទាប់។ |
| ២ | ការរំពឹងទុករបស់អ្នកចូលរួមក្នុងវគ្គនេះ | (១៥នាទី) | ▪ ចែកអ្នកចូលរួមជាក្រុមតូចៗ (៣ ទៅ ៤នាក់ ក្នុងមួយក្រុមរួចឱ្យគាត់ពិភាក្សា អំពីការរំពឹងទុករបស់ពួកគាត់ក្នុងការចូលរួមវគ្គទាំងមូល។<br>☞ ក្រុមនីមួយៗ ត្រូវជ្រើសរើសតំណាងក្រុមសម្រាប់កត់ត្រា រួចឡើងបង្ហាញទៅក្រុមទាំងមូល<br>▪ អ្នកសម្របសម្រួល កត់ត្រាការរំពឹងទុករបស់អ្នកចូលរួមដាក់ក្នុងក្រដាសផ្ទាំងធំ ដោយដាក់ការរំពឹងទុកទៅតាមក្រុមចំពោះការរំពឹងទុកណាដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នា។<br>**កំណត់សម្គាល់៖** អ្នកសម្របសម្រួលអាចរក្សាផ្ទាំងក្រដាសដែលសរសេរអំពីការរំពឹងទុកនេះដើម្បីធ្វើការពិភាក្សា និងប្រៀបធៀបជាមួយគោលបំណងនៃការជួបប្រជុំទាំងមូល និងការឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួននៅសកម្មភាពបន្ទាប់ទៀតបាន។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៣ | ណែនាំគោលបំណងវគ្គ | (១០នាទី) | ▪ អ្នកសម្របសម្រួលបង្ហាញពីចំណងជើងនៃវគ្គ (ដែលបានត្រៀមទុកជាស្រេច) រួចធ្វើការបង្ហាញពីគោលបំណងនៃការជួបជុំគ្នាថ្ងៃនេះដូចខាងក្រោម៖<br>☞ កសាងទំនាក់ទំនង និងបង្កើតភាពស្និទ្ធស្នាលជាមួយគ្នា<br>☞ ធ្វើលំហាត់សាកល្បងមុនពេលចាប់ផ្តើមវគ្គ<br>☞ ណែនាំ និងបង្ហាញពីគោលបំណងវគ្គទាំងមូល<br>☞ ចែករំលែក និងឆ្លុះបញ្ចាំងពីបទពិសោធន៍ផ្ទាល់ខ្លួនដែលទាក់ទងទៅនឹងការចិញ្ចឹមកូនកន្លងមក។<br>☞ បង្កើតគោលការណ៍ក្រុម និងអនុវត្តសម្រាប់វគ្គបន្តបន្ទាប់ |
| ៤ | លំហាត់សាកល្បងមុនវគ្គ | (៣០នាទី) | ▪ អ្នកសម្របសម្រួលចាប់ផ្តើមដោយពន្យល់ថា<br>☞ មុននឹងចាប់ផ្តើមមេរៀនយើងនឹងធ្វើលំហាត់មួយ ហើយលំហាត់នេះគឺគ្រាន់តែចង់ដឹងថា តើលោកអ្នកមានចំណេះដឹងអ្វីខ្លះ ហើយត្រូវការអ្វីបន្ថែមទៀតដើម្បីជួយលោកអ្នកក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារឱ្យមានការលូតលាស់បានល្អ។ ចម្លើយរបស់លោកអ្នកនឹងត្រូវរក្សាការសម្ងាត់ សូមលោកអ្នកធ្វើការបំពេញតាមបទពិសោធន៍រស់នៅប្រចាំថ្ងៃរបស់លោកអ្នក។<br>☞ សួរអ្នកចូលរួម បើមានអ្នកមិនចេះអក្សរ ឬមិនអាចអានបាន សរសេរបាន សូមឱ្យពួកគាត់អង្គុយមួយក្រុមដាច់ដោយឡែកពីអ្នកចេះអក្សរ ហើយអ្នកសម្របសម្រួលម្នាក់ទៀតជួយគាត់ក្នុងការឆ្លើយសំណួរ។<br>☞ ចែកឯកសារសំណួរឱ្យអ្នកចូលរួមធ្វើការបំពេញ រួចប្រាប់ថាការបំពេញសំណួរមានរយៈពេល ៣០នាទី។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៥ | ការឆ្លុះបញ្ចាំងអំពីភាពរីករាយ និងការលំបាករបស់ឪពុកម្ដាយ | (២៥នាទី) | ▪ ពន្យល់ថា ដោយសារតែយើងនឹងរៀនពីរបៀបនៃការចិញ្ចឹមកូនបែបវិជ្ជមាន ដូចនេះយើងនឹងពិភាក្សាពីបទពិសោធន៍ខ្លះៗក្នុងការចិញ្ចឹមកូនដែលលោកអ្នកអនុវត្តកន្លងមក។ អ្នកសម្របសម្រួលចាប់ផ្ដើមសួរសំណួរ៖<br>☞ តើឪពុកម្ដាយលោកអ្នកបានធ្វើអ្វីខ្លះ ដែលធ្វើឱ្យលោកអ្នកមានភាពរីករាយ ឬសប្បាយចិត្ត?<br>🗣 ចម្លើយរំពឹងទុក៖ ឱប ថើប លេងជាមួយ ទិញរបស់ឱ្យ និយាយពាក្យផ្អែមល្ហែម នៅជិតពេលខ្ញុំឈឺ ឬខ្លាចជាដើម។<br>▪ អ្នកសម្របសម្រួល ធ្វើការកត់ត្រាចំណុចសំខាន់ៗនៅលើក្រដាសផ្ទាំងធំ បន្ទាប់មកសួរសំណួរបន្ត៖<br>☞ តើឪពុកម្ដាយលោកអ្នកបានធ្វើអ្វីខ្លះ ដែលធ្វើឱ្យលោកអ្នកមិនសប្បាយចិត្ត ឬមិនពេញចិត្ត?<br>🗣 ចម្លើយរំពឹងទុក៖ វាយ បោចសក់ ស្ដីជេរ បន្ទោស សំឡុតគំរាមកំហែង បន្លាច ប្រដូចខ្ញុំទៅនឹងអ្វីដែលអាក្រក់ៗ ទុកខ្ញុំចោលជាដើម។<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រាចំណុចសំខាន់ៗនៅលើក្រដាសផ្ទាំងធំ បន្ទាប់មកសួរសំណួរបន្ត៖<br>☞ តើលោកអ្នកពេញចិត្តកិច្ចការអ្វីខ្លះ នៅក្នុងការចិញ្ចឹមបីបាច់កូន?<br>🗣 ចម្លើយរំពឹងទុក៖ បញ្ចុកអាហារ បំបៅកូន បំពេរកូន ងូតទឹកឱ្យកូន លេងជាមួយកូនជាដើម។<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រាចំណុចសំខាន់ៗនៅលើក្រដាសផ្ទាំងធំ បន្ទាប់មកសួរសំណួរបន្ត៖<br>☞ តើលោកអ្នកមានការលំបាកអ្វីខ្លះ នៅក្នុងការចិញ្ចឹមបីបាច់កូន?<br>🗣 ចម្លើយរំពឹងទុក៖ ពេលកូនយំ កូនឈឺ លួងកូនឱ្យគេង បោកកន្ទបកូន យកកូនទៅចាក់ថ្នាំបង្ការជាដើម។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលធ្វើការកត់ត្រាចំណុចសំខាន់ៗនៅលើក្រដាសផ្ទាំងធំ រួចធ្វើការសរុបគំនិតរបស់អ្នកចូលរួម។ បន្ទាប់មកធ្វើការពន្យល់បន្ថែម ជីវិតកុមារភាពដែលមានភាពរីករាយគឺមានឥទ្ធិពលវិជ្ជមានទៅលើជីវិត និងអារម្មណ៍របស់លោកអ្នកនៅពេលដែលលោកអ្នកធំឡើង។ ចំណែកឯកុមារភាពដែលមិនរីករាយក៏មានឥទ្ធិពលលើជីវិតផងដែរ ហើយឥទ្ធិពលនោះអាចជាឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន។ ក្នុងនាមជាឪពុកម្តាយត្រូវធ្វើអ្វីៗទាំងអស់ដែលទាក់ទងទៅនឹងការថែទាំ និងការផ្តល់ការគាំទ្រ ភាពកក់ក្តៅ សេចក្តីស្រឡាញ់ ថ្នាក់ថ្នមចំពោះកូនៗរបស់លោកអ្នក ដើម្បីឱ្យពួកគាត់មានកុមារភាពដ៏សែនរីករាយ និងការចងចាំរីករាយ ដែលអាចជួយឱ្យពួកគេអាចឈានទៅដល់ការសម្រេចបាននូវសក្តានុពលដ៏ពេញលេញ។<br>**កំណត់សម្គាល់៖** អ្នកសម្របសម្រួលគួរជួយឱ្យអ្នកចូលរួមបានត្រៀមខ្លួនជាមួយអារម្មណ៍ដូចជា ការឈឺចាប់ សោកស្តាយ បន្ទោសខ្លួនឯង ខកចិត្ត តានតឹង ខឹង ស្អប់ខ្លួនឯងជាដើម ដែលអាចកើតមានឡើងនៅពេលដែលពួកគាត់គិត និងឆ្លុះបញ្ចាំងអំពីអតីតកាលរបស់ពួកគាត់។ អ្វីដែលអាចធ្វើបានគឺ ជួយដល់អ្នកចូលរួមទទួលស្គាល់ពីការប៉ះទង្គិចនានា ដោយសុំឱ្យពួកគាត់ធ្វើលំហាត់ដកដង្ហើម។ វិធីសាស្ត្រមួយទៀតអ្នកសម្របសម្រួលអាចជួយឱ្យអ្នកចូលរួមវិលត្រឡប់មកពេលបច្ចុប្បន្នវិញ ដោយការស្នើឱ្យអ្នកចូលរួមរាប់ចំនួនរបស់របរនៅក្នុងបន្ទប់ សួរពីថ្ងៃ ខែ ឆ្នាំ និងសកម្មភាពដែលបានធ្វើនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ |
| ៦ | **ការណែនាំអំពីរចនាសម្ព័ន្ធ និងដំណើរការកម្មវិធីបណ្តុះបណ្តាល** | (១០នាទី) | ▪ អ្នកសម្របសម្រួលយកក្រដាសផ្ទាំងធំដែលមានបិទការរំពឹងទុក និងកំណត់ត្រាចំណុចសំខាន់ៗដែលជាឧបសគ្គក្នុងការចិញ្ចឹមកូនរបស់អ្នកចូលរួមមកបិទនៅកន្លែងដែលអ្នកចូលរួមអាចមើលឃើញ<br>▪ បន្ទាប់មកទៀត អ្នកសម្របសម្រួលបង្ហាញកម្មវិធីបណ្តុះបណ្តាលទាំងមូលដែលបានត្រៀម និងសរសេរនៅក្នុងក្រដាសផ្ទាំងធំរួចជាស្រេច អំពីរចនាសម្ព័ន្ធ និងរយៈពេលសិក្សា (ដូចមាននៅក្នុងខ្លឹមសារមេរៀន) រួចធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងការរំពឹងទុក និងលទ្ធផលនៃការឆ្លុះបញ្ចាំងរបស់គាត់។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៧ | បង្កើតគោលការណ៍ក្រុម | (១៥នាទី) | ▪ និយាយទៅកាន់អ្នកចូលរួមថា ដើម្បីឱ្យការប្រជុំក្រុមមានដំណើរការល្អ យើងនឹងពិភាក្សា ហើយកំណត់អំពីគោលការណ៍ និងវិន័យមួយចំនួនសម្រាប់អនុវត្តនៅក្នុងកិច្ចប្រជុំរបស់យើង។<br>▪ ស្នើអ្នកចូលរួមគិត និងលើកឡើងអំពីវិន័យដែលគាត់គិតឃើញ ហើយមានប្រយោជន៍សម្រាប់ការប្រជុំលើកក្រោយៗ។<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រាគំនិតយោបល់របស់អ្នកចូលរួមដាក់លើក្រដាសផ្ទាំងធំ ឬគូររូបតំណាងក៏បាន។ គោលការណ៍វគ្គអាចជា៖<br>‣ ចូលរួមទៀតទាត់ និងគោរពពេលវេលា<br>‣ គោរព និងឱ្យតម្លៃគ្នា<br>‣ គាំទ្រ និងលើកទឹកចិត្តគ្នា<br>‣ រក្សាការសម្ងាត់ និងមិនវិនិច្ឆ័យ<br>‣ ចូលរួមពិភាក្សា និងបញ្ចេញមតិយោបល់<br>‣ ផ្សេងទៀតអាស្រ័យលើការយល់ព្រម ឬយោបល់ពីអ្នកចូលរួម។ |
| ៨ | បញ្ចប់កម្មវិធី | (៥នាទី) | ▪ ឪពុកម្តាយចែករំលែកខ្លឹមសារដែលបានពិភាក្សាជាមួយសមាជិកគ្រួសារ និងកូនៗរបស់ពួកគាត់។<br>▪ កំណត់ពេលវេលា និងណែនាំប្រធានបទសម្រាប់វគ្គក្រោយ។<br>▪ ថ្លែងអំណរគុណ! |

# វគ្គទី២

## មេរៀនទី១៖ ការការពារកុមារ

## សេចក្ដីផ្ដើម

តាមការអង្កេតនៅឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការយូនីសេហ្វ (UNICEF) ស្ដីពីអំពើហិង្សាលើកុមារបានឱ្យដឹងថា កុមារម្នាក់ក្នុងចំណោមពីរនាក់ បានទទួលរងអំពើហិង្សាផ្លូវកាយ កុមារម្នាក់ក្នុងចំណោម៤នាក់បានទទួលរងអំពើហិង្សាផ្លូវចិត្ត ហើយកុមារម្នាក់ក្នុងចំណោម២០នាក់ បានទទួលរងអំពើហិង្សាផ្លូវភេទ។ ការសិក្សានោះក៏បានបង្ហាញដែរថា អ្នកដែលរំលោភបំពានលើកុមារភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតដូចជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ យោងទៅតាមលទ្ធផលស្រាវជ្រាវនេះបានបញ្ជាក់ថាកុមារនៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានសុវត្ថិភាព និងការអភិវឌ្ឍពេញលេញនៅឡើយទេ។

ដូចនេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរសិក្សាស្វែងយល់ពីអំពើហិង្សាលើកុមារ និងផលប៉ះពាល់លើកុមារ គ្រួសារ សង្គមជាតិ សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចប្រទេសជាតិ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ។ បន្ថែមពីលើនេះ ឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំគប្បីទទួលបានការគាំទ្រក្នុងការការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ រួមទាំងការមិនអើពើលើកុមារដែលអាចកើតមានឡើងទាំងនៅខាងក្នុងផ្ទះ និងក្រៅផ្ទះ។

| គោលបំណង | នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖<br>• កំណត់បានពីអំពើហិង្សាគ្រប់ទម្រង់ និងប្រភេទផ្សេងៗនៃការរំលោភបំពានលើកុមារ<br>• រៀបរាប់បានពីផលប៉ះពាល់នៃការរំលោភបំពានលើកុមារ<br>• កំណត់បាននូវឥរិយាបថដែលគួរធ្វើ និងមិនគួរធ្វើដើម្បីការពារកុមារពីការរំលោភបំពាន<br>• បង្កើនការយកចិត្តទុកដាក់ដល់កុមារដែលមានតម្រូវការពិសេស និងកុមារដែលមានពិការភាព។ |
|---|---|

**រយៈពេល**

**១៥០ នាទី**

**សម្ភារៈ ដែលត្រូវការ**

- រូបភាពទី ១ បង្ហាញពី ការរំលោភបំពានលើកុមារ
- រូបភាពទី ២ បង្ហាញពី ការរំលោភបំពានផ្លូវកាយ
- រូបភាពទី ៣ បង្ហាញពី ការរំលោភបំពានផ្លូវចិត្ត
- រូបភាពទី ៤ បង្ហាញពី ការរំលោភបំពានផ្លូវភេទ
- រូបភាពទី ៥ បង្ហាញពី ការមិនអើពើ
- រូបភាពទី ៦ បង្ហាញពី អារម្មណ៍ភ័យខ្លាច
- រូបភាពទី ៧ បង្ហាញពី យល់សប្ត
- រូបភាពទី ៨ បង្ហាញពី អារម្មណ៍អស់សង្ឃឹម
- រូបភាពទី ៩ បង្ហាញពី អារម្មណ៍ខូចចិត្ត
- រូបភាពទី ១០ បង្ហាញពី ហូបបាយមិនបាន
- រូបភាពទី ១១ បង្ហាញពី គិតថាខ្លួនឯងគ្មានតម្លៃ
- រូបភាពទី ១២ បង្ហាញពី រងរបួស
- រូបភាពទី ១៣ បង្ហាញពី អាកប្បកិរិយាផ្ទើន
- រូបភាពទី ១៤ បង្ហាញពី អាកប្បកិរិយាឆ្លើយតបហិង្សា
- រូបភាពទី ១៥ (A3) បង្ហាញពី ប្រភេទនៃការរំលោភបំពាន
- បណ្ណរូបភាព (Poster) សម្រាប់ចែកជូនអ្នកចូលរួម
- ចំណុចកុមារគួរចងចាំ
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- ក្រម៉ា ឬកន្សែង (សម្រាប់ធ្វើតុក្កតា) ឬរូបតុក្កតា
- កម្រាល សម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀម សម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រាអំពីគោលការណ៍ដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

ខ្លឹមសារលម្អិត

# I. និយមន័យ ការការពារ និងការរំលោភបំពានលើកុមារ

## ១. ការការពារកុមារ

ការការពារកុមារគឺជា វិធីដែលយើងទប់ស្កាត់ និងឆ្លើយតបទៅនឹងគ្រោះថ្នាក់ដែលកើតឡើងដោយចេតនា និងដោយអចេតនាចំពោះកុមារ។

គោលបំណងនៃការការពារកុមារគឺ ដើម្បីលើកកម្ពស់ការការពារ និងបំពេញសិទ្ធិកុមារក្នុងការការពារពីការរំលោភបំពាន ការមិនអើពើ ការកេងប្រវ័ញ្ច និងអំពើហិង្សា។

### ១.១. ការការពារ សម្រាប់កុមារដែលមានតម្រូវការពិសេស និងកុមារដែលមានពិការភាព

កុមារដែលមានពិការភាពត្រូវការ ការការពារពិសេសជាងកុមារផ្សេងទៀត ដោយសារពួកគាត់អាចមានការលូតលាស់ និងអភិវឌ្ឍយឺតជាងកុមារដទៃ ហើយពួកគាត់ត្រូវការ ការយកចិត្តទុកដាក់យ៉ាងខ្លាំងដែលតម្រូវឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានការអត់ធ្មត់ និងព្យាយាមស្វែងរកចំណេះដឹងផ្សេងៗដែលអាចជួយកុមារដែលមានពិការភាពឱ្យមានការលូតលាស់ និងអភិវឌ្ឍទៅតាមលទ្ធភាពរបស់ពួកគេ។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរផ្ដល់ការថែទាំជាពិសេសដើម្បីការពារកុមារដែលមានពិការភាពពីការរំលោភបំពានគ្រប់ប្រភេទ។ កុមារទាំងនោះនឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរដូចជា ចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេនឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យយ៉ាងហោចណាស់មួយឆ្នាំមុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តការគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពនានានៅក្នុងសង្គមផងដែរ។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) កំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀតអាចមានពិការភាពច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួន៖

- **ថ្លង់ ឬខ្សោយការស្ដាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អតែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺខ្សោយការស្ដាប់(មិនអាចស្ដាប់បានឬស្ដាប់បានមិនល្អ)។ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើល មិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍ ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្ដាប់អាចឱ្យពួកគាត់មានឱកាសរៀនភាសាបាន

ល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទទួលបាន ការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមារដែល មានពិការភាពនេះដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាព ទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍ ការប្រាស្រ័យទាក់ទង មានភាព កក់ក្តៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្ន មានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការ គ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។

- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយ សតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់បានចប់ បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹក គេង និងហូបចុកជាដើម។ មានកុមារមួយចំនួនទៀត មានបញ្ហាខ្សោយសតិបញ្ញា ប្រភេទធ្ងន់ធ្ងរ។ ពួកគេមិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការ អ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេស ថែមទៀតពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែល មាននៅមូលដ្ឋាន ឬទៅទទួលសេវានៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមាន ទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។
- **ខ្សោយកាយសម្បទា ឬរាងកាយ៖** កុមារមួយចំនួនទៀត មានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាច ដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទ នេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាពីមជ្ឈមណ្ឌលសុខភាព ផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល មជ្ឈមណ្ឌល ស្តារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌល ស្តារនីតិសម្បទានៅតាមខេត្ត។
- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះ អាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយ លំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារដែលមានបញ្ហាភ្នែក តាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិន ឈោងចាប់របស់របរលេង មិនលូន ឬវារ ទារកលេងកម្សាន្តតិចតួច នៅតែម្នាក់ឯង ច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះ

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារក ដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការការថែទាំ និងការគាំទ្រពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

## ២. ការរំលោភបំពានកុមារ

ការរំលោភបំពានលើកុមារ គឺសំដៅលើគ្រប់សកម្មភាពទាំងអស់នៃការធ្វើទុក្ខបុកម្នេញ ទាំងផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ការមិនអើពើ ការប្រព្រឹត្តខ្ជីខ្ជា ការជួញដូរ ឬការកេងប្រវ័ញ្ចផ្សេងៗទៀត ដែលជាហេតុបណ្តាលឱ្យមានការឈឺចាប់ឃើញជាក់ស្តែង ឬមិនទាន់ឃើញជាក់ស្តែងទៅលើសុខភាព ការរស់រានមានជីវិត ការអភិវឌ្ឍ ឬសេចក្ដីថ្លៃថ្នូររបស់កុមារនៅក្នុងបរិបទនៃទំនាក់ទំនង ការទទួលខុសត្រូវ ការជឿទុកចិត្ត ឬអំណាច។

ការរំលោភបំពានក៏បានគិតទៅដល់ការបង្ហាញរូបភាពអាក្រាត ប្រដាប់ភេទ ឬការបង្ហាញរូបភាពកុមារលើប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដែលគេបានថតយករូបភាពកុមារគ្មានសម្លៀកបំពាក់ ឬរូបភាពទាំងឡាយណាដែលកុមារមិនបានអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយជាសាធារណៈ។ បើករណីកុមារមិនទាន់មានសមត្ថភាពក្នុងការសម្រេចចិត្ត ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគិតពិចារណាទៅលើរូបភាពដែលអាចមានផលប៉ះពាល់ដល់កុមារ ឬធ្វើឱ្យកុមារមានគ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងដោយយថាហេតុ។

កុមារដែលមានពិការភាព និងកុមារមិនមានពិការភាព សុទ្ធតែអាចទទួលការរំលោភបំពានដូចគ្នា ហើយកុមារាក៏អាចទទួលការរំលោភបំពានផ្លូវភេទដូចកុមារីដែរ ដូចនេះពួកគេត្រូវទទួលបានការការពារយ៉ាងហ្មត់ចត់ពីមនុស្សពេញវ័យ និងមជ្ឈដ្ឋានជុំវិញខ្លួន។

# II. ប្រភេទនៃការរំលោភបំពាន

ការរំលោភបំពានលើកុមារមាន៤ប្រភេទ៖ ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

## ១. ការរំលោភបំពានផ្លូវកាយ

គឺជាការធ្វើឱ្យកុមារមានរបួស ឬស្នាមលើរាងកាយដោយចេតនា ឬអចេតនាពីសំណាក់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងមនុស្សពេញវ័យផ្សេងៗទៀត ហើយធ្វើឱ្យកុមារមានភាពអន់ថយសុខភាព និងប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ។

ការរំលោភបំពានផ្លូវកាយ មានដូចជា៖

- ការវាយដំ
- ការរុញច្រានខ្លាំងៗ
- មួល ទាត់ ឬទះ

- ក្អិច បោចសក់
- ច្របាច់ក
- ធ្វើឱ្យមានរបួសស្នាម។

### ការឆ្លើយតបលើការរំលោភបំពានផ្លូវកាយ

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរជៀសវាងធ្វើសកម្មភាពដូចជា វាយ អង្រួន ឬដាក់ទណ្ឌកម្មលើរាងកាយនៅពេលដែលកូន ឬកុមារមានអាកប្បកិរិយាដូចជា និយាយកុហក ឬធ្វើបែកសម្ភារៈ។ល។ ផ្ទុយទៅវិញឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរស្វែងរកសកម្មភាពឆ្លើយតបបែបវិជ្ជមានណាដែលផ្តល់នូវសេចក្តីស្រឡាញ់ ភាពកក់ក្តៅ ទំនុកចិត្ត ឬភាពជឿជាក់ដល់កូន ឬកុមារដែលជួយឱ្យកូន ឬកុមារមានការលូតលាស់ និងអភិវឌ្ឍបានល្អប្រសើរ រួមទាំងអាចក្លាយទៅជាមនុស្សដែលមានសុខុមាលភាពល្អ។

អំពើហិង្សា និងការមិនអើពើទាំងនោះនឹងមិនជួយដល់លោកអ្នកក្នុងការបង្រៀនកូន ឬកុមារប្រកបដោយប្រសិទ្ធភាព ឬសម្រេចបានតាមគោលបំណងឡើយ។ ផ្ទុយទៅវិញ វាអាចរួមចំណែកផ្តល់បទពិសោធន៍ផ្លូវចិត្តប្រកបដោយគ្រោះថ្នាក់ដល់កូន ឬកុមារ ដូចជា ជំងឺធ្លាក់ទឹកចិត្ត ឬថប់បារម្ភជាដើម។

ការណែនាំមានសារៈសំខាន់ណាស់ ពីព្រោះវាជួយឱ្យកូន ឬកុមាររៀនសូត្រអំពីអ្វីដែលគួរធ្វើ ឬមិនគួរធ្វើ។ ការធ្វើដូចនេះក៏ជួយឱ្យកូន ឬកុមារស្វែងយល់អំពីកំហុសរបស់ខ្លួន ហើយក៏ជួយឱ្យពួកគេធ្វើបានកាន់តែប្រសើរនៅពេលក្រោយ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនស្រឡាញ់កូន ឬកុមារ ហើយពួកគាត់ប្រៀនប្រដៅកូន ឬកុមារដោយប្រើអំពើហិង្សា ឬការមិនអើពើ ដោយមានជំនឿថា ជាវិធីត្រឹមត្រូវក្នុងការអប់រំ ឬប្រៀនប្រដៅកូន ឬកុមារ ដោយពួកគាត់មិនបានគិតទៅដល់ផលប៉ះពាល់ដូចបានបង្ហាញខាងលើ ហើយពួកគាត់ក៏មិនបានដឹងថា ការប្រើអំពើហិង្សា ឬការមិនអើពើលើកុមារគឺជាអំពើប្រឆាំងនឹងច្បាប់របស់ជាតិ និងអន្តរជាតិឡើយ។

## ២. ការរំលោភបំពានផ្លូវចិត្ត៖

គឺជាសកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ផ្លូវចិត្តកុមារ (ចេតនា ឬអចេតនាពីសំណាក់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងមនុស្សពេញវ័យផ្សេងៗទៀត ហើយធ្វើឱ្យកុមារមានភាពអន់ថយសុខភាព និងប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ។

### ការរំលោភបំពានផ្លូវចិត្តមានដូចជា៖

- ការរិះគន់ដែលកើតឡើងម្តងហើយម្តងទៀត
- ការនិយាយមើលងាយ បន្ទាបបន្ថោក
- ស្តីបន្ទោស ការគំរាមកំហែង

- ការបំបិទសិទ្ធិសេរីភាព
- សើចចំអក
- ការបដិសេធ ឬការប្រានចោលម្តងហើយម្តងទៀត
- ការបន្លាច ឬបំភ័យ
- ការបដិសេធចំពោះការឆ្លើយតបផ្លូវអារម្មណ៍ (មិនយកចិត្តទុកដាក់ពីអារម្មណ៍របស់កុមារ)។ល។

## ការឆ្លើយតបលើការរំលោភបំពានផ្លូវចិត្ត

ជៀសវាងការស្រែកគំហក ជេរប្រមាថដល់កូន ឬកុមារ ជាពិសេសការប្រៀបធៀបកូន ឬកុមារទៅកុមារផ្សេងទៀតដោយបែរមកពិភាក្សា សួរបញ្ជាក់ និងពន្យល់ហេតុផលដល់កូន ឬកុមារដើម្បីឱ្យគាត់បានដឹងពីគោលបំណងរបស់យើងជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវចែកឱ្យដាច់រវាងការប្រព្រឹត្ត និងអាកប្បកិរិយារបស់កូន ឬកុមារ (ទិតៀនលើអាកប្បកិរិយា ជៀសវាងទិតៀនលើកុមារទាំងមូល)។ ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំចាំបាច់ជួយកុមារឱ្យបានយល់ច្បាស់ថា អាកប្បកិរិយាណាដែលពួកគេអាចបន្តធ្វើ និងអាកប្បកិរិយាណាដែលធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនង និងអាចមានគ្រោះថ្នាក់។

## ៣. ការរំលោភបំពានផ្លូវភេទ

គឺជាការបង្ខិតបង្ខំកុមារ ឬប្រើកុមារជាមធ្យោបាយសម្រាប់រួមភេទ ដែលរាប់បញ្ចូលទាំងការប្រឈមទៅនឹងរូបភាពអាសអាភាស និងការប៉ះពាល់អង្គជាតិភេទក្នុងលក្ខណៈរួមភេទ។

### ការរំលោភបំពានផ្លូវភេទមានដូចជា៖

- រំលោភសេពសន្ថវៈ
- ទម្រង់ ឬរូបភាពណាមួយនៃការធ្វើឱ្យមានសម្រើបផ្នែកភេទដូចជា ការបៀតបៀនប្រដាប់ភេទ ស្ទាបគូទ ស្ទាបដោះ ឬស្ទាបភ្លៅ។ល។
- ការប៉ះពាល់ដោយមាត់ ឬដោយប្រដាប់ភេទ
- ការរួមសង្វាស ឬការដាក់បញ្ចូលប្រដាប់ភេទ
- ការប្រើរូបភាពណាមួយនៃការបង្ហាញផ្លូវភេទដល់កុមារដូចជា រូបភាព វត្ថុ ឬសម្ភារៈអាសអាភាស ឬការបង្ហាញឱ្យឃើញប្រដាប់ភេទខ្លួនផ្ទាល់
- ការប្រើប្រាស់កុមារដើម្បីផលិតរូបភាពអាសអាភាស
- ពេស្យាកម្មកុមារ។ល។

**ចំណាំ៖** ជនល្មើសអាចជាមនុស្សចាស់ ក្មេងជំទង់ ជាកុមារ ជាមនុស្សដែលអាយុច្រើនជាង ឬធំជាង ឬមានអំណាចជាង ជាមនុស្សដែលកុមារស្គាល់ ឬទុកចិត្ត ហើយពួកគេ កេងប្រវ័ញ្ចទៅលើភាពពឹងផ្អែករបស់កុមារ និងភាពមិនទាន់ពេញវ័យរបស់កុមារ។ ជនល្មើសមានទាំងមនុស្សប្រុស និងមនុស្សស្រី ហើយជនរងគ្រោះមានទាំងកុមារា និងកុមារី។

### ការឆ្លើយតបលើការរំលោភបំពានផ្លូវភេទ

- ស្វែងយល់អំពីល្បិចកលជនខិលខូច
- ទៅណាមកណាត្រូវមានគ្នាច្រើន ឬមានគ្រួសារ ចាស់ទុំនៅជាមួយ និងត្រូវស្ថិតនៅកន្លែងដែលអ្នកដទៃអាចមើលឃើញ
- ត្រូវផ្ដល់ព័ត៌មានអំពីទំនាក់ទំនងរបស់មនុស្សចម្លែកទៅឪពុកម្ដាយ ឬមនុស្សដែលកូន ឬកុមារទុកចិត្ត
- ត្រូវប្រុងប្រយ័ត្នចំពោះចំណីអាហារ ភេសជ្ជៈ នៅពេលដើរលេងជាមួយមិត្តភក្ដិ ឬអ្នកដែលទើបនឹងស្គាល់គ្នា
- ជៀសវាងដើរឆ្ងាញពីផ្ទះតែម្នាក់ឯង ឬទៅកន្លែងដែលមិនស្គាល់ហើយគ្មាននរណាដឹង
- មិនត្រូវស្ថិតនៅកន្លែងដែលស្ងាត់ ឬឆ្ងាយដាច់ពីភ្នែកអ្នកដទៃតែពីរនាក់
- មិនត្រូវជឿពាក្យលួងលោមរបស់គេដូចជា ការសន្យាផ្ដល់លុយកាក់ ឬរបស់របរផ្សេងៗ ឬសន្យាផ្ដល់ការងារឱ្យធ្វើ
- មិនត្រូវមើលវីដេអូ ឬអានទស្សនាវដ្ដីអាសអាភាស
- រាយការណ៍ពីមុខសញ្ញាជនសង្ស័យដែលលួងលោម និងបោកបញ្ឆោតកុមារទៅសមត្ថកិច្ច ឬអាជ្ញាធរឱ្យបានដឹង
- ត្រូវទំនាក់ទំនងទៅលេខទូរស័ព្ទពិសេសរបស់នគរបាល **១២៨៨** ឬ **១១៧** និងបណ្ដាញទូរស័ព្ទជំនួយកុមារ **១២៨០** ។

## ៤. ការមិនអើពើ៖

គឺជាការខកខានមិនបានផ្ដល់នូវតម្រូវការមូលដ្ឋានដល់កុមារ និងទុកកុមារចោលដោយគ្មានអ្នកណាត្រួតពិនិត្យ យកចិត្តទុកដាក់ និងការមើលថែពីសំណាក់មនុស្សធំ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។

### ការមិនអើពើមានដូចជា៖

- កុមារមិនមានឱកាសចូលរៀន
- មិនផ្ដល់ភាពកក់ក្ដៅ
- មិនបានទទួលការចាក់ថ្នាំបង្ការគ្រប់គ្រាន់

- មិនបានចុះសំបុត្រកំណើត
- ការបំបែកកូនចេញពីគ្រួសារ
- ការផ្ដល់អាហារូបត្ថម្ភមិនបានគ្រប់គ្រាន់
- សំលៀកបំពាក់មិនសមស្របនឹងរដូវកាល
- ការរស់នៅគ្មានអនាម័យ
- មិនមានការថែទាំសុខភាពបានត្រឹមត្រូវ
- ខ្វះការអប់រំ
- គ្មានសុវត្ថិភាព ។ល។

### ការឆ្លើយតបលើការមិនអើពើ

ស្ទើរតែគ្រប់គ្រោះថ្នាក់ដែលកើតមានឡើងទាំងអស់សុទ្ធតែអាចបង្ការបាន។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវតែយកចិត្តទុកដាក់ជាពិសេសក្នុងការរៀបចំផ្ទះសម្បែង បរិស្ថានឱ្យមានសុវត្ថិភាព និងមើលថែកូន ឬកុមារតូចៗដើម្បីទប់ស្កាត់ពួកគេពីឥរិយាបថដែលបង្កគ្រោះថ្នាក់។

សូមរក្សាឱ្យកូន ឬកុមារឱ្យស្ថិតនៅក្នុងគ្រួសារបើទោះជាគ្រួសារមានជីវភាពយ៉ាងណាក៏ដោយ។ នៅក្នុងមណ្ឌលកុមារកំព្រា កុមារងាយនឹងរងអំពើហិង្សា ការមិនអើពើ ឬការរំលោភបំពាននានាពីសំណាក់កុមារទៅលើកុមារ ឬពីមនុស្សធំទៅលើកុមារ។

ប្រសិនបើកូនរបស់លោកអ្នកមានពិការភាព សូមលើកទឹកចិត្តឱ្យមានការអភិវឌ្ឍច្រើនបំផុតតាមដែលលោកអ្នកអាចធ្វើបាន ដោយអនុញ្ញាតឱ្យកូន ឬកុមារបានលេងជាមួយកុមារដទៃទៀតឱ្យចូលរៀន និងស្វែងរកជំនួយពីក្រុមជំនាញ ពីបុគ្គលិកបម្រើសេវាសុខាភិបាល និងសេវាសង្គមកិច្ចនៅក្នុងមូលដ្ឋាន។

## III. ផលប៉ះពាល់ពីការរំលោភបំពាន

ការរំលោភបំពានគ្រប់ប្រភេទ សុទ្ធតែប៉ះពាល់ដល់កុមារ មានដូចជា៖

- ភ័យខ្លាច
- បាត់បង់ទំនុកចិត្តលើខ្លួនឯង
- រងរបួស ឬមានជំងឺ
- គិតថាខ្លួនគ្មានតម្លៃ
- ខូចចិត្ត
- អស់សង្ឃឹម
- ខួរក្បាលអភិវឌ្ឍយឺត។ល។

## IV. ការការពារកុមារកុំឱ្យមានការរំលោភបំពាន

### ក. ជំហានទាំង៥ ដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវធ្វើដើម្បីការពារកូន ឬកុមារពីការរំលោភបំពាន

១) **ស្តាប់** កូន ឬកុមារ

២) **ជឿ** លើកូន ឬកុមារ

៣) **ស្វែងយល់** អំពីការរំលោភបំពាន ឬការមិនអើពើលើកុមារ និងចរិកលក្ខណៈក្នុងការការពារកុមារ និងមនុស្សវ័យក្មេង

៤) **បង្រៀន** កូន ឬកុមារអំពីសិទ្ធិផ្សេងៗរបស់ពួកគេ និងយុទ្ធសាស្ត្រផ្សេងៗដើម្បីរៀបចំចរិកលក្ខណៈក្នុងការការពារ

៥) **បង្កើត** ឱ្យមានវប្បធម៌សុវត្ថិភាព និងមានការដឹងឮនៅក្នុងសហគមន៍របស់អ្នក

### ខ. ចំណុចដែលកុមារត្រូវចងចាំ

- ស្គាល់ ឬចាំលេខទូរស័ព្ទទំនាក់ទំនងរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងមនុស្សដែលយើងទុកចិត្ត
- ប្រាប់ និងសុំការអនុញ្ញាតពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅពេលដែលចាកចេញពីផ្ទះ ទោះបីជាទៅជាមួយមនុស្សដែលអ្នកស្គាល់ក៏ដោយ។
- មិនទទួលយកអំណោយ ឬរបស់របរពីមនុស្សដែលអ្នកស្គាល់ ឬមិនស្គាល់ ឬពីមនុស្សប្លែកមុខទេ លើកលែងតែឪពុកម្តាយរបស់អ្នកនៅជាមួយ។
- ជាទូទៅ ទៅណាមកណាតែងតែទៅជាមួយមិត្តភក្តិ និងមានគ្នាទៅជាមួយ។ ហើយមិនត្រូវទៅណាមកណាតែម្នាក់ឯងនោះទេ។
- ត្រូវនិយាយថាទេ ប្រសិនបើមាននរណាម្នាក់មកប៉ះពាល់ដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ ឬអារម្មណ៍ភ័យខ្លាច។
- ត្រូវចងចាំមនុស្សដែលអាចជួយអ្នក និងមនុស្សដែលអ្នកជឿជាក់អាចជួយអ្នកបាននៅពេលដែលអ្នកត្រូវការជំនួយ មានដូចជា មេភូមិ ជំនួយការភូមិ ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ បណ្តាញកុមារ ឬយុវវ័យ អ្នកស្ម័គ្រចិត្ត គ្រូបង្រៀន នាយកសាលា នាយប៉ុស្តិ៍ប្រជាការពារភូមិ មេឃុំ ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាដើម។
- ប្រាប់ដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរបស់អ្នក ប្រសិនបើមាននរណាម្នាក់មានអាកប្បកិរិយាមិនសមរម្យ ឬធ្វើឱ្យមានអារម្មណ៍ភ័យខ្លាច។
- ត្រូវបដិសេធ ប្រសិនបើមាននរណាម្នាក់ដែលអ្នកមិនស្គាល់សួរអ្នក ឬឱ្យអ្នកជួយជូនទៅទីកន្លែងណាមួយ។
- ត្រូវរត់គេចឱ្យឆ្ងាយ ប្រសិនបើមនុស្សដែលអ្នកមិនស្គាល់ដើរតាមអ្នក ទោះបីជាគាត់ស្គាល់ឈ្មោះអ្នកក៏ដោយ។

- ត្រូវនិយាយថាទេ  ប្រសិនបើមាននរណាម្នាក់បបួលអ្នកឱ្យប្រើប្រាស់គ្រឿងញៀន ឬប្រព្រឹត្តអ្វីដែលអ្នកគិតថាវាជាការមិនត្រឹមត្រូវ។
- ប្រាប់ដល់ឪពុកម្ដាយរបស់អ្នក និងរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចអំពីមនុស្ស ដែលមានបំណងមិនល្អមកលើអ្នក ឬមានបំណងមិនល្អចំពោះកុមារផ្សេងទៀត។
- ត្រូវស្រែកឱ្យខ្លាំង និងរកគេឱ្យជួយ ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពមានគ្រោះថ្នាក់ ឬត្រូវគេប៉ះពាល់រាងកាយ
- ត្រូវស្វែងយល់ពីការរំលោភបំពាននានា និងល្បិចកលជនខិលខូច
- ត្រូវរក្សាទុកលេខទូរស័ព្ទពិសេស និងសង្គ្រោះបន្ទាន់របស់អ្នកដែលពាក់ព័ន្ធ
- ត្រូវទំនាក់ទំនងទៅលេខទូរស័ព្ទពិសេសរបស់នគរបាល **១២៨៨** ឬ **១១៧** និង បណ្ដាញទូរស័ព្ទជំនួយកុមារ **១២៨០** ។

## V. ល្បិចកលជនខិលខូច

ជាទូទៅជនខិលខូចតែងតែប្រើល្បិចកលមួយចំនួនមានដូចជា៖

- សន្យាថា និងផ្ដល់ការងារដោយទទួលបានប្រាក់ខែខ្ពស់
- សន្យាថាជួយរកការងារឱ្យធ្វើ
- ទិញទឹកចិត្តក្រុមគ្រួសារដោយផ្ដល់ជាសម្ភារៈ និងប្រាក់កាស
- លួងលោមធ្វើជាសង្សារ
- ប្រើល្បិចជារៀបការជាមួយ រួចយកទៅលក់
- ប្រើថ្នាំញៀន ឬថ្នាំសណ្ដំ
- សុំធ្វើជាបងប្អូនធម៌ ឬកូនចិញ្ចឹម
- លួងលោម និងអូសទាញឱ្យចូលរួមពិធីផ្សេងៗ
- បបួលដើរលេងកន្លែងស្ងាត់ ឬកន្លែងដែលអ្នកដទៃមើលមិនឃើញ
- ធ្វើជាមានចិត្តសប្បុរស និងមនុស្សធម៌
- តាំងខ្លួនជាមនុស្សដែលចូលចិត្ត និងស្រឡាញ់កុមារដូចជាកូនរបស់ខ្លួន
- សន្យារៀបការជាមួយ
- ចេះផ្គាប់ផ្គុន និងធ្វើជាមនុស្សមានទំនាក់ទំនងល្អជាមួយកុមារ និងគ្រួសារ
- ការពួនស្ទាក់ និងការចាប់ពង្រត់
- ធ្វើជាគ្រូព្យាបាលជំងឺ
- ធ្វើជាអ្នកជួយឧបត្ថម្ភដល់មណ្ឌលកុមារកំព្រា
- ការឱ្យខ្ចីប្រាក់ ដើម្បីបង្ហាញការជឿជាក់ ដោយមិនយកការប្រាក់ ឬយកការប្រាក់ តិចៗ។ល។

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្រ្ត |
|---|---|---|---|
| ១ | <u>ការស្វាគមន៍</u> | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើម អ្នកសម្របសម្រួលសំណេះសំណាល ហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និង បន្តសកម្មភាពបន្ទាប់។ |
| ២ | <u>រំឭកគោលការណ៍ក្រុម</u> | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបាន បង្កើតរួមគ្នាកាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>🗣 បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាច រំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀង កាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុម ដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅ ពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | <u>រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំង ពីការអនុវត្ត</u> | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួប មុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>🗣 តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សា កាលពីជំនួបលើកមុនជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យ អ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេល ដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>🗣 អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួម លើកឡើង និងស្នើសុំឱ្យក្រុមផ្តល់ និងពិភាក្សាដើម្បីស្វែង ររករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នក សម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែង<br>ចាមពល<br>(១០នាទី) | ▪ អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមឈរជារង្វង់ និងប្រាប់ពីឈ្មោះសកម្មភាព "ល្បែងផ្តល់ក្តីស្រឡាញ់ដល់កុមារ"<br>• ដើម្បីលេងល្បែងនេះ យើងត្រូវមាន ឬបង្កើតតុក្កតាមួយ<br>• ករណីបង្កើតតុក្កតា ស្នើឱ្យអ្នកចូលរួមប្រើប្រាស់សម្ភារៈដែលមានអាចជា ក្រដាសផ្ទាំងធំ តុក្កតា ឬក្រម៉ា។ល។<br>▪ ក្រោយពេលបង្កើតតុក្កតារួចមក អ្នកសម្របសម្រួលពន្យល់ពីដំណើរការលេង ដោយសួរទៅអ្នកចូលរួមម្នាក់ម្តងៗ<br>☞ តើលោកអ្នកធ្វើអ្វី ដើម្បីបង្ហាញថា លោកអ្នកផ្តល់ក្តីស្រឡាញ់ចំពោះកុមារ?<br>▪ បន្តសួរអ្នកចូលរួមរហូតដល់គ្រប់ៗគ្នា បន្ទាប់មកចាប់ផ្តើមលេងល្បែងដោយឱ្យតុក្កតាទៅអ្នកចូលរួម ដើម្បីធ្វើសកម្មភាពនៃក្តីស្រឡាញ់ចំពោះកុមារដែលពួកគាត់បាននិយាយម្នាក់ម្តងៗ។ |
| ៥ | មេរៀនថ្មីៈ<br>ការការពារកុមារ | ការការពារ<br>កុមារ<br>(៥នាទី) | ▪ អ្នកសម្របសម្រួលចាប់ផ្តើមដោយនិយាយថាៈ<br>ឥឡូវនេះយើងនឹងនិយាយពីការការពារកុមារពីគ្រោះថ្នាក់ ឬការរំលោភបំពានផ្សេងៗដោយចេតនា និងអចេតនាពីមនុស្ស និងមជ្ឈដ្ឋានដែលនៅជុំវិញកូន ឬកុមារ បន្ទាប់មកសួរ<br>☞ ហេតុអ្វីបានជាកុមារត្រូវការ ការការពារ?<br>🗣 ចម្លើយរំពឹងទុកៈ កុមារសំខាន់ គាត់នៅតូច គ្មានអំណាច ទន់ខ្សោយ ច្រើនគេធ្វើបាប ងាយនឹងមានគ្រោះថ្នាក់។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចសួរបន្ត<br>☞ តើកុមារដែលមានពិការភាពត្រូវការ ការការពារដែរឬទេ? ព្រោះអ្វី?<br>🗣 ចម្លើយរំពឹងទុកៈ ត្រូវការ ព្រោះគាត់មិនអាចជួយខ្លួនឯងបាន គាត់ទន់ខ្សោយ អវៈយវៈមិនគ្រប់គ្រាន់ បញ្ញាខ្សោយ ងាយរងគ្រោះ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម ហើយសង្ខេបថា មិនថាកុមារា កុមារី ឬកុមារដែលមានពិការភាព គឺពួកគេសុទ្ធតែត្រូវការ ការការពារពីការរំលោភបំពានគ្រប់ប្រភេទ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្រ្ត |
|---|---|---|---|
| | | **ស្វែងយល់ពីអំពើហិង្សា និងការរំលោភបំពាន (១០នាទី)** | ▪ អ្នកសម្របសម្រួលបំផុសគំនិតដល់អ្នកចូលរួម ដោយបង្ហាញរូបភាពទី១ រួចសួរសំណួរ<br>☞ តើលោកអ្នកគិតថា រូបភាពនេះបង្ហាញពីអ្វី?<br>🗣 ចម្លើយរំពឹងទុក៖ យំ កើតទុក្ខ ភ័យខ្លាច មិនសប្បាយចិត្ត ទុក្ខព្រួយ ឯកោ ខឹង ឈឺចាប់ ឪពុកម្តាយវាយ ត្រូវបានគេធ្វើបាប គេស្តីឱ្យ គេមើលងាយ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម ព្រមទាំងអាចពន្យល់ពីនិយមន័យនៃការរំលោភបំពាន ករណីអ្នកចូលរួមមិនយល់ រួចបន្តសួរ<br>☞ តើសកម្មភាពអ្វីខ្លះដែលអាចចាត់ទុកជាការរំលោភបំពានលើកុមារ?<br>🗣 ចម្លើយរំពឹងទុក៖ វាយ ចាប់រំលោភ ជេរ ។ល។<br>▪ អ្នកសម្របសម្រួល កត់ត្រានូវអ្វីៗដែលអ្នកចូលរួមបានចែករំលែកនៅលើក្រដាសផ្ទាំងធំ។ បន្ទាប់មកសរុបចម្លើយអ្នកចូលរួម និងបន្ថែមខ្លឹមសារ។ |
| | | **ប្រភេទនៃការរំលោភបំពាន (២០នាទី)** | ▪ អ្នកសម្របសម្រួលសួរសំណួរ<br>☞ តាមរយៈការលើកឡើងពីសកម្មភាពខាងលើ លោកអ្នកគិតថា ការរំលោភបំពានលើកុមារ មានប៉ុន្មានប្រភេទ? គឺអ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ លើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ។ល។<br>▪ បន្ទាប់ពីអ្នកចូលរួមបានលើកឡើងពីប្រភេទនៃការរំលោភបំពាន រួចហើយ ធ្វើការសរុប ដោយពន្យល់អំពីរូបភាពនីមួយៗ (រូបភាពទី២ ទី៣ ទី៤ និងទី៥) ដែលបង្ហាញអំពីប្រភេទទាំង៤ នៃការរំលោភបំពានលើកុមារ (រំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ)។<br>▪ បន្ទាប់មកទៀត ធ្វើការបែងចែកអ្នកចូលរួមជា ៤ក្រុម ហើយក្រុមនីមួយៗធ្វើការឆ្លើយសំណួរដូចខាងក្រោម៖<br>• ក្រុមទី១៖ តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថា ជាការរំលោភបំពានផ្លូវកាយ?<br>• ក្រុមទី២៖ តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថា ជាការរំលោភបំពានផ្លូវចិត្ត? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | • ក្រុមទី៣៖ តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថា ជាការរំលោភបំពានផ្លូវភេទ?<br>• ក្រុមទី៤៖ តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថា ជាការមិនអើពើ?<br>▪ តំណាងក្រុមនីមួយៗ នឹងធ្វើការបង្ហាញលទ្ធផលរបស់ក្រុម បន្ទាប់ពីកិច្ចពិភាក្សាបានបញ្ចប់។<br>▪ អ្នកសម្របសម្រួលធ្វើការបូកសរុប និងបន្ថែមតាមខ្លឹមសារ ការរំលោភបំពានទាំង ៤ប្រភេទ និងអំពើហិង្សាលើកុមារ។ |
| | | **ផលប៉ះពាល់នៃការរំលោភបំពានលើកុមារ (១០នាទី)** | ▪ អ្នកសម្របសម្រួល សួរសំណួរបំផុសទៅក្រុមធំ ដោយសួរ៖<br>☞ នៅពេលដែលកុមារទទួលរងនូវការរំលោភបំពាន តើកុមាររងផលប៉ះពាល់អ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ ប៉ះពាល់សុខភាព មានវិបត្តិផ្លូវចិត្ត សរសៃប្រសាទ រងរបួស។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារ ដោយពន្យល់អំពីរូបភាពនិមួយៗ (រូបភាពទី៦ រហូតដល់រូបភាពទី១៨) ដែលបង្ហាញអំពី ផលប៉ះពាល់នៃការរំលោភបំពាន និងអំពើហិង្សាលើកុមារ |
| | | **ការទប់ស្កាត់ និង ការឆ្លើយតបចំពោះការរំលោភបំពានលើកុមារ (២៥នាទី)** | ▪ ដូចនេះ ដើម្បីជៀសវាងនូវផលប៉ះពាល់ផ្សេងៗចំពោះកូន ឬកុមារ យើងត្រូវការស្វែងយល់ពីរបៀបការពារកុមារ និងស្ថានភាពនៃការរំលោភបំពាន ដោយសួរ<br>☞ តើលោកអ្នកនឹងធ្វើយ៉ាងណាដើម្បីការពារកូន ឬកុមារ ពីការរំលោភបំពានផ្សេងៗ?<br>🗣 ចម្លើយរំពឹងទុក៖ មិនប្រើអំពើហិង្សាលើកូន ឬកុមារ ពន្យល់ហេតុផលពេលកុមារធ្វើអ្វីមួយខុស ធ្វើរបងការពារ ឬគ្របមាត់អណ្តូង មើលថែ បញ្ចុកចំណី មិនទុកចោលម្នាក់ឯង មិនឱ្យធ្វើការហួសកម្លាំង ផ្តល់អាហារគ្រប់គ្រាន់ ផ្តល់ភាពកក់ក្តៅ ថ្នាក់ថ្នម ក្តីស្រឡាញ់ និងការពារការឆក់ខ្សែភ្លើង ជាដើម។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបចម្លើយអ្នកចូលរួម និងបន្ថែមខ្លឹមសារដោយបិទរូបភាពទី១៥ ដែលបង្ហាញអំពីប្រភេទនៃការរំលោភបំពាន។<br>▪ បន្ទាប់មក អ្នកសម្របសម្រួលសួរបន្ត<br>☞ ចំណែកកុមារដែលមានពិការភាពវិញ តើលោកអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីការពារពួកគេ?<br>🗣 ចម្លើយរំពឹងទុក៖ មើលថែជិតដល់ យកចិត្តទុកដាក់ បង្រៀនលេងជាមួយ មិនរើសអើង បញ្ជូនកូនទៅសាលា។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយអ្នកចូលរួម និងបន្ថែមខ្លឹមសារ (មើលខ្លឹមសារអ្នកសម្របសម្រួលផ្នែកកុមារដែលមានពិការភាពខាងលើ) រួចសួរបន្ត<br>☞ តើកុមារអាចទទួលរងការរំលោភបំពាននៅកន្លែងណាខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ នៅកន្លែងស្ងាត់ តាមព្រៃ ផ្ទះ។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយអ្នកចូលរួម និងបញ្ជាក់ថា ការរំលោភបំពានអាចមាននៅគ្រប់ទីកន្លែង ហើយច្រើនជាងគេគឺនៅផ្ទះ។ រួចសួរបន្ត<br>☞ តើនរណាខ្លះ អាចជាអ្នករំលោភបំពានលើកុមារ?<br>🗣 ចម្លើយរំពឹងទុក៖ អ្នកជិតខាង អ្នកចម្ងាយ អ្នកដែលកុមារស្គាល់មិនច្បាស់ សាច់ញាតិ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយអ្នកចូលរួម និងបន្ថែមខ្លឹមសារ។ តាមការស្រាវជ្រាវ បានរកឃើញថា អ្នកដែលរំលោភបំពានកុមារច្រើនជាងគេ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយបំផុត។ រួចសួរបន្ត<br>☞ តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យកុមាររងការរំលោភបំពាន?<br>🗣 ចម្លើយរំពឹងទុក៖ ទុកកូន ឬកុមារចោល ត្រូវគេលួងលោមកុហក សន្យាឱ្យរបស់អ្វីមួយ ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចបន្ថែមខ្លឹមសារអំពីល្បិចឆបោករបស់ជនខិលខូច។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **សង្ខេបមេរៀន** (៥នាទី) | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីការការពារកុមារ ហើយដើម្បីការពារកុមារ សំខាន់យើងត្រូវ ស្វែងយល់ពីការរំលោភបំពានផ្សេងៗ ដែលអាចប៉ះពាល់ដល់កុមារ។ ការរំលោភបំពានចែកជាបួនប្រភេទខុសៗគ្នាគឺ ការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពាន ផ្លូវភេទ និងការមិនអើពើ។ គ្រប់ប្រភេទនៃការរំលោភបំពានទាំងអស់សុទ្ធតែមានផលប៉ះពាល់ ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ ការការពារកុមារមិនមែនផ្តោតតែលើកុមារដែលមានកាយសម្បទា និងសតិបញ្ញាល្អនោះទេ ហើយក៏ផ្តោតសំខាន់លើកុមារដែលខ្សោយកាយសម្បទា និងសតិបញ្ញាផងដែរ ព្រោះពួកគេត្រូវការ ការការពារជាពិសេសដើម្បីទទួលបានការលូតលាស់ និងអភិវឌ្ឍដូចជាកុមារទូទៅដែរ។ ចំណែកកុមារដែលអាចរងការរំលោភបំពានមិនមែនមានតែកុមារីនោះទេ កុមារាក៏ប្រឈមខ្លាំងពីការរំលោភបំពានផងដែរ ជាពិសេស គឺការរំលោភបំពានផ្លូវភេទ។ |
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន** (១០នាទី) | ▪ អ្នកសម្របសម្រួលសួរ៖<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះ មានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្តេចដែរទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្តេច នៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ** (៥នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្តើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង។<br>▪ ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយាដែលអាចការពារកុមារ មិនមែនផ្តោតតែលើកុមារនៅក្នុងផ្ទះប៉ុណ្ណោះទេ គឺអាចចូលរួមការពារកុមារដែលនៅក្រៅផ្ទះផងដែរ ក្នុងការជួយពួកគេឱ្យរួចផុតពីការរំលោភបំពានផ្សេងៗដែលកើតមានឡើងចំពោះពួកគេ។<br>▪ បើមានការរំលោភបំពានត្រូវរាយការណ៍ទៅ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) ឃុំ។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

## រូបភាពទី ១



# ការរំលោភបំពានលើកុមារ

## រូបភាពទី ២



# ការរំលោភបំពានផ្លូវកាយ

រូបភាពទី ៣



# ការរំលោភបំពានផ្លូវចិត្ត

រូបភាពទី ៤



# ការរំលោភបំពានផ្លូវភេទ

# រូបភាពទី ៥



# ការមិនអើពើ

# រូបភាពទី ៦



# អារម្មណ៍ភ័យខ្លាច

# រូបភាពទី ៧



# យល់សប្តិ

## រូបភាពទី ៨



# អារម្មណ៍អស់សង្ឃឹម

## រូបភាពទី ៩



# អារម្មណ៍ខូចចិត្ត

## រូបភាពទី ១០



# ហូបបាយមិនបាន

## រូបភាពទី ១១



# គិតថាខ្លួនឯងគ្មានតម្លៃ

# រូបភាពទី ១២



# រងរបួស

# រូបភាពទី ១៣



# អាកប្បកិរិយា ផ្ញើន

## រូបភាពទី ១៤



# អាកប្បកិរិយាឆ្លើយតបហិង្សា

## រូបភាពទី ១៥



# ប្រភេទនៃការរំលោភបំពាន

# វគ្គទី៣
# មេរៀនទី២៖ សុខុមាលភាពឪពុកម្ដាយ

## សេចក្ដីផ្ដើម

សុខុមាលភាពរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គឺជាគន្លឹះសម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន ដែលអាចបង្ការអំពើហិង្សា និងការមិនអើពើលើកុមារ។ តាមឯកសារមេរៀនស្ដីពីការចិញ្ចឹមបីបាច់កុមាររបស់អង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា (ICS-SP) អង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) និងការសិក្សាមួយចំនួនបានបង្ហាញថា ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានបញ្ហាសុខភាពផ្លូវចិត្តដូចជា តានតឹងចិត្តកម្រិតខ្ពស់ ជំងឺថប់បារម្ភ ជំងឺធ្លាក់ទឹកចិត្តអាចនឹងមានផលប៉ះពាល់បែបអវិជ្ជមានទៅលើកូននៅពេលដែលពួកគាត់បំពេញកាតព្វកិច្ចជាអ្នកចិញ្ចឹម និងការប្រាស្រ័យទាក់ទងជាមួយកូន ឬកុមារ។ ពួកគាត់ងាយនឹងប្រព្រឹត្តហិង្សា និងការមិនអើពើទៅលើកូន ឬកុមារដោយមិនបានដឹងថាទង្វើរបស់គាត់អាចមានផលប៉ះពាល់បែបអវិជ្ជមានទៅលើកុមារ ដូចជាអាចមានការពិបាកផ្ដោតអារម្មណ៍ក្នុងការសិក្សា មានភាពតានតឹងចិត្ត គេងមិនលក់ រត់ចេញពីផ្ទះ មានទំនាស់ជាមួយមិត្តភក្តិ គិតថាខ្លួនមានកំហុស ឬអាចចាប់ផ្ដើមមានអាកប្បកិរិយាប្រឆាំងសង្គមជាដើម។

យោងតាមផលប៉ះពាល់ខាងលើ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរសិក្សាស្វែងយល់អំពីទំនាក់ទំនងរវាងភាពតានតឹងចិត្ត និងការចិញ្ចឹមបីបាច់កូន។ ការស្វែងយល់ ឬការឆ្លុះបញ្ចាំងនេះអាចជួយឱ្យពួកគាត់គិតគូរពីសុខុមាលភាពរបស់ខ្លួនឯង និងពង្រឹងការចិញ្ចឹមបីបាច់កុមារប្រកបដោយវិជ្ជមាន។ លើសពីនេះទៅទៀត ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីទទួលបានការគាំទ្រពីវិធីដែលពួកគាត់អាចប្រឈមមុខ និងដោះស្រាយជាមួយភាពតានតឹងចិត្ត ឬកំហឹងដោយវិជ្ជមានពីព្រោះថាបើពួកគាត់ដឹងពីវិធីដែលធ្វើឱ្យមានសុខុមាលភាពល្អ នោះពួកគាត់នឹងអាចធ្វើជាគំរូ និងបង្រៀនកូន ឬកុមារពីវិធីនោះផងដែរ។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាចៈ**<br>• ឆ្លុះបញ្ចាំងពីស្ថានភាពទូទៅនៃសុខុមាលភាពរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។<br>• កំណត់បាននូវភាពតានតឹងចិត្តព្រមទាំងវិធីសាស្ត្រដែលអាចបន្ធូរភាពតានតឹងចិត្តរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។<br>• កំណត់បាននូវភាពតានតឹងចិត្តព្រមទាំងវិធីសាស្ត្រដែលអាចបន្ធូរភាពតានតឹងចិត្តរបស់កុមារ<br>• ធ្វើការប្រាស្រ័យទាក់ទងជាមួយកូន ឬកុមារឱ្យមានប្រសិទ្ធភាព។ |
| **រយៈពេល** | **១៥០ នាទី** |
| **សម្ភារៈដែលត្រូវការ** | • រូបភាពទី ១ បង្ហាញពី ភាពតានតឹងចិត្ត<br>• រូបភាពទី ២ បង្ហាញពី កូនមិនស្ដាប់បង្គាប់<br>• រូបភាពទី ៣ បង្ហាញពី មានជំងឺរ៉ាំរ៉ៃ<br>• រូបភាពទី ៤ បង្ហាញពី កូនឈ្លោះគ្នា<br>• រូបភាពទី ៥ បង្ហាញពី សេដ្ឋកិច្ចគ្រួសារជួបការលំបាក<br>• រូបភាពទី ៦ បង្ហាញពី វិវាទនៅក្នុងគ្រួសារ<br>• រូបភាពទី ៧ បង្ហាញពី អាហារូបត្ថម្ភ<br>• រូបភាពទី ៨ (A3) បង្ហាញពី ផលប៉ះពាល់ដែលបង្កឡើងដោយភាពតានតឹងចិត្ត<br>• រូបភាពទី ៩ បង្ហាញពី កំសាន្តជាលក្ខណៈគ្រួសារ<br>• រូបភាពទី ១០ បង្ហាញពី ការបួងសួង<br>• រូបភាពទី ១១ បង្ហាញពី និយាយទូរស័ព្ទជាមួយមនុស្សដែលទុកចិត្ត<br>• រូបភាពទី ១២ បង្ហាញពី ហាត់ប្រាណ ឬលេងកីឡា<br>• រូបភាពទី ១៣ បង្ហាញពី ដាំដំណាំ<br>• រូបភាពទី ១៤ បង្ហាញពី ពិភាក្សាជាមួយមនុស្សដែលទុកចិត្ត<br>• រូបភាពទី ១៥ បង្ហាញពី សមាធិ<br>• រូបភាពទី ១៦ បង្ហាញពី ស្ដាប់ចម្រៀង<br>• បណ្ណរូបភាព (Poster) សម្រាប់ចែកជូនអ្នកចូលរួម<br>  - បណ្ណរូបភាព បង្ហាញពី ផលប៉ះពាល់បង្កឡើងដោយភាពតានតឹងចិត្ត។<br>  - បណ្ណរូបភាព បង្ហាញពី វិធីនានាសម្រាប់កាត់បន្ថយភាពតានតឹងចិត្ត។<br>• ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ<br>• កងមូលសម្រាប់លេងល្បែងថាមពល<br>• កម្រាលសម្រាប់អ្នកចូលរួមអង្គុយ |

- ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រាអំពីវិន័យដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

## ខ្លឹមសារលម្អិត

### ១. សុខុមាលភាព

សុខុមាលភាពសំដៅទៅលើ អារម្មណ៍រីករាយ ឬសប្បាយ មានសុខភាពរាងកាយរឹងមាំ មានគុណភាពជីវិតល្អ។

### ២. ការតានតឹងចិត្ត

មានមូលហេតុជាច្រើនដែលនាំឱ្យមានភាពតានតឹងចិត្ត ហើយភាពតានតឹងចិត្តខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ ភាពតានតឹងចិត្តនោះអាចបណ្តាលមកពី៖

- កូនមិនស្តាប់បង្គាប់៖ មានមិត្តភក្តិមិនល្អ ដើរលេង លេងល្បែង បង្ហោះម៉ូតូ ក្រុមបងតូចបងធំ ឬធ្វើសកម្មភាពដែលសង្គមមិនឱ្យតម្លៃ។
- មានជំងឺរ៉ាំរ៉ៃ៖ ដូចជាជំងឺមហារីកថ្លើម ទឹកនោមផ្អែម លើសឈាម ឬអេដស៍ជាដើម។
- កូនមិនគោរព និងស្រឡាញ់បងប្អូន ឈ្លោះគ្នា និងប្រើហិង្សាដាក់គ្នា។
- សេដ្ឋកិច្ចគ្រួសារជួបការលំបាក៖ គ្រួសារមានចំណូលតិច ចំណាយច្រើន ជំពាក់បំណុលគេ ។ល។
- វិវាទនៅក្នុងគ្រួសារ៖ មានដូចជា ឈ្លោះគ្នាជាញឹកញាប់ មិនទុកចិត្តគ្នា មិនឱ្យតម្លៃគ្នា។
- ខ្វះអាហារូបត្ថម្ភ៖ អាហារមិនគ្រប់គ្រាន់សម្រាប់សមាជិកគ្រួសារ ។ល។

កាតព្វកិច្ចរបស់ឪពុកម្តាយក្នុងការចិញ្ចឹមកូនក៏ជាកត្តាដែលបង្កឱ្យមានភាពតានតឹងចិត្តខ្លាំងផងដែរ។ ហេតុដូចនេះបានជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនបានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ រំលោភបំពាន និងមិនអើពើលើកូន ឬកុមារ។ ការមិនបានចូលរួមចំណែក និងការមិនទទួលខុសត្រូវរបស់ឪពុក ក្នុងការចិញ្ចឹមកូនក៏ជាកត្តានាំឱ្យមានបន្ទុកកាន់តែធ្ងន់ធ្ងរ និងបង្កឱ្យមានកម្រិតនៃភាពតានតឹងចិត្តកាន់តែខ្លាំងដល់ម្តាយ។ កត្តាទាំងនេះអាចបណ្តាលឱ្យពួកគាត់បាត់បង់ការជឿជាក់លើខ្លួនឯងក្នុងការចិញ្ចឹម អប់រំ និងប្រៀនប្រដៅកូន ដោយអាកប្បកិរិយាហិង្សាដូចជា វាយ ជេរ មិនអើពើ បោះបង់កូនចោល បំបែកកូនចេញពីគ្រួសារ ឬយកកូនដាក់ក្នុងមណ្ឌលថែទាំ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនយល់ថាមណ្ឌលថែទាំជាកន្លែងដែលអាចជួយឱ្យកូន ឬកុមារទទួលបានការថែទាំ និងអប់រំល្អប្រសើរជាងខ្លួនដោយមិនបានគិតទៅដល់ការរំលោភបំពានផ្សេងៗដែលអាចកើតឡើងរវាងកុមារ និងកុមារ រវាងអ្នកថែទាំ និងកុមារ ការគិត អារម្មណ៍ តម្រូវការមូលដ្ឋានចាំបាច់សម្រាប់កូន ឬកុមារ ដូចជាសេចក្តីស្រឡាញ់ និងភាពកក់ក្តៅពី ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។

## ៣. រោគសញ្ញានៃភាពតានតឹងចិត្ត

| ខ្លឹមសារសម្រាប់អ្នកសម្របសម្រួល | | | |
|---|---|---|---|
| **រោគសញ្ញា និងផលប៉ះពាល់បង្កឡើងដោយភាពតានតឹងចិត្ត** | | | |
| រោគសញ្ញា | បញ្ហាលើផ្លូវកាយ | បញ្ហាលើផ្លូវចិត្ត | បញ្ហាលើអាកប្បកិរិយា |
| • ឈឺក្បាល (គិតច្រើន ព្រួយច្រើន)<br>• វិលមុខ ស្រវាំងភ្នែក<br>• ស្ងួតមាត់ ណែនបំពង់ក<br>• តឹងសាច់ដុំ<br>• ចុករោយសាច់ដុំក្នុងរាងកាយ (រោយក ស្មា ចុកចង្កេះ)<br>• ញ័រទ្រូង ក្ដៅទ្រូង ថប់ដង្ហើម ឬតឹងទ្រូង<br>• បែកញើស<br>• រមួលពោះចង់ក្អួត ឈឺពោះ (ឈឺក្រពះ ពោះវៀន រាគរូស)<br>• ស្ពឹកស្រពន់ ត្រជាក់ចុងដៃចុងជើង | • សម្ពាធឈាមឡើងខ្ពស់<br>• ឈឺក្រពះ (ដំបៅក្រពះ)<br>• ឈឺសន្លាក់ដៃ ជើង<br>• អសកម្ម(ខ្ជិល) ហត់នឿយ អស់កម្លាំង<br>• ថយចុះចំណង់ផ្លូវភេទ | • ពិបាកផ្ចង់អារម្មណ៍<br>• ឆាប់ខឹង<br>• សោប់សសល់<br>• ម្ញេម៉ៅ ធុញថប់<br>• សម្រាន្តមិនលក់<br>• យល់សប្តច្រើន យល់សប្តអាក្រក់<br>• ភ្លេចភ្លាំង<br>• បាត់បង់ការជឿជាក់លើខ្លួន<br>• មានអារម្មណ៍ឯកា | • ធ្វើអាកប្បកិរិយាប្រថុយនឹងគ្រោះថ្នាក់<br>• បង្កអំពើហិង្សា<br>• គេចចេញពីគេ |

## ៤. វិធីសាស្ត្រ ដើម្បីដោះស្រាយភាពតានតឹងចិត្តដោយវិជ្ជមាន

ពេលដែលមានភាពតានតឹងចិត្តយើងតែងតែរកវិធីសាស្ត្រផ្សេងៗក្នុងការដោះស្រាយ ឬបន្ធូរភាពតានតឹងចិត្ត ហើយរបៀបដោះស្រាយនីមួយៗតែងតែទទួលបានលទ្ធផលជាវិជ្ជមាន។ ដូចនេះយើងមានវិធីសាស្ត្រមួយចំនួនដែលអាចដោះស្រាយភាពតានតឹងចិត្តដូចជា៖

- **កម្សាន្តជាលក្ខណៈគ្រួសារ៖** វាមិនត្រឹមតែធ្វើឱ្យយើងមានអារម្មណ៍ធូរស្រាលពីភាពតានតឹងចិត្តប៉ុណ្ណោះទេ វាថែមទាំងជួយឱ្យគ្រួសារមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នាទៀតផង។
- **ការបួងសួង៖** អាចធ្វើបានទៅតាមជំនឿ ឬសាសនារបស់មនុស្សម្នាក់ៗ។ តាមទំនៀមទម្លាប់របស់ខ្មែរមួយចំនួន ចូលចិត្តធ្វើការបួងសួង ឬបន់ស្រន់នៅពេលដែលគាត់ពិបាក ឬមានបញ្ហាអ្វីមួយពិបាកដោះស្រាយនៅក្នុងគ្រួសារ ដូចនេះការបន់ស្រន់

ក៏អាចអាចធ្វើឱ្យមនុស្សបានធូរស្បើយពីទុក្ខលំបាកផ្សេងៗមួយកម្រិត ឬមួយរយៈពេលផងដែរ។

- **និយាយទូរស័ព្ទជាមួយមនុស្សដែលទុកចិត្ត៖** និយាយពីនេះពីនោះ ជជែកលេងជាមួយគាត់ បង្កើតភាពសប្បាយរីករាយ និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃឱ្យកាន់តែជិតស្និទ្ធ។
- **ហាត់ប្រាណ ឬលេងកីឡា៖** អាចជួយឱ្យមានសុខភាពល្អ និងអារម្មណ៍ស្រស់ថ្លាឡើងវិញ។
- **ដាំដំណាំ៖** យើងអាចទាញប្រយោជន៍ពីវាបានច្រើនដូចជា កាត់បន្ថយចំណាយទៅលើម្ហូបអាហារ ហើយក៏ជាគំរូដល់កូនចៅជំនាន់ក្រោយសម្រាប់អនុវត្តផងដែរ។
- **និយាយជាមួយមនុស្សដែលទុកចិត្ត៖** ស្វែងរកជំនួយពីមនុស្សដែលទុកចិត្តព្រោះគេអាចស្តាប់រឿងរ៉ាវរបស់យើងដោយយកចិត្តទុកដាក់ មិនធ្វើការវិនិច្ឆ័យ និងអាចរក្សាការសម្ងាត់ឱ្យយើងបាន។
- **សមាធិ៖** របៀបក្នុងការសមាធិមិនមែនមានន័យថាឱ្យយើងស្ងប់មិនគិតអ្វីនោះទេ តែវាអាចជួយឱ្យយើងបានយល់ច្បាស់ពីបញ្ហា ឬរឿងរ៉ាវផ្សេងៗដែលបានកើតឡើង ទទួលស្គាល់បញ្ហាព្រមទាំងអារម្មណ៍ផ្សេងៗដែលកើតមានហើយ ធ្វើឱ្យយើងមានភាពតានតឹងចិត្ត។ បន្ទាប់មកយើងបន្ធូរឱ្យវាចេញទៅ ដោយផ្តោតអារម្មណ៍លើលំហាត់ខ្យល់ដង្ហើមចេញ និងចូល។
- **ស្តាប់ចម្រៀង៖** ជាមធ្យោបាយមួយដែលជួយឱ្យអ្នកមានអារម្មណ៍ស្រស់ថ្លា និងបំបាត់នូវភាពតានតឹងទាំងឡាយ។

មនុស្សមួយចំនួនមិនបានជ្រើសរើសវិធីដោះស្រាយបែបវិជ្ជមានដូចបានរៀបរាប់ខាងលើទេ តែបែរជាជ្រើសរើសវិធីដោះស្រាយបែបអវិជ្ជមានដូចជា លេងល្បែងស៊ីសង ចូលក្លឹប ចាយលុយខ្ជះខ្ជាយ ផឹកស្រា បោករបស់របរ ឈ្លោះ វាយគ្នា វាយកូន ជេរកូន ឬបង្អោះម៉ូតូជាដើម។ វិធីអវិជ្ជមានទាំងនោះពិតជាអាចធ្វើឱ្យខាតបង់ប្រយោជន៍ ប៉ះពាល់ដល់សុខុមាលភាពខ្លួនឯង ទំនាក់ទំនងគ្រួសារ និងការចិញ្ចឹមកូន ឬកុមារ។

ការលៃលកដោះស្រាយភាពតានតឹងចិត្តឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព គឺពិតជាមានសារៈសំខាន់បំផុតសម្រាប់លោកអ្នកដែលជាឪពុកម្តាយអាណាព្យាបាល ឬអ្នកថែទាំ ពីព្រោះការដោះស្រាយទាន់ពេលវេលាអាចជួយលោកអ្នក៖

- មានសុខុមាលភាពល្អ
- បំពេញកាតព្វកិច្ចចិញ្ចឹមកូន ឬកុមារដោយមានភាពតានតឹងចិត្តតិចតួច
- មានទំនាក់ទំនង និងអធ្យាស្រ័យល្អជាមួយសមាជិកគ្រួសារ ឬអ្នកនៅជុំវិញខ្លួន
- ធ្វើជាគំរូល្អដល់កូន ឬកុមារក្នុងការដោះស្រាយបញ្ហា ឬភាពតានតឹងចិត្ត។ កូន ឬកុមារភាគច្រើន រៀនធ្វើសកម្មភាពតាមអ្នកនៅជុំវិញខ្លួនគេ
- ជៀសផុតពីការប្រព្រឹត្តអំពើហិង្សាលើកូន ឬកុមារ ។ល។

## ការយល់ដឹងពីកំហឹង

ជាការបង្ហាញពីឆាគសញ្ញានៃការប៉ះពាល់មកលើផ្លូវចិត្តដែលបណ្ដាលមកពីភាពតានតឹងចិត្ត ហើយកត្តានេះអាចបណ្ដាលឱ្យមនុស្សឆាប់ខឹង ឬនិយាយយ៉ាងខ្លីហៅថាកំហឹងដែលអាចឈានទៅដល់ការប្រព្រឹត្តអំពើហិង្សា។

កំហឹងជាអារម្មណ៍មួយដែលផ្ដល់នូវកម្លាំងថាមពលដើម្បីធ្វើសកម្មភាព ហើយអាចជួយឱ្យយើងបញ្ចេញចោលនូវភាពតានតឹងចិត្ត។ ការដែលមានអារម្មណ៍ខឹងនេះគឺជាការធម្មតាទេ ប៉ុន្តែអាកប្បកិរិយាខឹងមួយចំនួនដូចជា អំពើហិង្សា ឬការរំលោភបំពានដោយពាក្យសំដីអាចបង្កើតឱ្យមានជម្លោះ ឬឱ្យខូចខាតដល់ទ្រព្យសម្បត្តិអ្នកដទៃ និងខ្លួនឯង ព្រមទាំងអាយុជីវិតផងដែរ។

ដើមហេតុដែលបង្កជាកំហឹងអាចបណ្ដាលមកពីអារម្មណ៍ ភ័យព្រួយ ខ្លាច ឈឺចាប់ តូចចិត្ត កណ្ដោចកណ្ដែង ឯកោ ឬគ្មានការគោរពជាដើម។

*ឧទាហរណ៍៖ ឪពុកម្នាក់អាចមើលទៅដូចជាខឹងខ្លាំងដោយសារតែកូនស្រីរបស់គាត់អត់ចេះធ្វើការងារអ្វីសោះសូម្បីតែដាំបាយ។ ប៉ុន្តែអ្វីដែលបង្កប់ក្នុងកំហឹងរបស់គាត់អាចជាការព្រួយបារម្ភពីអនាគតកូនស្រី ឬអារម្មណ៍ខ្មាស់គេ ដោយសារគិតថាខ្លួនជាឪពុកម្ដាយមិនល្អ ទើបកូនស្រីមិនចេះធ្វើការងារផ្ទះ។*

តើត្រូវធ្វើដូចម្ដេចដើម្បីដោះស្រាយកំហឹងឱ្យល្អប្រសើរ ហើយជៀសវាងការប្រព្រឹត្តអំពើហិង្សា?

ប្រសិនបើអ្នកអាចកត់សម្គាល់ពីអារម្មណ៍នានា ឬខឹង ហើយដឹងពីហេតុផលនៃអារម្មណ៍ទាំងនោះ យើងនឹងអាចរកវិធីដើម្បីបញ្ចេញកំហឹងដោយសុវត្ថិភាព។

ការព្រងើយកន្តើយ ឬមិនដោះស្រាយនូវអារម្មណ៍ខឹងទាំងនោះវានឹងជះឥទ្ធិពលដល់ខ្លួនយើង និងអ្នកនៅជុំវិញជាពិសេសកូនៗ ឬកុមារ។

មនុស្សគ្រប់គ្នាមិនមែនសុទ្ធតែបញ្ចេញប្រតិកម្មដោយកំហឹងចំពោះស្ថានភាពដូចគ្នានោះឡើយ។ ការបញ្ចេញប្រតិកម្មដោយកំហឹងចំពោះស្ថានភាពជាក់លាក់មួយគឺអាស្រ័យទៅលើការគិត គំនិត ជំនឿ និងបទពិសោធន៍ដែលនៅពីក្រោយស្ថានភាពនោះ ដែលអាចជះឥទ្ធិពលដល់ប្រតិកម្មរបស់យើងចំពោះស្ថានភាពពិសេសណាមួយដែលអាចបង្ហាញនៅក្នុងគំរូនៃការយល់ដឹងអំពីអាកប្បកិរិយាខាងក្រោម៖

| ដើមហេតុ (ក) | គំនិត ឬជំនឿស្វ័យប្រវត្តិ (ខ) | លទ្ធផល (គ) |
|---|---|---|
| កូនធ្វើបែកកែវ | "កូននេះ លើកណាក៏ភ្លើអញ្ជឹងដែរ ស្អីក៏មិនចេះដែរពូកែតែខាងបង្ខិនបង្ខោច" | ចាប់ផ្តើមមានកំហឹង |
| | "កំហុស និងរឿងចៃដន្យ វាកើតមានចំពោះមនុស្សគ្រប់គ្នា រួមទាំងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថៃទាំផងដែរ" | • ប្រតិកម្មតបតវិញដោយស្ងប់អារម្មណ៍ |

ដូច្នេះ ចំពោះស្ថានភាពដូចគ្នា អាចមានប្រតិកម្មតបខុសៗគ្នាច្រើន អាស្រ័យតាមគំនិតផ្សេងៗ។ សារៈសំខាន់មិនមែនស្ថិតលើដើមហេតុដែលកើតឡើងនោះទេ តែវាស្ថិតលើការដែលយើងប្រតិកម្មតបតទៅវិញ។ ការយល់ដឹងអំពីចំណុចនេះ គឺជាគន្លឹះក្នុងការទប់ស្កាត់ និងគ្រប់គ្រងកំហឹង ប្រសិនបើយើងផ្លាស់ប្តូរអំពីគំនិត ជំនឿ នោះលទ្ធផលក៏មានការផ្លាស់ប្តូរដែរ។ ម្យ៉ាងទៀតយើងអាចយកវិធីសាស្ត្រនៃការដោះស្រាយភាពតានតឹងចិត្តខាងលើ ដើម្បីដោះស្រាយកំហឹង។

ប្រសិនបើមនុស្សម្នាក់ខឹង វិធីល្អបំផុត គឺដើរចេញឱ្យឆ្ងាយពីគាត់ ហើយចំណាយពេលដើម្បីគិតរកហេតុផល បន្ទាប់មកត្រូវរង់ចាំរហូតដល់គាត់ស្ងប់អារម្មណ៍ ទើបជជែកអំពីបញ្ហានោះ។

## ៥. រោគសញ្ញានៃភាពតានតឹងចិត្តរបស់កុមារ

យើងអាចកត់សម្គាល់កូន ឬកុមារមានភាពតានតឹងចិត្តដោយសង្កេតឱ្យបានដិតដល់លើការប្រែប្រួលរបស់ពួកគេតាមរយៈរោគសញ្ញាមួយចំនួនដូចខាងក្រោម៖

| រោគសញ្ញា | បញ្ហាលើផ្លូវកាយ | បញ្ហាលើផ្លូវចិត្ត | បញ្ហាលើ<br>អាកប្បកិរិយា |
|---|---|---|---|
| • ឈឺក្បាល<br>• តឹងសាច់ដុំ<br>• ចុករោយសាច់ដុំក្នុងរាងកាយ (រោយក ស្មា ចុកចង្កេះ)<br>• ញ័រទ្រូង ក្តៅទ្រូង ថប់ដង្ហើម ឬ តឹងទ្រូង<br>• បែកញើស<br>• រមួលពោះ ចង់ក្អួត ឈឺពោះ (ឈឺក្រពះ ពោះវៀន រាគរូស)<br>• ស្ពឹកស្រពន់ ត្រជាក់ចុងដៃ ចុងជើង | • អសកម្ម (ខ្ជិល)<br>• អស់កម្លាំង<br>• គេងច្រើន ឬគេងមិនលក់<br>• បេះដូងលោតញាប់<br>• ឈឺសន្លាក់ដៃ ជើង | • ពិបាកផ្ចង់អារម្មណ៍<br>• ឆាប់ខឹង<br>• ឆេវឆាវ<br>• ស្រងូតស្រងាត់<br>• ភ័យខ្លាច<br>• ធុញទ្រាន់ច្រើន អំពីសកម្មភាព នៅសាលា<br>• ការសិក្សាធ្លាក់ចុះ<br>• រសាប់រសល់<br>• មួម៉ៅ ធុញថប់<br>• សម្រាន្តមិនលក់<br>• យល់សប្តច្រើន យល់សប្តអាក្រក់<br>• បាត់បង់ការជឿជាក់ លើខ្លួន<br>• មានអារម្មណ៍ឯកា | • បង្កអំពើហិង្សា<br>• ញ៉ាំច្រើន ឬមិនសូវញ៉ាំ<br>• តាមស្អិតជាមួយ ឪពុកម្តាយ ឬគ្រូ<br>• គេចមុខពី ឪពុកម្តាយ<br>• មិនចូលរួម សកម្មភាព ជាមួយអ្នកដទៃ<br>• នោមដាក់កន្ទេល<br>• និយាយត្រដឹត<br>• និយាយកុហក<br>• ធ្វើសកម្មភាព ប្រឆាំង |

ចំពោះកុមារដែលមានពិការភាព ការបង្ហាញថាមានភាពតានតឹងចិត្ត គឺមិនសូវខុសពីកូន ឬកុមារទូទៅទេ ហើយក៏អាស្រ័យទៅលើប្រភេទ និងកម្រិតពិការភាពរបស់ពួកគាត់ដែរ។

*ឧទាហរណ៍៖ បើសិនជាកូន ឬកុមារមានបញ្ហាខ្សោយសតិបញ្ញា ហើយមានភាពតានតឹងចិត្ត ពួកគាត់អាចស្រែកយំ បោករបស់របរ ធ្វើបាបខ្លួនឯង (បោចសក់ ខាំ បោកក្បាល) ស្ងៀមស្ងាត់ ឬពិបាកគេង ។ល។ ចំពោះកូន ឬកុមារពិការភ្នែក អវៈយវៈ ឬថ្លង់ក៏អាចបង្ហាញ ឬសម្តែងចេញអារម្មណ៍ និងអាកប្បកិរិយា ប្រហាក់ប្រហែលនឹងកូន ឬកុមារទូទៅដែរ នៅពេលពួកគេមានភាពតានតឹងចិត្ត។*

## ៦. របៀបដោះស្រាយភាពតានតឹងចិត្តរបស់កុមារ

កូន ឬកុមារតូចប្រហែលជាអាចសង្កេត ឬធ្វើត្រាប់តាមនូវសកម្មភាពទាំងឡាយដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបានធ្វើនៅពេលដែលពួកគាត់មានភាពតានតឹងចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរជួយកូន ឬកុមារដោយប្រើប្រាស់វិធីទាំងឡាយណាដែលមានអត្ថប្រយោជន៍ចំពោះពួកគេ។ វិធីទាំងនោះមានដូចជា៖

## កុមារដែលមានអាយុចន្លោះពី ០ឆ្នាំ ដល់ ១២ឆ្នាំ

- ឱបកូន ដោយបង្ហាញថា លោកអ្នកស្រឡាញ់ និងបារម្ភពីពួកគេ។
- ផ្ដល់តុក្កតា ឬរបស់លេងណាដែលពួកគេចូលចិត្ត ដើម្បីជួយឱ្យមានអារម្មណ៍កក់ក្ដៅ និងមានសុវត្ថិភាព។
- ផ្អំ និងបន្ធូរប៉ោងប៉ោងចំពោះកូនតូចៗ ហើយចំពោះកូន ឬកុមារដែលមានអាយុធំ អាចឱ្យពួកគាត់ដកដង្ហើមវែងៗ។
- ចំណាយពេលនៅក្បែរ និងលេងជាមួយកូន។
- លេងល្បែងណាដែលអាចឱ្យកូនបញ្ចេញអារម្មណ៍ ដូចជាគូរគំនូរ ផាត់ពណ៌ តុក្កតា ហើយលើកទឹកចិត្តកូននិយាយពីអារម្មណ៍នោះ។
- និទានរឿងឱ្យកូន ឬកុមារស្ដាប់ ដែលរឿងនោះគឺអាចប្រហាក់ប្រហែលទៅនឹងរឿងរបស់កូន ហើយពិភាក្សាជាមួយកូនពីតួអង្គក្នុងសាច់រឿងនោះ។
- ប្រាប់កូនឱ្យច្បាស់ថា អ្វីៗដែលកើតមានឡើងមិនមែនជាកំហុសរបស់ពួកគេទេ។ កូន ឬកុមារមួយចំនួនតែងបន្ទោសខ្លួនឯង ហើយអាចគិតថាជម្លោះឪពុកម្ដាយ គឺអាចមកពីកំហុសខ្លួនគេ។
- ក្នុងនាមជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវថែរក្សាខ្លួនឯង ហើយត្រូវធ្វើចិត្តឱ្យស្ងប់ក្នុងការប្រឈមជាមួយស្ថានភាពតានតឹងចិត្ត ឬកំហឹងរបស់កូន។

## កុមារដែលមានអាយុចន្លោះពី ១៣ ដល់ក្រោម ១៨ឆ្នាំ

- កាត់បន្ថយសកម្មភាពមួយចំនួនដែលកូនកំពុងធ្វើ បើសិនជាអាចធ្វើបាន។
- ទទួលស្គាល់អារម្មណ៍ដែលកូនមាន ហើយពន្យល់កូនឱ្យយល់ពីស្ថានភាពតានតឹងចិត្តនោះ។
- ស្ដាប់កូននិយាយដោយមិនវិនិច្ឆ័យ ហើយជួយពួកគេឱ្យនិយាយពីបញ្ហាដែលនាំឱ្យមានភាពតានតឹងចិត្ត។
- ឱ្យកូនយំ ឬស្រែកនៅកន្លែងដែលមានសុវត្ថិភាព ឬក្នុងបន្ទប់ ប្រសិនបើពួកគេចង់ធ្វើ។
- បង្រៀនកូនឱ្យចេះដោះស្រាយភាពតានតឹងចិត្តបែបវិជ្ជមានដោយជ្រើសរើសនូវសកម្មភាពដូចជា លេងកីឡា ដាំផ្កា ងូតទឹក ស្ដាប់ចំរៀង ។ល។
- ជានិច្ចកាល ធ្វើជាគំរូដល់កូន ក្នុងការដោះស្រាយជាមួយភាពតានតឹងចិត្ត។

## វិធីបង្កើនទំនុកចិត្ត និងភាពជឿជាក់ខ្លួនឯងចំពោះកូន

- ទិតៀនតែលើការប្រព្រឹត្ត តែមិនទិតៀនកូន។ ឧទាហរណ៍ "ការដែលនិយាយកុហក" "ការយករបស់អ្នកដទៃដោយមិនមានការអនុញ្ញាត" មិនមែនជាអាកប្បកិរិយាល្អទេ ហើយក៏ជាអាកប្បកិរិយាដែលគេមិនអាចទទួលយកបានដែរ។
- អនុញ្ញាតឱ្យកូនធ្វើការសាកល្បង ដើម្បីជួយឱ្យគេបានរៀន និងស្វែងយល់នូវផលវិបាកពីសកម្មភាពនោះ។ ឧទាហរណ៍ កូនមិនមើលមេរៀន ឬធ្វើកិច្ចការសាលា នាំឱ្យកូនទទួលបានពិន្ទុមិនល្អ ឬធ្លាក់។ ពន្យល់កូនឱ្យយល់ពីទំនាក់ទំនងរវាង

"អំពើ និងផល" (ធ្វើអ្វីនឹងទទួលបានផលនោះ)។ ដូចនេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរលើកទឹកចិត្តឱ្យកូន ឬកុមារគិតពីអ្វីដែលគេអាចធ្វើបានកុំឱ្យដូចលើកមុន។

- ដាក់គោលដៅណាដែលកូនអាចសម្រេចបាន។ ពិភាក្សាពីគោលដៅនោះ ហើយត្រូវប្រាកដថាកូន ឬកុមារយល់ពីគោលដៅនេះ។ ផ្ដល់ការលើកទឹកចិត្តដល់កូន និងចំណាយពេលស្ដាប់ ឬសង្កេតពីអ្វីដែលកូនសម្រេចបាន។ ទង្វើបែបនេះធ្វើឱ្យកូនមានអារម្មណ៍ថាខ្លួនគេមានតម្លៃ។

### ផ្ដល់ឱកាសឱ្យកុមារនិយាយ៖

លើកទឹកចិត្តកូនឱ្យនិយាយពីអារម្មណ៍របស់គេ ដែលបណ្ដាលមកពីភាពតានតឹងចិត្ត។ វាមានសារៈសំខាន់ណាស់ដែលយើងជួយឱ្យកូនអាចដាក់ឈ្មោះអារម្មណ៍នានារបស់គេដែលកំពុងកើតមាន។ ឧទាហរណ៍ ពេលដែលម្ដាយមានជំងឺកូនអាចមានអារម្មណ៍ភ័យខ្លាច ទុក្ខសោក ឬច្របូកច្របល់។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវពិភាក្សាពីអារម្មណ៍នោះ ហើយបង្ហាញនូវការអះអាងថា មិនមានបញ្ហាអ្វីកើតឡើងចំពោះកូនទេ ព្រោះមានមនុស្សដែលកូនទុកចិត្តនៅមើលថែទាំកូនបាន។

### រក្សារបៀបរស់នៅដែលល្អ៖

ត្រូវផ្ដល់នូវរបបអាហារ (អាហារ ៣ក្រុម) ការសម្រាក និងគេងបានត្រឹមត្រូវដល់កូន ឬកុមារ។ មួយទៀត ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវទុកឱកាសឱ្យកូនបានលេងសប្បាយ និងលំហែផងដែរ។ ចំពោះកូនវ័យជំទង់គួរផ្ដល់ពេលវេលាសម្រាប់ពួកគេ ក្នុងការជួបជាមួយមិត្តភក្តិ ដើម្បីពិភាក្សាពីការងារនៅសាលា ឬបញ្ហាសង្គមនានា។

### អនុញ្ញាតឱ្យកុមារចូលរួមក្នុងការសម្រេចចិត្តដោះស្រាយ៖

វាមានសារៈសំខាន់ណាស់ដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បង្កើតឱ្យមានការពិភាក្សាដោយបំផុសគំនិត និងការចូលរួមយ៉ាងសកម្មពីកូន ឬកុមារ។ ឧទាហរណ៍ ឱ្យកុមារលើកយកមធ្យោបាយមួយចំនួនដែលធ្វើឱ្យគេមានអារម្មណ៍បានប្រសើរ ហើយពិភាក្សានូវជម្រើសនោះ។

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាល ហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួម ចែករំលែកបទពិសោធន៍នៃការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួម ដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួលជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នាកាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>🗣 បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុច ដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះនៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមជំផ្តល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្រ្ត |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែងថាមពល (១៥នាទី) | ▪ អ្នកសម្របសម្រួលអាចជ្រើសរើសល្បែងដែលធ្វើឱ្យមានការរំជួលចិត្តខ្លាំង រីករាយ និងមានការប្រកួតប្រជែង។ អ្នកសម្របសម្រួលអាចយកល្បែងដែលមានស្រាប់ ឬបង្កើតដោយខ្លួនឯង។<br>· បែងចែកអ្នកចូលរួមជា ២ក្រុម ដែលមានសមាជិកស្មើគ្នា<br>· ក្រុមនីមួយៗ ឈរជាជួរ កាន់ដៃបន្តគ្នា<br>· ចែកកងមួយក្រុម១ ដោយក្រុមនីមួយៗធ្វើយ៉ាងណាបញ្ជូនកងពីម្នាក់ទៅម្នាក់រហូតដល់អ្នកចុងក្រោយ ដោយឱ្យកងនោះអាចឆ្លងកាត់ដងខ្លួនទាំងមូល និងមិនរបេះដៃពីគ្នា<br>· ពេលទៅដល់ចុងក្រោយ ធ្វើវាត្រឡប់មកវិញ ដាក់លក្ខខណ្ឌលេង ៣ដង ដើម្បីរកអ្នកឈ្នះ អ្នកចាញ់។<br>· បើមានពេលគ្រប់គ្រាន់អាចលេងហ្គេមមួយទៀតកាន់តែល្អ ដើម្បីអ្នកចូលរួមមានអារម្មណ៍ច្រើន និងសប្បាយផង។<br>▪ បន្ទាប់ពីលេងល្បែងរួច សួរទៅអ្នកចូលរួមថា៖<br>☞ បន្ទាប់ពីលេងល្បែងហើយ តើអ្នកមានអារម្មណ៍ដូចម្ដេច?<br>☞ ពេលកំពុងលេង តើអ្នកមានអារម្មណ៍អ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ សប្បាយ ភ័យ អន្ទះសារ ខឹង ខកចិត្ត ខ្លាច រីករាយ ព្រួយបារម្ភ ។ល។<br>▪ អ្នកសម្របសម្រួលកត់ចម្លើយ អ្នកចូលរួមលើក្ដារខៀន។ បើអ្នកចូលរួមមិនចេះអក្សរ ប្រើរូបភាពបង្ហាញពីអារម្មណ៍ផ្សេងៗ ហើយបិទលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ |
| ៥ | មេរៀនថ្មី៖ សុខុមាលភាពឪពុកម្ដាយ | ស្វែងយល់ពីភាពតានតឹងចិត្ត និងមូលហេតុដែលនាំឱ្យមានភាពតានតឹងចិត្ត (២០នាទី) | ▪ អ្នកសម្របសម្រួលអាចលើកឡើងថា អារម្មណ៍កើតឡើងដោយស្វ័យប្រវត្តិ នៅពេលដែលយើងបានជួបនឹងស្ថានភាពណាមួយ យើងមិនអាចបញ្ជាឱ្យមានអារម្មណ៍បែបនេះ ឬបែបនោះឡើយ។ អារម្មណ៍ទាំងនោះអាចជាអារម្មណ៍ ឈឺចាប់ ខឹង តូចចិត្ត សប្បាយ ឬខ្មាស់អៀន។<br>▪ អ្នកសម្របសម្រួលបន្ត ដោយលើកឡើងថា ថ្ងៃនេះយើងនឹងពិភាក្សាគ្នាអំពី សុខុមាលភាពឪពុកម្ដាយ ដែលផ្ដោតទៅលើភាពតានតឹងចិត្ត។ បន្ទាប់មកធ្វើការបំផុសដោយសួរ<br>☞ តើលោកអ្នកយល់ថា សុខុមាលភាពសំដៅទៅលើអ្វី?<br>🗣 ចម្លើយរំពឹងទុក៖ មិនមានជំងឺ ធាត់ សប្បាយចិត្ត មានដៃជើងខ្លួនប្រាណគ្រប់គ្រាន់ ។ល។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបគំនិតរបស់អ្នកចូលរួម និងពន្យល់អត្ថន័យ**សុខុមាលភាព** ដើម្បីឱ្យអ្នកចូលរួមបានយល់ បើសិនអ្នកចូលរួមនៅតែមិនយល់ អ្នកសម្របសម្រួលពន្យល់ និងលើកឧទាហរណ៍មកបញ្ជាក់។ បន្ទាប់មកអ្នកសម្របសម្រួលលើករូបភាពទី១ រួចសួរ<br>☞ តើរូបភាពនេះបង្ហាញពីអ្វី?<br>🗣 ចម្លើយរំពឹងទុក៖ ធុញថប់ តប់ប្រមល់ ស្មុគស្មាញ មួម៉ៅ ពិបាកចិត្ត ឈឺក្បាល។ល។<br>▪ អ្នកសម្របសម្រួលបន្តសួរសំណួរ<br>☞ តើភាពតានតឹងចិត្តបណ្តាលមកពីអ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ កូននិយាយមិនស្តាប់ ទំនាក់ទំនងមិនល្អជាមួយដៃគូ កូនឈឺ បាត់បង់ការងារ អត់លុយ ។ល។<br>▪ អ្នកសម្របសម្រួល ធ្វើការពន្យល់រូបភាពនីមួយៗ (រូបភាពទី២ រហូតដល់រូបភាពទី៧) ដែលបង្ហាញអំពីមូលហេតុដែលនាំឱ្យមានភាពតានតឹងចិត្ត។ |
| | | **ស្វែងយល់អំពីភាពតានតឹងចិត្តរបស់កុមារ**<br>(១៥នាទី) | ▪ បន្ទាប់ពីបង្ហាញ និងបន្ថែមខ្លឹមសាររួច អ្នកសម្របសម្រួលបន្តសួរសំណួរ<br>☞ តើកុមារអាចមានភាពតានតឹងចិត្តដែរឬទេ?<br>☞ នៅពេលកុមារ មានភាពតានតឹងចិត្ត តើពួកគេមានអាកប្បកិរិយាដូចម្តេចខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ យំ រញ៉ាំរញ៉ូវ បោកប្រាស់របស់របរ មិននិយាយស្តី គេចចេញពីគេឯង នៅស្ងៀមស្ងាត់ ស្រែកគំហក ។ល។<br>▪ អ្នកសម្របសម្រួល ធ្វើការបូកសរុបគំនិតអ្នកចូលរួម និងពន្យល់បន្ថែម។ |
| | | **ផលប៉ះពាល់ដែលបង្កឡើងដោយភាពតានតឹងចិត្ត**<br>(២០នាទី) | ▪ អ្នកសម្របសម្រួលសួរសំណួរបំផុសទៅអ្នកចូលរួម<br>☞ តើភាពតានតឹងចិត្តបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ ភ្លេចភ្លាំង ពិបាកគេង យល់សប្តច្រើន ឈឺក្បាល ឈឺសាច់ដុំ ឈឺពោះ។ល។<br>▪ អ្នកសម្របសម្រួល សរុបគំនិតអ្នកចូលរួម ដោយបង្ហាញរូបភាពទី៨ ស្តីពីផលប៉ះពាល់បង្កឡើងដោយភាពតានតឹងចិត្ត រួមទាំងពន្យល់ថា កុមារ និងកុមារដែលមានពិការភាព ក៏មានផលប៉ះពាល់ដូចមនុស្សពេញវ័យដែរ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **របៀបបន្ធូរភាពតានតឹងចិត្ត (២០នាទី)** | ▪ ឥឡូវនេះយើងពិភាក្សាគ្នា អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយភាពតានតឹងចិត្តដោយសួរ<br>☞ តាមបទពិសោធន៍កន្លងមក តើសកម្មភាពអ្វីខ្លះ ដែលលោកអ្នកធ្លាប់បានធ្វើនៅពេលដែលមានភាពតានតឹងចិត្ត?<br>🗣 ចម្លើយរំពឹងទុក៖ ដើរចេញ វាយកូន ជេរ ផឹកស្រា ដើរលេងរកគ្រូទាយ បួងសួង ច្រៀងខារ៉ាអូខេ ផឹកទឹក ស្តាប់ភ្លេង ដាំដំណាំ ឱ្យចំណីសត្វ ហែលទឹក ជិះកង់ នៅស្ងាត់ម្នាក់ឯង។ល។<br>▪ បន្ទាប់មក អ្នកសម្របសម្រួលសួរបន្ត<br>☞ តើយើងអាចជួយកុមារក្នុងការដោះស្រាយភាពតានតឹងចិត្តយ៉ាងដូចម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ លួងលោម ឱប ច្រៀង លេងជាមួយ ស្តាប់គាត់និយាយ ជជែកលេង នាំកូនដើរលេង។ល។<br>សម្គាល់៖ អ្នកសម្របសម្រួល ព្យាយាមជួយអ្នកចូលរួមឱ្យស្វែងរកវិធីសាស្ត្របែបវិជ្ជមានឱ្យបានច្រើន ប្រសិនបើមានចម្លើយបែបអវិជ្ជមាន អ្នកសម្របសម្រួលសួរសំណួរដើម្បីឱ្យអ្នកចូលរួមបានវិភាគពីលទ្ធផល និងផលប៉ះពាល់របស់វា។<br>▪ សរុបយោបល់អ្នកចូលរួម រួចបង្ហាញរូបភាព (រូបភាពទី៩ រហូតដល់ទី១៦) ស្តីពីវិធីនានាសម្រាប់ដោះស្រាយភាពតានតឹងចិត្តដោយពន្យល់បន្ថែមតាមខ្លឹមសារមេរៀន។ |
| | | **សង្ខេបមេរៀន (៥នាទី)** | ថ្ងៃនេះយើងបានពិភាក្សាគ្នា អំពីសុខុមាលភាពរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ហើយយើងបានដឹងពីមូលហេតុដែលធ្វើឱ្យយើងមានភាពតានតឹងចិត្ត ផលប៉ះពាល់ និងវិធីដែលជួយកាត់បន្ថយភាពតានតឹងចិត្តសម្រាប់ដោះស្រាយនៅក្នុងគ្រួសារ។ បើសិនជាយើងមិនបានបន្ធូរភាពតានតឹងចិត្តឱ្យបានត្រឹមត្រូវ នោះវានឹងអាចមានឥទ្ធិពលដល់ការចិញ្ចឹមកូន និងទំនាក់ទំនងក្នុងគ្រួសារ។ ម្យ៉ាងវិញទៀត យើងក៏បានពិភាក្សាដែរអំពីរបៀបដែលអាចកត់សម្គាល់ថា កូន ឬកុមារមានភាពតានតឹងចិត្ត និងជួយឱ្យគាត់ចេះដោះស្រាយភាពតានតឹងចិត្ត ព្រមទាំងធ្វើឱ្យពួកគេកាន់តែមានទំនុកចិត្តលើខ្លួនឯងថែមទៀត។ ដូច្នេះ ដើម្បីជៀសវាងពីផលប៉ះពាល់អវិជ្ជមានចំពោះការចិញ្ចឹមកូន ចាំបាច់ឪពុកម្តាយ អាណាព្យាបាលឬអ្នកថែទាំត្រូវដឹងពីវិធីដែលធ្វើឱ្យមានសុខុមាលភាពល្អ គឺត្រូវមានរបៀបកាត់បន្ថយភាពតានតឹងនោះតាមបែបវិជ្ជមាន។ |

## រូបភាពទី ១



# ភាពតានតឹងចិត្ត

## រូបភាពទី ២



# កូនមិនស្ដាប់បង្គាប់

# រូបភាពទី ៣



# មានជំងឺរ៉ាំរ៉ៃ

## រូបភាពទី ៤



# កូនឈ្លោះគ្នា

## រូបភាពទី ៥



# សេដ្ឋកិច្ចគ្រួសារជួបការលំបាក

## រូបភាពទី ៦



# វិវាទនៅក្នុងគ្រួសារ

## រូបភាពទី ៧



# ខ្វះអាហារូបត្ថម្ភ

# រូបភាពទី ៨




# ផលប៉ះពាល់បង្កឡើងដោយ ភាពតានតឹងចិត្ត

# រូបភាពទី ៩



# កម្សាន្តលក្ខណៈគ្រួសារ

## រូបភាពទី ១០



# ការបួងសួង

## រូបភាពទី ១១



# និយាយទូរស័ព្ទជាមួយមនុស្ស ដែលទុកចិត្ត

## រូបភាពទី ១២



# ហាត់ប្រាណ ឬលេងកីឡា

# រូបភាពទី ១៣



# ដាំដំណាំ

## រូបភាពទី ១៤



# ពិភាក្សាជាមួយមនុស្ស ដែលទុកចិត្ត

# រូបភាពទី ១៥



# សមាធិ

# រូបភាពទី ១៦



# ស្តាប់ចម្រៀង

# វគ្គទី៤

## មេរៀនទី៣៖ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ

### សេចក្ដីផ្ដើម

គ្រួសារគឺជាគ្រឹះមួយនៃសង្គម ដូចនេះការប្រាស្រ័យទាក់ទងនៅក្នុងគ្រួសារ គឺជាផ្នែកសំខាន់មួយនៃជីវិតគ្រួសារវិជ្ជមាន។ នៅក្នុងគ្រួសារ កុមាររៀនពីការធ្វើអន្តរកម្មនានាជាមួយអ្នកនៅជុំវិញខ្លួនរបស់ពួកគេ ដូចជា ការរៀននិយាយ និងរៀនស្ដាប់ជាដើម។ កុមាររៀនប្រាស្រ័យទាក់ទង តាមរយៈគំរូពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បងប្អូន និងសាច់ញាតិរបស់ពួកគេក្នុងការរស់នៅប្រចាំថ្ងៃ។ កុមារដឹងពីគុណតម្លៃ និងទទួលបានការស្រលាញ់តាមរយៈរបៀបប្រាស្រ័យទាក់ទងរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។

ការប្រាស្រ័យទាក់ទងគឺជាការផ្ដល់ និងទទួលបានព័ត៌មាន ការគិត និងអារម្មណ៍នានាតាមរយៈការ និយាយ (ជួបផ្ទាល់ និងតាមប្រព័ន្ធអេឡិចត្រូនិច) ដោយការសរសេរ (កត់ត្រា សារព័ត៌មាន សារតាមទូរស័ព្ទ អ៊ីម៉ែល ហ្វេសប៊ុក) និងកាយវិការ (ចលនាដៃជើង ទឹកមុខ ទម្រង់រាងកាយ សម្លេង និងក្រសែភ្នែក)។

**ការប្រាស្រ័យទាក់ទងធ្វើឡើងក្នុងរង្វង់សមាជិកគ្រួសារក្នុងគោលបំណង៖**

- ចែករំលែកព័ត៌មានដែលកើតឡើងប្រចាំថ្ងៃ
- បង្ហាញ និងប្រាប់អំពីអារម្មណ៍ និងការគិតនានាដែលអាចកើតមាន
- ពិភាក្សាអំពីបញ្ហានិងស្វែងរកដំណោះស្រាយជាមួយគ្នា។

| គោលបំណង | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• រៀបរាប់ពីហេតុផល និងសារៈសំខាន់នៃការប្រាស្រ័យទាក់ទងក្នុងរង្វង់គ្រួសារ<br>• កត់សម្គាល់ និងយល់ពីអត្ថន័យនៃការប្រាស្រ័យទាក់ទងតាមរយៈកាយវិការ និងការនិយាយ<br>• ឆ្លុះបញ្ចាំងពីកម្រិតនៃការប្រាស្រ័យទាក់ទងក្នុងរង្វង់ក្រុមគ្រួសារខ្លួន<br>• បង្ហាញពីការស្ដាប់ដោយយកចិត្តទុកដាក់ និងលើកទឹកចិត្តកូន ឬកុមារឱ្យមានជំនាញប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព។ |
|---|---|

រយៈពេល ១៦០ នាទី

**សម្ភារៈ ដែលត្រូវការ**

- ផ្ទាំងសំណួរងាយៗដែលសមាជិកគ្រួសារអាចសួរនាំគ្នាដើម្បីបង្កើនទំនាក់ទំនង និងប្រាស្រ័យទាក់ទងល្អនៅក្នុងគ្រួសារ។
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- កម្រាល សម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀម សម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រា អំពីវិន័យដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

**ខ្លឹមសារលម្អិត**

## I. និយមន័យនៃពាក្យ ការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទងគឺជាការផ្តល់ និងទទួលបានព័ត៌មាន ការគិត និងអារម្មណ៍នានាតាមរយៈ៖

- ការនិយាយមានដូចជា ការជួបផ្ទាល់ និងតាមប្រព័ន្ធអេឡិចត្រូនិច
- ការសរសេរមានដូចជា ការកត់ត្រា សារព័ត៌មាន សារតាមទូរស័ព្ទ អ៊ីមែល ហ្វេសប៊ុក
- កាយវិការមានដូចជា ធ្វើចលនាដៃជើង ទឹកមុខ ទម្រង់រាងកាយ សម្លេង និងក្រសែភ្នែកជាដើម។

មនុស្សជាច្រើនគិតថាការប្រាស្រ័យទាក់ទងគ្រាន់តែជាការផ្តល់ព័ត៌មាន ប៉ុន្តែវាក៏ជាការទទួលព័ត៌មាន ឬបង្ហាញពីការស្តាប់ផងដែរ។ ការស្តាប់ រួមបញ្ចូលទាំងការឮនូវខ្លឹមសារអ្វីមួយដែលមនុស្សម្នាក់ទៀតកំពុងនិយាយឮ និងយល់ពីអ្វីដែលគាត់កំពុងនិយាយ (លឿន យឺត ខ្សាវៗ ឮដាច់ៗ ឬលួន)។ ការប្រាស្រ័យទាក់ទង ក៏រាប់បញ្ចូលទាំងការមើលឃើញ ការសម្គាល់ យល់ពីទឹកមុខ កាយវិការ ទម្រង់រាងកាយដែលមនុស្សម្នាក់នោះមាននៅពេលគាត់កំពុងនិយាយ។ កាយវិការទាំងនោះបញ្ជូនសារអារម្មណ៍នានានៃការប្រាស្រ័យទាក់ទង។

## II. សារៈសំខាន់នៃការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ គឺធ្វើឡើងក្នុងរង្វង់សមាជិកគ្រួសារដើម្បីចែករំលែកព័ត៌មានដែលកើតឡើងប្រចាំថ្ងៃ (ឧទាហរណ៍តើបង ឬអូនញ៉ាំបាយហើយឬនៅ? តើថ្ងៃនេះមានរឿងអ្វីកើតឡើងនៅផ្ទះ? ឬប្រាប់គ្នាទៅវិញទៅមកអំពីអារម្មណ៍) និងការគិតនានាដែលអាចមាន ឬពិភាក្សាអំពីបញ្ហា និងស្វែងរកដំណោះស្រាយជាមួយគ្នា។

នៅក្នុងគ្រួសារដែលមានភាពរីករាយ និងមានសុខភាពល្អ ធ្វើឱ្យសមាជិកគ្រួសារចង់និយាយរកគ្នា និងសួរគ្នាអំពីការគិត អារម្មណ៍និងសកម្មភាពរស់នៅប្រចាំថ្ងៃ។ ប្រសិនបើឪពុកម្តាយ បង្ហាញចំណាប់អារម្មណ៍ និងការគិតចំពោះជីវិតប្រចាំថ្ងៃរបស់កូន ឬកុមារ នោះពួកគេមានអារម្មណ៍ថារូបគេមានតម្លៃ និងមានការអភិវឌ្ឍទំនុកចិត្តលើខ្លួនឯង សុវត្ថិភាពក្នុងការប្រាប់ ឬចែករំលែករឿងរ៉ាវនានាដែលកើតឡើងចំពោះរូបគេ។

បើឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គ្រាន់តែប្រាប់កូនឱ្យធ្វើអ្វីដែលខ្លួនចង់បាន ជេរ ស្ដីបន្ទោស ឬកែតម្រូវកូន នោះកូននឹងមានអារម្មណ៍ឯកោ គ្មានតម្លៃ និងខ្លាចក្នុងការចែករំលែកព័ត៌មាន ដែលជាហេតុធ្វើឱ្យកូន ឬសមាជិកគ្រួសារដទៃទៀតគិតថា ពួកគេមិនមានអ្នកដែលគាត់ត្រូវប្រាប់អំពីបញ្ហាដែលគាត់ជួបប្រទះទាំងនៅក្នុងគ្រួសារ និងក្នុងសហគមន៍។

គ្រួសារដែលមិនបានចែករំលែកព័ត៌មាន អារម្មណ៍ ឬការគិត នឹងធ្វើឱ្យសមាជិកគ្រួសារមានអារម្មណ៍ឯកោ និងមិនបានឱ្យពួកគាត់ចេះពីរបៀបប្រាស្រ័យទាក់ទង ទាំងនៅក្នុងគ្រួសារ ក្នុងសហគមន៍ ឬនៅសាលារៀន។ កុមារដែលរស់នៅក្នុងគ្រួសារមានការប្រាស្រ័យទាក់ទងតិច ខ្សោយ ឬអវិជ្ជមាន នឹងធ្វើឱ្យមានការអភិវឌ្ឍយឺតលើការគិត អារម្មណ៍ រងអំពើហិង្សា ការមិនអើពើ និងការបែកបាក់គ្រួសារ។

ហេតុអ្វីបានជាការស្ដាប់មានសារៈសំខាន់សម្រាប់ការប្រាស្រ័យទាក់ទង?

- លើកទឹកចិត្តឱ្យសមាជិកគ្រួសារបាននិយាយ និងសម្ដែងនូវអារម្មណ៍ និងការគិតរបស់ពួកគេ។
- ផ្ដល់ឱកាសឱ្យអ្នកនិយាយ និងសមាជិកដទៃទៀត បានចែករំលែកនូវអារម្មណ៍ (ទាំងការរីករាយ និងក្រៀមក្រំ) និងស្វែងរកការជួយគាំទ្រ និងដំណោះស្រាយប្រសិនបើមានការស្នើសុំ។
- បង្កើនទំនុកចិត្ត និងផ្ដល់តម្លៃដល់អ្នកនិយាយក្នុងការបង្ហាញ និងប្រាប់អំពីរឿងរ៉ាវរបស់ពួកគេ។
- ផ្ដល់ឱកាសឱ្យសមាជិកគ្រួសារបានយល់ពីគ្នាទៅវិញទៅមកនូវបញ្ហាដែលសមាជិកម្នាក់ៗកំពុងជួបប្រទះ។
- ធ្វើឱ្យសមាជិកគ្រួសារបានយល់ស៊ីជម្រៅ និងដឹងកាន់តែច្បាស់អំពីស្ថានភាពរបស់ពួកគេម្នាក់ៗកាន់តែច្បាស់។
- បង្កើនទំនាក់ទំនងរឹងមាំនៅក្នុងគ្រួសារ រវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ និងធ្វើឱ្យសមាជិកគ្រួសារអាចកសាងភាពទុកចិត្តគ្នា។
- ដើម្បីឱ្យអ្នកនិយាយមានអារម្មណ៍សុវត្ថិភាព និងជឿជាក់ក្នុងការចែករំលែក និងប្រាប់ពីបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។

## III. ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

ចំណុចខាងក្រោមនេះ គឺជាផ្នែកសំខាន់ៗសម្រាប់ជួយឱ្យការប្រាស្រ័យទាក់ទងក្នុងគ្រួសារប្រកបដោយប្រសិទ្ធភាព៖

- **ការយល់ចិត្ត៖** មានសារៈសំខាន់ណាស់ ពីព្រោះអ្នកកំពុងព្យាយាមស្វែងយល់ពីមជ្ឈដ្ឋានរស់នៅជុំវិញខ្លួនទៅតាមការយល់ឃើញរបស់ដៃគូ និងកូនរបស់អ្នក មិនមែនតាមទស្សនៈរបស់អ្នកនោះឡើយ។ កត្តានេះកសាងឱ្យមានទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។

- **ស្តាប់៖** ដោយយកចិត្តទុកដាក់ (មើលគេ ឬសម្លឹង ងក់ក្បាល នៅពេលធ្វើការប្រាស្រ័យទាក់ទង) នៅពេលដែលយើងផ្តល់ស្តាប់កូនៗដោយយកចិត្តទុកដាក់ ទាំងបន្ទាបខ្លួនឱ្យស្មើនឹងកម្ពស់របស់កូន ឬកុមារ និងត្រូវធានាឱ្យបានថាពួកគេអាចប្រាប់ពីអ្វីដែលគេចង់និយាយ ព្រមទាំងដឹងថា សម្តីនោះពិតជាសំខាន់។ សំខាន់បំផុត គឺត្រូវយកចិត្តទុកដាក់ចំពោះគេទាំងស្រុង យល់ពីអារម្មណ៍ និងខ្លឹមសារនៃសម្តីរបស់គេ។ យកល្អមិនត្រូវឱ្យដំបូន្មានគេភ្លាមៗនោះទេ ត្រូវស្តាប់ឱ្យចប់សិន។

- **សង្កេត៖** ការសង្កេតមានសារៈសំខាន់ណាស់ក្នុងការប្រាស្រ័យទាក់ទងជាមួយសមាជិកនៅក្នុងក្រុមគ្រួសារ ជាពិសេសជាមួយកូន ឬកុមារ និងកុមារដែលមានពិការភាព។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវចេះសង្កេតទៅលើទឹកមុខ សម្លៀកបំពាក់ កាយវិការ និងការនិយាយស្តីរបស់ដៃគូ កូន ឬកុមារ កុមារដែលមានពិការភាព ព្រមទាំងសមាជិកផ្សេងទៀតនៅក្នុងគ្រួសារថា ពួកគេកំពុងត្រូវការអ្វី ឬចង់ប្រាប់អ្វីដល់យើង។ល។

  *ឧទាហរណ៍៖ នៅពេលមនុស្សមានអារម្មណ៍ខឹង អាចសម្តែងតាមរយៈទឹកមុខក្រហម ក្តាប់ដៃ ខាំធ្មេញ សំលេងខ្លាំង ដើរចេញ យំ។ល។*

- **វិនិច្ឆ័យ៖** ជាទូទៅមនុស្សមានការវិនិច្ឆ័យលឿនដោយស្វ័យប្រវត្តិនៅពេលដែលគេទទួលបាន តាមរយៈញាណទាំង៥របស់មនុស្សដែលការវិនិច្ឆ័យនោះមិនប្រាកដថាបានត្រឹមត្រូវនោះទេ។

  *ឧទាហរណ៍៖ មនុស្សម្នាក់យំ មិនប្រាកដថាគាត់ពិបាកចិត្តទេ ជួនកាលគាត់អាចមានអារម្មណ៍រំភើប ឬសប្បាយខ្លាំង។ ដូច្នេះហើយ យើងត្រូវតែពន្យាពេលក្នុងការវិនិច្ឆ័យដោយ ព្យាយាមយល់តាមរយៈ សង្កេត សួរ និងស្តាប់មុនធ្វើការវិនិច្ឆ័យ។*

- **សំណួរបញ្ជាក់៖** ការប្រើសំណួរបំផុសអាចជួយលើកទឹកចិត្តសមាជិកគ្រួសារឱ្យរៀបរាប់កាន់តែលម្អិតអំពីរឿងរ៉ាវដែលបានកើតឡើងដើម្បីជួយលោកអ្នកឱ្យស្វែងយល់នូវព័ត៌មានដែលជាក់លាក់ និងពេញលេញ។

ប្រសិនបើយើងមិនមានពេលក្នុងការស្តាប់គាត់ទេ សូមប្រាប់ទៅពួកគាត់វិញ ពីពេលវេលាដែលយើងអាចស្តាប់ពួកគាត់បាន (សូមចាំ ១០នាទី ចាំស្អែក ឬចាំពេលយប់)។ បើករណីបន្ទាន់ យើងគួរសម្រេចចិត្តក្នុងការផ្អាកនូវអ្វីដែលយើងកំពុងធ្វើបន្តិច ដើម្បីស្តាប់នូវតម្រូវការរបស់សមាជិកគ្រួសារជាមុនសិន។

ក្នុងករណីដែលកូន ឬកុមារដែលមានពិការភាព ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវតែស្តាប់ និងសួរពួកគាត់ នៅពេលដែលពួកគាត់មានរឿងរ៉ាវប្រាប់យើង។

## IV. ការប្រាស្រ័យទាក់ទងពេលមានអារម្មណ៍មិនល្អ

នៅពេលដែលលោកអ្នកមានអារម្មណ៍ខឹងនឹងអាកប្បកិរិយាមិនគប្បីរបស់សមាជិកគ្រួសារ ឬកូនៗ សូមជៀសវាងមិននិយាយជាមួយអ្នកណាឱ្យសោះ រហូតទាល់តែលោកអ្នកស្ងប់អារម្មណ៍សិន មិនដូច្នោះទេ លោកអ្នកមិនអាចនិយាយចំគោលដៅបានឡើយ តែផ្ទុយទៅវិញលោកអ្នកអាចបង្កផលប៉ះពាល់បែបអវិជ្ជមានទៅដល់សមាជិកគ្រួសារ កូន ឬកុមារ។ យកល្អគឺត្រូវរំងាប់អារម្មណ៍ និងអាចជជែកជាមួយសមាជិកគ្រួសារ ឬកូនរបស់អ្នកនៅពេលក្រោយ។

## V. ការបែកបាក់គ្រួសារ និងប្រាស្រ័យទាក់ទងក្នុងគ្រួសារ

នៅពេលដែលគ្រួសារមួយមានការប្រាស្រ័យទាក់ទងខ្សោយ ឬមិនគ្រប់គ្រាន់ដូចជាពួកគាត់មិនបានពិភាក្សាពីជីវិតប្រចាំថ្ងៃ ឬបញ្ហានានាដែលកំពុងជួបប្រទះ ហើយមិនបានស្វែងរកដំណោះស្រាយ ឬមិនបានយកចិត្តទុកដាក់ចំពោះតម្រូវការនានានោះអាចនាំទៅដល់ការបែកគ្នា។ ឪពុកម្ដាយ ឬកូនធំៗអាចចុះចេញពីផ្ទះ ឬបញ្ជូនកូនទៅឱ្យសាច់ញាតិ ឬនៅក្នុងមណ្ឌលថែទាំ។ ដោយសារការបែកបាក់គ្រួសារ វាអាចមានគ្រោះថ្នាក់ចំពោះកុមារដែលត្រូវការភាពកក់ក្ដៅ ដែនកំណត់ និងបរិយាកាសគាំទ្រជាការសំខាន់ដែលត្រូវមានទំនាក់ទំនងជិតដិតជាមួយកុមារ និងត្រូវយល់ពីការគិតនិងអារម្មណ៍របស់ពួកគេ។

## VI. ការការពារកុមារ និងប្រាស្រ័យទាក់ទងក្នុងគ្រួសារ

នៅពេលកុមាររស់នៅក្នុងគ្រួសារដែលសមាជិកគ្រួសារ មិនមានការប្រាស្រ័យទាក់ទងល្អជាមួយគ្នា (ស្ដីបន្ទោស ឬកំហឹង) នោះកុមារមិនមានអារម្មណ៍សុវត្ថិភាពក្នុងការប្រាប់ពីហេតុការណ៍ ឬបញ្ហាដែលពួកគេបានជួបប្រទះឡើយ។

- ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវបើកចំហរ និងឆ្លើយតបចំពោះកូនៗ ដើម្បីឱ្យពួកគេមានអារម្មណ៍ថាឪពុកម្ដាយទទួលយក និងស្ដាប់ពួកគេនៅពេលណាដែលរឿងរ៉ាវអាក្រក់ណាមួយកើតឡើង។
- កុមារដែលមិនមានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំនឹងមិនប្រាប់ពីបញ្ហាដែលពួកគេមាន ឬមិនសួរសំណួរនានាអំពីបញ្ហាដែលគេកំពុងជួបប្រទះនោះទេ។
- ទាំងនេះនាំឱ្យកុមារមិនទទួលបាននូវការការពារនៅក្នុងគ្រួសារ ជាកន្លែងដែលពួកគេគិតថាមានសុវត្ថិភាពបំផុត និងអាចនិយាយបានដោយសេរី។

## ១. វិធីដែលកុមារប្រើដើម្បីការពារខ្លួនពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ

- ស្វែងយល់អំពីល្បិចកលជនខិលខូចៈ
  - សន្យាថា និងផ្តល់ការងារដោយទទួលបានប្រាក់ខែខ្ពស់
  - សន្យាថាជួយរកការងារឱ្យធ្វើ
  - ទិញទឹកចិត្តក្រុមគ្រួសារដោយផ្តល់ជាសម្ភារៈ និងប្រាក់កាស
  - លួងលោមធ្វើជាសង្សារ
  - ប្រើល្បិចជារៀបការជាមួយ រួចយកទៅលក់
  - ប្រើថ្នាំញៀន ឬថ្នាំសណ្តំ
  - សុំធ្វើជាបងប្អូនធម៌ ឬកូនចិញ្ចឹម
  - លួងលោម និងអូសទាញឱ្យចូលរួមពិធីផ្សេងៗ
  - បបួលដើរលេងកន្លែងស្ងាត់ ឬកន្លែងដែលអ្នកដទៃមើលមិនឃើញ
  - ធ្វើជាមានចិត្តសប្បុរស និងមនុស្សធម៌
  - តាំងខ្លួនជាមនុស្សដែលចូលចិត្ត និងស្រឡាញ់កុមារដូចជាកូនរបស់ខ្លួន
  - សន្យារៀបការជាមួយ
  - ចេះផ្គាប់ផ្គុន និងធ្វើជាមនុស្សមានទំនាក់ទំនងល្អជាមួយកុមារ និងគ្រួសារ
  - ការពួនស្ទាក់ និងការចាប់ពង្រត់
  - ធ្វើជាគ្រូព្យាបាលជំងឺ
  - ធ្វើជាអ្នកជួយឧបត្ថម្ភដល់មណ្ឌលកុមារកំព្រា
  - ការឱ្យខ្ចីប្រាក់ ដើម្បីបង្ហាញការជឿជាក់ ដោយមិនយកការប្រាក់ ឬយកការប្រាក់តិច ។ល។
  - ការប្រើល្បិចឆបោក តាមបណ្តាញសង្គមនានា
- ទៅណាមកណា ត្រូវមានគ្នាច្រើន ឬមានគ្រួសារ ចាស់ទុំនៅជាមួយ និងត្រូវស្ថិតនៅកន្លែងដែលអ្នកដទៃអាចមើលឃើញ
- ត្រូវផ្តល់ព័ត៌មានអំពីទំនាក់ទំនងរបស់មនុស្សចម្លែក ទៅឪពុកម្តាយ ឬមនុស្សដែលកូន ឬកុមារទុកចិត្ត
- ត្រូវប្រុងប្រយ័ត្នចំពោះចំណីអាហារ ភេសជ្ជៈ នៅពេលដើរលេងជាមួយមិត្តភក្តិ ឬអ្នកដែលទើបនឹងស្គាល់គ្នា
- ជៀសវាងដើរឆ្ងាយពីផ្ទះតែម្នាក់ឯង ឬទៅកន្លែងដែលអ្នកមិនស្គាល់ហើយគ្មាននរណាដឹង
- មិនត្រូវស្ថិតនៅកន្លែងដែលស្ងាត់ ឬឆ្ងាយដាច់ពីភ្នែកអ្នកដទៃតែពីរនាក់

- មិនត្រូវជឿពាក្យលួងលោមរបស់គេដូចជា ការសន្យាផ្តល់លុយកាក់ ឬរបស់របរផ្សេងៗ ឬសន្យាផ្តល់ការងារអោយធ្វើ
- មិនត្រូវមើលវីដេអូ ឬអានទស្សនាវដ្តីអាសអាភាស
- រាយការណ៍ពីមុខសញ្ញាជនសង្ស័យដែលលួងលោម និងបោកបញ្ឆោតកុមារ ទៅសមត្ថកិច្ច ឬអាជ្ញាធរអោយបានដឹង
- ត្រូវហៅទៅលេខទូរស័ព្ទពិសេសរបស់នគរបាល **១២៨៨** ឬ**១១៧** ឬបណ្តាញទូរស័ព្ទជំនួយកុមារ **១២៨០** ។

## ២. ចំណុចដែលកុមារត្រូវចងចាំបន្ថែមទៀត

- ស្គាល់ ឬចាំលេខទូរស័ព្ទទំនាក់ទំនងរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងមនុស្សដែលយើងទុកចិត្ត
- ប្រាប់ និងសុំការអនុញ្ញាតពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅពេលដែលចាកចេញពីផ្ទះ ទោះបីជាទៅជាមួយមនុស្សដែលអ្នកស្គាល់ក៏ដោយ។
- មិនទទួលយក អំណោយ ឬរបស់របរ ពីមនុស្សដែលអ្នកស្គាល់ ឬមិនស្គាល់ ឬពីមនុស្សប្លែកមុខទេ លើកលែងតែឪពុកម្តាយរបស់អ្នកនៅជាមួយ។
- ជាទូទៅ ទៅណាមកណាតែងតែទៅជាមួយមិត្តភក្តិ និងមានគ្នាទៅជាមួយ។ ហើយមិនត្រូវទៅណាមកណា តែម្នាក់ឯងនោះទេ។
- ត្រូវនិយាយថាទេ ប្រសិនបើមាននរណាម្នាក់មកប៉ះពាល់ ដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ ឬអារម្មណ៍ភ័យខ្លាច។
- ត្រូវចងចាំ មនុស្សដែលអាចជួយអ្នក និងមនុស្សដែលអ្នកជឿជាក់អាចជួយអ្នកបាននៅពេលដែលអ្នកត្រូវការជំនួយ មានដូចជា មេភូមិ ជំនួយការភូមិ ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ បណ្តាញ កុមារ ឬយុវវ័យ អ្នកស្ម័គ្រចិត្ត គ្រូបង្រៀន នាយកសាលា នាយប៉ុស្តិ៍ ប្រជាការពារភូមិ មេឃុំ ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាដើម។
- ប្រាប់ដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរបស់អ្នក ប្រសិនបើមាននរណាម្នាក់មានអាកប្បកិរិយាមិនសមរម្យ ឬធ្វើឱ្យមានអារម្មណ៍ភ័យខ្លាច។
- ត្រូវបដិសេធ ប្រសិនបើមាននរណាម្នាក់ដែលអ្នកមិនស្គាល់សួរអ្នក ឬឱ្យអ្នកជួយជូនទៅទីកន្លែងណាមួយ។
- ត្រូវរត់គេចឱ្យឆ្ងាយ ប្រសិនបើមនុស្សដែលអ្នកមិនស្គាល់ដើរតាមអ្នក ទោះបីជាគាត់ស្គាល់ឈ្មោះអ្នកក៏ដោយ។

- ត្រូវនិយាយថាទេ ប្រសិនបើមាននរណាម្នាក់បបួលអ្នកឱ្យប្រើប្រាស់គ្រឿងញៀន ឬប្រព្រឹត្តអ្វីដែលអ្នកគិតថាវាជាការមិនត្រឹមត្រូវ។
- ប្រាប់ដល់ឪពុកម្តាយរបស់អ្នក និងរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច អំពីមនុស្សដែលមានបំណងមិនល្អមកលើអ្នក ឬមានបំណងមិនល្អចំពោះកុមារផ្សេងទៀត។
- ត្រូវស្រែកឱ្យខ្លាំង និងរកគេឱ្យជួយ ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពមានគ្រោះថ្នាក់ ឬត្រូវគេប៉ះពាល់រាងកាយ
- ត្រូវស្វែងយល់ពីការរំលោភបំពាននានា និងល្បិចកលជនខិលខូច
- ត្រូវរក្សាទុកលេខទូរស័ព្ទពិសេស និងសង្គ្រោះបន្ទាន់ពីអ្នកដែលពាក់ព័ន្ធ
- ត្រូវទំនាក់ទំនងទៅលេខទូរស័ព្ទពិសេសរបស់នគរបាល **១២៨៨** ឬ **១១៧** និងបណ្តាញទូរស័ព្ទជំនួយកុមារ **១២៨០** ។

## VII. ការប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសាររួមទាំងកុមារដែលមានពិការភាព

ការប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសារដែលមានពិការភាព គឺត្រូវគិតទៅលើសមត្ថភាពរបស់គាត់ក្នុងការប្រាស្រ័យទាក់ទង ដូចជាគថ្លង់ មិនអាចនិយាយបាន និយាយមិនច្បាស់ យឺតក្នុងការរៀន ឬយល់។ កុមារដែលពិការភ្នែកគឺអាចស្តាប់ឮ ប៉ុន្តែគេមិនអាចទទួលបានព័ត៌មានផ្នែកកាយវិការបានទេ ដូច្នេះយើងត្រូវពិចារណានូវចំណុចនានាដូចខាងក្រោម៖

- ដោយសារការប្រាស្រ័យទាក់ទងក្នុងគ្រួសារសំខាន់ ហើយអ្វីដែលសំខាន់ទៀតនោះគឺការគិតពីរបៀបដែលធានាថាសមាជិកគ្រួសារទាំងអស់ត្រូវបានរាប់បញ្ចូលក្នុងដំណើរការប្រាស្រ័យទាក់ទងដោយមាន ការបញ្ជូន និង ការទទួល ។
- នៅពេលដែលសមាជិកគ្រួសារណាម្នាក់មិនអាចស្តាប់ឮ ឬមិនអាចនិយាយកើត ឬមិនអាចយល់ពីអ្វីដែលអ្នកផ្សេងៗកំពុងនិយាយ សមាជិកគ្រួសារ ផ្សេងទៀតត្រូវតែខិតខំប្រើវិធីនានា ដូចជា ការនិយាយ សរសេរ ធ្វើកាយវិការដៃ ឬជើង។ល។ ដូចនេះសមាជិកគ្រួសារត្រូវធានាបានថា អ្នកដែលមានបញ្ហាក្នុងការប្រាស្រ័យទាក់ទងត្រូវបានរាប់បញ្ចូលក្នុងការផ្តល់ ទទួលព័ត៌មាន អារម្មណ៍ និងអាចយល់ និងធ្វើអ្វីៗបានជាមួយអ្នកផ្សេងៗទៀតផងនៅក្នុងរង្វង់គ្រួសារ។
- នៅពេលដែលអ្នកមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារជាការសំខាន់ណាស់ដែលត្រូវមានការខិតខំដើម្បីធានាថា កុមារពិតជាដឹងនូវអ្វីៗដែលគេត្រូវការដឹងដើម្បីលូតលាស់ អភិវឌ្ឍ និងចូលរួមបានពេញលេញក្នុងជីវិតគ្រួសារ។ ចំណុចនេះរាប់បញ្ចូលទាំងផែនការសកម្មភាព និងព័ត៌មានដែលសមាជិកគ្រួសារទាំងអស់កំពុងធ្វើ កំពុងគិត និងអារម្មណ៍ដែលពួកគេកំពុងមាន។ ហើយការខិតខំក៏ត្រូវធ្វើឡើងដើម្បីស្វែងរកវិធីនានា ក្នុងការជួយកុមារដែលមានបញ្ហាក្នុងការប្រាស្រ័យ

ទាក់ទង បានចូលរួមគំនិត ក្ដីប្រាថ្នាចូលរួមមតិយោបល់ ចូលរួមសម្រេចចិត្ត និងធ្វើផែនការសកម្មភាពនៅក្នុងគ្រួសារ។

## VIII. ភាពខុសគ្នា រវាងការប្រាស្រ័យទាក់ទងជាមួយកុមារី និងការប្រាស្រ័យទាក់ទងជាមួយកុមារា

ការប្រាស្រ័យទាក់ទងរវាងកុមារី និងកុមារាមានរបៀបខុសៗគ្នា។ ជាទូទៅកុមារីនិយាយច្រើនជាងកុមារា។ ចំណែកឯកុមារាវិញ មានសកម្មភាពច្រើនជាងកុមារី។ ដូច្នេះនៅពេលយើងពិចារណាពីរបៀប ប្រាស្រ័យទាក់ទងជាមួយកុមារ យើងត្រូវសម្របទាំងការស្ដាប់ និងការនិយាយរបស់យើងឱ្យត្រូវគ្នានឹងរបៀបប្រាស្រ័យទាក់ទងជាមួយពួកគេ។

ត្រូវចងចាំផងដែរថាកុមារដែលមានអាយុផ្សេងៗគ្នា មានកម្រិតយល់ដឹងខុសៗគ្នា។ ដូច្នេះក្នុងនាមជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវប្រាកដថា អ្នកត្រូវប្រើពាក្យ និងគំនិតសាមញ្ញៗពេលនិយាយជាមួយកូនអាយុតិច ហើយពាក្យ និងគំនិតកាន់តែជ្រៅនៅពេលដែលពួកគេមានអាយុច្រើន។

## IX. បង្រៀនកូនពីការប្រាស្រ័យទាក់ទង

ដោយសារជំនាញស្ដាប់ សង្កេត សួរ និងឆ្លើយតបដោយមិនវិនិច្ឆ័យនាំឱ្យមានការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពក្នុងគ្រួសារ និងសង្គម។ ដូច្នេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនកូនអំពីការស្ដាប់ សង្កេត សួរ និងឆ្លើយតបក្នុងការប្រាស្រ័យទាក់ទងតាំងពីកូន ឬកុមារក្នុងផ្ទៃម្ដាយ ហើយនៅតែបន្តបង្រៀនកូនតាមរយៈការប្រាស្រ័យទាក់ទងប្រចាំថ្ងៃជាមួយកូន ឬកុមារដោយអនុវត្តនូវជំនាញនេះជាប្រចាំ។

ម៉្យាងទៀត កូន ឬកុមាររៀនតាមរយៈការសង្កេតពីរបៀបការប្រាស្រ័យទាក់ទងរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយពួកគេ។ ដូចនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរធ្វើជាគំរូល្អ ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងសមាជិកគ្រួសារ។

**កុមារឃើញទង្វើអ្វី កុមារធ្វើត្រាប់តាម!**

**កុំព្រួយបារម្ភនូវអ្វីដែលកូនមិនស្ដាប់អ្នក អ្វីដែលត្រូវប្រុងប្រយ័ត្ននោះ គឺអ្វីដែលកូនមើលឃើញ!**

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកការរស់នៅរបស់ពួកគាត់<br>ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>🗣 បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>អ្នកសម្របសម្រួលកត់ត្រានូវការលំបាក ដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំផ្តល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | កសាងក្រុម | ល្បែងចាមពល "ខ្សឹបបន្តគ្នា" (១០នាទី) | ▪ ចែកអ្នកចូលរួមជា២ក្រុមស្មើៗគ្នា ដោយក្រុមនីមួយៗឈរជាជួរ រួចរើសអ្នកស្ម័គ្រចិត្តម្នាក់តំណាងឱ្យក្រុមនីមួយៗ<br>▪ អ្នកសម្របសម្រួលផ្តល់សារដល់អ្នកស្ម័គ្រចិត្ត □ពូសុខជិះម៉ូតូទៅផ្សារទិញផ្កា និងក្រម៉ាយកទៅធ្វើបុណ្យផ្កានៅវត្តក្រពើហា□ ។ បន្ទាប់ពីអ្នកស្ម័គ្រចិត្តនោះអានសាររួច ឱ្យគាត់ខ្សឹបប្រាប់បន្តសារនោះទៅអ្នកបន្ទាប់នៅក្នុងក្រុម<br>▪ អ្នកបន្ទាប់ បន្តខ្សឹបប្រាប់អ្នកបន្ទាប់ទៀតរហូតដល់អស់សមាជិកក្នុងក្រុម អ្នកចុងក្រោយនឹងត្រូវសរសេរសារដែលស្តាប់បាននោះនៅលើក្តារខៀន ឬប្រាប់ទៅក្រុមធំនូវអ្វីដែលបានឮ<br>▪ បើមានពេលអ្នកសម្របសម្រួលអាចសួរសំណួរឆ្លុះបញ្ចាំងពីសកម្មភាព ដោយសួរ<br>☞ តើលោកអ្នកយល់យ៉ាងម៉េចដែរចំពោះសកម្មភាពនេះ ?<br>☞ តើលោកអ្នកអាចរៀនបានអ្វីពីសកម្មភាពនេះ ?<br>☞ តើអ្នកស្តាប់ ទទួលបានព័ត៌មានគ្រប់គ្រាន់ដែរឬទេ ? ហេតុអ្វី ?<br>☞ តើធ្វើដូចម្តេច ដើម្បីជៀសវាងការបាត់បង់ព័ត៌មានដូចនេះ ? |
| ៥ | មេរៀនថ្មីៈ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ | និយមន័យនៃការប្រាស្រ័យទាក់ទង (១៥នាទី) | ▪ អ្នកសម្របសម្រួលបញ្ចប់សកម្មភាពណែនាំរួចចូលប្រធានបទ។ ថ្ងៃនេះយើងនឹងនិយាយពីការប្រាស្រ័យទាក់ទងនៅក្នុងគ្រួសារ រួចសួរសំណួរ<br>☞ តើការប្រាស្រ័យទាក់ទងមានន័យយ៉ាងដូចម្តេច ?<br>🗣 ចម្លើយរំពឹងទុកៈការចែករំលែកព័ត៌មានជាក់ស្តែង ការបង្ហាញនូវអារម្មណ៍ទាំងវិជ្ជមាន និងអវិជ្ជមាន ការដោះស្រាយបញ្ហា ការយល់ពីអារម្មណ៍ និងការគិតពីគ្នាទៅវិញទៅមក<br>☞ តើយើងអាចធ្វើការប្រាស្រ័យទាក់ទងបានតាមរបៀបណាខ្លះ ?<br>🗣 ចម្លើយរំពឹងទុកៈ និយាយគ្នាញញឹមដាក់គ្នា សួរសុខទុក្ខហៅគ្នាទៅវិញទៅមក ផ្តល់សញ្ញាអ្វីមួយ ជំរាបសួរ និយាយទូរស័ព្ទជាមួយគ្នា ផ្ញើសារសរសេរសំបុត្រឱ្យគ្នា។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចបន្ថែមខ្លឹមសារចំណុចទី I និងចំណុចទី II |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | ប្រើប្រាស់សំណួរជាមួយកូន និងដៃគូ (២០នាទី) | ▪ បន្ទាប់មក អ្នកសម្របសម្រួល សូមឱ្យអ្នកចូលរួមចែកជា៣ក្រុម ដោយពិភាក្សាទៅលើសំណួរ៖<br>☞ តើលោកអ្នកមានការប្រាស្រ័យទាក់ទងយ៉ាងដូចម្ដេចជាមួយកូនរបស់អ្នក?<br>☞ ជារៀងរាល់ថ្ងៃ តើលោកអ្នកមានការប្រាស្រ័យទាក់ទងជាមួយដៃគូ (ប្ដី ឬប្រពន្ធ) របស់លោកអ្នកដូចម្ដេចខ្លះ?<br>▪ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកគំនិត និងបង្ហាញគំនិតនៅក្នុងក្រុមធំ<br>▪ អ្នកសម្របសម្រួលសួរសំណួរបន្ថែម ដោយផ្ដោតលើកុមារដែលមានពិការភាព ដោយសួរ<br>☞ តើលោកអ្នកមានការប្រាស្រ័យទាក់ទងយ៉ាងដូចម្ដេចដែរចំពោះកុមារដែលមានពិការភាព?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារ |
| | | សារៈសំខាន់នៃការប្រាស្រ័យទាក់ទងក្នុងរង្វង់គ្រួសារ សម្ដែងតួ (៤៥នាទី) | ▪ ឥឡូវនេះ យើងនឹងបង្ហាញពីរបៀបប្រាស្រ័យទាក់ទងតាមរយៈការនិយាយ។<br>▪ អ្នកសម្របសម្រួលពន្យល់ថា នឹងមានការសម្ដែងឈុត ២ឈុត រួចសុំអ្នកចូលរួមស្ម័គ្រចិត្តម្នាក់មកសម្ដែងតួជាកូន ហើយអ្នកសម្របសម្រួលសម្ដែងតួជាឪពុកម្ដាយ<br>▪ ការសម្ដែងឈុតទី១ អ្នកចូលរួមសម្ដែងតួជាកូន និងអ្នកសម្របសម្រួលសម្ដែងតួជាឪពុកម្ដាយដែលមានការស្ដាប់មិនល្អ<br>▪ ក្រោយពីការសម្ដែងឈុតទី១ចប់ អ្នកសម្របសម្រួលធ្វើការឆ្លុះបញ្ចាំងដោយសួរ៖<br>☞ អ្នកនិយាយមានអារម្មណ៍យ៉ាងដូចម្ដេច?<br>☞ អ្នកស្ដាប់មានអារម្មណ៍យ៉ាងដូចម្ដេច?<br>☞ តើអ្នកស្ដាប់បានធ្វើអ្វីខ្លះនៅពេលដែលគាត់កំពុងស្ដាប់? (ជំនួយការសម្របសម្រួលកត់ត្រាចម្លើយអ្នកចូលរួម)<br>☞ របៀបស្ដាប់បែបនេះ តើមានលទ្ធផលយ៉ាងដូចម្ដេច?<br>🗣 លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកគំនិតទៅក្នុងក្រុមធំ ហើយកត់ត្រាគំនិតទុក |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម។បន្ទាប់មកទៀត បង្ហាញឈុតទី២ ដោយសុំតួកូនមកសម្តែងម្តងទៀត និងអ្នកសម្របសម្រួលសម្តែងជាឪពុកម្តាយដែលមានការស្តាប់ល្អ<br>▪ ក្រោយពីការសម្តែងឈុតទីពីរចប់ អ្នកសម្របសម្រួលធ្វើការឆ្លុះបញ្ចាំងដូចការសម្តែងលើកទី១។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារភ្ជាប់នឹងមេរៀនការការពារ កុមារចំណុចជំហានទាំង៥ រួមមាន៖ ១) ស្តាប់កូន ឬកុមារ ២) ជឿជាក់លើកូន ឬកុមារ ៣)ស្វែងយល់ពីការរំលោភបំពាន ឬការមិនអើពើលើកុមារ និងចរិកលក្ខណៈក្នុងការការពារកុមារ និងមនុស្សវ័យក្មេង ៤)បង្រៀនកូន ឬកុមារអំពីសិទ្ធិផ្សេងៗរបស់ពួកគេ និងយុទ្ធសាស្ត្រផ្សេងៗ ដើម្បីរៀបចំចរិកលក្ខណៈក្នុងការការពារ ៥) បង្កើតឱ្យមានវប្បធម៌សុវត្ថិភាព និងមានការដឹងឮនៅក្នុងសហគមន៍របស់អ្នក។ ដូចនេះការស្តាប់កូន ឬកុមារជួយឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបានស្វែងយល់ និងអាចជួយកូនទាន់ពេលវេលាពីការរំលោភបំពានផ្សេងៗ។ |
| | | **សង្ខេបមេរៀន**<br>**រយៈពេល**<br>**(១០នាទី)** | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីការប្រាស្រ័យទាក់ទងក្នុងគ្រួសារ ដែលមានសារៈសំខាន់ណាស់ក្នុងការផ្តល់ និងទទួលព័ត៌មានផ្សេងៗពីសមាជិកនៅក្នុងគ្រួសារ ជាពិសេសជាមួយកូន ឬកុមារ រួមទាំងកុមារដែលមានពិការភាព។ ដើម្បីងាយស្រួលក្នុងការទទួលព័ត៌មានពីគ្នាយើងត្រូវគិតពីរបៀបក្នុងការស្តាប់ដោយយល់ចិត្ត និងសង្កេត ដើម្បីជួយសម្រួល ដល់ការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាព។ បើទោះជាមានសមាជិកក្នុងគ្រួសារណាដែលមានពិការភាព យើងត្រូវស្វែងរកពីរបៀបផ្សេងៗដើម្បីឱ្យការប្រាស្រ័យទាក់ទងគ្នាកាន់តែមានភាពជិតស្និទ្ធ។យើងក៏បានដឹងដែរថា ដើម្បីឱ្យកូន និងកុមាររៀនបានការប្រាស្រ័យទាក់ទងដោយមានប្រសិទ្ធភាព យើងដែលជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវស្តាប់កូន ដោយយកចិត្តទុកដាក់ ហើយក៏ត្រូវធ្វើជាគំរូល្អដល់កូនៗ ឬកុមារផងដែរ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន** (១០នាទី) | ▪ អ្នកសម្របសម្រួលសួរ៖<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្តេចដែរ ទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្តេចនៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ រយៈពេល** (១០នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្តើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង<br>▪ លើកទឹកចិត្តអោយអ្នកចូលរួមចាប់ផ្តើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និងធ្វើឱ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទងជាមួយគ្រួសារកូន ឬកុមារ រួមទាំងកុមារដែលមានពិការភាពផងដែរ ដើម្បីឱ្យពួកគេមានការលូតលាស់ និងអភិវឌ្ឍបានល្អ<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ដែលបានមកចូលរួម។ |

# ឧបសម្ព័ន្ធ១ សំណួរនានាសម្រាប់ប្រើប្រាស់ក្នុង ការប្រាស្រ័យទាក់ទង

នៅក្នុងការប្រាស្រ័យទាក់ទងមានរបៀបផ្សេងៗ ដើម្បីដឹងពីគ្នាទៅវិញទៅមក ហើយក្នុង នោះដែរយើងមានចំណុចខ្លះៗសម្រាប់ការប្រាស្រ័យទាក់ទងតាមរយៈពាក្យសម្ដី សួរ ឆ្លើយទៅតាមកម្រិតអាយុ និងដៃគូ (ប្ដី/ប្រពន្ធ) ដូចខាងក្រោម៖

## ១- សំណួរនានាសំរាប់ប្រើប្រាស់ជាមួយកូនអាយុតិច

- តើកូនបានញ៉ាំអ្វីខ្លះនៅថ្ងៃនេះ ?
- តើនៅផ្ទះកូនបានលេងជាមួយអ្នកណាខ្លះ ?
- តើថ្ងៃនេះនៅសាលាកូនបានលេងជាមួយអ្នកណាខ្លះ ?
- តើថ្ងៃនេះកូនទៅរៀនសប្បាយទេ ?
- តើអ្នកណាជាមិត្តភក្តិល្អជាងគេរបស់កូន ?
- តើនៅសាលារៀនមានអ្នកណាខ្លះធ្វើឱ្យកូនមិនសប្បាយចិត្ត ?
- តើមានរឿងអ្វីកើតឡើង ដែលល្អជាងគេសម្រាប់កូននៅថ្ងៃនេះ ?
- តើមានរឿងអ្វីកើតឡើង ដែលអាក្រក់ជាងគេសម្រាប់កូននៅថ្ងៃនេះ ?
- តើអាហារបស់កូនស្អាតឬទេថ្ងៃនេះ ?
- តើថ្ងៃនេះគ្រូរបស់កូនធ្វើអ្វីខ្លះ ?
- តើកូនរៀនចេះអ្វីខ្លះនៅថ្ងៃនេះ ?
- តើពេលចេញលេង កូនលេងអ្វីខ្លះជាមួយមិត្តភក្តិ ?
- តើមិត្តភក្តិអង្គុយរៀនក្បែរកូនយ៉ាងដូចម្ដេចដែរនៅថ្ងៃនេះ ?

## ២- សំណួរនានាសម្រាប់សំរាប់សួរកូន ឬកុមារ ដែលមានអាយុច្រើន

- នៅថ្ងៃនេះកូននិយាយជាមួយអ្នកណាខ្លះ ?
- តើកូនបានរៀនពីអ្វីខ្លះនៅសាលារៀនថ្ងៃនេះ ?
- តើកូនបានធ្វើអ្វីខ្លះក្រោយពីត្រឡប់មកពីសាលា ?
- តើអ្នកណាជាមិត្តភក្តិល្អជាងគេរបស់កូន ?
- តើកូនចូលចិត្តមិត្តល្អរបស់កូនចំណុចណាខ្លះ ?
- តើកន្លែងកំសាន្តមួយណាដែលកូនចង់ទៅ ?
- តើថ្ងៃនេះមានរឿងអ្វីកើតឡើង ដែលល្អចំពោះកូន ?
- តើថ្ងៃនេះមានរឿងអ្វីកើតឡើង ដែលធ្វើឱ្យកូនមិនសប្បាយចិត្ត ?
- តើកូនមានអារម្មណ៍ដូចម្ដេចដែរថ្ងៃនេះ ?

### ៣- សំណួរនានាសម្រាប់សួរប្ដី ឬប្រពន្ធ (សូមព្យាយាមសួរសំណួរអំពីទំនាក់ទំនង និងអារម្មណ៍នានា កុំសួរអំពីតម្លៃរបស់របរ ឬវត្ថុ)

- តើអូន ឬបងមានអារម្មណ៍យ៉ាងណាដែរថ្ងៃនេះ?
- តើបង ឬអូនគិតថាយើងគួរជួសជុលផ្ទះរបៀបណាដែរ?
- តើបងស្រីរបស់បង ឬអូនយ៉ាងដូចម្ដេចហើយ?
- តើអូន ឬបងចូលចិត្តញ៉ាំ ឬធ្វើម្ហូបអ្វីជាងគេ?
- តើបងឬអូនមានចំណុចអ្វីខ្លះល្អជាងគេ?តើបងឬអូនមានចំណុចអ្វីខ្លះមិនល្អ?
- តើបង ឬអូនមាននឹកអ្នកណាគេ?
- តើធ្វើជាម្ដាយ ឬឪពុកមានចំណុចណាដែលពិបាកជាងគេ? និងងាយស្រួលជាងគេ?
- តើអូន ឬបងមានបំណងប្រាថ្នាអ្វីខ្លះ?
- តើអូន ឬបងបារម្ភពីអ្វីខ្លះ?
- នៅពេលដែលបង ឬអូនសោកសៅ តើបងរកអ្នកណានិយាយជាមួយ?
- តើមានអ្វីកើតឡើងនៅថ្ងៃនេះ?
- តើអ្វីដែលធ្វើឱ្យបងឬអូនសប្បាយចិត្តនៅថ្ងៃនេះ?
- តើអ្វីដែលធ្វើឱ្យបងឬអូនមិនសប្បាយចិត្តនៅថ្ងៃនេះ?
- តើអ្វីដែលធ្វើឱ្យបង ឬអូនមានអារម្មណ៍ធុញទ្រាន់នៅថ្ងៃនេះ?
- តើការងារបង ឬអូនយ៉ាងដូចម្ដេចដែរនៅថ្ងៃនេះ?
- តើអូនបានជួបមិត្តភក្តិអូនណាម្នាក់ទេថ្ងៃនេះ? តើអូនជួបអ្នកណា? តើគាត់សុខសប្បាយជាទេ?
- តើបងឬអូនចូលចិត្តការងារដែលធ្វើរាល់ថ្ងៃនេះទេ? តើការងារប្រភេទណាទៀតដែលបង ឬអូនចូលចិត្តធ្វើ?
- តើទីកន្លែងណាដែលបង ឬអូនចង់ទៅរស់នៅ?
- តើបង ឬអូនគិតថាកូនៗយើងយ៉ាងដូចម្ដេចដែរ?
- តើអូន ឬបងចូលចិត្តកូនៗរបស់មិត្តភក្តិយើងទេ?
- តើបង ឬអូនគិតថា មិត្តភក្តិរបស់កូនៗយើង ដូចម្ដេចដែរ?
- តើបង ឬអូន ធ្វើអ្វីដើម្បីឱ្យមានអារម្មណ៍ល្អនៅពេលដែលអូន ឬបងខឹង ឬមួម៉ៅ?
- តើអ្វីខ្លះដែលធ្វើឱ្យបងឬអូនមានអារម្មណ៍ថា មានមោទនភាព?

# វគ្គទី៥

# មេរៀនទី៤៖ កាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កូន

## សេចក្ដីផ្ដើម

ការស្វែងយល់ពីកាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងភារកិច្ចរបស់កូន ឬកុមារពិតជាមានសារៈសំខាន់ណាស់សម្រាប់ពួកគាត់ក្នុងការថែទាំចិញ្ចឹមបីបាច់កូន ឬកុមារស្របតាមយុទ្ធសាស្ត្រស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមានរបស់ក្រសួងកិច្ចការនារី ឆ្នាំ ២០១៧-២០២១។ ការយល់ដឹងនេះបានជួយពង្រឹង និងធ្វើឱ្យកាន់តែប្រសើរឡើងនៅក្នុងគ្រួសារនីមួយៗដែលជំរុញឱ្យការទំនាក់ទំនងរវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ជាមួយនឹងកូន ឬកុមារកាន់តែប្រសើរ និងរឹងមាំថែមទៀត ដើម្បីកាត់បន្ថយ ឬបញ្ឈប់អំពើហិង្សា ការមិនអើពើនៅក្នុងគ្រួសារដែលនាំឱ្យពួកគេរស់នៅដោយភាពរីករាយ មានសុខភាពល្អ កិរិយាមារយាទថ្លៃថ្នូរ ចេះគោរពចាស់ទុំ ហើយទទួលបានការអប់រំដែលជាឧត្ដមប្រយោជន៍សម្រាប់ពួកគេ និងការរស់នៅប្រកបដោយសុភមង្គលជាមួយក្រុមគ្រួសារ។

ម្យ៉ាងទៀតក្នុងប្រទេសកម្ពុជា ផ្ដោតការយកចិត្តទុកដាក់ខ្លាំងលើផ្នែកសីលធម៌សង្គម ដែលអាចមានឥទ្ធិពលទៅលើទម្លាប់នៃការចិញ្ចឹមកូន ឬកុមាររបស់គ្រួសារនីមួយៗ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ តែងតែរំពឹងដល់កូនថា នឹងមើលថែទាំនៅពេលដែលពួកគាត់ចាស់ជរា ដើម្បីជាកិច្ចតបស្នងសងគុណ។ ការកំណត់គោលដៅនៃការចិញ្ចឹមកូន ឬកុមាររបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ក៏អាចបង្កឱ្យមានផលប៉ះពាល់ទៅលើគុណតម្លៃ និងអនាគតកូន ឬកុមារផងដែរ។

យោងទៅតាមហេតុផលខាងលើ យើងឃើញថា កាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកូន ឬកុមារមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ផ្ដល់ភាពកក់ក្ដៅ សេចក្ដីស្រឡាញ់ ដើម្បីប្រែក្លាយពួកគេទៅជាមនុស្សពេញវ័យដែលមានសុខុមាលភាពល្អ។

រយៈពេល ១៥០ នាទី

## គោលបំណង

**នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាចៈ**

- វិភាគបាននូវអាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ។
- លើកកម្ពស់ទម្លាប់ល្អ ឬរបៀបនៃការចិញ្ចឹមកូន ឬកុមារ និងផ្លាស់ប្តូរនូវអាកប្បកិរិយាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបំពេញកាតព្វកិច្ច និងគាំទ្រដល់កូន ឬកុមារ ដើម្បីឱ្យពួកគេមានការលូតលាស់ និងអភិវឌ្ឍបានល្អ។
- បង្កើនការយកចិត្តទុកដាក់ដល់កូន ឬកុមារដែលមានតម្រូវការពិសេស ដូចជាកុមារដែលមានពិការភាព។

## សម្ភារៈដែលត្រូវការ

- រូបភាពទី ១ បង្ហាញពី ការពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ
- រូបភាពទី ២ បង្ហាញពី ការបំបៅដោះកូន
- រូបភាពទី ៣ បង្ហាញពី ការចុះសំបុត្រកំណើត
- រូបភាពទី ៤ បង្ហាញពី ការថែទាំសុខភាពកូន
- រូបភាពទី ៥ បង្ហាញពី ការកំណត់គោលដៅរយៈពេលវែង
- រូបភាពទី ៦ បង្ហាញពី ការការពារ និងសុវត្ថិភាពនៃការលេង
- រូបភាពទី ៧ បង្ហាញពី ការធ្វើជាគំរូល្អ
- រូបភាពទី ៨ បង្ហាញពី ការផ្តល់ឱកាស
- រូបភាពទី ៩ បង្ហាញពី ការបង្រៀន និងអប់រំ
- រូបភាពទី ១០ បង្ហាញពី ការផ្តល់ភាពកក់ក្តៅ និងក្តីស្រឡាញ់
- រូបភាពទី ១១ បង្ហាញពី ការធ្វើការងារផ្ទះ
- រូបភាពទី ១២ បង្ហាញពី ការរស់នៅចុះសម្រុងគ្នា
- រូបភាពទី ១៣ បង្ហាញពី អាកប្បកិរិយា និងឥរិយាបថល្អ
- រូបភាពទី ១៤ បង្ហាញពី ការអនាម័យខ្លួនប្រាណ
- រូបភាពទី ១៥ បង្ហាញពី ការដោះស្រាយទំនាស់
- រូបភាពទី ១៦ បង្ហាញពី ការថែទាំសុខភាព
- រូបភាពទី ១៧ បង្ហាញពី ការស្តាប់ដំបូន្មានឪពុកម្តាយ
- រូបភាពទី ១៨ បង្ហាញពី ការរៀនសូត្រ
- រូបភាពទី ១៩ បង្ហាញពី អាហារូបត្ថម្ភ
- រូបភាពទី ២០ បង្ហាញពី ការរៀនបំណិនជីវិត
- រូបភាពទី ២១ បង្ហាញពី ការលេង
- រូបភាពទី ២២ បង្ហាញពី ការគេង
- បណ្ណរូបភាព (Poster) (០,៦០ម x ០,៨០ម) ដែលបង្ហាញពីតួនាទីឪពុកម្តាយ និងភារកិច្ចកូន ឬកុមារ ដើម្បីចែកជូនអ្នកចូលរួម
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- កម្រាលសម្រាប់អ្នកចូលរួមអង្គុយ

- ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រាអំពីវិន័យដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

## ខ្លឹមសារលម្អិត

## I. កាតព្វកិច្ចរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី)

ឪពុកម្តាយអាណាព្យាបាល ឬអ្នកថែទាំមានកាតព្វកិច្ច ចាប់តាំងពីកូនបង្កកំណើត រហូតដល់ពេញវ័យ។

### ១. ការពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ

ក្នុងអំឡុងពេលមានផ្ទៃពោះគួរធ្វើការពិគ្រោះយោបល់ និងពិនិត្យសុខភាពឱ្យបាន៤ដង និងចាក់ថ្នាំបង្ការដើម្បីជួយឱ្យទារកក្នុងផ្ទៃមានសុខភាពល្អ។ នៅពេលដែលកូនចាប់កំណើត ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវយកចិត្តទុកដាក់ថែបំប៉នសុខភាពអ្នកមានផ្ទៃពោះ ដោយគិតទៅដល់របបអាហារដែលផ្តល់នូវសុខភាពល្អសម្រាប់ខ្លួនឯង និងទារកក្នុងផ្ទៃ ដោយជៀសវាងការប្រើគ្រឿងញៀន ហូបបារី និងប្រើគ្រឿងស្រវឹង ដែលនាំឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់ទារកក្នុងផ្ទៃ។ ម្យ៉ាងទៀតឪពុកម្តាយត្រូវព្យាយាមនិយាយលេង ស្ទាបអង្អែលជាមួយទារកក្នុងផ្ទៃដោយក្តីស្រឡាញ់ ថ្នាក់ថ្នម និងស្វែងរកកន្លែងដែលមានសុវត្ថិភាពក្នុងពេលសម្រាលកូន (ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក) ដែលមានឆ្មប ឬពេទ្យជំនាញ។

### ២. ការបំបៅដោះកូន

បន្ទាប់ពីសម្រាលកូនរួច ឪពុកម្តាយត្រូវផ្តល់ឱ្យកូននូវភាពកក់ក្តៅ ក្តីស្រឡាញ់ និងយកចិត្តទុកដាក់ក្នុងការថែទាំទារក ដោយផ្តល់ទឹកដោះដំបូង និងបំបៅកូនដោយទឹកដោះម្តាយតែមួយមុខរយៈពេល ៦ខែ ឬបន្តការបំបៅដោះកូនរហូតដល់អាយុ ២ឆ្នាំ។

### ៣. ការចុះសំបុត្រកំណើត

បន្ទាប់ពីបានសម្រាលកូនរួច ឪពុក ឬម្តាយមានកាតព្វកិច្ចទៅសុំចុះសំបុត្រកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះមិនឱ្យហួសពី ៣០ថ្ងៃ។

### ៤. ការថែទាំសុខភាពកូន

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវយកកូន ឬកុមារទៅពិនិត្យសុខភាព ដូចជា សុខភាពមាត់ធ្មេញ សុខភាពភ្នែក ខ្លួនប្រាណ បញ្ចុះសត្វល្អិត ព្រមទាំងចាក់ថ្នាំបង្ការផ្សេងៗនៅប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកទៅតាមការ

កំណត់អាយុកុមាររបស់ក្រសួងសុខាភិបាល និងស្វែងរកសេវាត្រួតពិនិត្យការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។

## ៥.ការកំណត់គោលដៅរយៈពេលវែង

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំតែងតែចង់ឱ្យកូន ឬកុមារធំឡើង ក្លាយជាមនុស្សប្រកបដោយគុណតម្លៃល្អដូចជា ស្មោះត្រង់ ស្លូតបូត យល់ចិត្ត ជួយយកអាសារអ្នកដទៃ ដោះស្រាយបញ្ហាដោយអហិង្សា ឬមានមុខរបរសុចរិតជាដើម។ ប៉ុន្តែសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់មួយចំនួនដែលប្រព្រឹត្តក្នុងការចិញ្ចឹមបីបាច់ កូន ឬកុមារបានរួមចំណែកកែប្រែនូវសេចក្តីប្រាថ្នានោះមិនបានដូចបំណងទៅវិញ។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមបីបាច់កូន ឬកុមារ ដែលមានលក្ខណៈលើកទឹកចិត្ត ផ្តល់ឱកាសចូលរួម សម្រេចចិត្ត និងមិនប្រើទណ្ឌកម្មពេលប្រៀនប្រដៅកូន ឬកុមារជាដើម។

## ៦.ការការពារ និងសុវត្ថិភាពនៃការលេង

ធ្វើយ៉ាងណាឱ្យកុមារជៀសផុតពីគ្រោះថ្នាក់ផ្សេងៗដែលវាអាចកើតមានឡើង ដោយចេតនា ឬអចេតនា។ ប្រាប់កូន ឬកុមារពីគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើង ដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រឿងញៀន លង់ទឹក ។ល។ ដោយពន្យល់ពីហេតុផលច្បាស់លាស់ត្រឹមត្រូវដល់ពួកគាត់។

## ៧. ការធ្វើជាគំរូល្អ

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំប្រើរបៀបដោះស្រាយបញ្ហា ភាពតានតឹងចិត្ត ឬជម្លោះដែលបានកើតឡើងតាមមធ្យោបាយវិជ្ជមាន និងអហិង្សា។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីធ្វើជាគំរូល្អដល់កូន ឬកុមារពីរបៀបប្រាស្រ័យទាក់ទងល្អជាមួយសមាជិកគ្រួសារ និងជាមួយមនុស្សដែលនៅខាងក្រៅផ្ទះ ដើម្បីឱ្យកូន ឬកុមារបានរៀនសូត្រ និងអនុវត្តតាម។

## ៨.ការផ្តល់ឱកាស

កុមារដែលមានពិការភាពទទួលបានឱកាសចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍សង្គមនានា ព្រមទាំងទទួលបានឧត្តមប្រយោជន៍ស្មើគ្នា នោះការលូតលាស់ និងអភិវឌ្ឍនឹងកើតមានឡើងដល់កុមារ។

## ៩.ការបង្រៀន និងអប់រំ

នៅពេលកូន ឬកុមារចម្រើនវ័យ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវចុះឈ្មោះកូន ឬកុមារ ឱ្យបានចូលរៀននៅសាលាមត្តេយ្យ និងតាមកម្រិតថ្នាក់ជាបន្តបន្ទាប់

ព្រមទាំងបន្តអប់រំកូន ឬកុមារពីអាកប្បកិរិយា សីលធម៌ ចំណេះដឹង បំណិនជីវិត និងជំនាញបន្ថែម។

- **បង្រៀន និងអប់រំកុមារពីសុខភាពផ្លូវភេទ៖** ពន្យល់កូន ឬកុមារ ពីការលូតលាស់នៃរូបកាយនៅពេលដែលកុមារពេញវ័យ ឬកុមារចាប់ផ្តើមមានចំណង់ផ្លូវភេទ។ ដូចនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំពន្យល់កុមារពីរបៀបគ្រប់គ្រងចំណង់ផ្លូវភេទតាមបែបវិជ្ជមាន ដូចជាហាត់ប្រាណ អានសៀវភៅ ដើរលំហែ ស្តាប់ចម្រៀង ជជែកគ្នាលេងជាមួយមិត្តភក្តិដែលទុកចិត្តបានមើលរឿងកំប្លែង និងខ្សែភាពយន្ត ឬលេងកីឡាជាដើម ដែលសកម្មភាពទាំងអស់នេះ មិនធ្វើឱ្យប៉ះពាល់ដល់ខ្លួនឯង និងអ្នកដទៃឡើយ។
- **គ្រឿងញៀន៖** នៅពេលដែលកុមារចូលវ័យជំទង់ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅតែបន្តលើកទឹកចិត្ត អប់រំឱ្យកូនយល់ពីភារកិច្ចដែលត្រូវជៀសវាងការសេពគប់មិត្តដែលសង្គមមិនឱ្យតម្លៃដូចជា ប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង។ល។ លើសពីនេះ ពន្យល់កុមារពីមូលហេតុដែលនាំឱ្យមានការប្រើប្រាស់គ្រឿងញៀន ផលប៉ះពាល់ និងមធ្យោបាយដែលធ្វើឱ្យខ្លួនគេសប្បាយដោយមិនប្រើគ្រឿងញៀន។

## ១០. ការផ្តល់ភាពកក់ក្តៅ និងក្តីស្រឡាញ់

មានពេលវេលាសម្រាប់កុមារដូចជា និទានរឿង ស្តាប់កុមារនិយាយ និយាយគ្នាលេង ឱប ថើប ឬប្រើពាក្យសម្តីទន់ភ្លន់។ល។

## ១១. ការធ្វើការងារផ្ទះ

ក្រៅអំពីការសិក្សារៀនសូត្រ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវផ្តល់ឱកាសឱ្យកូន ឬកុមារ បានចូលរួមធ្វើការងារផ្ទះ តាមលទ្ធភាព និងកម្រិតអាយុរបស់ពួកគេ ដើម្បីអភិវឌ្ឍបំណិនជីវិត។

## ១២. ការរស់នៅចុះសម្រុងគ្នា

មានកន្លែងស្នាក់នៅសមរម្យ និងសម្លៀកបំពាក់ទៅតាមស្ថានភាពជីវភាព អាកាសធាតុ ព្រមទាំងបរិស្ថានរស់នៅដោយការគោរពឱ្យតម្លៃគ្នា និងគ្មានអំពើហិង្សា។ល។

## ១៣. អាកប្បកិរិយា និងឥរិយាបថល្អ

ការគោរព ការប្រាស្រ័យទាក់ទងដោយការយល់ចិត្ត ការចែករំលែក និងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ល។

**ចំណាំ**

- ការរក្សាកូន ឬកុមារឱ្យនៅជាមួយគ្រួសារ គឺជាមធ្យោបាយតែមួយគត់ក្នុងការផ្តល់ឱកាសឱ្យកូនទទួលបានការលូតលាស់ និងអភិវឌ្ឍបានល្អ។ នៅក្នុងមណ្ឌលកុមារកំព្រា កុមារងាយរងគ្រោះពីអំពើហិង្សា ការរំលោភបំពាន ឬការមិនអើពើ ។ល។ ដូចនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរតែឱ្យកូន ឬកុមាររស់នៅក្នុងគ្រួសារ បើទោះជាមានស្ថានភាពជីវភាពយ៉ាងណាក៏ដោយ ហើយត្រូវចងចាំថា គ្មានទីណាដែលប្រសើរជាងផ្ទះ ឬគ្រួសាររបស់កូន ឬកុមារឡើយ។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី) គួរផ្តល់ការថែទាំពិសេសទៅលើកូន ឬកុមារដែលមានពិការភាព ដើម្បីការពារកុមារទាំងនោះពីការរំលោភបំពានគ្រប់ទម្រង់។ កុមារទាំងនោះ នឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរ ដូចជាទៅចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេនឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យយ៉ាងហោចណាស់មួយឆ្នាំ មុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យយ៉ាងហោចណាស់។ បើសិនជាអាច សូមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី) បន្តគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យរៀនដល់មហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពសង្គមនានាដែរ។

## II. ភារកិច្ចរបស់កូន ឬកុមារ

កូន ឬកុមារ មានភារកិច្ចមួយចំនួន សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ភារកិច្ចទាំងនោះរួមមាន៖

### ១. ការអនាម័យខ្លួនប្រាណ

ដូចជា ងូតទឹកសម្អាតខ្លួនប្រាណ រស់នៅស្អាត ហូបស្អាត ផឹកស្អាត ដែលអាចជួយឱ្យមានសុខភាពល្អ និងរូបរាងកាយមានការលូតលាស់ និងអភិវឌ្ឍបានល្អ។

### ២. ការដោះស្រាយទំនាស់

របៀបដោះស្រាយបញ្ហាដោយសន្តិវិធី ជៀសវាងពីការប្រើអំពើហិង្សាគ្រប់ទម្រង់ តាមរយៈការស្តាប់ហេតុផល សួរសំណួរបញ្ជាក់ ស្វែងរកឫសគល់នៃបញ្ហា មានការពិភាក្សា និងការចរចាជាដើម។

## ៣. ការថែទាំសុខភាព

ហាត់ប្រាណឱ្យបានទៀងទាត់ដូចជា ជិះកង់ លេងបាល់ ឬកីឡាផ្សេងៗទៀតតាមកម្រិតអាយុដែលអាចធ្វើបាន។

## ៤. ការស្តាប់ដំបូន្មានឪពុកម្តាយ

រៀនពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើទាំងនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ ពិសេសរៀនពីគំរូល្អៗ និងស្តាប់ការទូន្មានប្រៀនប្រដៅរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។

## ៥. ការរៀនសូត្រ

ការចូលរៀននៅសាលាមត្តេយ្យរហូតដល់កម្រិតមហាវិទ្យាល័យ បើសិនគាត់អាចមានលទ្ធភាព និងសមត្ថភាព។ កុមារធ្វើកិច្ចការសាលា អាន សួរ ឆ្លើយ ជាពិសេសកុមារមានទីកន្លែង និងពេលវេលាគ្រប់គ្រាន់ក្នុងការរៀនសូត្រនៅសាលារៀន និងជាមួយមិត្តភក្តិ។

## ៦. អាហារូបត្ថម្ភ

ញ៉ាំឱ្យបានទៀងទាត់ និងគិតដល់អាហារទាំង៣ក្រុម (អាហារការពារ អាហារសាងសង់ និងអាហារថាមពល) និងអាហារដែលមានសុវត្ថិភាព។

## ៧. ការរៀនអំពីបំណិនជីវិត

គ្រប់គ្រងពេលវេលា និងលុយកាក់ រៀនពីរបាំខ្មែរ ចម្រៀង ឬសិល្បៈនានា ដាំដំណាំ ឬបន្លែ ការចិញ្ចឹមសត្វ ជំនាញក្នុងការទំនាក់ទំនង ឬការរស់នៅប្រចាំថ្ងៃជាដើម។ ការជួយសម្រាលការងារផ្ទះ មិនប៉ះពាល់ដល់ការអភិវឌ្ឍរបស់កូន ឬកុមារទេ។ សកម្មភាពទាំងនោះមានដូចជា ដាំស្ល ស្រោចផ្កា សម្អាតផ្ទះ និងជួយអ្នកជិតខាង មិត្តភក្តិ ឬអ្នកដែលត្រូវការជំនួយ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវពន្យល់ឱ្យច្បាស់ពីព្រំដែននៃការជួយដែលមិនមានការប៉ះពាល់ដល់ការលូតលាស់ អភិវឌ្ឍ និងមានគ្រោះថ្នាក់ដល់កូន ឬកុមារ។

## ៨. ការលេង

ការបង្កើនន្ធវភាពរីករាយ មានសារៈសំខាន់ណាស់ចំពោះកូន ឬកុមារ។ ពួកគេអាចស្វែងយល់ពីខ្លួនឯងព្រមទាំងបរិស្ថាននៅជុំវិញរបស់ពួកគេ។ ការលេងក៏ជួយឱ្យកូន ឬកុមារមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា ការសម្របខ្លួនទៅតាមស្ថានភាព ទទួល

ស្គាល់អំពីការឈ្នះ និងចាញ់ ចេះរងចាំ និងចែករំលែកនូវអ្វីដែលកុមារមានជាមួយបងប្អូន មិត្តភក្តិ ឬអ្នកផ្សេងទៀត។

### ៩. ការគេង

គេងឱ្យបានគ្រប់គ្រាន់ ឧទាហរណ៍៖

- ទារកអាយុ ០-៣ ខែ ត្រូវគេង ១៤-១៧ ម៉ោង (អាចគេង ១១-១៩ ម៉ោង)
- ទារកអាយុ ៤-១១ ខែ ត្រូវគេង ១២-១៥ ម៉ោង (អាចគេង ១០-១៨ ម៉ោង)
- កូន ឬកុមារតូចអាយុ ១-២ ឆ្នាំ ត្រូវគេង ១១-១៤ ម៉ោង (អាចគេង ៩-១៦ ម៉ោង)
- កូន ឬកុមារតូចអាយុ ៣-៥ ឆ្នាំ ត្រូវគេង ១០-១៣ ម៉ោង (អាចគេង ៨-១៤ ម៉ោង)
- កូន ឬកុមារអាយុ ៦-១៣ ឆ្នាំ ត្រូវគេង ៩-១១ ម៉ោង (អាចគេង ៧-១២ ម៉ោង)
- កូន ឬកុមារអាយុ ១៤-១៧ ឆ្នាំ ត្រូវគេង ៨-១០ ម៉ោង (អាចគេង ៧-១១ ម៉ោង)

### ១០. ភារកិច្ចផ្សេងទៀតមានដូចជា

- **ទំនាក់ទំនងនានាក្នុងសង្គម៖** ចូលរួមកម្មវិធីខ្លះៗជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ សួរសុខទុក្ខសាច់ញាតិ អ្នកជិតខាង ការជួយសម្រួលចរាចរលើដងផ្លូវតាមសាលា ឬការចូលរួមប្រជុំផ្សព្វផ្សាយនានាតាមសហគមន៍ជាដើម។
- ការគោរពច្បាប់ និងសីលធម៌សង្គម៖ ពាក់មួកសុវត្ថិភាព ឬខ្សែក្រវាត់ពេលធ្វើដំណើរ គោរពភ្លើងសញ្ញាចរាចរណ៍ មិនប្រព្រឹត្តអំពើល្បួចឆក់ប្លន់ ឬប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន រួមទាំងការគោរព និងឱ្យតម្លៃដល់មនុស្សនៅជុំវិញខ្លួន។

## III. ភាពជាឪពុក

នៅក្នុងការបំពេញតួនាទីនេះដែរ ឪពុកមានការរួមចំណែកយ៉ាងសំខាន់នៅក្នុងគ្រួសារក្នុងការថែទាំកូន ឬកុមារក្នុងការចូលរួមបញ្ឈប់អំពើហិង្សាលើកុមារផងដែរ។ ការសិក្សាស្រាវជ្រាវធំមួយបានបង្ហាញថា នៅពេលដែលមានការចូលរួមពីឪពុក គឺទទួលបានលទ្ធផលវិជ្ជមានជាច្រើនដល់កូន ប្រពន្ធ និងឪពុកខ្លួនឯងផងដែរ។

ការបង្កើតពិភពលោកមួយដែលគ្មានអំពើហិង្សា សមភាពគំនិត និងការចិញ្ចឹមបីបាច់កូន ឬកុមារ ឪពុកគឺមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងយល់ពីតម្រូវការរបស់កូន ឬកុមារ ដែលអាចធានាដល់សិទ្ធិកុមារ ការគាំទ្រសុខភាពមាតា និងការកាត់បន្ថយនូវការរើសអើងផ្អែកយេនឌ័រ និងទម្រង់ផ្សេងៗនៃអំពើហិង្សា ព្រមទាំងផ្លាស់ប្តូរជីវិតរបស់កុមារា និងបុរសថែមទៀតផង។

ការសិក្សាស្រាវជ្រាវនេះ ក៏បានបង្ហាញដែរថា ការចូលរួមរបស់ឪពុក ឬបុរស គឺមានប្រយោជន៍សម្រាប់ការយល់ដឹង ការអភិវឌ្ឍសង្គម សុខភាពផ្លូវចិត្ត និងរាងកាយរបស់កុមារ ព្រមទាំងការអភិវឌ្ឍអាកប្បកិរិយាប្រកបដោយសមភាពយេនឌ័រ។

ធ្វើការជាមួយនឹងឪពុក គឺជាការងារសាមញ្ញបំផុត ហើយមានប្រសិទ្ធភាពខ្ពស់សម្រាប់លើកកម្ពស់ការបញ្ឈប់អំពើហិង្សា សមភាពសម្រាប់កុមារ និងស្ត្រី ដែលមិនមែនមានតែនៅក្នុងទ្រឹស្តីនោះទេ ប៉ុន្តែវាជាការអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃនៅក្នុងគ្រួសារ និងសហគមន៍របស់យើង ហើយក៏ជាវិធីដែលមានប្រសិទ្ធភាពក្នុងការធ្វើឱ្យឪពុកចូលរួមគិតពិចារណាពីរបៀបផ្លាស់ប្តូរផ្នត់គំនិតដែលបុរសជាធំទៅជាសមភាពយេនឌ័រ និងគ្មានអំពើហិង្សា។

ប្រសិនបើមានការចូលរួមពីឪពុក និងកុមារាក្នុងការផ្តួចផ្តើម និងគាំទ្រលើកកម្ពស់តម្រូវការ និងសិទ្ធិរបស់កុមារ គឺជាមធ្យោបាយសម្រាប់ឱ្យមានការផ្សារភ្ជាប់ទៅនឹងការរស់នៅរបស់កុមារី និងផ្តល់អាទិភាពស្មើគ្នាទៅនឹងតម្រូវការរបស់កុមារាផងដែរ។

## IV. ភេទ និងយេនឌ័រ

**ភេទ៖** គឺជាលក្ខណៈជីវសាស្ត្ររបស់បុរស និងស្ត្រី ដែលធម្មជាតិបានកំណត់ឱ្យស្រាប់តាំងពីកំណើតមក ហើយគេពុំអាចកែប្រែ ឬផ្លាស់ប្តូរបានឡើយ។

*ឧទាហរណ៍៖ មានតែស្ត្រីទេដែលអាចពពោះ និងបំបៅកូនដោយទឹកដោះម្តាយ និងមានតែបុរសទេដែលអាចផ្តល់មេជីវិតឈ្មោល។*

**យេនឌ័រ៖** គឺជាទំនាក់ទំនងរវាងបុរស និងស្ត្រីនៅក្នុងគ្រួសារ សហគមន៍ សង្គម ពាក់ព័ន្ធនឹងការបែងចែកសិទ្ធិអំណាច ឋានៈ តួនាទី ការងារ និងភារកិច្ចដែលកំណត់ដោយសង្គម ហើយអាចកែប្រែបានទៅតាមកាលៈទេសៈ។

*ឧទាហរណ៍៖ ស្ត្រី និងបុរសអាចធ្វើជាវិស្វករ និងអ្នកគ្រប់គ្រងបានដូចគ្នា។ ស្ត្រី និងបុរសអាចធ្វើការផ្ទះសម្លៀង និងមើលថែទាំកូនចៅបានដូចគ្នា។*

## V. គុណតម្លៃ

គុណតម្លៃ គឺជាអ្វីដែលកំណត់ដោយបុគ្គល ដូច្នេះសមាជិកគ្រួសារ អាចមានជំហរខុសៗគ្នាចំពោះគុណតម្លៃនេះ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី) ក៏មិនមែនជាមនុស្សតែម្នាក់ដែលកំពុងមានឥទ្ធិពលលើការគិតរបស់កូនៗចំពោះគុណតម្លៃនោះទេ។ សមាជិកនៅក្នុងគ្រួសារ សហគមន៍ និងមិត្តភក្តិ គឺសុទ្ធតែមានឥទ្ធិពលដល់ការគិត និងគុណតម្លៃរបស់កូនអ្នកដែរ។ បុគ្គលផ្សេងទៀតដែលជិតស្និទ្ធនៅក្រៅរង្វង់គ្រួសារដូចជា គ្រូបង្រៀន ព្រះសង្ឃ សមាជិកសហគមន៍ក៏រួមចំណែកកាន់តែខ្លាំងផងដែរ ជាពិសេសគឺនៅពេលដែលកូននោះកាន់តែធំដឹងក្តី។

ការកំណត់ និងការស្វែងយល់ពីគុណតម្លៃរបស់លោកអ្នក គឺមានសារៈសំខាន់ណាស់ ពីព្រោះវាជាស្នូលនៃជីវិតរបស់លោកអ្នក និងគ្រួសារក្នុងការចិញ្ចឹមកូន។

## ១. គុណតម្លៃគ្រួសារ

គុណតម្លៃគ្រួសារ គឺជាបទដ្ឋានសង្គម ដែលត្រូវបានកំណត់ដោយគ្រួសារ និងប្រវត្តិប្រពៃណីដែលផ្ដល់នូវមូលដ្ឋានផ្លូវចិត្ត និងផ្លូវកាយសម្រាប់ការចិញ្ចឹមបីបាច់កូន ឬកុមារនៅក្នុងគ្រួសារ។ ការបំពេញការងាររួមគ្នាជាមួយសមាជិកគ្រួសារ ដូចជា ប្ដី ប្រពន្ធ និងកូនក្នុងការកំណត់ និងបង្កើតគុណតម្លៃគ្រួសារ តាមរយៈការជួបជុំគ្នាក្នុងគ្រួសារ គឺជាការសំខាន់បំផុត។ ការនិទានរឿង និងការធ្វើជាគំរូល្អ ជាមធ្យោបាយសំខាន់សម្រាប់ឱ្យឪពុកម្ដាយបង្រៀនកូនរបស់ពួកគាត់អំពីគុណតម្លៃ។

## ២. ការដោះស្រាយវិវាទនៃគុណតម្លៃ

វិវាទគុណតម្លៃក្នុងគ្រួសារ គឺសំដៅលើសមាជិកក្នុងគ្រួសារម្នាក់ៗ ដែលមានការគិត និងយល់ឃើញខុសៗគ្នា។ ដូច្នេះដើម្បីដោះស្រាយនូវវិវាទនៃគុណតម្លៃ មានវិធីសាស្ត្រដូចខាងក្រោម៖

- ចំណាយពេលវេលាស្វែងយល់ និងពិចារណាអំពីខ្លួនឯង ដើម្បីសម្រេចចិត្តថាត្រូវធ្វើយ៉ាងណា?
- គោរពគុណតម្លៃរបស់បុគ្គលម្នាក់ ហើយញែកឱ្យដាច់រវាងគុណតម្លៃផ្ទាល់ខ្លួន និងគុណតម្លៃរបស់អ្នកដទៃទៀត។
- ពិគ្រោះជាមួយមិត្តភក្តិ មិត្តរួមការងារ អ្នកជិតខាង បុគ្គលិកសង្គមកិច្ច អ្នកផ្ដល់ប្រឹក្សា ឬប្រធានភូមិដើម្បីឱ្យគេជួយជាគំនិត និងយោបល់។
- រៀបចំការជួបជុំគ្រួសារដើម្បីជជែកគ្នាអំពីបញ្ហា និងឫសគល់របស់វា។

ស្វែងរកដំណោះស្រាយក្នុងឯកសារផ្លូវការដូចជា ឯកសារច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬឯកសារសំខាន់ៗ ស្ដីអំពីសិទ្ធិមនុស្ស និងសិទ្ធិកុមារ។

បង្ហាញកូន ឬកុមារ អំពីគុណតម្លៃល្អៗ និងមានប្រយោជន៍តាមរយៈការប្រព្រឹត្តដូចជាការគោរព និងឱ្យតម្លៃមនុស្សជុំវិញ ជួយមនុស្សដែលត្រូវការជំនួយ ប្រឹងប្រែងរៀនសូត្រ ឬធ្វើការងារដោយសុចរិត ត្បិតកូនតែងមានទំនោរត្រាប់តាមការប្រព្រឹត្តរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ហើយទំនងមានឥទ្ធិពលច្រើនជាងពាក្យសម្ដីដែលប្រៀនប្រដៅ។ ការធ្វើជាគំរូដ៏ល្អ ក៏ជាឧបករណ៍មួយផ្នែកដែរក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារប្រកបដោយប្រសិទ្ធភាព លើកកម្ពស់គុណតម្លៃវិជ្ជមាន និងការប្រព្រឹត្តដោយអហិង្សា (ICS-SP ឆ្នាំ២០១៣)

**កុំបារម្ភថា កូនមិនស្ដាប់តាមអ្នកឱ្យសោះ**

**តែត្រូវប្រយ័ត្ន ត្បិតកូនរបស់អ្នកកំពុងតែឃ្លាំមើលរាល់ទង្វើរបស់អ្នកជានិច្ច**

## ៣. ទម្លាប់ និងជំនឿនៃការចិញ្ចឹមកូន

**ជំនឿ និងការពិតនៃការចិញ្ចឹមកូននៅកម្ពុជា**

| លរ | ជំនឿ | ការពិត |
|---|---|---|
| ១ | ប្របាច់ក្រូចឆ្មារដាក់ភ្នែកទារកពេលទារកកើតភ្លាមដើម្បីបង្ការរោគ | ទឹកក្រូចឆ្មារគឺជាប្រភេទមួយនៃអាស៊ីត។ វាអាចធ្វើឱ្យរលាកភ្នែកទារកជាលទ្ធផល គឺវាបានបំផ្លាញភ្នែក និងអាចធ្វើឱ្យទារកខ្វាក់បាន។ |
| ២ | ដាក់ទឹកដោះ ឬទឹកនោមចូលភ្នែកពេលឈឺភ្នែក | ទឹកនោមមិនបង្ការជំងឺឆ្លងទេ ការពិតគឺវាអាចបង្កជាជំងឺឆ្លងបាន។ វាអាចមានគ្រោះថ្នាក់នៅពេលដែលដាក់ទឹកដោះទៅក្នុងភ្នែកទារក ប្រសិនបើភ្នែក ឈឺស្រាលគឺអាចជួយឱ្យជាបាន ប៉ុន្តែបើវាមិនធ្វើឱ្យភ្នែកស្រឡះបានឆាប់រហ័សនោះទេ គឺត្រូវតែទៅជួបគ្រូពេទ្យ។ |
| ៣ | មុជ ឬលាងស្រាបៀរពេលទារកកើត ដើម្បីធ្វើឱ្យស្បែកស្អាត | បែបនេះ គឺមិនបង្កគ្រោះថ្នាក់ដល់ទារកទេ ប៉ុន្តែស្រាបៀរមានជាតិសុរា ហើយសុរាងាយស្ងួត ដូច្នេះវាធ្វើឱ្យស្បែករបស់ទារកស្ងួត ជាជាងធ្វើឱ្យស្បែកទារកស្អាត។ |
| ៤ | ពន្លៃ ប្រេងកូឡា មេដំបែ ទំពាស្លឹកត្រគាបក្លាមបិតបង្ហើយដើម្បីឱ្យបង្ហើយឆាប់រឹង | វាគ្រោះថ្នាក់ណាស់ក្នុងការដែលយកអ្វីមួយទៅត្រដុសបង្ហើយទារក។ បង្ហើយទារកទន់ណាស់ ហើយបើប៉ះវា គឺគួរប៉ះថ្នមៗ។ គ្មានអ្វីត្រូវយកមកបិតបង្ហើយទារកទេគឺមានតែពេលវេលាប៉ុណ្ណោះ ឆ្អឹងនឹងលូតលាស់រឹងមាំនៅពេលទារកមានអាយុចន្លោះពី ៨ ទៅ ២៤ ខែ។ ប្រសិនបើបង្ហើយផតគឺវាជាសញ្ញាមួយនៃការខ្វះជាតិទឹក។ បើវាប៉ោងគឺជាសញ្ញាមួយនៃជំងឺឆ្លងចំពោះខួរក្បាល។ សូមពិគ្រោះជាមួយគ្រូពេទ្យ ប្រសិនបើរឿងបែបនេះកើតឡើង។ |
| ៥ | បៀមទឹកអ៊ុនៗទៅស្រូបបង្ហើយ ដើម្បីឱ្យបង្ហើយឆាប់រឹង | |
| ៦ | ដាក់កាំបិត កន្ត្រៃលើក្បាលដើម្បីដេញខ្មោចព្រាយចេញ និងជួយឱ្យទារកឆាប់គេងលក់ | អ្វីៗដែលមុតស្រួចដាក់ក្បែរទារកគឺគ្រោះថ្នាក់ណាស់។ ទារកងាយនឹងរើ ហើយវត្ថុស្រួចៗងាយនឹងមុតពួកគេ។ |

| ជំនឿ និងការពិតនៃការចិញ្ចឹមកូននៅកម្ពុជា | | |
|---|---|---|
| លរ | ជំនឿ | ការពិត |
| ៧ | កាត់រោមភ្នែក ដើម្បីឱ្យបានរោមភ្នែកឆាប់ដុះបានវែងៗ | គ្រោះថ្នាក់ណាស់ក្នុងការដែលយកកន្ត្រៃស្រួច ឬវត្ថុមុតស្រួចនានាទៅដាក់ជិតភ្នែកទារក។ ការកាត់រោមភ្នែកមិនធ្វើឱ្យរោមភ្នែកនោះវែង ឬស្អាតជាងមុននោះទេ។ |
| ៨ | យកប្រេងកូឡា ឬម្រាមដៃទៅញីពងកូន ឬពាក់ក្រវិលឱ្យកូនពេលឃើញពងរបស់គេមិនស្មើគ្នា | ប្រេងកូឡា គឺសម្រាប់ធ្វើឱ្យសាច់ដុំដែលចុករោយបានសម្រាក និងធូរស្រាលពីការឈឺចាប់ មិនមែនសម្រាប់គោលបំណងផ្សេងៗទៀតទេ។ វាមានជាតិយ៉ៃមហូ ដែលពុល និងជាតិហិរ។ វាបង្កើតឱ្យមានអារម្មណ៍ក្រហាយនៅលើស្បែក ដូច្នេះទារកនឹងឈឺក្នុងការដែលញីពងទារកជាមួយនឹងប្រេងកូឡា ព្រោះស្បែកនៅទីនេះទន់ណាស់។ ទារកអាចនឹងប៉ះវា និងយកដៃទៅញីភ្នែក ឬមាត់ដែលអាចបណ្តាលឱ្យមានអន្តរាយធ្ងន់ធ្ងរ។ វាមិនជួយឱ្យពងលូតលាស់ទេ ហើយការពាក់ក្រវិលក៏មិនជួយដែរ។ |
| ៩ | លាបប្រេងកូឡា ឬប្រមាត់ជ្រូកនៅពោះ ដើម្បីបង្ការការឈឺពោះ | សូមមើលចម្លើយ៨។ ការប្រើជាតិ យ៉ៃមហូច្រើនពេកពិតជាបង្កឱ្យមានជំងឺពោះវៀនជាជាងការព្យាបាលពោះវៀន ចំណែកឯប្រមាត់ជ្រូកពោរពេញដោយមេរោគ (បាក់តេរី)។ សូមយកវាចេញឱ្យឆ្ងាយពីទារក បើមិនដូច្នេះទេវាអាចបង្កឱ្យមានជំងឺធ្ងន់ធ្ងរ។ |
| ១០ | ច្របាច់គ្រាប់ដោះចេញដើម្បីកុំឱ្យកូនស្រី និងកូនប្រុសមានដោះធំ | ការច្របាច់ដោះទារកគឺឈឺចាប់ណាស់ ហើយព្រៃផ្សៃ និងអាចបង្ករោគ។ ដូច្នេះវាគ្រោះថ្នាក់។ ជាធម្មតាទារកជាច្រើននៅពេលដែលកើតមកមានវត្ថុរាវដូចទឹកដោះខ្លះៗបណ្តាលពីអរម៉ូនរបស់ម្តាយ។ វានឹងបាត់ដោយខ្លួនឯងនៅពីរបីថ្ងៃក្រោយមក។ ការច្របាច់នេះមិនបានផលអ្វីទៅលើការលូតលាស់ដោះរបស់កូនប្រុស និងកូនស្រីនោះទេ។ |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន៖

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើម អ្នកសម្របសម្រួលសំណេះសំណាលហើយអាច៖<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួលជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរ៖<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>🗣 បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់៖** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុនជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំផ្តល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែងថាមពល "ទេវតាថា" (១០នាទី) | ▪ ឱ្យអ្នកចូលរួមឈរជារង្វង់ រួចណែនាំអំពីរបៀបនៃការចូលរួមក្នុងល្បែងថាមពល។<br>▪ ចូរពន្យល់ថា អ្នកទាំងអស់គ្នានឹងត្រូវធ្វើតាមអ្នកសម្របសម្រួល ប្រសិនបើអ្នកពូពាក្យនាំមុខដោយពាក្យ "ទេវតាថា..."។<br>*(ឧទាហរណ៍៖ ទេវតាថា ដូរកន្លែង" អ្នកទាំងអស់ត្រូវប្តូរកន្លែងគ្នា។*<br>▪ ប៉ុន្តែ អ្នកទាំងអស់គ្នានឹងមិនត្រូវធ្វើអ្វីទាំងអស់ ប្រសិនបើអ្នកមិនពូពាក្យនាំមុខដោយពាក្យ "ទេវតាថា..." នោះទេ។<br>*ឧទាហរណ៍៖ ដូរកន្លែង នោះអ្នកចូលរួមមិនត្រូវធ្វើតាមទេ។ បើករណីអ្នកចូលរួមធ្វើខុសល័ក្ខខ័ណ្ឌ អ្នកនោះនឹងចាញ់ ហើយក្លាយជាអ្នកដឹកនាំវិញម្តង។*<br>▪ អ្នកដែលដឹកនាំបន្តដឹកនាំរហូតដល់ស្វែងរកអ្នកចាញ់ ហើយអ្នកចាញ់នឹងបន្តដឹកនាំ និងធ្វើដំណើរការដូចគ្នា។ |
| ៥ | មេរៀនថ្មី៖ កាតព្វកិច្ចរបស់ ឪពុកម្តាយ និងភារកិច្ចរបស់កូន | កាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន (៥០នាទី) | ▪ អ្នកសម្របសម្រួលអាចពន្យល់ពីនិយមន័យនៃពាក្យ *កាតព្វកិច្ច* និង *ភារកិច្ច* ករណីអ្នកចូលរួមមិនយល់ បន្ទាប់មកនិយាយថា៖ ឥឡូវនេះ យើងនឹងពិភាក្សាគ្នាលម្អិតពីកាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន<br>▪ ចែកអ្នកចូលរួមជា ៤ក្រុម (បើសិនជាមានចំនួនអ្នកចូលរួមបុរសប្រហាក់ប្រហែលគ្នានឹងស្ត្រី ចែកក្រុមបុរសផ្សេង ក្រុមស្ត្រីផ្សេង ហើយក្រុមនីមួយៗនឹងពិភាក្សាលើសំណួរ៖<br>☞ ក្រុមទី១៖ តើឪពុក ឬប្តីមានកាតព្វកិច្ច និងការទទួលខុសត្រូវអ្វីខ្លះ?<br>☞ ក្រុមទី២៖ តើម្តាយ ឬប្រពន្ធមានកាតព្វកិច្ច និងការទទួលខុសត្រូវអ្វីខ្លះ?<br>☞ ក្រុមទី៣៖ តើកូនស្រី ឬកុមារីមានភារកិច្ចអ្វីខ្លះ?<br>☞ ក្រុមទី៤៖ តើកូនប្រុស ឬកុមារាមានភារកិច្ចអ្វីខ្លះ?<br>▪ ចាត់តំណាងក្រុមនីមួយៗ ឡើងបង្ហាញដល់ក្រុមធំ។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងសួរសំណួរបំផុសខ្លះៗទាក់ទងនឹងកាតព្វកិច្ច និងភារកិច្ចដែលពួកគាត់អាចធ្វើបានដូចគ្នា។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | • ការថែទាំកូន គឺជាកាតព្វកិច្ច និងតួនាទីរបស់ម្ដាយ ឬស្ត្រី មិនមែនជាកាតព្វកិច្ច ឬភារកិច្ចរបស់បុរសទេ។ ដូចនេះអ្នកសម្របសម្រួលពន្យល់ និងជួយឱ្យអ្នកចូលរួមយល់ថា ការថែទាំកូន គឺជាកាតព្វកិច្ច និងភារកិច្ចរបស់ឪពុកម្ដាយ ឬស្ត្រី និងបុរស។<br>*ឧទាហរណ៍៖ ដូតទឹក បញ្ចុកបាយ ស្លៀកពាក់ ទូន្មានអប់រំកូនជាដើម។*<br>▪ បង្ហាញរូបភាពទី១ ដល់ ទី១៣ កាតព្វកិច្ចឪពុកម្ដាយ ដោយពន្យល់ពីកាតព្វកិច្ចនីមួយៗតាមខ្លឹមសារមេរៀន។<br>▪ បន្ទាប់មក បង្ហាញរូបភាពទី១៤ ដល់ទី២២ ដោយពន្យល់ពីភារកិច្ចនីមួយៗរបស់កូន ឬកុមារតាមខ្លឹមសារមេរៀន។ |
| | | **ទម្លាប់ ជំនឿ ឬផ្នត់គំនិត ពីការចិញ្ចឹមកូន** (១៥នាទី) | ▪ អ្នកសម្របសម្រួលបន្តណែនាំសកម្មភាពបន្ទាប់ពីទម្លាប់ ឬជំនឿ ឬផ្នត់គំនិតដោយពន្យល់អ្នកចូលរួមពីនិយមន័យនៃគុណតម្លៃ រួចបន្តសួរសំណួរបំផុសអំពីគុណតម្លៃ ទៅក្រុមធំថា<br>☞ តើលោកអ្នកមានទម្លាប់ ជំនឿ ឬផ្នត់គំនិតដូចម្ដេច ក្នុងការប្រៀនប្រដៅកូន ឬកុមារ?<br>🗣 ចម្លើយរំពឹងទុក៖ ស្ដីបន្ទោសពេលកូនធ្វើខុស ផ្ដល់រង្វាន់ពេលកូនរៀនពូកែ បន់ស្រន់ពេលកូនមានជំងឺ។ល។ អ្នកសម្របសម្រួលកត់ចម្លើយអ្នកចូលរួម<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម មនុស្សម្នាក់មានការកំណត់នូវទម្លាប់ ជំនឿ ឬផ្នត់គំនិតរៀងៗខ្លួន ជួនកាលនៅក្នុងគ្រួសារមួយរវាងប្ដី និងប្រពន្ធក៏មានទម្លាប់ ជំនឿ ឬផ្នត់គំនិតខុសៗគ្នាដែរ។ |
| | | **ទម្លាប់ ជំនឿ ឬផ្នត់គំនិត** (១៥នាទី) | ▪ សូមអ្នកចូលរួមគិតពីលទ្ធផលផ្សេងៗចំពោះទម្លាប់ ជំនឿ ឬផ្នត់គំនិតរៀងៗខ្លួន ១នាទី។ បន្ទាប់មក អ្នកសម្របសម្រួលជ្រើសរើសទម្លាប់ ជំនឿ ឬផ្នត់គំនិតរបស់អ្នកចូលរួមមួយមកធ្វើរង្វាស់សង្គម<br>☞ ដៅចំណុច៣ ចំណុចទី១ដាក់ពាក្យ "ល្អ" ចំណុចទី២ ដាក់ពាក្យ "មិនល្អ" និង ចំណុចទី៣ដាក់ពាក្យ "ស្ទាក់ស្ទើរ" |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ☞ សុំឱ្យអ្នកចូលរួមទៅឈរនៅចំណុចដែលពួកគាត់បានជ្រើសរើសក្នុងចំណោមពាក្យទាំងបីខាងលើ សុំអ្នកចូលរួមបកស្រាយនូវគំនិតរបស់ខ្លួនពីមូលហេតុដែលជ្រើសរើសយកគុណតម្លៃនោះ (ម្តងម្នាក់)។<br>▪ អ្នកសម្របសម្រួលសរុបនូវអ្វីអ្នកចូលរួមបានបកស្រាយ រួចសួរសំណួរ៖<br>☞ ប្រសិនបើនៅក្នុងគ្រួសាររបស់អ្នក មានទម្លាប់ ជំនឿ ឬផ្នត់គំនិតក្នុងការប្រៀនប្រដៅកូនខុសៗគ្នា តើមានអ្វីកើតឡើង ?<br>☞ តើលោកអ្នកធ្វើយ៉ាងម៉េចបើមានបញ្ហានេះកើតឡើង ?<br>▪ អ្នកសម្របសម្រួលសរុប និងបន្ថែមខ្លឹមសារដោយធ្វើការពន្យល់បន្ថែម អំពីទម្លាប់ ជំនឿ ឬផ្នត់គំនិតទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ សូមមើលឯកសារភ្ជាប់ដែលបង្ហាញអំពី ទម្លាប់ ជំនឿ និងការពិតនៃការចិញ្ចឹមកូន។ |
| | | **សង្ខេបមេរៀន**<br>(**៥នាទី**) | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីកាតព្វកិច្ចរបស់ឪពុកម្តាយ និងភារកិច្ចរបស់កូន ឬកុមារ។ ដូចអ្វីដែលលោកអ្នកបានលើកឡើង និងការបង្ហាញរបស់អ្នកសម្របសម្រួល ហើយមានកាតព្វកិច្ចច្រើនណាស់ ដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវបំពេញក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារ និងទាមទារឱ្យមានការជួយគាំទ្រគ្នាទៅវិញទៅមករវាងអ្នកពាក់ព័ន្ធ។ ម្យ៉ាងទៀតយើងក៏អាចជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមកូន ដែលជួយដល់ការសម្រេចបាននូវគោលដៅរយៈពេលវែង ដោយមិនមានការរំពឹង ការតបស្នងពីកូន ឬកុមារឱ្យមើលថៃ ឬចិញ្ចឹមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំវិញឡើយ។ ចំណែកកូន ឬកុមារក៏មានភារកិច្ចដែលត្រូវធ្វើ ដើម្បីជួយដល់គ្រួសារ និងអភិវឌ្ឍខ្លួន។ ចំពោះកុមារដែលមានពិការភាពក៏មានភារកិច្ចផងដែរ ហើយភារកិច្ចទាំងនោះគឺអាស្រ័យទៅតាមលទ្ធភាព សមត្ថភាព និងប្រភេទនៃពិការភាពរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថា ភារកិច្ចទាំងអស់នោះមិនមានប៉ះពាល់ដល់សិទ្ធិ ការលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារឡើយ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៦ | ការឆ្លុះបញ្ចាំង | ការឆ្លុះបញ្ចាំងមេរៀន (១០នាទី) | ▪ អ្នកសម្របសម្រួលសួរៈ<br>☞ តើលោកអ្នកយល់ថា ប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្ដេចដែរ ទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្ដេច នៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | កិច្ចការផ្ទះ រយៈពេល (៥នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្ដើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ លើកទឹកចិត្តអោយអ្នកចូលរួម ចាប់ផ្ដើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និងធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយាដែលអាចដោះស្រាយភាពតានតឹងចិត្ត ដើម្បីជួយខ្លួនឯង ព្រមទាំងគ្រួសារទាំងមូលមានសុភមង្គល<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

# ឧបសម្ព័ន្ធ ជំនឿ និងការពិត នៃការចិញ្ចឹមកូននៅកម្ពុជា

| លរ | ជំនឿ | ការពិត |
|---|---|---|
| ១ | ប្រុបាច់ក្រូចឆ្មារដាក់ភ្នែកទារកពេលទារកកើតភ្លាមដើម្បីបង្ការរោគ | ទឹកក្រូចឆ្មារគឺជាប្រភេទមួយនៃអាស៊ីត។ វាអាចធ្វើឱ្យរលាកភ្នែកទារកជាលទ្ធផលគឺវាបានបំផ្លាញភ្នែក និងអាចធ្វើឱ្យទារកខ្វាក់បាន។ |
| ២ | ដាក់ទឹកដោះ ឬទឹកនោមចូលភ្នែកពេលឈឺភ្នែក | ទឹកនោមមិនបង្ការជំងឺឆ្លងទេ ការពិតគឺវាអាចបង្ករជាជំងឺឆ្លងបាន។ វាអាចមានគ្រោះថ្នាក់នៅពេលដែលដាក់ទឹកដោះទៅក្នុងភ្នែកទារក ប្រសិនបើភ្នែកឈឺស្រាលគឺអាចជួយឱ្យជាបាន ប៉ុន្តែបើវាមិនធ្វើឱ្យភ្នែកស្រលះបានឆាប់រហ័សនោះទេ គឺត្រូវតែទៅជួបគ្រូពេទ្យ។ |
| ៣ | មុជ ឬលាងស្រាបៀរពេលទារកកើត ដើម្បីធ្វើឱ្យស្បែកស្អាត | បែបនេះ គឺមិនបង្ករគ្រោះថ្នាក់ដល់ទារកទេ ប៉ុន្តែស្រាបៀរមានជាតិសុរា ហើយសុរាងាយស្ងួត ដូច្នេះវាធ្វើឱ្យស្បែករបស់ទារកស្ងួត ជាជាងធ្វើ ឱ្យស្បែកទារកស្អាត។ |
| ៤ | ពន្លៃប្រេងកូឡាមេដំបែទំពាស្លឹកត្រគាបក្តាមបិតបង្ហើយដើម្បីឱ្យបង្ហើយឆាប់រឹង | វាគ្រោះថ្នាក់ណាស់ក្នុងការដែលយកអ្វីមួយទៅត្រដុសបង្ហើយទារក។ បង្ហើយទារកទន់ណាស់ ហើយបើប៉ះវា គឺគួរប៉ះថ្នមៗ។ គ្មានអ្វីត្រូវយកមកបិតបង្ហើយទារកទេ គឺមានតែពេលវេលាប៉ុណ្ណោះ។ឆ្អឹងនឹងលូតលាស់រឹងមាំនៅពេលទារកមានអាយុចន្លោះពី ៨ ទៅ ២៤ ខែ។ ប្រសិនបើបង្ហើយផតគឺវាជាសញ្ញាមួយនៃការខ្វះជាតិទឹក។ បើវាប៉ោង គឺជាសញ្ញា មួយនៃជំងឺឆ្លងចំពោះខួរក្បាល។ សូមពិគ្រោះជាមួយគ្រូពេទ្យ ប្រសិនបើរឿងបែបនេះ កើតឡើង។ |
| ៥ | បៀមទឹកអ៊ុនៗទៅស្រូបបង្ហើយ ដើម្បីឱ្យបង្ហើយឆាប់រឹង | |
| ៦ | ដាក់កាំបិត កន្ត្រៃលើក្បាលដើម្បីដេញខ្មោចព្រាយចេញ និងជួយឱ្យទារកឆាប់ គេងលក់ | អ្វីៗដែលមុតស្រួចដាក់ក្បែរទារកគឺគ្រោះថ្នាក់ណាស់។ ទារកងាយនឹងរើ ហើយវត្ថុស្រួចៗងាយនឹងមុតពួកគេ។ |
| ៧ | កាត់រោមភ្នែក ដើម្បីឱ្យបានរោមភ្នែកឆាប់ដុះបានវែងៗ | គ្រោះថ្នាក់ណាស់ក្នុងការដែលយកកន្ត្រៃស្រួច ឬវត្ថុមុតស្រួចនានាទៅដាក់ជិតភ្នែកទារក។ ការកាត់រោមភ្នែកមិនធ្វើឱ្យរោមភ្នែកនោះវែង ឬស្អាតជាងមុននោះទេ។ |
| ៨ | យកប្រេងកូឡា ឬម្រាមដៃទៅញីពងកូន ឬពាក់ក្រវិលឱ្យកូនពេលឃើញពងរបស់គេមិនស្មើគ្នា | ប្រេងកូឡាគឺសម្រាប់ធ្វើឱ្យសាច់ដុំដែលចុករោយបានសម្រាក និងធូរស្រាលពីការឈឺចាប់ មិនមែនសម្រាប់គោលបំណងផ្សេងៗទៀតទេ។ វាមានជាតិឃែមហ្វ ដែលពុលនិងជាតិហិរ។ វាបង្កើតឱ្យមានអារម្មណ៍ក្រហាយនៅលើស្បែក ដូច្នេះទារកនឹងឈឺក្នុងការដែលញីពងទារកជាមួយនឹងប្រេងកូឡា ព្រោះស្បែកនៅទីនេះទន់ណាស់។ ទារកអាចនឹងប៉ះវា និងយកដៃទៅញីភ្នែក ឬមាត់ដែលអាចបណ្តាលឱ្យមានអន្តរាយធ្ងន់ធ្ងរ។ វាមិនជួយឱ្យពងលូតលាស់ទេ ហើយការពាក់ក្រវិលក៏មិនជួយដែរ។ |
| ៩ | លាបប្រេងកូឡា ឬប្រមាត់ជ្រូកនៅពោះ ដើម្បីបង្ការការឈឺពោះ | សូមមើលចម្លើយ ៨។ ការប្រើជាតិ ឃែមហ្វ ច្រើនពេកពិតជាបង្ករឱ្យមានជំងឺពោះវៀន ជាជាងការព្យាបាលពោះវៀន ចំណែកឯប្រមាត់ជ្រូកពោរពេញដោយមេរោគ (បាក់តេរី)។ សូមយកវាចេញឱ្យឆ្ងាយពីទារក បើមិនដូច្នេះទេ វាអាចបង្ករឱ្យមានជំងឺធ្ងន់ធ្ងរ។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ១០ | ច្របាច់គ្រាប់ដោះចេញដើម្បីកុំឱ្យកូនស្រី និងកូនប្រុសមានដោះធំ | ការច្របាច់ដោះទារកគឺឈឺចាប់ណាស់ហើយព្រៃផ្សៃ និងអាចបង្ករោគ។ ដូច្នេះវាគ្រោះថ្នាក់។ ជាធម្មតាទារកជាច្រើននៅពេលដែលកើតមកមានវត្ថុរាវដូចទឹកដោះខ្លះៗបណ្ដាលពីអកម៉ូនរបស់ម្ដាយ។ វានឹងបាត់ដោយខ្លួនឯងនៅពីរបីថ្ងៃក្រោយមក។ ការច្របាច់នេះមិនបាន ផលអ្វីទៅលើការលូតលាស់ដោះរបស់ក្មេងប្រុស និងក្មេងស្រីនោះទេ។ |
| ១១ | នៅពេលទារកទើបនឹងកើតញញឹម ពេលកំពុងគេងលក់ គឺត្រូវជេរ និងស្រែកដាក់ដើម្បីដេញពួកខ្មោចព្រាយចេញ | ការជេរ និងស្រែកដាក់ទារកទើបនឹងកើត គឺធ្វើឱ្យទារកភ័យខ្លាចខ្លាំងណាស់ ហើយការធ្វើបែបនេះ គឺមានភាពព្រៃផ្សៃ និងអាចបណ្ដាលឱ្យពួកគេមានបញ្ហាចំពោះការគេង។ |
| ១២ | បិតសំបុកឆ្កែញាំង សំបុកពីងពាង ឬអំបិលច្រិចបិទផ្ចិត | ការធ្វើបែបនេះ គឺមានភាពគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះផ្ចិតនៅពេលនេះជាមុខរបួសមួយដែលកំពុងផ្សះ។ □ទង្វើ□ បែបនេះអាចបណ្ដាលឱ្យទារកមានជំងឺធ្ងន់ធ្ងរ និងអាចស្លាប់បាន។ |
| ១៣ | ពេលធ្មេញព្រៃបាក់បោះឡើង ឬ ចុះក្រោមដើម្បីឱ្យធ្មេញថ្មីដុះបានល្អ | មិនមានអន្តរាយអ្វីទេចំពោះការធ្វើបែបនេះ ហើយក៏មិនមានភស្តុតាងណាបញ្ជាក់ថាការធ្វើបែបនេះបានផលចំណេញដែរ។ |
| ១៤ | អុចពោះពេលឈឺ | ក្នុងខណៈពេលដែល ប៉ុយ អាចជាថ្នាំដ៏មានប្រសិទ្ធិភាពសម្រាប់បំបាត់ការឈឺចាប់ វាក៏គ្រោះថ្នាក់ផងដែរប្រសិនបើអ្នកដែលប្រើវាមិនមែនជាគ្រូពេទ្យឆ្លងកាត់វគ្គបណ្ដុះបណ្ដាល។ វាងាយធ្វើឱ្យរលាកខ្លាំងដល់កុមារ។ សូមកុំប្រើវាដោយគ្មានជំនួយពីគ្រូពេទ្យ។ |
| ១៥ | ជួសពិសអាចម៍កុក ដើម្បីយកមេរោគចេញពីក្នុងពោះ | បែបនេះគឺគ្រោះថ្នាក់ខ្លាំងណាស់។មានសរសៃពួរជាច្រើននៅនឹងដៃ។ប្រសិនបើសរសៃពួរត្រូវបានកាត់ផ្ដាច់កុមារនឹងពិការអស់មួយជីវិត។ប៉ារ៉ាស៊ីតនៅក្នុងពោះមិនត្រូវបានព្យាបាលតាមរយៈការវះដៃនោះទេ។ |
| ១៦ | មិនយកទារកចេញក្រៅផ្ទះ ពេលទារកអាយុក្រោមប្រាំមួយខែ | ខ្យល់អាកាសបរិសុទ្ធ និងពន្លឺព្រះអាទិត្យបរិមាណតូចគឺល្អណាស់សម្រាប់ទារក។ មិនមានអ្វីចាំបាច់ត្រូវទុកទារកក្នុងផ្ទះនោះទេ។ ជាការពិតប្រសិនបើទុកនៅកន្លែងតូចចង្អៀត គឺកាន់តែងាយឈឺទៅវិញទេ |
| ១៧ | កោសខ្យល់ប្រើប្រេងកាត ម្ល ប្រេងកូឡាប្រេងដូង ដើម្បីព្យាបាលជំងឺផ្ដាសសាយគ្រុន ឈឺក្បាល ឈឺបំពង់ក ។ល។ | មិនមានភស្តុតាងបែបវិទ្យាសាស្ត្រណាបង្ហាញថាការកោសខ្យល់មានប្រសិទ្ធិភាពទេ។ ការកោសខ្យល់ឱ្យកុមារគឺឈឺចាប់ខ្លាំងណាស់ ព្រោះស្បែករបស់គេទន់ ហើយច្រើនដាច់ស្បែកពេលកោសដែលអាចធ្វើឱ្យឆ្លងរោគ។ ការកោសខ្យល់ក៏នាំឱ្យរលាកស្បែក និងបង្ករឱ្យឡើងសំពាធឈាម ដូច្នេះវាបង្ករគ្រោះថ្នាក់ចំពោះកុមារ។ ការប្រើប្រេងកាតកោសគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះវាកាន់តែធ្វើឱ្យរលាកស្បែកថែមទៀត ហើយចំហាយរបស់វាអាចបង្ករជាជំងឺ និងអាចធ្វើឱ្យកុមារសន្លប់។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ១៨ | ផឹកទឹកដូងត្រាំជន្លេន អាចម៍ក្រៀម និងឆ្អឹងខ្មោចនៅពេលក្តៅខ្លួន ឬកើតកញ្ជ្រឹល | ការដែលឱ្យកុមារផឹកល្បាយនេះ គឺស្មើតែបណ្តាលឱ្យទារកឈឺខ្លាំងដោយសារក្នុងល្បាយនេះពោពេញដោយបាក់តេរី។ ការដែលឱ្យល្បាយនេះទៅកុមារដែលឈឺស្រាប់ផឹកនោះ គឺធ្វើឱ្យជំងឺគ្រុនក្តៅរបស់គេ រឹតតែធ្ងន់ធ្ងរទៅទៀត ហើយកុមារអាចនឹងស្លាប់ទៀតផង។ ការធ្វើបែបនេះគឺមានគ្រោះថ្នាក់ខ្លាំងណាស់។ |
| ១៩ | កញ្ជ្រិល-ថ្នាំត្រជាក់ (សំបកខ្យង ស្នែងក្របី ឬសឈើ) ត្រាំទឹកឱ្យកុមារមុជ ឬដុសឱ្យកុមារផឹក | សូមមើលចម្លើយ ១៨។<br>ការដែលមុជល្បាយនេះមិនសូវគ្រោះថ្នាក់ ដូចការផឹកវាទេ ប៉ុន្តែក៏មិនត្រូវឱ្យទារកមុជវាដែរ ជាពិសេសនៅពេលណាដែលស្បែកទារកដាច់រហែក។ ទារកដែលកើតកញ្ជ្រិលគួរត្រូវព្យាបាលដោយគ្រូពេទ្យ ព្រោះវាជាជំងឺមួយ គ្រោះថ្នាក់ដែលឥឡូវនេះមានវ៉ាក់សាំងការពារហើយ។ |
| ២០ | ចងខ្សែសីម៉ា ពាក់ខ្នង កូនសោនៅក កុំឱ្យកូនកាច និងកើតជំងឺ | ខ្សែសីម៉ាពាក់នៅដៃមិនបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីទេដល់កុមារ បើខ្សែនេះមិនកខ្វក់ ហើយកុមារមិនជញ្ជក់វាទេនោះ ខ្សែសីម៉ាដែលចងជាមួយកូនសោពាក់នៅក គឺមានគ្រោះថ្នាក់ព្រោះ កុមារអាចលេបខ្សែក ឬកូនសោដែលអាចធ្វើឱ្យស្ទះខ្យល់បានយ៉ាងងាយ។ មិនមានភស្តុតាងណាបញ្ជាក់ថាវិធីទាំងនេះអាចបង្ការជំងឺបាននោះទេ។ |
| ២១ | ធ្វើខ្សែដៃដោយភ្ជាប់ក្តៅខ្មៅឆ្អែរឱ្យទារកពាក់ ដើម្បីការពារកុំឱ្យកូនយំ និងកាច | សូមមើលចម្លើយ ២០។<br>ប្រសិនបើទារកដាក់វាចូលក្នុងមាត់ នោះគេនឹងអាចឈឺធ្ងន់ដោយសារតែសាច់ដែលរលួយនោះ ពោរពេញទៅដោយមេរោគ (បាក់តេរី)។ ដូច្នេះហើយវាមានគ្រោះថ្នាក់ណាស់។ ហើយវាមិនបានការពារ ឬរាំងទារកមិនឱ្យយំច្រើន ឬទារកកាចនោះទេ។ |
| ២២ | ពេកកូនឈឺទៅបញ្ជាន់គ្រូ មើលគ្រូ ឬសែនព្រេន | មិនមានភស្តុតាងណាបញ្ជាក់ថាវិធីទាំងនេះបានផលនោះទេ ហើយវិធីទាំងនេះក៏មិនបណ្តាលឱ្យមានអន្តរាយអ្វីដែរ។ ប្រសិនបើគ្រូមិនប្រើសកម្មភាព អ្វីដែលគ្រោះថ្នាក់ ឬធ្វើឱ្យកុមារភ័យខ្លាចទេនោះ។ |
| ២៣ | រៀបសង្ហា - យកវាមកបបរឱ្យកូនហូប | ទារកទើបនឹងកើតមិនគួរឱ្យអ្វីញ៉ាំក្រៅតែពីទឹកដោះម្តាយនោះទេ។ អ្នកខ្លះជឿថាប្រសិន បើម្តាយបរិភោគសុកគឺល្អសម្រាប់ខ្លួនគាត់។ មិនមានភស្តុតាងអ្វីពន្យល់ថានេះជាការពិតនោះទេ ប៉ុន្តែការធ្វើបែបនេះក៏មិនមានគ្រោះថ្នាក់អ្វីដែរ។ ប៉ុន្តែការដែលឱ្យទារកញ៉ាំវាអាចឱ្យមានគ្រោះថ្នាក់។ |

| ល.រ | ជំនឿ | ការពិត |
|---|---|---|
| ២៤ | ទារកទើបកើតមិនគួរឱ្យអ្វីញ៉ាំទេ ត្រូវចាំរហូតទឹកដោះម្ដាយចេញ។ មិនត្រូវឱ្យកូនបៅទឹកដោះព្រៃ ឬទឹកដោះដំបូង (ទឹកពណ៌លឿងដែលចេញពីចុងដោះលើកដំបូង) នោះទេ | ទឹកដោះដំបូង គឺល្អខ្លាំងណាស់សម្រាប់ទារក ហើយវាផ្ដល់អាហារចិញ្ចឹមសំខាន់សម្រាប់រយៈពេល ពីរបីថ្ងៃដំបូងនៃជីវិត បើមិនបានញ៉ាំវាទេ ទារកអាចស្រកទំងន់រហូតដល់កម្រិតគ្រោះថ្នាក់មួយ។ វាក៏ផ្ដល់ផងដែលនូវការការពារដ៏សំខាន់ប្រឆាំងនឹងជំងឺឆ្លង រហូតទាល់តែទារកមានអាយុច្រើនគ្រប់គ្រាន់ដែលអាចទទួលថ្នាំបង្ការជំងឺបាន។ បើសិនពុំបានបៅវាទេ ទារកមានឱកាសខ្ពស់ក្នុងការឆ្លងជំងឺ ដូចជា ខាន់ស្លាក់ គ្រុនស្វិតដៃ ជើង និងក្អកមាន់។ ម្ដាយគួរឱ្យកូនរបស់ខ្លួនបៅឱ្យបានភ្លាមៗ ក្រោយពីកូនកើត |
| ២៥ | ក្មេងកើតថ្ងៃសៅរ៍ត្រូវរៀបសែនព្រេង ព្រោះក្មេងងាយឈឺ (ក្មេងកើតថ្ងៃអង្គារ ច្រើនរឹងរូស) | មិនមានភស្តុតាងណាបញ្ជាក់ជំនឿនេះពិតទេ។ ប៉ុន្តែសកម្មភាពនេះមិនគ្រោះថ្នាក់ដល់កុមារទេ ប្រសិនបើឪពុកម្ដាយ និងគ្រួសារមិនជឿខ្លាំងរហូតដល់ប្រព្រឹត្តដាក់កូន ដូចជារបស់គ្មានតម្លៃទេនោះ។ |
| ២៦ | កុមារចេះដើរមុនខួបគឺមិនល្អ ឬចាប់កុមារកុំឱ្យដើរមុនខួប | តាមធម្មតាកុមារចេះដើរទៅតាមពេលវេលារបស់ខ្លួន ប្រសិនបើគេមិនត្រូវបានបង្ខំឱ្យឈរ ឬឱ្យប្រើឧបករណ៍ជំនួយការដើរឆាប់ទេនោះ។ វាជារឿងធម្មតាទេដែលកុមារចេះដើរក្នុងអាយុចន្លោះពី១០ ទៅ ១៨ ខែ។ មិនគួរបង្ខំឱ្យកុមាររៀនដើរទេ ប៉ុន្តែក៏មិនគួរចាប់គេមិនឱ្យដើរដែរ។ |
| ២៧ | ធ្វើពុតជាលក់កូនទៅឱ្យអ្នកដទៃ បន្ទាប់មកឪពុកម្ដាយទៅទិញកូននោះមកវិញ ដោយសារយើងពិបាកចិញ្ចឹមគេពេក | ជំនឿនេះមិនមែនជាការពិតទេ។ សកម្មភាពនេះមិនមានគ្រោះថ្នាក់អ្វីទេ។ ប៉ុន្តែប្រសិនបើកុមារដឹងរឿងនេះនៅពេលក្រោយមក ពួកគេនឹងគិតថា ខ្លួនត្រូវបានគេ □លក់□។ |
| ២៨ | រៀបការឱ្យកូនពេលបានកូនភ្លោះប្រុសមួយ ស្រីមួយ ព្រោះកាលពីជាតិមុន ពួកគេជាប្ដីប្រពន្ធនឹងគ្នា | ប្រសិនបើពិធីនេះសាមញ្ញនោះមិនមានគ្រោះថ្នាក់អ្វីទេ។ ប៉ុន្តែប្រសិនបើជំនឿនេះត្រូវបានជឿលើសនេះថែមទៀតនោះ វាអាចនាំទៅរកអំពើស្មុនការដែលធ្វើឱ្យប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្ត។ |
| ២៩ | ពេលមានផ្ទៃពោះ ញ៉ាំពងក្ងាន ព្រោះវាធ្វើឱ្យកូនកើតមកឆ្លាត | មិនមានអ្វីដែលជួយម្ដាយមានផ្ទៃពោះ ញ៉ាំទៅជួយឱ្យកូនកាន់តែឆ្លាតនោះទេ។ ការញ៉ាំអាហារឱ្យមានតុល្យភាពល្អ គឺជានាំឱ្យទារកមានសុខភាពល្អបាន។ ស៊ុតគឺជាប្រភេទអាហារមួយសំបូរប្រូតេអ៊ីន មិនថាស៊ុតមាន់ ទា ឬក្ងាននោះទេ។ |
| ៣០ | ផឹកថ្នាំខ្មែរដើម្បីឱ្យងាយស្រួលក្នុងការសម្រាល និងផឹកស្រាថ្នាំក្រោយពេលសម្រាល | នៅពេលមានផ្ទៃពោះ ស្ត្រីមិនគួរញ៉ាំ ឬផឹកអ្វីដែលមិនដឹងថាខាងក្នុងវាមានអ្វីខ្លះនោះទេ។ ចំពោះថ្នាំបុរាណ អាចផឹកបានលុះត្រាតែគ្រូពេទ្យឱ្យផឹក បើមិនដូច្នេះទេ គួរតែជៀសវាងឱ្យបាន។ គ្រោះថ្នាក់នៃការហូបស្រាក្នុងកំឡុងពេលមានផ្ទៃពោះ និងនៅពេលបំបៅដោះកូនត្រូវបានគេសិក្សាយ៉ាងច្បាស់លាស់។ ការធ្វើបែបនេះ អាចបណ្ដាលឱ្យខូចខួរក្បាលកុមារ និងធ្វើឱ្យឡើងសម្ពាធឈាមរបស់ម្ដាយ។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ៣១ | កុំញ៉ាំច្រើនកំពុងពេលមានផ្ទៃពោះ | ស្ត្រីមានផ្ទៃពោះគួរបរិភោគអាហារដែលមានសារជាតិចិញ្ចឹមឱ្យបានគ្រប់គ្រាន់។ គាត់មិនគួរកាត់បន្ថយការបរិភោគចំណីអាហាររបស់ខ្លួនទេ បើមិនដូច្នេះទេវាអាចបណ្តាលឱ្យមានការខ្វះជីវជាតិចំពោះខ្លួនគាត់ និងកូនគាត់។ ហើយគាត់ក៏មិនគួរបរិភោគអាហារច្រើនពេកនោះដែរ។ |
| ៣២ | ពេលកើតកូន ម្តាយត្រូវផឹកទឹកនោមជាមួយម្រេច | ការផឹកទឹកនោមអាចមានគ្រោះថ្នាក់ ព្រោះវាជាសារធាតុបញ្ចេញចោល និងអាចផ្ទុកជាតិប្រៃ និងជាតិអំបិលកម្រិតខ្ពស់ដែលអាចបំផ្លាញតម្រងនោម និងវាអាចផ្ទុកនូវបាក់តេរី ប្រសិនបើវាជាទឹកនោមរបស់ខ្លួនគាត់ ហើយគាត់ផឹកវា ដោយលាយជាមួយទឹកសុទ្ធបន្ទាប់ពីគាត់នោមភ្លាមៗ គឺឱកាសនៃគ្រោះថ្នាក់មានតិចតួច។ ទឹកនោមមិនអាចព្យាបាលជំងឺបានទេ។ |
| ៣៣ | យកទឹកនោមកូន ជូតអណ្តាតពួកគេដើម្បីកុំឱ្យកើតច្រាំង | |
| ៣៤ | ក្មេងចាំជាតិត្រូវហូបពងមាន់ | ការជឿលើការចាប់ជាតិឡើងវិញ គឺមិនគ្រោះថ្នាក់ចំពោះអ្នកណាម្នាក់ទេ។ |
| ៣៥ | ពេលមានផ្ទៃពោះកុំឱ្យឈោងខ្ពស់ ឬលើករបស់ធ្ងន់ឬពិបាកចិត្តនិងមិនហូបម្ហូបហិល | អនុសាសន៍ទាំងនេះ មានមូលដ្ឋានពិតប្រាកដ ផ្អែកតាមការសិក្សាស្រាវជ្រាវលក្ខណៈវេជ្ជសាស្ត្រ និងត្រឹមត្រូវ។ ការចាក់ថ្នាំការពារ ពិនិត្យផ្ទៃពោះ ហូបវិតាមីនបន្ថែម និងពិភាក្សាជាមួយពេទ្យដើម្បីឱ្យកូនមានសុខភាពល្អ។ |
| ៣៦ | ស្ត្រីមានផ្ទៃពោះ ត្រូវរស់នៅក្នុងបរិយាកាសល្អ រីករាយ និងមានផាសុខភាពក្នុងគ្រួសារ | ប្រសិនបើស្ត្រីមានផ្ទៃពោះមានអារម្មណ៍សុវត្ថិភាព និងរីករាយ នោះនាងនឹងមិនសូវមានការតានតឹងចិត្ត ដូច្នេះអ្នកមានផ្ទៃពោះ និងកូនមានសុខភាពល្អ។ |
| ៣៧ | ពេលម្តាយមានផ្ទៃពោះត្រូវមើលរូបស្អាត និយាយពាក្យល្អៗ ឬនិទានរឿង ឱ្យកូននៅក្នុងផ្ទៃស្តាប់ | ការសិក្សាស្រាវជ្រាវបានបង្ហាញថា ទារកដែលនៅក្នុងផ្ទៃអាចស្តាប់លឺ ប៉ុន្តែមិនយល់អត្ថន័យនៃពាក្យនោះទេ។ ហើយអាចទទួលអារម្មណ៍តាមរយៈផ្លូវចិត្តរបស់ម្តាយ។ ដូច្នេះការនិយាយដោយទន់ភ្លន់ និងដោយស្ងប់ស្ងៀមប្រាកដជាជួយទាំងម្តាយ និងទារក ។ |
| ៣៨ | ពេលមានផ្ទៃពោះកុំស្តាប់គេនិយាយពាក្យអាក្រក់ៗ កុំមើលរូបភាពអាក្រក់ ឬរឿងខ្មោច កុំឱ្យចូលរួមបុណ្យសព ហែរអ្នកតា ព្រោះវាជារឿងសំណាងអាក្រក់ | សូមមើលព័ត៌មាន ៣៧ |
| ៣៩ | កុំឱ្យអង្គុយមាត់ជណ្តើរខ្លាចពិបាកកើតកូន | ការដែលម្តាយមានលទ្ធភាពក្នុងការអង្គុយចោងហោងនោះ វានឹងអាចជួយឱ្យការសម្រាលកូនបានងាយស្រួល។ ដូច្នេះវាពុំមានការពិតទេនៅក្នុងជំនឿនេះ។ |
| ៤០ | ពេលស្ត្រីមានផ្ទៃពោះ ទៅទិញឥវ៉ាន់មុនគេ (កៅឆាយ) ត្រូវដុតក្រដាសដើម្បីបណ្តេញចង្រៃចេញ | ការជឿបែបនេះ គឺមានការរើសអើងចំពោះស្ត្រីមានផ្ទៃពោះ និងធ្វើឱ្យមានការរំខានដល់ចិត្ត និងការស្ងប់ស្ងាត់ដែលត្រូវការចាំបាច់សម្រាប់ឱ្យស្ត្រី និងទារកមានសុខភាពល្អ ។ |
| ៤១ | នៅពេលទារកកើតមក ធ្វើឱ្យក្នុងគ្រួសារមានបញ្ហាច្រើនគឺជា កូនចង្រៃ | ទារកទើបនឹងកើតដែលមានសុខភាពល្អ ជាទូទៅត្រូវបានគេស្វាគមន៍ឱ្យចូលមកនៅក្នុងគ្រួសារ ហើយចាត់ទុកថានេះជាពរជ័យទៅវិញទេ ទោះបីជាមានរឿងហេតុការអ្វីកើតឡើងក៏ដោយ។ |

| លរ | ជំនឿ | ការពិត |
| --- | --- | --- |
| ៤២ | កូនស្រីដូចប្រហុក កូនប្រុសដូចមាសទឹកដប់ | ពាក្យស្លោកណាដែលបែងចែកអំពីភេទ ដោយភាពអវិជ្ជមាន នោះវានឹងធ្វើឱ្យមានគ្រោះថ្នាក់ផ្នែកផ្លូវចិត្តរបស់កុមារ ដោយសារតែការរើសអើង និងលទ្ធផលនៃការបែងចែកនោះ ។ |
| ៤៣ | កូនប្រុសហួចលើផ្ទះមិនល្អ | សូមមើលចម្លើយ ៤២ |
| ៤៤ | កូនស្រីបង្វិលចង្ក្រានមិនជុំ | សូមមើលចម្លើយ ៤២។<br>កូនស្រីមានលទ្ធភាពធ្វើការងារជាច្រើនទៀត ជាជាងធ្វើតែការងារនៅចង្ក្រានបាយ ហើយកូនប្រុសក៏មានលទ្ធភាពធ្វើការងារនៅចង្ក្រានបាយដែរ។ |
| ៤៥ | កូនប្រុសត្រូវតែក្លាហាន មិនត្រូវស្រក់ទឹកភ្នែក | សូមមើលចម្លើយ ៤២ ។ កូនប្រុសក៏មានអារម្មណ៍ដូចគ្នាទៅនឹងកូនស្រីដែរ ដូច្នេះ កូនប្រុសគួតែត្រូវបានគេលើកទឹកចិត្តឱ្យបញ្ចេញអារម្មណ៍ទាំងនោះ។ |
| ៤៦ | កូនស្រីកុំដើរ ឬនិយាយខ្លាំងៗព្រោះវាអត់ល្អទេ | សូមមើលចម្លើយ ៤២។ ការដាក់កម្រិតដូច្នេះលើស្ត្រីគឺជាការពង្រឹងនូវការវាយតម្លៃទូទៅរបស់សង្គម ភាពអាម៉ាស និងការរើសអើង ។ |
| ៤៧ | ក្មេងប្រុសរៀនច្រើនហៅថាអាញី អាខ្ទើយខ្ទរ | សូមមើលចម្លើយ ៤២។ អត្តចរិតជាលក្ខណៈជីវសាស្ត្រ ។ មនុស្សទាំងពីរភេទអាចមានលក្ខណៈរៀនដូចគ្នា។ វាមិនមែនមានន័យថាគេខ្ទើយដូចគ្នានោះទេ ។ |
| ៤៨ | ក្មេងប្រុសត្រូវលេងរបស់ប្រុស ក្មេងស្រីត្រូវលេងរបស់ស្រី | សូមមើលចម្លើយ ៤២ ។ គំនិតដែលថា របស់លេងនេះសម្រាប់ក្មេងប្រុស គឺជាគំនិតមួយដែលកំណត់ឡើងដោយសង្គម។ កុមារគ្រប់រូបគួរតែផ្តល់ឱកាស និងលើកទឹកចិត្តលេងរបស់លេងគ្រប់ប្រភេទមិនថាសម្រាប់ក្មេងប្រុស ឬក្មេងស្រីនោះទេ។ កុមារកើតមកគឺមានចំណង់ផ្លូវភេទរួចទៅហើយ អំពីថាតើគេស្រឡាញ់ភេទដូចគ្នា ឬខុសគ្នានោះ។ ពុំមានការទាក់ទងរវាងការចូលចិត្តភេទដូចគ្នា ជាមួយនឹងរបស់ដែលកុមារលេងនោះទេ។ |
| ៤៩ | ក្មេងស្រីត្រូវធ្វើការងារផ្ទះ ប្រុសធ្វើការងារប្រុស ដូចជាស្រែចំការជាដើម ។ | សូមមើលចម្លើយ ៤២។ ការកំណត់ឱ្យមនុស្សធ្វើការទៅតាមតួនាទីយេនឌ័រដែលកំណត់ដោយសង្គមនោះ គឺបានកម្រិតពីបទពិសោធន៍របស់គេ ហើយនិងលើកទឹកចិត្តឱ្យមានការរើសអើង។ |
| ៥០ | កូនស្រីហួចចង្រៃ ហើយបើច្រៀងនៅក្នុងចង្ក្រាននឹងបានប្តីចាស់ | សូមមើលចម្លើយ ៤២។ |
| ៥១ | ក្មេងប្រុសស្រាតក៏មិនអីដែរ កុំឱ្យតែស្រី | កុមារទាំងពីរភេទ ចូលចិត្ត និងសប្បាយរីករាយនឹងសេរីភាពក្នុងការរត់ដោយមិនមានសំលៀកបំពាក់ឱ្យតែគេនៅក្នុងបរិស្ថានមួយដែលមានសុវត្ថិភាព និងមានអ្នកថែទាំដែលគួរឱ្យជឿទុកចិត្តបាន សកម្មភាពនេះ គឺធ្វើឱ្យគេសប្បាយ និងមានសុខភាពល្អ។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ៥២ | ក្មេងស្រីមានរូបរាងនៃប្រដាប់ភេទផ្សេងៗគ្នា ហើយគេមានសំណាង ឬអត់សំណាង (តណ្ហាក្រាស់) គឺអាស្រ័យទៅលើរូបរាងនៃប្រដាប់ភេទទាំងនោះ | ពុំមានភស្តុតាងណាដែលអះអាងនូវជំនឿទាំងនេះទេ។ វាមិនមានគ្រោះថ្នាក់ដល់កុមារទេ បើសិនជាពុំមានការរំពឹងទុកឱ្យកុមារីនោះបានដូចអ្វី (វាសនា) ដែលគេទស្សទាយនោះទេ។ តែការធ្វើនេះអាចឱ្យមានគ្រោះថ្នាក់ដល់ផ្លូវចិត្តរបស់កុមារ ហើយវាជាការសំខាន់ណាស់ក្នុងការដែលយើងមិនត្រូវបញ្ចេញប្រដាប់ភេទរបស់កុមារដោយគ្មានការចាំបាច់នោះឡើង ដូចជាអ្វីដែលបានធ្វើនៅក្នុងជំនឿនេះជាដើម។ |
| ៥៣ | ការលេងប្រដាប់ភេទរបស់កុមារជាពិសេសកុមារាគឺជាសញ្ញានៃការបង្ហាញការស្រឡាញ់ជិតស្និត | គ្រោះថ្នាក់ចំពោះសកម្មភាពនេះគឺថា កុមារគិតថាការធ្វើនេះជាអាកប្បកិរិយាធម្មតា ហើយមិនអាចមានលទ្ធភាពក្នុងការបែងចែកបានទេនៅពេលដែលមានការរំលោភបំពានកើតឡើង។ ហើយវាក៏បង្កឱ្យជនល្មើសមានលេសក្នុងការរំលោភបំពានផងដែរ ។ |
| ៥៤ | ការឱ្យក្មេងលេងទឹកភ្លៀង ឬលេងដី គឺធ្វើឱ្យគេសាំុនឹងជំងឺ និងមិនចាញ់ជំងឺ | ការលេងនៅក្រៅផ្ទះ គឺធ្វើឱ្យកុមារមានសុខភាពល្អ។ ក៏ប៉ុន្តែការដែលឱ្យកុមារនៅហាលភ្លៀង និងមានធូលីច្រើនហួសហេតុពេកអាចនាំឱ្យមានជំងឺបាន ។ |
| ៥៥ | ឱ្យក្មេងរៀនកុំឱ្យវាលេងព្រោះគ្មានប្រយោជន៍ | កុមារមានសិទ្ធក្នុងការលេង (អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ)។ កុមារត្រូវការលេង។ ការលេងវាសំខាន់ណាស់សម្រាប់ការរៀនរបស់គេ។ ការលេងគឺជារបៀបដែលកុមាររៀន។ |
| ៥៦ | ការបន្លាចក្មេង ដើម្បីកុំឱ្យពួកគេទៅកន្លែងណាមួយ | ការបន្លាចកុមារទោះជាមានហេតុផលអ្វីក៏ដោយ វាគឺជាការរំលោភបំពានផ្លូវចិត្តដល់កុមារ។ យើងអាចបង្រៀនកុមារឱ្យនៅឆ្ងាយពីអ្វីៗដែលមិនមានសុវត្ថិភាពបានដោយមិនចាំបាច់ ប្រើប្រាស់វិធីបំភ័យនេះឡើយ ។ |
| ៥៧ | បង្រៀនឱ្យក្មេងមិនទទួលយកការបរាជ័យដែលនាំឱ្យអាម៉ាស់ដល់គ្រួសារ | កុមារត្រូវការលើកទឹកចិត្ត មិនមែនការធ្វើឱ្យអាម៉ាស់ ឬការស្តីបន្ទោសនោះទេ ព្រោះវានាំឱ្យមានគ្រោះថ្នាក់ដល់ផ្លូវចិត្តរបស់កុមារ។ |
| ៥៨ | និយាយថា កូនឆ្លាត កូនល្អ កូននាំសំណាងឱ្យឪពុកម្តាយ | ជំនឿនេះគឺមានន័យថាកុមារដែលមិនសូវឆ្លាតនឹងមានអារម្មណ៍ថាខ្លួនត្រូវបានគេមិនរាប់រក ឬគិតថាខ្លួនជាមនុស្សអន់។ កុមារមានលទ្ធភាពក្នុងការធ្វើអ្វីឱ្យបានសម្រេចដោយល្អបំផុត និងដោយអស់ពីសមត្ថភាពរបស់គេនោះ លុះត្រាតែពួកគេត្រូវបានគេលើកទឹកចិត្ត និងមានអារម្មណ៍ថាខ្លួនត្រូវបានគេស្រឡាញ់ ។ |
| ៥៩ | ត្រូវមានមេត្តាករុណាចំពោះកូន និងផ្តល់ឱកាសឱ្យកូន | ជំនឿនេះត្រូវជាមួយនឹងភស្តុតាងបែបវិទ្យាសាស្ត្រ អំពីការចិញ្ចឹមកូនឱ្យមានសុខភាពល្អ និងសប្បាយរីករាយ ។ |
| ៦០ | ត្រូវស្វែងយល់ពីអារម្មណ៍របស់កូន ពេលគាត់ត្រូវការអ្វីមួយ ? | សូមមើលចម្លើយ ៦០។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ៦១ | ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់លេង និងនៅជាមួយកូនដើម្បីផ្តល់ភាពកក់ក្តៅ | សូមមើលចម្លើយ ៦០។ |
| ៦២ | ថែទាំ ការពារ និងយកចិត្តទុកដាក់ពេលកូនឈឺ ជួយបង្រៀន និងអប់រំកូន | សូមមើលចម្លើយ ៦០។ |
| ៦៣ | កុមារជាទំពាំងស្នងឫស្សី | កុមារ គឺជាអនាគតរបស់យើង ហើយគេនឹងជំនួសឱ្យមនុស្សធំទៅថ្ងៃក្រោយ |
| ៦៤ | ក្មេងត្រូវតែគោរព និងធ្វើតាមចាស់ទុំ | បើសិនជាយើងរំពឹងឱ្យកុមារគោរព និងធ្វើអ្វីៗតាមយើងនោះ យើងត្រូវតែគោរពគេ និងស្តាប់ពួកគេសិន ហើយត្រូវសម្តែងអាកប្បកិរិយាគោរពដែលជាគំរូសម្រាប់គេ។ |
| ៦៥ | ពត់ដែកទាន់នៅក្តៅ ប្រដៅកូនចៅទាន់នៅក្មេង | កុមាររៀនតាំងតែពីគេនៅក្មេងមកម្ល៉េះ។ ប្រសិនបើយើងប្រព្រឹត្តដាក់គេដោយភាពយុត្តិធម៌ ភាពកក់ក្តៅ និងផ្តល់នូវការណែនាំដល់គេតាំងតែពីគេនៅក្មេងនោះ គេនឹងរៀនធ្វើនូវអាកប្បកិរិយាដែលសមរម្យទាំងនោះ។ ហើយប្រសិនបើយើងប្រព្រឹត្តដាក់គេដោយភាពកាចសាហាវ មិនយុត្តិធម៌ នោះគេនឹងរៀនក្លាយទៅជាកាចសាហាវ ហើយវានឹងមានការលំបាកក្នុងការបង្រៀនគេនូវអាកប្បកិរិយាសមរម្យនៅពេលដែលគេកាន់តែធំ ។ |
| ៦៦ | ក្មេងទាល់តែប្រើធម៌ក្តៅដើម្បីអប់រំ និងប្រដៅពួកគេ (ប្រើហឹង្សា ដូចជា វាយដំ គំរាមកំហែង ស្រែកសំឡុត ជេរ ស្តី បន្ទោស។) | នេះមិនមែនជាការប្រដៅទេ វាជាការរំលោភបំពាន។ កុមារនឹងទទួលរងគ្រោះទាំងផ្នែក ផ្លូវកាយ និងផ្លូវចិត្តដោយសារការប្រើនូវវិធីសាស្ត្រនេះ។ |
| ៦៧ | វិធីសាស្ត្រដែលល្អក្នុងការកែប្រែកុមារ គឺ វាយ ស្តី បន្ទោស ជេរ | សូមមើលចម្លើយ ៦៦ និង ៦៧។ |
| ៦៨ | ក្មេងកុំតបតជាមួយមនុស្សចាស់ ត្រូវតែស្តាប់មនុស្សចាស់ ។ | កុមារមានសិទ្ធិក្នុងការបញ្ចេញមតិ ចូលរួម និងការទទួលបានព័ត៌មាន (អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ) ដូច្នេះប្រសិនបើមនុស្សធំ លើកទឹកចិត្តកុមារឱ្យសួរសំណួរ ហើយស្តាប់យោបល់កុមារ នោះកុមារនឹងលូតលាស់ទៅជាមនុស្សដែលមានអារម្មណ៍ល្អចំពោះខ្លួនឯង និងមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត ។ |
| ៦៩ | ក្មេងមិនត្រូវសួរ ឆ្ងល់ ឬកុំចង់ដឹងច្រើនពេកទេ | សូមមើលចំលើយ ៦៩។ |
| ៧០ | ក្មេងមិនសូវចេះឈឺចាប់ទេ ដឹងតែពីស៊ី (មិនដឹងខ្យល់អីទេ) | កុមារមានអារម្មណ៍ឈឺចាប់និងអារម្មណ៍ផ្សេងទៀតដូចមនុស្សចាស់ដែរ។ហើយអារម្មណ៍ទាំងនោះគួរតែត្រូវបានគេទទួលស្គាល់ ដើម្បីឱ្យគេមានសុខភាពផ្លូវចិត្តល្អ ។ |

| លរ | ជំនឿ | ការពិត |
|---|---|---|
| ៧១ | ក្មេងល្ងង់មិនសូវគិតជ្រៅទេ | ការដែលលាបពណ៌ឱ្យកុមារថាជាក្មេងល្ងង់នោះគឺជាការរំលោភបំពានផ្លូវចិត្ត។ |
| ៧២ | ក្មេងមិនត្រូវដឹងរឿងរបស់មនុស្សចាស់ទេ | ខណៈពេលដែលមានរឿងខ្លះដែលមនុស្សធំពិភាក្សាអាចហួសពីសមត្ថភាពយល់ដឹងរបស់កុមារ ឬក៏អាចធ្វើឱ្យគេមិនសប្បាយចិត្តដោយគ្មានការចាំបាច់នោះ កុមារចូលចិត្តឱ្យគេបញ្ចូលខ្លួនទៅក្នុងការពិភាក្សារបស់ក្រុមគ្រួសារ និងគេអាចរៀនបានតាមរយៈការធ្វើដូច្នេះ។ |
| ៧៣ | កុំសរសើរក្មេងនាំឱ្យពួកគេបានចិត្ត | កុមារត្រូវការការលើកទឹកចិត្តដើម្បីឱ្យពួកគេមានការអភិវឌ្ឍនូវការឱ្យតម្លៃខ្លួនឯងបានល្អ។ |
| ៧៤ | និយាយឱ្យកុមារឈឺចាប់ដើម្បីឱ្យកុមារខំប្រឹង (ជេរ ស្តី បន្ទះបង្អាប់ ឬប្រៀបធៀប) | ការបន្ទះបង្អាប់ ធ្វើឱ្យទាបថោកគឺជាទម្រង់មួយនៃការរំលោភបំពានផ្លូវចិត្ត ហើយវាក៏មិនធ្វើឱ្យកុមារខំប្រឹងនោះទេ ផ្ទុយទៅវិញគឺវាធ្វើឱ្យកុមារបាក់ទឹកចិត្ត និងបំផ្លាញនូវការឱ្យតម្លៃខ្លួនរបស់ពួកគេ។ |
| ៧៥ | ទុកក្មេងចោល ដោយមិនយកចិត្តទុកដាក់ដើម្បីឱ្យគេកែអាកប្បកិរិយារបស់គេ | នេះគឺជាទម្រង់មួយនៃការរំលោភបំពានផ្លូវចិត្ត។ មានពេលខ្លះមានប្រយោជន៍ក្នុងការមិនអើពើចំពោះ អាកប្បកិរិយា មួយចំនួនដូចជា ការយំឡាំប៉ាជាដើម។ តែការមិនយកចិត្តទុកដាក់ និងការមិនផ្តល់ក្តីស្រឡាញ់ស្និតស្នាលគឺធ្វើឱ្យមានគ្រោះថ្នាក់ដល់កុមារ។ |
| ៧៦ | ពេលកុមារជួបការពិបាក កុំជួយវាដើម្បីឱ្យក្មេងមានភាពរឹងមាំ | កុមារត្រូវការការណែនាំ។ កុមារអាចរៀនដោះស្រាយបញ្ហាដោយខ្លួនឯងបានលុះត្រាតែពួកគេត្រូវបានគេបង្រៀនអំពីវិធីដោះស្រាយបញ្ហា តាំងពីពេលគេនៅពីក្មេងមក។ |
| ៧៧ | ពេលក្មេងរពិស ថាក្មេងមិនល្អ (បំផ្លាញ) | កុមាររៀនតាមរយៈការស្វែងយល់ និងការលេង។ នេះជាសកម្មភាពធម្មតាដែលនាំឱ្យកុមារមានសុខភាព ទាំងផ្លូវកាយ និងផ្លូវចិត្ត។ |
| ៧៨ | ត្រូវមានហេតុផល មុនពេលវាយកូន | មនុស្សធំមិនត្រូវវាយកុមារឡើយទោះជាមានហេតុផលអ្វីក៏ដោយ។ ការវាយកុមារ គឺជាទម្រង់មួយនៃការរំលោភបំពាន។ |
| ៧៩ | គ្រប់គ្រងអាកប្បកិរិយាមិនល្អដោយការដាក់ទណ្ឌកម្ម (ញ៉ឹងស្លឹកត្រចៀក ខោកក្បាល បង្អត់បាយ ចងដៃជើងដាក់អង្រួង ឬស្រមោច ចាប់បោក ទាត់ លត់ជង្គង់លើសំបកខ្នុរ ឈរហាលថ្ងៃ ឈរជើងមួយជាដើម) | គ្រប់សកម្មភាពទាំងនេះ គឺសុទ្ធតែជាការរំលោភបំពានលើកុមារ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ អាកប្បកិរិយាទាំងនេះនឹងធ្វើឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់កុមារ ទាំងផ្លូវចិត្ត និងផ្លូវកាយ ជាពិសេសនៅពេលគេប្រើវាជាបន្តបន្ទាប់។ |
| ៨០ | កូនគោរពចាស់ទុំ ស្លូត សុភាពរាបសារ ជួយការងារផ្ទះខិតខំរៀនសូត្រ មិនចេះដើរលេង ហៅថាកូនល្អ | មនុស្សធំត្រូវតែអនុញ្ញាតឱ្យកុមារលេង ដើម្បីឱ្យគេអភិវឌ្ឍទៅជាមនុស្សធំដែលមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត។ |

| លរ | ជំនឿ | ការពិត |
| --- | --- | --- |
| ៨១ | ពូជហ្មែងអញ្ចឹង | អាកប្បកិរិយាមិនមែនទទួលបានមកពីតំណពូជនោះទេ លើកលែងតែរោគសញ្ញានៃជម្ងឺមួយចំនួន។ អាកប្បកិរិយា គឺបានមកពីការរៀន និងការប្រព្រឹត្តរបស់មនុស្សចាស់។ |
| ៨២ | កូនអាក្រក់មកពីសារជាតិវាអាក្រក់ ហើយមិនអាចកែវាបានទេ។ | សូមមើលចម្លើយ ៨១។<br>អាកប្បកិរិយាអាចផ្លាស់ប្តូរបានតាមរយៈ ការធ្វើជាគំរូ និង ការណែនាំ។ |
| ៨៣ | ក្មេងមិនត្រូវនិយាយកុហក ឬនិយាយអាក្រក់ពីមនុស្សចាស់ឡើយ ។ | សូមមើលចម្លើយ ៨២។<br>កុមារអាចរៀនបាននូវអាកប្បកិរិយា និងការប្រព្រឹត្តទាំងនេះ ពីមនុស្សជុំវិញខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏កុមារជាច្រើន ដែលទៀងត្រង់ និងគោរពមនុស្សធំ ដែលចេះគោរព និងឱ្យតម្លៃពួកគេ ។ |
| ៨៤ | ក្មេងស៊ីកន្ទុយត្រី ចុងអំពៅ ចេះហែលទឹក | របបអាហារមិនប៉ះពាល់ដល់សមត្ថភាពរបស់កុមារក្នុងការហែលទឹកទេ។ មនុស្សយើងត្រូវការរៀនដើម្បីអាចធ្វើអ្វីមួយបាន ។ |
| ៨៥ | ក្មេងលេងច្រើន វានឹងខូច | សូមមើលចម្លើយ ៥៥។ |
| ៨៦ | ក្មេងអត់របប (ពេលកុមារសុំអ្វីៗរបស់អ្នកដទៃញ៉ាំ) | វាជារឿងធម្មជាតិសម្រាប់កុមារដែលឃ្លាន ហើយចង់ញ៉ាំពេលឃើញអ្នកដទៃញ៉ាំ។ ទោះបីជានៅពេលកុមារមិនឃ្លានក៏ដោយ ក៏កុមារនៅតែចាប់អារម្មណ៍នូវរាល់សកម្មភាពដែលអ្នកដទៃទៀតធ្វើ។ |
| ៨៧ | ពេលកុមារវាយចាញ់គេ វាយកុមារនោះថែមទៀត | ការវាយដំលើកុមារគឺជាការរំលោភបំពាន។ ការដាក់ទណ្ឌកម្ម អ្នកចាញ់ គឺលើកទឹកចិត្តឱ្យកាន់តែមានការវាយតប់ និងអំពើកាចសាហាវ។ |
| ៨៨ | កោងធ្វើកង់ ត្រង់ធ្វើកាំ។ | កុមារទាំងអស់សុទ្ធតែខុសៗគ្នា ហើយគេមានភាពខ្លាំងលើផ្នែកខុសៗគ្នា។ កុមារម្នាក់ៗគឺសុទ្ធតែមានអ្វីៗដែលសំខាន់សម្រាប់ចូលរួមចំណែកនៅក្នុងពិភពលោកនេះ។ |
| ៨៩ | រលកក្រោយច្រានរលកមុខ | កុមារ គឺជាមនុស្សធំនៅជំនាន់ក្រោយ ។ |
| ៩០ | ពេលស្លាប់ទៅកុំកប់ក្បែរក្មេង | ពុំមានភស្តុតាងបែបវិទ្យាសាស្ត្រដើម្បីគាំទ្រជំនឿនេះទេ ក៏ប៉ុន្តែវាក៏មិនមានគ្រោះថ្នាក់អ្វីដល់កុមារទេ។ |

## រូបភាពទី ១




# ការពិនិត្យសុខភាព
# អំឡុងពេលមានផ្ទៃពោះ

រូបភាពទី ២



# ការបំបៅដោះកូន

## រូបភាពទី ៣



# ការចុះសំបុត្រកំណើត

រូបភាពទី ៤



# ការថែទាំសុខភាពកូន

# រូបភាពទី ៥



# ការកំណត់គោលដៅ
# រយៈពេលវែង

## រូបភាពទី ៦



# ការការពារ និងសុវត្ថិភាព នៃការលេង

## រូបភាពទី ៧



# ការធ្វើជាគំរូល្អ

# រូបភាពទី ៨



# ការផ្តល់ឱកាស

## រូបភាពទី ៩



# ការបង្រៀន និងអប់រំ

## រូបភាពទី ១០



# ការផ្តល់ភាពកក់ក្តៅ និងក្តីស្រឡាញ់

## រូបភាពទី ១១



# ការធ្វើការងារផ្ទះ

## រូបភាពទី ១២



# ការរស់នៅចុះសម្រុងគ្នា

## រូបភាពទី ១៣



# អាកប្បកិរិយា និងឥរិយាបថល្អ

## រូបភាពទី ១៤



# ការអនាម័យខ្លួនប្រាណ

## រូបភាពទី ១៥



# ការដោះស្រាយទំនាស់

## រូបភាពទី ១៦



# ការថែទាំសុខភាព

## រូបភាពទី ១៧



# ការស្តាប់ដំបូន្មានឪពុកម្តាយ

# រូបភាពទី ១៨



# ការរៀនសូត្រ

## រូបភាពទី ១៩



# អាហារូបត្ថម្ភ

## រូបភាពទី ២០



# ការរៀនបំណិនជីវិត

## រូបភាពទី ២១



# ការលេង

# វគ្គទី៦
## មេរៀនទី៥៖ របៀបនៃការចិញ្ចឹមកូន

## សេចក្ដីផ្ដើម

ការស្វែងយល់ពីរបៀបនានានៃការចិញ្ចឹមកូន មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ដើម្បីវិភាគ និងឆ្លុះបញ្ចាំងនូវរាល់ទង្វើ ឬសកម្មភាពនៃការចិញ្ចឹមកូនដែលពួកគាត់បានទទួលពីឪពុកម្ដាយ និងការអនុវត្តរបៀបចិញ្ចឹមកូនរបស់ពួកគាត់ជាមួយកូនៗក្នុងពេលបច្ចុប្បន្ននេះផងដែរ។ ការវិភាគ និងការឆ្លុះបញ្ចាំងពីរបៀបនៃការចិញ្ចឹមកូនពីជំនាន់មួយទៅជំនាន់មួយទៀត អាចជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបានដឹងពីផលប៉ះពាល់នៃរបៀបចិញ្ចឹមកូន និងការជ្រើសរើសរបៀបនៃការចិញ្ចឹមកូនប្រកបដោយគុណភាព និងមានប្រសិទ្ធភាព។ របៀបនៃការចិញ្ចឹមកូនដែលមានប្រសិទ្ធភាព គឺអាចជួយពង្រឹង និងធ្វើឱ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនងរវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ និងសមាជិកដទៃទៀតនៅក្នុងគ្រួសារ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកកាត់បន្ថយ ឬបញ្ឈប់អំពើហិង្សា និងការមិនអើពើនៅក្នុងគ្រួសារ។ ម្យ៉ាងទៀតយើងក៏អាចជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមកូន ដែលជួយដល់ការសម្រេចបាននូវគោលដៅរយៈពេលវែង ដោយមិនមានការរំពឹងដល់កូនថា នឹងមើលថែទាំនៅពេលដែលពួកគាត់ចាស់ជរា ដើម្បីជាកិច្ចតបស្នងសងគុណ។

យោងទៅតាមហេតុផលខាងលើ យើងសង្កេតឃើញថា របៀបនៃការចិញ្ចឹមកូនប្រកបដោយគុណភាព គឺពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ ដែលអាចឱ្យកូន ឬកុមាររស់នៅប្រកបដោយភាពរីករាយ កក់ក្ដៅ និងមានសុភមង្គលជាមួយក្រុមគ្រួសារហើយពួកគេនឹងក្លាយទៅជាមនុស្សពេញវ័យដែលមានសុខុមាលភាពល្អ និងមាំមួន បើទោះជាគ្រួសារមានជីវភាពលំបាកយ៉ាងណាក៏ដោយ។

| គោលបំណង | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• កំណត់ពីអត្ថន័យ នៃការចិញ្ចឹមកូនបែបវិជ្ជមាន<br>• ស្វែងយល់ពីរបៀបផ្សេងៗគ្នានៃការចិញ្ចឹមកូន<br>• វិភាគនូវអាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ ហើយបន្តអនុវត្តនូវអាកប្បកិរិយាដែលគួរធ្វើ និងផ្លាស់ប្ដូរនូវអាកប្បកិរិយាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ ( បានពិភាក្សារួចមកហើយ នៅក្នុងជំនួបដំបូង )<br>• ស្វែងយល់ពីភាពខុសគ្នារវាង ការដាក់ទណ្ឌកម្ម និងការអនុវត្តវិន័យ។ |
|---|---|

**រយៈពេល**

**១២០ នាទី**

**សម្ភារៈដែលត្រូវការ**

- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- កម្រាលសម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ

**ខ្លឹមសារលម្អិត**

## I. កាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី)

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ មានកាតព្វកិច្ចចាប់តាំងពីកូនបង្កកំណើតរហូតដល់ពេញវ័យ។

### ១. ការពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ

ក្នុងអំឡុងពេលមានផ្ទៃពោះ គួរធ្វើការពិគ្រោះយោបល់ និងពិនិត្យសុខភាពឱ្យបាន ៤ដង និងចាក់ថ្នាំបង្ការដើម្បីជួយឱ្យទារកក្នុងផ្ទៃមានសុខភាពល្អ។ នៅពេលដែលកូនចាប់កំណើត ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវយកចិត្តទុកដាក់ថែបំប៉នសុខភាពអ្នកមានផ្ទៃពោះ ដោយគិតទៅដល់របបអាហារដែលផ្តល់នូវសុខភាពល្អសម្រាប់ខ្លួនឯង និងទារកក្នុងផ្ទៃ ដោយជៀសវាងការប្រើគ្រឿងញៀន ហ្វបបារី និងប្រើគ្រឿងស្រវឹង ដែលនាំឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់ទារកក្នុងផ្ទៃ។ ម៉្យាងទៀតឪពុកម្ដាយត្រូវព្យាយាមនិយាយលេង ស្ទាបអង្អែលជាមួយទារកក្នុងផ្ទៃដោយក្ដីស្រឡាញ់ ថ្នាក់ថ្នម និងស្វែងរកកន្លែងដែលមានសុវត្ថិភាពក្នុងពេលសម្រាលកូន (ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក) ដែលមានឆ្មប ឬពេទ្យជំនាញ។

### ២. ការបំបៅដោះកូន

បន្ទាប់ពីសម្រាលកូនរួច ឪពុកម្ដាយ ត្រូវផ្តល់ឱ្យកូននូវភាពកក់ក្ដៅ ក្ដីស្រឡាញ់ និងយកចិត្តទុកដាក់ក្នុងការថែទាំទារក ដោយផ្តល់ទឹកដោះដំបូង និងបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខរយៈពេល ៦ខែ ឬបន្តការបំបៅដោះកូន រហូតដល់អាយុ ២ឆ្នាំ។

## ៣. ការចុះសំបុត្រកំណើត

បន្ទាប់ពីបានសម្រាលកូនរួច ឪពុក ឬម្ដាយ មានកាតព្វកិច្ចទៅសុំចុះសំបុត្រកំណើត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្ដាយទារកនោះមិនឱ្យហួសពី ៣០ថ្ងៃ។

## ៤. ការថែទាំសុខភាពកូន

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវយកកូន ឬកុមារទៅពិនិត្យសុខភាព ដូចជា សុខភាពមាត់ធ្មេញ សុខភាពភ្នែក ខ្លួនប្រាណ បញ្ញុះសត្វល្អិត ព្រមទាំងចាក់ថ្នាំបង្ការផ្សេងៗនៅ មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ទៅតាមការកំណត់អាយុកុមាររបស់ក្រសួងសុខាភិបាល និងស្វែងរកសៅវាត្រួតពិនិត្យការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។

## ៥. ការកំណត់គោលដៅរយៈពេលវែង

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ តែងតែចង់ឱ្យកូន ឬកុមារធំឡើងក្លាយជាមនុស្សប្រកបដោយគុណតម្លៃល្អដូចជា ស្មោះត្រង់ ស្លូតបូត យល់ចិត្ត ជួយយកអាសាអ្នកដទៃ ដោះស្រាយបញ្ហាដោយអហិង្សា ឬមានមុខរបរសុចរិតជាដើម។ ប៉ុន្តែសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់មួយចំនួនដែលប្រព្រឹត្តក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារបានរួមចំណែកកែប្រែនូវសេចក្ដីប្រាថ្នានោះមិនបានដូចបំណងទៅវិញ។ ដូចនេះឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំត្រូវជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមបីបាច់កូន ឬកុមារដែលមានលក្ខណៈលើកទឹកចិត្ត ផ្ដល់ឱកាសចូលរួម សម្រេចចិត្ត និងមិនប្រើទណ្ឌកម្មពេលប្រៀនប្រដៅកូន ឬកុមារជាដើម។

## ៦. ការការពារ និងសុវត្ថិភាពនៃការលេង

ធ្វើយ៉ាងណាឱ្យកុមារជៀសផុតពីគ្រោះថ្នាក់ផ្សេងៗដែលវាអាចកើតមានឡើងដោយចេតនា ឬអចេតនា។ ប្រាប់កូន ឬកុមារពីគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រឿងញៀន លង់ទឹក។ល។ ដោយពន្យល់ពីហេតុផលច្បាស់លាស់ត្រឹមត្រូវដល់ពួកគាត់។

## ៧. ការធ្វើជាគំរូល្អ

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ប្រើរបៀបដោះស្រាយបញ្ហា ភាពតានតឹងចិត្ត ឬជម្លោះដែលបានកើតឡើងតាមមធ្យោបាយវិជ្ជមាន និងអហិង្សា។ ឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំគប្បីធ្វើជាគំរូល្អដល់កូន ឬកុមារពីរបៀបប្រាស្រ័យទាក់ទងល្អជាមួយសមាជិកគ្រួសារ និងជាមួយមនុស្សដែលនៅខាងក្រៅផ្ទះ ដើម្បីឱ្យកុមារបានរៀនសូត្រ និងអនុវត្តតាម។

## ៨. ការផ្តល់ឱកាស

កុមារដែលមានពិការភាព ទទួលបានឱកាសចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍សង្គមនានា ព្រមទាំងទទួលបានឧត្តមប្រយោជន៍ស្មើគ្នា នោះការលូតលាស់ និងអភិវឌ្ឍនឹងកើតមានឡើងដល់កុមារ។

## ៩. ការបង្រៀន និងអប់រំ

នៅពេលកូន ឬកុមារចម្រើនវ័យ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ចុះឈ្មោះកូន ឬកុមារ ឱ្យបានចូលរៀននៅសាលាមត្តេយ្យ និងតាមកម្រិតថ្នាក់ ជាបន្តបន្ទាប់ ព្រមទាំងបន្តអប់រំកូន ឬកុមារពីអាកប្បកិរិយា សីលធម៌ ចំណេះដឹង បំណិនជីវិត និងជំនាញបន្ថែម។

- **បង្រៀន និងអប់រំកុមារពីសុខភាពផ្លូវភេទ៖** ពន្យល់កូន ឬកុមារ ពីការលូតលាស់នៃរូបកាយនៅពេលដែលកុមារពេញវ័យ កុមារចាប់ផ្តើមមានចំណង់ផ្លូវភេទ។ ដូចនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំពន្យល់កុមារពីរបៀបគ្រប់គ្រងចំណង់ផ្លូវភេទតាមបែបវិជ្ជមាន ដូចជាហាត់ប្រាណ អានសៀវភៅ ដើរលំហែ ស្តាប់ចម្រៀង ជជែកគ្នាលេងជាមួយមិត្តភក្តិដែលទុកចិត្តបាន រឿងកំប្លែង ខ្សែភាពយន្ត ឬលេងកីឡាជាដើម ដែលសកម្មភាពទាំងអស់នេះមិនធ្វើឱ្យប៉ះពាល់ដល់ខ្លួនឯង និងអ្នកដទៃឡើយ។
- **គ្រឿងញៀន៖** នៅពេលដែលកុមារចូលវ័យជំទង់ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅតែបន្តលើកទឹកចិត្ត អប់រំឱ្យកូនយល់ពីភារកិច្ចដែលត្រូវជៀសវាងការសេពគប់មិត្តដែលសង្គមមិនឱ្យតម្លៃដូចជា ប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង។ល។ លើសពីនេះ ពន្យល់កុមារពីមូលហេតុដែលនាំឱ្យមានការប្រើប្រាស់គ្រឿងញៀន ផលប៉ះពាល់ និងមធ្យោបាយដែលធ្វើឱ្យខ្លួនគេសប្បាយដោយមិនប្រើគ្រឿងញៀន។

## ១០. ការផ្តល់ភាពកក់ក្តៅ និងក្តីស្រឡាញ់

មានពេលវេលាសម្រាប់កុមារដូចជា និទានរឿង ស្តាប់កុមារនិយាយ និយាយគ្នាលេង ឱប ថើប ឬប្រើពាក្យសម្តីទន់ភ្លន់។ល។

## ១១. ការធ្វើការងារផ្ទះ

ក្រៅអំពីការសិក្សារៀនសូត្រ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវផ្តល់ឱកាសឱ្យកូន ឬកុមារ បានចូលរួមធ្វើការងារផ្ទះ តាមលទ្ធភាព និងកម្រិតអាយុរបស់ពួកគេ ដើម្បីអភិវឌ្ឍបំណិនជីវិត។

### ១២. ការរស់នៅចុះសម្រុងគ្នា

មានកន្លែងស្នាក់នៅសមរម្យ និងសម្លៀកបំពាក់ទៅតាមស្ថានភាពជីវភាព អាកាសធាតុ ព្រមទាំងបរិស្ថានរស់នៅដោយការគោរពឱ្យតម្លៃគ្នា និងគ្មានអំពើហិង្សា។ល។

### ១៣. អាកប្បកិរិយា និងឥរិយាបថល្អ

ការគោរព ការប្រាស្រ័យទាក់ទងដោយការយល់ចិត្ត ការចែករំលែក និងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ល។

**ចំណាំ**

- ការរក្សាកូន ឬកុមារឱ្យនៅជាមួយគ្រួសារ គឺជាមធ្យោបាយតែមួយគត់ ក្នុងការផ្តល់ឱកាសឱ្យកូនទទួលបានការលូតលាស់ និងអភិវឌ្ឍបានល្អ។ នៅក្នុងមណ្ឌលកុមារកំព្រា កុមារងាយរងគ្រោះពីអំពើហិង្សា ការរំលោភបំពាន ឬការមិនអើពើ ។ល។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គួរតែឱ្យកូន ឬកុមាររស់នៅក្នុងគ្រួសារ បើទោះជាមានស្ថានភាពជីវភាពយ៉ាងណាក៏ដោយ ហើយត្រូវចងចាំថាគ្មានទីណាដែលប្រសើរជាងផ្ទះ ឬគ្រួសាររបស់កូន ឬកុមារឡើយ។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី) គួរផ្តល់ការថែទាំពិសេសទៅលើកូន ឬកុមារដែលមានពិការភាព ដើម្បីការពារកុមារទាំងនោះ ពីការរំលោភបំពានគ្រប់ទម្រង់។ កុមារទាំងនោះ នឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរ ដូចជាទៅចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេនឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យយ៉ាងហោចណាស់មួយឆ្នាំ មុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យយ៉ាងហោចណាស់។ បើសិនជាអាច សូមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ទាំងបុរស និងស្ត្រី) បន្តគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យរៀនដល់មហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពសង្គមនានាដែរ។

## II. ភារកិច្ចរបស់កូន ឬកុមារ

កូន ឬកុមារ មានភារកិច្ចមួយចំនួន សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ភារកិច្ចទាំងនោះរួមមាន៖

### ១. ការអនាម័យខ្លួនប្រាណ

ដូចជា ងូតទឹកសម្អាតខ្លួនប្រាណ រស់នៅស្អាត ហូបស្អាត ផឹកស្អាត ដែលអាចជួយឱ្យមានសុខភាពល្អ និងរូបរាងកាយមានការលូតលាស់ និងអភិវឌ្ឍបានល្អ។

## ២. ការដោះស្រាយទំនាស់

របៀបដោះស្រាយបញ្ហាដោយសន្តិវិធី ជៀសវាងពីការប្រើអំពើហិង្សាគ្រប់ប្រភេទ តាមរយៈ ការស្តាប់ហេតុផល សួរសំណួរបញ្ជាក់ ស្វែងរកឫសគល់នៃបញ្ហា មានការពិភាក្សា និងការចរចាជាដើម។

## ៣. ការថែទាំសុខភាព

ហាត់ប្រាណឱ្យបានទៀងទាត់ដូចជា ជិះកង់ លេងបាល់ ឬកីឡាផ្សេងៗទៀត តាមកម្រិតអាយុ ដែលអាចធ្វើបាន។

## ៤. ការស្តាប់ដំបូន្មានឪពុកម្តាយ

រៀនពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើទាំងនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ ពិសេសរៀនពីគំរូល្អៗ និងស្តាប់ការទូន្មានប្រៀនប្រដៅរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។

## ៥. ការរៀនសូត្រ

ការចូលរៀននៅសាលាមត្តេយ្យរហូតដល់កម្រិតមហាវិទ្យាល័យ បើសិនគាត់អាចមានលទ្ធភាព និងសមត្ថភាព។ កុមារធ្វើកិច្ចការសាលា អាន សួរ ឆ្លើយ ជាពិសេសកុមារមានទីកន្លែង និងពេលវេលាគ្រប់គ្រាន់ក្នុងការរៀនសូត្រនៅសាលារៀន និងជាមួយមិត្តភក្តិ។

## ៦. អាហារូបត្ថម្ភ

ញ៉ាំឱ្យបានទៀងទាត់ និងគិតដល់អាហារទាំង៣ក្រុម (អាហារការពារ អាហារសាងសង់ និងអាហារថាមពល) និងអាហារដែលមានសុវត្ថិភាព។

## ៧. ការរៀនអំពីបំណិនជីវិត

គ្រប់គ្រងពេលវេលា និងលុយកាក់ រៀនពីរបាំខ្មែរ ចម្រៀង ឬសិល្បៈនានា ដាំដំណាំ ឬបន្លែ ការចិញ្ចឹមសត្វ ជំនាញក្នុងការទំនាក់ទំនង ឬការរស់នៅប្រចាំថ្ងៃជាដើម។ ការជួយសម្រាលការងារផ្ទះ មិនប៉ះពាល់ដល់ការអភិវឌ្ឍរបស់កូន ឬកុមារទេ។ សកម្មភាពទាំងនោះមានដូចជា ដាំស្ល ស្រោចផ្កា សម្អាតផ្ទះ និងជួយអ្នកជិតខាង មិត្តភក្តិ ឬអ្នកដែលត្រូវការជំនួយ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវពន្យល់ឱ្យច្បាស់ពីព្រំដែននៃការជួយដែលមិនមានការប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍ និងមានគ្រោះថ្នាក់ដល់កូន ឬកុមារ។

## ៨. ការលេង

ការបង្កើននូវភាពរីករាយមានសារៈសំខាន់ណាស់ចំពោះកូន ឬកុមារ។ ពួកគេអាចស្វែងយល់ពីខ្លួនឯងព្រមទាំងបរិស្ថាននៅជុំវិញរបស់ពួកគេ។ ការលេងក៏ជួយឱ្យកូន ឬកុមារមានសមត្ថភាពក្នុងការដោះស្រាយបញ្ហា ការសម្របខ្លួនទៅតាមស្ថានភាព ទទួលស្គាល់អំពីការឈ្នះ និងចាញ់ ចេះរងចាំ និងចែករំលែកនូវអ្វីដែលកុមារមានជាមួយបងប្អូន មិត្តភក្តិ ឬអ្នកផ្សេងទៀត។

## ៩. ការគេង

គេងឱ្យបានគ្រប់គ្រាន់ ឧទាហរណ៍៖

- ទារកអាយុ ០-៣ ខែ ត្រូវគេង ១៤-១៧ ម៉ោង (អាចគេង ១១-១៩ ម៉ោង)
- ទារកអាយុ ៤-១១ ខែ ត្រូវគេង ១២-១៥ ម៉ោង (អាចគេង ១០-១៨ ម៉ោង)
- កូន ឬកុមារតូចអាយុ ១-២ ឆ្នាំ ត្រូវគេង ១១-១៤ ម៉ោង (អាចគេង ៩-១៦ ម៉ោង)
- កូន ឬកុមារតូចអាយុ ៣-៥ ឆ្នាំ ត្រូវគេង ១០-១៣ ម៉ោង (អាចគេង ៨-១៤ ម៉ោង)
- កូន ឬកុមារអាយុ ៦-១៣ ឆ្នាំ ត្រូវគេង ៩-១១ ម៉ោង (អាចគេង ៧-១២ ម៉ោង)
- កូន ឬកុមារអាយុ ១៤-១៧ ឆ្នាំ ត្រូវគេង ៨-១០ ម៉ោង (អាចគេង ៧-១១ ម៉ោង)

## ១០. ភារកិច្ចផ្សេងទៀតមានដូចជា

- **ទំនាក់ទំនងនានាក្នុងសង្គម៖** ចូលរួមកម្មវិធីខ្លះៗជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ សួរសុខទុក្ខសាច់ញាតិ អ្នកជិតខាង ការជួយសម្រួលចរាចរលើដងផ្លូវតាមសាលា ឬការចូលរួមប្រជុំផ្សព្វផ្សាយនានាតាមសហគមន៍ជាដើម។
- **ការគោរពច្បាប់ និងសីលធម៌សង្គម៖** ពាក់មួកសុវត្ថិភាព ឬខ្សែក្រវ៉ាត់ពេលធ្វើដំណើរ គោរពភ្លើងសញ្ញាចរាចរ មិនប្រព្រឹត្តអំពើលួចឆក់ប្លន់ ឬប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន រួមទាំងការគោរព និងឱ្យតម្លៃដល់មនុស្សនៅជុំវិញខ្លួន។

# III. របៀបនៃការចិញ្ចឹមកូន

## ១. អត្ថន័យនៃ ការចិញ្ចឹមកូន

សំដៅលើទង្វើ ឬសកម្មភាពដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ មានកាតព្វកិច្ចក្នុងការចិញ្ចឹមកូនឬកុមាររួមទាំងកុមារដែលមានពិការភាព ដូចជា ការផ្តល់ជម្រក សម្លៀកបំពាក់ ចំណីអាហារ ផ្តល់សេចក្តីស្រឡាញ់ ភាពកក់ក្តៅ ពន្យល់ណែនាំ ឬប្រៀនប្រដៅជាដើម។

## ២. របៀបនានា នៃការចិញ្ចឹមកូន

សំដៅទៅលើ របៀបផ្សេងៗគ្នាដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ប្រព្រឹត្ត ឬអនុវត្តក្នុងការចិញ្ចឹមកូនរបស់ពួកគេ ដែលក្នុងនោះរួមបញ្ចូលអំពីកម្រិតនៃការរំពឹងទុក ទង្វើ ឬសកម្មភាព ច្បាប់ ឬវិន័យ ដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បានប្រើប្រាស់នៅក្នុងក្រុមគ្រួសារ ដើម្បីពង្រឹង និងសម្រេចនូវការរំពឹងទុករបស់ពួកគេ។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ជាច្រើនបានចម្លងបន្តគ្នានូវរបៀបនៃការចិញ្ចឹមកូនពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជំនាន់មុនៗ។ យោងតាមឯកសារបណ្ដុះបណ្ដាលរបស់អង្គការបុគ្គាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា (ICS-SP) និងអង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) ស្ដីពី ការចិញ្ចឹមកូនបែបវិជ្ជមាន បានបង្ហាញថា របៀបនៃការចិញ្ចឹមកូនមាន ៤ប្រភេទ ដូច ខាងក្រោម

| របៀបនៃការចិញ្ចឹមកូន | លក្ខណៈដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ស្ដែងចេញ | លទ្ធផល និង ឥទ្ធិពលចំពោះកុមារ |
|---|---|---|
| **បែបត្រជាក់មាត់តូច ឬ ការផ្ដល់សិទ្ធិ** | **យកចិត្តទុកដាក់ខ្លាំង**<br>• ជ្រោមជ្រែងជានិច្ច ប្រព្រឹត្តបែបអហិង្សា និងផ្ដល់នូវភាពកក់ក្ដៅដល់កូន ឬកុមារ<br>• ឆ្លើយតបទៅនឹងតម្រូវការ របស់កូន ឬកុមារ ហើយស្ដាប់គំនិត យោបល់របស់ពួកគេ<br>• មានការរំពឹងទុកខ្លាំង និងមានការរឹតត្បិត ប៉ុន្តែពន្យល់ និងស្ដាប់ហេតុផល<br>• ប្រើគោលការណ៍ចំនួន៥ មាន៖<br>១) ភាពអហិង្សា<br>២) ផ្ដោតទៅលើការរកដំណោះស្រាយ<br>៣) ការគោរព<br>៤) ផ្ដែកលើដំណាក់កាលលូតលាស់ និងការអភិវឌ្ឍរបស់កុមារ<br>៥) ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ<br>• ធាតុផ្សំទាំង៤ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន<br>១) គោលដៅយូរអង្វែង<br>២) ភាពកក់ក្ដៅ និងដែនកំណត់<br>៣) យល់អំពីការគិត និងអារម្មណ៍<br>៤) ដោះស្រាយបញ្ហា | • កូន ឬកុមារមានការសប្បាយចិត្ត<br>• មានទំនុកចិត្ត<br>• ចេះទទួលខុសត្រូវ<br>• មានសីលធម៌ល្អ និងគោរពគ្នាទៅវិញទៅមក។ |

| របៀបនៃការចិញ្ចឹមកូន | លក្ខណៈដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ស្តែងចេញ | លទ្ធផល និង ឥទ្ធិពលចំពោះកុមារ |
|---|---|---|
| **បែបក្តៅ មាត់ធំ ឬផ្តាច់ការ** | **យកចិត្តទុកដាក់តិច - ត្រួតត្រាខ្លាំង**<br>• ក្រឹត្យក្រម តឹងតែង ត្រួតត្រាដោយការបង្គាប់បញ្ជា ប្រើទណ្ឌកម្ម ឬអំពើហឹង្សា<br>• ចង់បានការស្តាប់បង្គាប់ (កូនត្រូវស្តាប់តាមទាំងងងឹតងងល់)<br>• ទាមទារច្រើនពីកូន ដោយគ្មានការពន្យល់ ឬណែនាំច្បាស់លាស់<br>• មិនយល់ មិនបំពេញតម្រូវការ ឬអារម្មណ៍របស់កូន ឬកុមារ<br>• *ខ្មែរមានពាក្យមួយឃ្លាថា □អញស៊ីអំបិលច្រើនជាងឯងស៊ីបាយ! ដូច្នេះឯងត្រូវតែស្តាប់អញ!□* | • កូនស្តាប់បង្គាប់ ប៉ុន្តែមិនសូវ ជាសប្បាយ ចិត្ត<br>• មិនសូវមានការចូលរួមក្នុងសង្គម<br>• មិនសូវចេះគោរព និងឱ្យតម្លៃខ្លួនឯង<br>• កុមារីច្រើនមានទំនោរលើភាពអៀនប្រៀន ឯកុមារាវិញ ច្រើនតែមិនសូវរាក់ទាក់ ។ |
| **បែបសេរី ឬទំនើង** | **យកចិត្តទុកដាក់ខ្លាំងពេក - ខ្វះការត្រួតត្រា**<br>• គ្មានការណែនាំ គ្មានទណ្ឌកម្ម ឬការប្រៀនប្រដៅអ្វីទាំងអស់<br>• មានទំនោរចុះញ៉ម និងយល់ព្រមចំពោះការទាមទាររបស់កូន ឬកុមារ<br>• គ្មានការបកស្រាយ ពន្យល់ដើម្បីចៀសវាងពីអារម្មណ៍ឆេវឆាវ ឬវិវាទរវាងគ្នានឹងគ្នា<br>• រវល់នឹងកូនខ្លាំងជ្រុល<br>• ប្រើឋានៈ តួនាទីជាមិត្តភក្តិច្រើនជាងឋានៈជាឪពុកម្តាយ | • កូនមិនសប្បាយចិត្ត និងពិបាកក្នុងការចូលរួមក្នុងសង្គម<br>• កូនទំនងជាជួបបញ្ហាច្រើន ជាមួយនឹងការត្រួតត្រាពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ<br>• កូនអាចរៀនខ្សោយ។ |
| **បែបមិនអើពើ** | **ខ្វះការយកចិត្តទុកដាក់ - ខ្វះការត្រួតត្រា**<br>• មានការបង្គាប់បញ្ជាតិចតួច<br>• យកចិត្តទុកដាក់តិចតួច<br>• និយាយរកគ្នាតិចតួច<br>• ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ បដិសេធ ឬមិនអើពើទៅនឹងតម្រូវការរបស់កូន ឬកុមារ | • កូនខ្វះការគ្រប់គ្រងខ្លួនឯង<br>• មិនចេះគោរពខ្លួនឯង និងខ្សោយសមត្ថភាព។<br>• ងាយរងគ្រោះដោយសារឥទ្ធិពល និងបរិយាកាសមិនល្អនៅក្នុងគ្រួសារ។ |

# IV. ការអនុវត្តវិន័យ និងការដាក់ទណ្ឌកម្ម

## ១. របៀបផ្សេងៗ នៃការអនុវត្តវិន័យបែបវិជ្ជមាន

### ១.១ គោលការណ៍ណែនាំទូទៅសម្រាប់ការដាក់វិន័យឱ្យមានប្រសិទ្ធភាព

- ផ្តល់ឱ្យកូននូវសណ្តាប់ធ្នាប់ និងទម្លាប់ ពោលគឺនៅពេលញ៉ាំអាហារ និងពេលគេងជាដើម ត្រូវតែទៀងទាត់។
- បង្កើតនូវបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រួសារ ដែលមានលក្ខណៈសាមញ្ញ ខ្លី ហើយសមស្របទៅតាមកម្រិតអាយុរបស់កុមារ ព្រមទាំងកំណត់ច្បាស់លាស់នូវផលវិបាកប្រសិនបើមិនគោរពតាម។
- ត្រូវតែស្ថិតស្ថេរ ពោលត្រូវធានាថា បទបញ្ជាផ្ទៃក្នុង និងការរំពឹងទុករបស់អ្នកមិនមានការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃនោះឡើយ។
- ត្រូវមានភាពយុត្តិធម៌ ពោលគឺមិនត្រូវស្រឡាញ់កូនខ្លះច្រើនកូនខ្លះតិចឡើយ។
- អភិវឌ្ឍទំនាក់ទំនងដ៏ជឿជាក់មួយជាមួយកុមារ ដោយការពារពួកគេពីអន្តរាយ ធ្វើខ្លួនឱ្យមានភាពស្មោះត្រង់ និងគួរឱ្យជឿជាក់ ដោយការបង្ហាញនូវអាកប្បកិរិយាដែលអាចស្មានដឹង និងមានភាពចាស់ទុំ។
- ផ្តល់ការសរសើរចំពោះឥរិយាបថដែលសមស្រប ការសរសើរនឹងបង្កើននូវការប្រព្រឹត្តអាកប្បកិរិយានោះ ហើយជៀសវាងនូវចរិកមិនល្អរបស់កុមារដែលធ្វើដើម្បីគ្រាន់តែទាក់ទាញចំណាប់អារម្មណ៍។
- ត្រូវពន្យល់ដល់កុមារអំពីអ្វីដែលពួកគេបានធ្វើខុស និងហេតុអ្វីបានជាអ្នកខឹងជាមួយនឹងពួកគេ។
- ជៀសវាងការសើចចំអកចំពោះកុមារ ឬធ្វើឱ្យកុមារមានអារម្មណ៍ថា ខ្លួនជាមនុស្សគ្មានតម្លៃ ឬការធ្វើឱ្យពួកគេមានភាពអាម៉ាស់ជាសាធារណៈ។
- ត្រូវតែម៉ឺងម៉ាត់ នៅពេលដែលកំពុងអនុវត្តវិន័យកុមារ។
- ទទួលយកនូវឥរិយាបថ □គ្មានការវាយដំ□ គ្មាននរណាម្នាក់មានសិទ្ធិវាយដំលើនរណាម្នាក់ផ្សេងទៀតនៅក្នុងផ្ទះឡើយ ដោយរួមទាំងការវាយដំលើកុមារចំពោះការដែលគេមានចរិតមិនល្អផងដែរ។

### ១.២ វិធីសាស្ត្រដើម្បីដាក់ពិន័យទៅលើកុមារ

- អង្គុយនៅកន្លែងមួយដើម្បីពិចារណាកំហុស ប្រសិនបើ កុមារមានភាពខិលខូច ឬមានអាកប្បកិរិយាលំបាក ត្រូវប្រាប់ពួកគេអំពីអ្វីដែលពួកគេបានធ្វើខុស និងប្រាប់ពួកគេថា ត្រូវតែអង្គុយនៅកន្លែងមួយដើម្បីជាការពិន័យ។ ប្រាប់កុមារអំពីកន្លែងដែលគេត្រូវអង្គុយ និងជាកន្លែងមានសុវត្ថិភាព (យកល្អនៅកន្លែងណាមួយដែលមិនមានការរំខានពីអ្នកដទៃ ហើយប្រាប់គេថា ត្រូវអង្គុយនៅទីនោះយ៉ាងស្ងៀមស្ងាត់ និងមិន

ត្រូវធ្វើចលនាចុះឡើងទេរហូតទាល់តែដល់ពេលកំណត់។ រយៈពេលនៃការដាក់ពិន័យត្រូវតែកំណត់ឱ្យច្បាស់លាស់ (ចន្លោះពីប្រាំ ទៅដប់នាទីអាស្រ័យទៅលើអាយុរបស់គេ) ហើយក្រោយពីពេលនោះ មកប្រាប់កូនអ្នកថា គេបានបញ្ចប់ការដាក់ពិន័យហើយ និងប្រាប់ថា អ្នកចង់ឱ្យគេសុំទោសចំពោះទង្វើដែលគេបានធ្វើខុស។ ការឱ្យកុមារអង្គុយនៅកន្លែងមួយតែម្នាក់ឯង ជាការផ្តល់ពេលវេលាឱ្យគេស្ងប់អារម្មណ៍ និងពិចារណាពីកំហុសដែលគេបានធ្វើ។

- ដកហូតនូវអ្វីដែលគេចូលចិត្ត ប្រសិនបើ កុមារខិលខូចត្រូវប្រាប់ពួកគេអំពីអ្វីដែលពួកគេបានធ្វើខុស និងថា អ្នកនឹងដកហូតនូវអ្វីម៉្យាងដែលពួកគេចូលចិត្ត ឬរីករាយជាមួយ ដើម្បីជាការដាក់ពិន័យ។ ឧទាហរណ៍ កុមារមិនត្រូវបានអនុញ្ញាតឱ្យលេងជាមួយមិត្តភក្តិរបស់គេ ឬមើលទូរទស្សន៍ ឬញ៉ាំស្ករគ្រាប់។

## ២. ផលប៉ះពាល់នៃការដាក់ទណ្ឌកម្ម ចំពោះកុមារ

ផលប៉ះពាល់នៃការដាក់ទណ្ឌកម្ម គឺអាស្រ័យទៅតាមបទពិសោធន៍ ការរស់នៅ និងបរិបទនៃគ្រួសារនីមួយៗ។ ប៉ុន្តែការស្រាវជ្រាវបានបង្ហាញថា ការដាក់ទណ្ឌកម្មនឹងប៉ះពាល់ចំពោះកុមារ ដូចតទៅ៖

- កូន ឬកុមារ មិនមានការគោរពលើខ្លួនឯង ហើយគិតថាខ្លួនឯងគ្មានតម្លៃ និងគ្មានការជឿជាក់លើខ្លួនឯង។
- ពួកគេនឹងក្លាយជាជនរងគ្រោះ ដែលផ្អយនឹងជំនឿថា ការប្រើទណ្ឌកម្មនឹងធ្វើឱ្យកូន ឬកុមារ □កាន់តែរឹងមាំ□ ឬបង្រៀនកុមារឱ្យចេះតស៊ូ
- បង្អាក់ដំណើរការរៀនសូត្ររបស់គេ និងរាំងស្ទះដល់ការលូតលាស់ និងអភិវឌ្ឍខាងសតិបញ្ញា អារម្មណ៍ និងផ្លូវចិត្ត
- ធ្វើឱ្យកុមារ មានអារម្មណ៍ឯកោ សោកសៅ កណ្តោចកណ្តែង និងក្រៀមក្រំម្នាក់ឯង
- ធ្វើឱ្យកុមារ មានទស្សនៈមិនល្អចំពោះមនុស្សទូទៅ និងសង្គម ដោយចាត់ទុកមជ្ឈដ្ឋានជុំវិញខ្លួន ជាការគំរាមកំហែងដល់ពួកគេ
- មានការលំបាកដល់ការប្រាស្រ័យទាក់ទង និងចំណងមនោសញ្ចេតនាជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ
- មានអារម្មណ៍មួម៉ៅ ខ្វះភាពកក់ក្តៅ និងធ្វើឱ្យកូន ឬកុមាររចង់រត់ចេញពីផ្ទះ
- បង្កឱ្យមានអំពើហិង្សាកាន់តែច្រើន និងបង្រៀនកូនឱ្យគិតថាអំពើហិង្សាគឺជាមធ្យោបាយដ៏សមស្របនៅក្នុងការដោះស្រាយបញ្ហា និងវិវាទផ្សេងៗ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំភាគច្រើនដែលប្រើហិង្សាលើកូន ឬកុមារ ច្រើនរងនូវអំពើហិង្សាកាលពីពួកគេនៅក្មេង
- បង្អាក់ដល់ការចូលរួមរបស់កុមារនៅក្នុងសង្គម
- បង្រៀនឱ្យកុមាររចេះស្តាប់ (ឬមិនស្តាប់) តាមក្រឹត្យក្រម និងសីលធម៌សង្គម។

លើសពីនេះទៅទៀត ការប្រើទណ្ឌកម្មក៏អាចនាំមកនូវលទ្ធផលមិនល្អដល់ឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងអាចបង្កឱ្យពួកគាត់មានបញ្ហាថប់បារម្ភ និងស្ដាយក្រោយ ពិសេសអាចបង្កើតឱ្យមានអំពើហិង្សានៅក្នុងគ្រួសារកាន់តែច្រើនឡើងៗ និងរាំងស្ទះដល់ការប្រាស្រ័យទាក់ទង និងសម្ព័ន្ធភាពគ្រួសារផងដែរ។

## V. អាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ

វិភាគនូវអាកប្បកិរិយាដែលគួរធ្វើ និងមិនគួរធ្វើក្នុងការចិញ្ចឹមកូន ឬកុមារ ហើយបន្តអនុវត្តនូវអាកប្បកិរិយាដែលគួរធ្វើ និងផ្លាស់ប្ដូរនូវអាកប្បកិរិយាដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។

តាមការអង្កេតនៅឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការយូនីសេហ្វ (UNICEF) ស្ដីពីអំពើហិង្សាលើកុមារ បានបង្ហាញឱ្យឃើញថា ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បានប្រើប្រាស់របៀបនៃការចិញ្ចឹមកូនដោយប្រើហិង្សា ដូចជា អំពើហិង្សាលើរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើលើកុមារ។ ពួកគាត់មួយចំនួនធំមិនបានដឹងថា របៀបនៃការចិញ្ចឹមកូនដូចបានលើកឡើងខាងលើនេះ មានផលប៉ះពាល់អវិជ្ជមានខ្លាំងដល់ការលូតលាស់ និងអភិវឌ្ឍកុមាររួមទាំងកុមារដែលមានពិការភាពឡើយ។ ( សូមរំឭកអ្នកចូលរួមឱ្យបានគិតឡើងវិញអំពីមេរៀនការការពារកុមារ ដែលបង្ហាញអំពីផលប៉ះពាល់នៃការប្រើហិង្សាលើកុមារ )

យោងទៅតាមលទ្ធផលស្រាវជ្រាវនេះផងដែរ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គួរសិក្សាស្វែងយល់ និងជ្រើសរើសយករបៀបនៃការចិញ្ចឹមកូន ឬកុមារដែលជួយឱ្យការប្រាស្រ័យទាក់ទងរវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ជាមួយនឹងកូនៗ កាន់តែរឹងមាំ ហើយអាចរស់នៅជាមួយគ្នាដោយមានមោទនភាព និងពេញចិត្ត បើទោះជាពួកគេរស់នៅក្នុងផ្ទះដ៏តូចមួយក៏ដោយ "ស៊ូចង្អៀតផ្ទះកុំឱ្យតែចង្អៀតចិត្ត" ។

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្ដើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាច៖<br>· សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>· លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកការរស់នៅរបស់ពួកគាត់<br>▪ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែកនិងបន្ត សកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរ៖<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្ដេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់៖** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំផ្ដល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែង ថាមពល "ស្រាយ ចំណង" (១០នាទី) | ▪ ចែកអ្នកចូលរួមជា២ក្រុម ដោយធានាថាសមាជិកក្រុមនីមួយៗ ត្រូវមានចំនួនសេស<br>· ស្នើឱ្យក្រុមនិមួយៗឈរជារង្វង់<br>· បន្ទាប់មក ឱ្យអ្នកចូលរួមយកដៃស្តាំរបស់ខ្លួនទៅចាប់ដៃឆ្វេង របស់អ្នកចូលរួមម្នាក់ និងដៃឆ្វេងទៅចាប់ដៃស្តាំរបស់អ្នក ចូលរួមម្នាក់ទៀត ដោយមិនអនុញ្ញាតឱ្យចាប់ដៃជាមួយអ្នក ដែលឈរក្បែរខ្លួនឡើយ។<br>▪ បន្ទាប់ពីចាប់ដៃរួចហើយ ឱ្យសមាជិកក្រុមដោះដៃឱ្យទៅជារង្វង់ ម្តងទៀត ដោយមិនអនុញ្ញាតឱ្យបូតដៃចេញពីគ្នាឡើយ។<br>**ចំណាំ៖**<br>▪ (ក្រុម១ សមាជិកក្រុមមានចំនួនសេស និងក្រុម១ទៀត សមាជិក ក្រុមមានចំនួនគូ)<br>▪ ក្រុម១ ដែលសមាជិកក្រុមមានចំនួនសេសគ្មានអ្នកដឹកនាំ សមាជិកក្រុមទាំងអស់អាចពិភាក្សាគ្នាបាន។ ក្រុម១ទៀតដែល សមាជិក្រុមមានចំនួនគូ ស្នើសុំម្នាក់ជាអ្នកដឹកនាំ និងប្រាប់ ឱ្យសមាជិកក្រុមធ្វើតាមការប្រាប់របស់អ្នកដឹកនាំក្រុម ដោយ សមាជិកក្រុមមិនត្រូវនិយាយអ្វីទាំងអស់ក្រៅពីធ្វើតាមការបញ្ជា) |
| ៥ | មេរៀនថ្មី៖ របៀបនៃការចិញ្ចឹមកូន | ស្វែងយល់ ពីរបៀប ផ្សេងៗ នៃ ការចិញ្ចឹមកូន (៣៥នាទី) | ▪ មុនចាប់ផ្តើម អ្នកសម្របសម្រួលបំផុសគំនិត ដោយសួរ<br>☞ តើរបៀបនៃការចិញ្ចឹមកូនដែលលោកអ្នកអនុវត្តសព្វថ្ងៃនេះ រៀនមកពីណា?<br>☞ តើសកម្មភាព ឬរបៀបអ្វីខ្លះធ្វើឱ្យអ្នកមានភាពសប្បាយ រីករាយ ដែលឪពុកម្តាយបានផ្តល់ឱ្យកាលអ្នកនៅវ័យកុមារ?<br>☞ តើសកម្មភាព ឬរបៀបអ្វីខ្លះធ្វើឱ្យអ្នកមានភាពមិនពេញចិត្ត ដែលឪពុកម្តាយបានធ្វើ កាលអ្នកនៅវ័យកុមារ?<br>▪ អ្នកសម្របសម្រួលធ្វើការសរុបគំនិតរបស់អ្នកចូលរួម រួចពន្យល់ បន្ថែមដោយលើកឡើងថា របៀបនៃការចិញ្ចឹមកូនមានច្រើនរបៀប ផ្សេងៗគ្នាទៅតាម បុគ្គល គ្រួសារ និងជាតិសាសន៍នីមួយៗ។<br>▪ បន្ទាប់មកអ្នកសម្របសម្រួល បង្ហាញអំពីរបៀបទាំង ៤នៃការ ចិញ្ចឹមកូនកន្លងមកដែលមាននៅក្នុងប្រទេសកម្ពុជា មាន៖<br>១. ការចិញ្ចឹមកូនបែបត្រជាក់ មាត់តូច ឬការផ្តល់សិទ្ធិ<br>២. ការចិញ្ចឹមកូន បែបក្តៅ មាត់ធំ ឬផ្តាច់ការ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ៣. ការចិញ្ចឹមកូន បែបសេរី ឬទំនើង<br>៤. ការចិញ្ចឹមកូន បែបមិនអើពើ<br>▪ បន្ទាប់មក ធ្វើការបែងចែកអ្នកចូលរួមជា ៤ក្រុម ហើយក្រុមនីមួយៗធ្វើការពិភាក្សានូវសំណួរដូចខាងក្រោម៖<br>ក្រុមទី១៖ តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថាជា ការចិញ្ចឹមកូនបែបត្រជាក់ ?<br>ក្រុមទី២៖ តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថាជា ការចិញ្ចឹមកូនបែបក្តៅ ?<br>ក្រុមទី៣៖ តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថាជា ការចិញ្ចឹមកូនបែបសេរី ឬទំនើង ?<br>ក្រុមទី៤៖ តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថាជា ការចិញ្ចឹមកូនបែបមិនអើពើ ?<br>▪ តំណាងក្រុមនីមួយៗនឹងធ្វើការបង្ហាញលទ្ធផលរបស់ក្រុមទៅក្រុមធំ ។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារអំពីរបៀបទាំង ៤នៃការចិញ្ចឹមកូន។ រួចបន្តនូវសកម្មភាពបន្ទាប់ |
| | | **ស្វែងយល់ពីភាពខុសគ្នារវាងការដាក់ទណ្ឌកម្ម និងការអនុវត្តវិន័យបែបវិជ្ជមាន** (**១៥នាទី**) | ▪ ឱ្យអ្នកចូលរួមចាប់ដៃគូពីរៗនាក់ រួចពិភាក្សាគ្នានូវសំណួរខាងក្រោម៖<br>១. តើ **ទណ្ឌកម្ម** មានន័យដូចម្តេច ?<br>២. នៅក្នុងសហគមន៍ដែលលោកអ្នករស់នៅ តើលោកអ្នកធ្លាប់បានដឹង ឮ ឬឃើញកុមារ (ទាំងកុមារដែលមានពិការភាព) ត្រូវបានគេដាក់ទណ្ឌកម្មដែរឬទេ ?<br>៣. តើការដាក់ទណ្ឌកម្ម មានភាពខុសគ្នាពីការអនុវត្តវិន័យបែបវិជ្ជមានដូចម្តេចខ្លះ ?<br>▪ ឱ្យអ្នកចូលរួម ៣ ទៅ ៤គូ ចែករំលែកអំពីអ្វីដែលបានពិភាក្សាទៅក្រុមធំ<br>▪ អ្នកសម្របសម្រួលធ្វើការបូកសរុប និងបន្ថែមខ្លឹមសារ រួចធ្វើការសង្កត់ធ្ងន់លើការពិតថា ទណ្ឌកម្មមិនមែនគ្រាន់តែជាអំពើហិង្សាលើរាងកាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាអំពើហិង្សាខាងផ្លូវចិត្ត ឬការមិនអើពើផងដែរ។ ឧទាហរណ៍ ដូចជាការបន្ទោសបង្អាប់ ការទុកចោលឱ្យនៅដោយឡែក ការធ្វេសប្រហែស និងការបង្អត់អាហារដល់កុមារជាដើម។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលធ្វើការពន្យល់ផងដែរពីផលប្រយោជន៍ និងផលប៉ះពាល់ពីរបៀបទាំង ៤នៃការចិញ្ចឹមកូន។ |
| | | **សង្ខេបមេរៀន រយៈពេល** (៥នាទី) | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីរបៀបផ្សេងៗនៃការចិញ្ចឹមកូន ដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បានប្រើប្រាស់ក្នុងការប្រៀនប្រដៅកូន ព្រមទាំងកាតព្វកិច្ចក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារ ដោយទាមទារឱ្យមានការជួយគាំទ្រគ្នាទៅវិញទៅមករវាងអ្នកពាក់ពន្ធ័។ ម៉្យាងទៀតយើងក៏អាចជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមកូន ដែលជួយដល់ការសម្រេចបាននូវគោលដៅរយៈពេលវែង ដោយមិនមានការរំពឹងពីការតបស្នងរបស់កូន ឬកុមារឱ្យមើលថែ ឬចិញ្ចឹមឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំវិញឡើយ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថា របៀបដែលយើងគួរយកមកអនុវត្ត ក្នុងការប្រៀនប្រដៅកូន នឹងមិនប៉ះពាល់ដល់សិទ្ធិ ការលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារឡើយ។ |
| ៦ | <u>ការឆ្លុះបញ្ចាំង</u> | **ការឆ្លុះបញ្ចាំងមេរៀន** (១០នាទី) | ▪ អ្នកសម្របសម្រួលសួរៈ<br>☞ តើលោកអ្នកយល់ថា ប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្ដេចដែរទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្ដេច នៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ** (៥នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្ដើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយាដែលអាចជួយគាំទ្រដល់កុមាររួមទាំងកុមារដែលមានពិការភាពផងដែរ ដើម្បីជួយឱ្យពួកគាត់មានការលូតលាស់ និងអភិវឌ្ឍបានល្អប្រសើរ។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

# វគ្គទី៧

# មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (១)

## សេចក្ដីផ្ដើម

យោងទៅតាមលទ្ធផលស្រាវជ្រាវឆ្នាំ ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការ UNICEF ស្ដីពីអំពើហិង្សាលើកុមារបានបញ្ជាក់ថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតមានដូចជា ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ ដូចនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគួរសិក្សាស្វែងយល់ពីអំពើហិង្សា ការមិនអើពើ និងផលប៉ះពាល់លើកុមារ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការ បញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ ដែលកន្លងមកពួកគាត់តែងតែគិតថាការអប់រំប្រដៅកូនមានរបៀបពីរគឺ ត្រជាក់ (អហិង្សា) និងក្ដៅ (ហិង្សា) ពិសេសគឺយោងទៅលើនិស្ស័យរបស់កូន ឬកុមារ។ ការអប់រំប្រដៅកូនដោយបែបក្ដៅដូចជាការស្ដីបន្ទោស ជេរ គំរាម សំឡុត ដាក់ទណ្ឌកម្ម វាយដំ គឺគ្រាន់តែចង់ឱ្យកូនៗ ឬកុមារមាន អាកប្បកិរិយាល្អតែប៉ុណ្ណោះ។ ដូច្នេះពួកគាត់គិតថាការធ្វើបែបនេះវាមិនមែនជាការរំលោភបំពាននោះទេ ដោយសារមានការគិត ឬទម្លាប់បែបនេះហើយទើបនាំឱ្យមានការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាបន្តកើតមានលើកូន ឬកុមារ នៅក្នុងគ្រួសារមួយចំនួនធំ។

ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគិត ឬទម្លាប់ខាងលើ យើងក៏បានរៀបចំចងក្រងប្រធានបទនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន ដែលជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដែលផ្ដោតទៅលើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន៤ ក្នុងគោលបំណង ជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ កំណត់បានពីរបៀបនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន និងការដោះស្រាយបញ្ហាជាមួយកូន ឬកុមារតាមដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍកុមារ ព្រមទាំងជ្រើសរើស និងអនុវត្តនូវវិធីសាស្ត្រ ឬរបៀបចិញ្ចឹមកូនបែបវិជ្ជមាន ដោយប្រើគោលការណ៍សំខាន់ចំនួន៥ និងធាតុផ្សំចំនួន ៤។

# ១. គោលការណ៍ទាំង៥

គោលការណ៍

ទី១

## ភាពអហិង្សា

គឺជាការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកូន ឬកុមារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

---

គោលការណ៍

ទី២

## ផ្តោតទៅលើការរកដំណោះស្រាយ

គឺជាការស្តាប់ និងការបង្ហាញហេតុផល រួមទាំងការពិភាក្សា និងការស្វែងរកវិធី ឬរបៀបណាមួយដើម្បីដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ឬបែបវិជ្ជមានដែលមានការចូលរួមយល់ព្រម និងការចរចារគ្នា។

---

គោលការណ៍

ទី៣

## ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នា ក្នុងភាពជាមនុស្ស ដោយគ្មានការរើសអើង និងវិនិច្ឆ័យ។

---

គោលការណ៍

ទី៤

## ផ្តោតលើដំណាក់កាលលូតលាស់ និងអភិវឌ្ឍកុមារ

គ្រប់កុមារទាំងអស់ (កុមារា កុមារី ឬកុមារដែលមានពិការភាព) មានការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ទៅតាមកម្រិតអាយុរបស់ពួកគេ ដូចជាការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈ ការគិត និងអារម្មណ៍ ដូច្នេះការបំពេញទៅនឹងតម្រូវការរបស់ពួកគេ គឺមានភាពខុសៗគ្នា។

---

គោលការណ៍

ទី៥

## ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

សិទ្ធិកុមារ គឺជាអ្វីៗដែលកុមារមាន និងអ្វីដែលមនុស្សទទួលខុសត្រូវចំពោះកុមារ។ ពួកគេត្រូវធានាថា កុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំ និងនិយាយនូវអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ។ កុមារទាំងអស់ រួមទាំង កុមារដែលមានពិការភាពទទួលបាននូវសិទ្ធិទាំងនេះ មិនថាពួកគេជានរណា មានពណ៌សម្បុរអ្វី ភាសាអ្វី សាសនាណា ក្មេងប្រុស ឬក្មេងស្រី អ្នកក្រ ឬអ្នកមានឡើយ។ ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក បានចុះហត្ថលេខាលើឯកសារនេះ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មានន័យថា ពួកគេបានសន្យានឹងធ្វើអ្វីៗទាំងអស់ដើម្បីធានាថា កុមារទាំងអស់ ទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។

## ២. ធាតុផ្សំទាំង៤

| ធាតុផ្សំទី១ | ធាតុផ្សំទី២ | ធាតុផ្សំទី៣ | ធាតុផ្សំទី៤ |
|---|---|---|---|
| គោលដៅយូរអង្វែង | ភាពកក់ក្តៅ និងដែនកំណត់ | យល់អំពីការគិត និងអារម្មណ៍ | ដោះស្រាយបញ្ហា |

ក្នុងវគ្គនេះ យើងនឹងលើកយក **ធាតុផ្សំទី១៖ គោលដៅយូរអង្វែង** និង **ធាតុផ្សំទី២៖ ភាពកក់ក្តៅ និងដែនកំណត់** មកធ្វើការពិភាក្សាគ្នា និងហាត់អនុវត្ត។ ដោយឡែកធាតុផ្សំចំនួន២ទៀតនឹងត្រូវសិក្សានៅវគ្គបន្ទាប់។ ការអនុវត្តនូវរបៀបទាំងនេះ គឺអាចជួយឱ្យកូន ឬកុមារទទួលបាននូវសេចក្តីណែនាំ ភាពកក់ក្តៅ បង្ហាញពីការគោរពឱ្យតម្លៃ រួមទាំងជួយឱ្យពួកគេក្លាយជាមនុស្សពេញវ័យដែលមានសុខភាពផ្លូវកាយ និងផ្លូវចិត្តល្អ ពិសេសគឺសម្រេចបាននូវការរំពឹងទុករបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប។

ប្រធានបទនេះវាជាមូលដ្ឋាននៃដំបូន្មាន និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការប្រៀនប្រដៅកូនបែបវិជ្ជមាន ដែលមានលក្ខណៈលើកទឹកចិត្ត ប្រសើរជាងការប្រៀនប្រដៅកូនបែបអវិជ្ជមាន ឬហិង្សាដូចដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបបានគិត និងអនុវត្តកន្លងមក។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• កំណត់ និងវិភាគអំពីចំណុចដែលត្រូវផ្សារភ្ជាប់រវាងគោលដៅរយៈពេលខ្លី និងគោលដៅយូរអង្វែង។<br>• ប្រើប្រាស់វិធីដ៏សមស្របទៅតាមអាយុកាលរបស់កូនសម្រាប់ផ្តល់ភាពកក់ក្តៅដល់កូនក្រោមការថែរក្សារបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតាមរយៈអាកប្បកិរិយាភាសាកាយវិការ និងពាក្យសម្តី។<br>• ទទួលស្គាល់ពីសារសំខាន់នៃការផ្តល់ដែនកំណត់ និងអនុវត្តនូវវិធីនានាដែលមានប្រសិទ្ធភាពក្នុងការផ្តល់ដែនកំណត់សម្រាប់កូន។ |
| **រយៈពេល** | **១៥០ នាទី** |

**សម្ភារៈ ដែលត្រូវការ**

- រូបភាពទី ១ បង្ហាញពី ការប្រៀនប្រដៅកូនបែបវិជ្ជមាន
- រូបភាពទី ២ បង្ហាញពី គោលការណ៍ទាំង ៥ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន
- រូបភាពទី ៣ បង្ហាញពី តើអ្វីទៅជាការប្រៀនប្រដៅកូនបែបវិជ្ជមាន ?
- រូបភាពទី ៤ បង្ហាញពី ធាតុផ្សំទី១៖ គោលដៅយូរអង្វែង
- រូបភាពទី ៥ បង្ហាញពី ធាតុផ្សំទី២៖ ភាពកក់ក្តៅ និងដែនកំណត់
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- កម្រាល សម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀម សម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រាអំពីគោលការណ៍ក្រុមដែលបានចងក្រងកាលពីជំនួបដំបូង

**ខ្លឹមសារលម្អិត**

## I. ធាតុផ្សំទី១ ៖ គោលដៅយូរអង្វែង

គោលដៅយូរអង្វែង គឺជាការរំពឹងទុករបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទៅលើកូន ឬកុមារនៅពេលដែលគេធំឡើង។ ជាបទពិសោធន៍ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ តែងតែកំណត់គោលដៅនេះទៅលើភាពមានបានទ្រព្យសម្បត្តិ និងមុខរបរផ្សេងៗដូចជា គ្រូពេទ្យ សាស្ត្រាចារ្យ មន្ត្រីរាជការដែលមានបុណ្យសក្តិ អំណាច ឬជាឧកញ៉ាជាដើម។ គោលដៅយូរអង្វែងគឺផ្តោតសំខាន់ទៅលើអត្តចរិតរបស់កូន ឬកុមារនៅពេលពួកគេធំឡើង។

### គោលដៅយូរអង្វែង មានដូចជា៖ ពេលកូនធំឡើង ចង់ឱ្យកូន

- មានទំនុកចិត្តលើខ្លួនឯង
- អាចដោះស្រាយបញ្ហាដោយសន្តិវិធី ឬអហិង្សា
- មានការទទួលខុសត្រូវក្នុងគ្រួសារ និងសហគមន៍
- មានចរិតស្លូតបូត និងចិត្តល្អ
- ជាអ្នកដែលចេះសម្រេចចិត្តដោយភាពឆ្លាតវៃ
- ចេះយល់ចិត្តអ្នកដទៃ ឬអ្នកនៅជុំវិញខ្លួន ។ល។

ប្រសិនបើអ្នកស្រម៉ៃចង់ឱ្យកូនអ្នកក្លាយជាមនុស្សប្រភេទណានោះ អ្នកនឹងដឹងថា មានអ្វីខ្លះដែលអ្នកត្រូវធ្វើក្នុងការប្រៀនប្រដៅកូន និងជួយពួកគេឱ្យក្លាយជាមនុស្សបែបនោះ។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចផ្តល់នូវគោលដៅយូរអង្វែងដល់កូន តាមរយៈ

- ធ្វើជាគំរូល្អដល់កូន ឬកុមារ
- បង្ហាញដល់កូននូវទង្វើ សកម្មភាព ឬអាកប្បកិរិយាគួរធ្វើ និងមិនគួរធ្វើ

- បង្រៀនកូនអំពីទម្លាប់ល្អ ក្នុងការរស់នៅប្រចាំថ្ងៃទាំងនៅក្នុងគ្រួសារ និងមជ្ឈដ្ឋាននៅជុំវិញខ្លួន
- ណែនាំអំពីការទទួលខុសត្រូវ ការឆ្លើយតប និងការដោះស្រាយបញ្ហា ដោយអហិង្សា
- ចេះអត់ធ្មត់ និងមានភាពស្មោះត្រង់ ។ល។

**គួរចងចាំ**

**រាល់អាកប្បកិរិយា សកម្មភាព និងទង្វើរបស់អ្នក**
**វាជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់កូន ឬកុមារ**
**ពីព្រោះនៅពេលគេឃើញ អ្នកធ្វើអ្វីមួយ គេនឹងអាចធ្វើតាម**
**និងរៀនតាមអ្នក!**

## II. ធាតុផ្សំទី២៖ ភាពកក់ក្ដៅ និងដែនកំណត់

### ១. ភាពកក់ក្ដៅ

ភាពកក់ក្ដៅ គឺជាការគាំទ្រ តាមរយៈការបង្ហាញក្ដីស្រឡាញ់ ដូចជា ការឱប ថើប លួងលោម បំពេរ នៅជិតកូន លេងជាមួយកូន ការប្រើពាក្យសរសើរ និងលើកទឹកចិត្ត ការយកចិត្តទុកដាក់ ការខ្វាយខ្វល់ ការឱ្យតម្លៃ ជឿជាក់ ការយល់ចិត្ត និងយល់ពីតម្រូវការ រួមទាំងការបីបាច់ថែរក្សា រាងកាយកូនឱ្យបានល្អ។

**ភាពកក់ក្ដៅ មានដូចជា៖**

- សុវត្ថិភាព និងសុខភាពផ្លូវចិត្តល្អ
- ផ្ដល់នូវសេចក្ដីស្រឡាញ់ដែលគ្មានល័ក្ខខ័ណ្ឌ
- សេចក្ដីស្រឡាញ់ថ្នាក់ថ្នមទាំងកាយ ចិត្ត និងវាចា
- សេចក្ដីគោរព
- ការតភ្ជាប់ទំនាក់ទំនងជាមួយនឹងកូន ឬកុមារដោយផ្អែកលើកម្រិតនៃការលូតលាស់ និងការអភិវឌ្ឍ
- ការយកចិត្តទុកដាក់ក្នុងការឆ្លើយតបទៅនឹងបំពេញតម្រូវការរបស់កូន

នៅក្នុងបរិយាកាសកក់ក្ដៅណាមួយកូនតែងតែចង់យកចិត្តឪពុកម្ដាយអាណាព្យាបាល ឬ អ្នកថែទាំរបស់ពួកគេ។ ភាពកក់ក្ដៅបែបនេះអាចជួយលើកទឹកចិត្តនៃការប្រព្រឹត្តតាមរបស់កូន តែរយៈពេលខ្លីប៉ុណ្ណោះ ហើយមិនអាចបង្រៀនពីគុណតម្លៃសម្រាប់រយៈពេលយូរបានឡើយ។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាចផ្ដល់ភាពកក់ក្ដៅទៅដល់កូន ឬកុមារតាមរយៈ

- និយាយពាក្យថា ម៉ែស្រឡាញ់កូន ឬ កូនជាមនុស្សសំខាន់សម្រាប់ម៉ែ។
- បង្ហាញឱ្យពួកគេដឹងថាអ្នកស្រឡាញ់ពួកគេ ទោះបីជានៅពេលដែលពួកគេធ្វើអ្វីខុសក៏ដោយ
- អាន ឬនិទានរឿងឱ្យពួកគេស្ដាប់
- បំពេរ និងឱបពួកគេ
- លួងលោមពួកគេនៅពេលពួកគេឈឺចាប់ ឬភ័យខ្លាច
- ស្ដាប់ពួកគេ
- ពិចារណាលើស្ថានភាពអ្វីមួយទៅតាមគំនិតរបស់ពួកគេ
- អរគុណនៅពេលពួកគេជួយធ្វើអ្វីមួយ
- លេងជាមួយពួកគេ
- សើចជាមួយពួកគេ
- គាំទ្រពួកគេនៅពេលដែលជួបការលំបាក
- លើកទឹកចិត្តពួកគេនៅពេលធ្វើអ្វីៗដែលលំបាក
- ប្រាប់កូន ឬកុមារថា លោកអ្នកជឿជាក់លើពួកគេ
- ទទួលស្គាល់ការប្រឹងប្រែងរបស់ពួកគេ ទោះជាបរាជ័យ ឬជោគជ័យក៏ដោយ។
- បង្ហាញឱ្យពួកគេឃើញថា អ្នកជឿទុកចិត្តលើពួកគេ។ល។

*ឧទាហរណ៍៖ កុមារស្ថិតក្នុងកម្រិតអាយុ ០ឆ្នាំ ដល់ក្រោម៣ឆ្នាំ ត្រូវការភាពកក់ក្ដៅពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ដូចជា ពរ ឱប ថើប បំពេរ បញ្ចុកអាហារ នៅជិតពួកគេ ជាដើម។ល។ កូន ឬកុមារកាន់តែត្រូវការភាពកក់ក្ដៅពីសំណាក់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ទោះជាពួកគេមានអាយុច្រើនក៏ដោយ ហើយការផ្ដល់នោះគឺមានរបៀបផ្សេងៗគ្នា។ កុមារចាប់ពីអាយុពី ៦ ដល់ ១២ ឆ្នាំឡើងទៅ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចផ្ដល់ភាពកក់ក្ដៅ តាមរយៈ ផ្ដល់ពេលវេលាសម្ដែងចេញនូវតម្រូវការរបស់គេ ផ្ដល់ជម្រើសដែលអាចឱ្យគេរៀនបាន ស្ដាប់ និងឆ្លើយតបនូវបញ្ហាដោយមានការយល់ចិត្តជាដើម។ ការផ្ដល់ភាពកក់ក្ដៅគឺជួយឱ្យកូន ឬកុមារ ទទួលបាននូវអារម្មណ៍រីករាយ មានទំនុកចិត្ត មានគុណតម្លៃ ភាពជឿជាក់ និងការយល់ចិត្ត។*

**គួរចងចាំ**

**កុមារគ្រប់រូប (កុមារា កុមារី និងកុមារពិការ)
ត្រូវការភាពកក់ក្ដៅពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ
ច្រើនដូចដែលគេត្រូវការម្ហូបអាហារ និងទីជម្រកផងដែរ។
ការស្រឡាញ់ខ្វល់ខ្វាយរបស់អ្នកចំពោះកូន គឺធ្វើនៅគ្រប់ពេលវេលាទាំងអស់
ដែលរួមបញ្ចូលទាំងនៅពេលដែលគេ បានប្រព្រឹត្តអ្វីមួយផ្ដាំផ្ដង។**

## ២. ដែនកំណត់

ដែនកំណត់ គឺជាការផ្តល់ព័ត៌មានពីសេចក្តីណែនាំ លក្ខខណ្ឌ ឬគោលការណ៍ច្បាស់លាស់ ការចរចា និងយល់ពីហេតុផលនានានូវអ្វីដែលគួរធ្វើ និងមិនគួរធ្វើ។

### ដែនកំណត់ មានដូចជា៖

- បង្កើតគោលការណ៍ណែនាំច្បាស់លាស់ពីអាកប្បកិរិយា និងរបៀបប្រព្រឹត្តនានា
- ប្រាប់ពីការរំពឹងទុក និងបញ្ជាក់ប្រាប់ពីផលប៉ះពាល់នានាឱ្យបានច្បាស់លាស់
- ប្រាប់ហេតុផលនានាសម្រាប់អាកប្បកិរិយា និងការប្រព្រឹត្ត
- ផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីជួយឱ្យធ្វើការសម្រេចចិត្តបានត្រឹមត្រូវ
- ប្រាប់ពីអ្វីដែលគួរធ្វើ ឬមិនគួរធ្វើ
- ការបង្ហាញនូវហេតុផលនានា
- ការចរចា ។ល។

ដែនកំណត់ជួយកូន ឬកុមារឱ្យរៀនអំពីអ្វីដែលមានសារៈសំខាន់ ដែលជួយពួកគេឱ្យយល់អំពីកំហុស នឹងធ្វើអ្វីមួយដែលពួកគេអាចធ្វើទៅបានដើម្បីកែកំហុសទាំងនោះ។ ដែនកំណត់ក៏បានផ្តល់ឱ្យកូនផងដែរនូវព័ត៌មានដែលគេត្រូវការ ដើម្បីទទួលបានជោគជ័យនៅពេលក្រោយទៀត។វិធីសាស្រ្តនេះ សម្រាប់ជួយពួកគេឱ្យចេះដោះស្រាយបញ្ហានានាដោយខ្លួនឯង នៅពេលមិនមានវត្តមានមនុស្សចាស់ដែលធ្លាប់ជួយពួកគេនៅទីនោះ។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចផ្តល់ដែនកំណត់ដល់កូន ឬកុមារតាមរយៈ

- រៀបចំឱ្យពួកគេត្រៀមខ្លួនសម្រាប់ស្ថានភាពពិបាកៗ ដោយប្រាប់ ពួកគេពីអ្វីៗដែលត្រូវរំពឹងទុក និងរបៀបដែលពួកគេត្រូវដោះស្រាយ
- ប្រាប់ ឬពន្យល់ហេតុផលនានាទាក់ទងនឹងច្បាប់ទម្លាប់ដែលមាន
- ពិភាក្សាពីច្បាប់ទម្លាប់ជាមួយពួកគេ និងស្តាប់ពីទស្សនៈនានារបស់ពួកគេទៅតាមអាយុ
- ជួយពួកគេឱ្យរកឃើញនូវវិធីនានាដើម្បីកែកំហុសរបស់ពួកគេ តាមរបៀបមួយដែលពួកគេរៀនបានពីកំហុសនោះ
- ដោយប្រកាន់យកភាពយុត្តិធម៌ត្រឹមត្រូវ និងចេះបត់បែន
- ជួយពួកគេរៀនអំពីរបៀបគ្រប់គ្រងអារម្មណ៍ (កំហឹង)
- ពន្យល់អំពីទស្សនៈរបស់យើង និងស្តាប់ពីទស្សនៈរបស់ពួកគេ
- បង្រៀនកូន ឬកុមារពីផលប៉ះពាល់នៃទង្វើរបស់ពួកគេចំពោះអ្នកដទៃ
- ផ្តល់ព័ត៌មានដែលពួកគេត្រូវការ ដើម្បីជួយពួកគេឱ្យធ្វើការសម្រេចចិត្តបានត្រឹមត្រូវ
- ព្យាយាមប្រាប់ ឬរំឭកពួកគេឱ្យបានញឹកញាប់

- ជៀសវាងការគំរាមកំហែង វាយ ឈប់ផ្ដល់ក្ដីស្រឡាញ់ បន្លាចថាមានសត្វចម្លែក ខ្មោច ឬ អ្វីៗដែលកុមារខ្លាច
- ធ្វើជាគំរូល្អ និងជាអ្នកនាំផ្លូវដ៏ល្អចំពោះពួកគេ។

*ឧទាហរណ៍៖ កុមារតូចស្ថិតក្នុងកម្រិតអាយុ ០ខែ ដល់ក្រោម៦ខែ ពួកគេត្រូវការភាពកក់ក្ដៅច្រើនជាងដែនកំណត់ ដោយសារក្នុងអាយុនេះ ចំពោះការស្ដាប់ និងការគិតរបស់ពួកគេមានកម្រិតនៅឡើយ។ ដូច្នេះការផ្ដល់ដែនកំណត់នានា ពួកគេមិនអាចយល់បានទេ ប៉ុន្តែខណៈពេលដែលពួកគេមានអាយុកាន់តែច្រើន ការផ្ដល់ដែនកំណត់កាន់តែមានសារៈសំខាន់ដែលត្រូវផ្ដល់ឱ្យពួកគេ ដើម្បីជួយឱ្យពួកគេមានអាកប្បកិរិយាល្អ យល់អំពីកំហុស និងធ្វើអ្វីមួយដែលអាចកែកំហុសទាំងនោះបាន។*

**គួរចងចាំ**

**កុមារគ្រប់រូប (កុមារា កុមារី និងកុមារពិការ)**
**ត្រូវការដែនកំណត់ទាំងអស់គ្នា ប៉ុន្តែការផ្ដល់ដែនកំណត់ដល់កូន ឬកុមារ**
**ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីផ្ដល់ឱ្យពួកគេទៅ**
**តាមកម្រិតអាយុ និងដំណាក់កាលនៃការអភិវឌ្ឍទើបមានប្រសិទ្ធភាព។**

## ៣. ភាពកក់ក្ដៅ និងដែនកំណត់ រួមបញ្ចូលគ្នា

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់ដល់កូន ឬកុមារក្នុងពេលតែមួយ ពីព្រោះ៖

- ការផ្ដល់ភាពកក់ក្ដៅតែមួយដោយមិនមានដែនកំណត់ កូននឹងយល់ថា ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំស្រឡាញ់ពួកគេ ហើយពួកគេនឹងមានឆន្ទៈធ្វើអ្វីមួយផ្គាប់ចិត្តឪពុកម្ដាយគេវិញ ប៉ុន្តែគេនឹងមិនដឹងពីរបៀបសម្របខ្លួនទៅនឹងមនុស្សជុំវិញពួកគេឡើយ (មានន័យថា ទំនើង ឬទំយើ)
- ការផ្ដល់តែដែនកំណត់ ដោយមិនមានភាពកក់ក្ដៅ កូនអាចមានរបៀបគិតហ្មត់ចត់ និងជាក់លាក់អំពីហេតុផលនានា ថាអ្វីដែលគួធ្វើ និងមិនគួធ្វើ តែបានត្រឹមតែជួយកូនឱ្យយល់ដឹងពីសេចក្ដីណែនាំ ច្បាប់ទម្លាប់នានាតែប៉ុណ្ណោះ។ ប៉ុន្តែពួកគេនឹងមានឆន្ទៈតិចតួចក្នុងការធ្វើតាមច្បាប់ទម្លាប់ទាំងនោះ ហើយមានអាកប្បកិរិយារឹងរូសខ្លាំងដែលគ្មានការលើកលែង និងបត់បែនរួមទាំងខ្វះការស្វែងយល់ពីទស្សនៈអ្នកដទៃ។

ភាពកក់ក្ដៅ និងដែនកំណត់គឺជាធាតុផ្សំទី២ ហើយត្រូវប្រើជាមួយគ្នាក្នុងពេលតែមួយ ព្រោះវាគឺជារបៀបមួយក្នុងការបង្រៀនកូននៅពេលគេធំឡើងដើម្បី៖

- ក្លាយជាមនុស្សមានចិត្ត និងអាកប្បកិរិយាល្អ
- ចេះគួរសម និងសម្របខ្លួនទៅតាមច្បាប់ទម្លាប់សង្គម
- រៀនពីរបៀបរស់នៅ ចុះសម្រុងក្នុងគ្រួសារ ឬមនុស្សជុំវិញខ្លួន នៅក្នុងសហគមន៍
- បង្កើត និងរក្សាមិត្តភាពល្អ

- ចេះដោះស្រាយបញ្ហាដោយខ្លួនឯង និងដោយសន្តិវិធី
- អាចធ្វើអ្វីមួយដែលត្រឹមត្រូវដោយខ្លួនឯងបាន នៅពេលដែលមនុស្សធំមិននៅ
- ឱ្យកូនយល់ពីកំហុសនានារបស់ខ្លួន និងធ្វើអ្វីៗដែលពួកគេអាចធ្វើបានដើម្បីកែកំហុសនោះ
- ឱ្យពួកគេរកឃើញនូវរបៀបនានា និងវិធីសាស្ត្រដែលគេត្រូវការ ដើម្បីដោះស្រាយបញ្ហា
- មានអាកប្បកិរិយាបែបសហប្រតិបត្តិការ និងមានអារម្មណ៍សុវត្ថិភាព ពីព្រោះពួកគេដឹងពីអ្វីដែលអ្នកដទៃទៀតរំពឹងទុកពីពួកគេ
- ប្រកាន់យកភាពយុត្តិធម៌ ត្រឹមត្រូវ ចេះបត់បែន និងយល់ចិត្តអ្នកដទៃ
- ចេះគ្រប់គ្រងកំហឹង និងជួយឱ្យគេយល់ពីផលប៉ះពាល់នៃទង្វើរបស់ខ្លួនចំពោះអ្នកដទៃ
- មិនប្រព្រឹត្តទង្វើ ឬអាកប្បកិរិយាបែបហិង្សា ដូចជា ការគំរាមកំហែង ស្តីបន្ទោស ដាក់ទណ្ឌកម្ម វាយ និងជេរប្រមាថ។ល។

**គួរចងចាំ**

**កូនអ្នកអាចក្លាយជាមនុស្សបែបណានោះ**
**គឺអាស្រ័យលើការជួយគាំទ្រ និងការផ្តល់នូវព័ត៌មានពីអ្នក!**

## ខ្លឹមសារបន្ថែម

អ្នកសម្របសម្រួលត្រូវបញ្ចូលខ្លឹមសារស្តីពី ពិការភាព និងភាពខុសគ្នាក្នុងការចិញ្ចឹមកូនស្រី និងកូនប្រុសផងដែរ។ អ្នកសម្របសម្រួលគួរសួរបំផុសខ្លះៗអំពីកុមារដែលមានពិការភាព។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គួរផ្តល់ការថែទាំជាពិសេសដើម្បីការពារកុមារដែលមានពិការភាព ពីការរំលោភបំពានគ្រប់ប្រភេទ។ កុមារទាំងនោះនឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរដូចជា ចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេ នឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យ យ៉ាងហោចណាស់មួយឆ្នាំមុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តការគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈសិក្ខាសិលា និងសកម្មភាពនានានៅក្នុងសង្គមផងដែរ។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) កំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀតអាចមានច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួនៈ

- **ថ្លង់ ឬខ្សោយការស្តាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អ តែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺ ខ្សោយការស្តាប់ (មិនអាចស្តាប់បាន ឬស្តាប់បានមិនល្អ)។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើល មិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្តាប់នោះអាចឱ្យពួកគាត់មានឱកាសរៀនភាសាបានល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ទទួលបានការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមាររបស់គាត់ដែលមានពិការភាពនេះ ដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាពទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍការប្រាស្រ័យទាក់ទង មានភាពកក់ក្តៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្នមានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការគ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។

- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយសតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់បានចប់បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹក គេង និងហូបចុកជាដើម។ មានកុមារមួយចំនួនទៀតមានបញ្ហាខ្សោយសតិបញ្ញាប្រភេទធ្ងន់ធ្ងរ។ ពួកគេមិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការអ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេសថែមទៀតពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាពីមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។

- **ខ្សោយកាយសម្បទា ឬរាងកាយ៖** កុមារមួយចំនួនទៀតមានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាចដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាពីមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល មជ្ឈមណ្ឌលស្តារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលស្តារនីតិសម្បទានៅតាមខេត្ត។

- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះអាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយលំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារ ដែលមានបញ្ហាភ្នែកតាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិនឈោងចាប់របស់របរលេង មិនលូន ឬវារ ទារកលេងកម្សាន្តតិចតួច នៅតែម្នាក់ឯងច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារក ដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការថែទាំ និងការគាំទ្រ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

| កុមារា | កុមារី |
|---|---|
| • រាងកាយមានភាពរហ័សរហួន និងសកម្ម<br>• មានជំនាញវិភាគ ក្នុងលំហ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយនឹងការធ្វើឱ្យអ្វីៗផ្លាស់ទី<br>• រៀនតាមរយៈការមើល<br>• តក់ក្រហល់ក្នុងការធ្វើអ្វីមួយ<br>• បែងចែកការងារច្បាស់ ដោយផ្ដោតអារម្មណ៍ម្ដងមួយៗ<br>• ត្រូវការពេលវេលាដើម្បីផ្ចង់អារម្មណ៍ក្នុងការធ្វើអ្វីមួយ<br>• រុករក ឬស្វែងយល់ និងចង់ដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តបង្ហាញសកម្មភាពជាងនិយាយពីអារម្មណ៍របស់គេ | • រាងកាយមានភាពទន់ភ្លន់<br>• មិនសូវមានជំនាញវិភាគ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយពណ៌<br>• រៀនតាមរយៈការស្ដាប់<br>• គិតច្បាស់លាស់មុននឹងធ្វើអ្វីមួយ<br>• មិនមានការបែងចែកច្បាស់ អាចធ្វើការច្រើនមុខក្នុងពេលតែមួយ<br>• អាចធ្វើបានភ្លាមៗ<br>• ស្ដាប់ ដើម្បីដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តនិយាយ ដើម្បីបង្ហាញពីអារម្មណ៍របស់ខ្លួន |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្ដើម អ្នកសម្របសម្រួលសំណេះសំណាល ហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួលជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្ដេចខ្លះ?<br>🗣 បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុច ដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំ ផ្ដល់ និងពិភាក្សាដើម្បីស្វែងរកវិធីដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្រ្ត |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែងចាប់ពល ទឹក គោក អាកាស (១៥នាទី) | ▪ ចូរនិយាយថា មុននឹងយើងបន្តទៅមេរៀនថ្មី យើងនឹងចាប់ផ្តើមដោយការលេងល្បែងមួយហៅថា **ទឹក គោក អាកាស**។ សុំឱ្យអ្នកចូលរួមឈរជារង្វង់ ហើយពន្យល់ថា<br>• អ្នកសម្របសម្រួលនឹងចង្អុលទៅចំនួរណាម្នាក់ ហើយស្រែកថា **ទឹក** ដូច្នេះអ្នកដែលត្រូវបានគេចង្អុលនោះត្រូវប្រាប់ឈ្មោះសត្វដែលរស់នៅក្នុងទឹកដូចជា (ត្រីអណ្តែង ត្រីកញ្ចុះ ឬកង្កែប ក្រពើ ។ល។ )<br>• បើអ្នកសម្របសម្រួលស្រែកថា **គោក** ដូច្នេះអ្នកដែលត្រូវបានគេចង្អុលនោះត្រូវប្រាប់ឈ្មោះសត្វដែលរស់នៅលើគោក ដូចជា (គោ រមាំង ក្ងាន ឆ្មា។ល។)<br>• បើអ្នកសម្របសម្រួលស្រែកថា **អាកាស** ដូច្នេះអ្នកដែលត្រូវបានគេចង្អុលនោះត្រូវប្រាប់ឈ្មោះសត្វបក្សាបក្សី ដូចជា (លលក ក្អែក ប្រចៀវ មាន់ព្រៃ ចាបស្រុក។ល។)<br>▪ លក្ខខណ្ឌនៃការលេង៖<br>១) បើមាននរណាម្នាក់ប្រាប់ឈ្មោះសត្វមួយណាហើយ អ្នកផ្សេងមិនអាចប្រាប់ឈ្មោះសត្វនោះម្តងទៀតបានទេ។<br>២) អ្នកដែលត្រូវបានគេចង្អុល ត្រូវប្រាប់ឈ្មោះសត្វឱ្យបានទាន់ពេលមុនអ្នកដែលចង្អុលរាប់ចាប់ពីលេខមួយ ដល់លេខដប់។<br>៣) អ្នកដែលប្រាប់ឈ្មោះសត្វខុសពីរបៀបលេងខាងលើ (ឧ. ត្រីចាប។ល។) ជាអ្នកចាញ់ រួចត្រូវទៅឈរនៅកណ្តាលរង្វង់ ដើម្បីសម្របសម្រួលម្តង។<br>▪ សូមបន្តលេងល្បែងនេះ រហូតដល់អ្នកចូលរួមបានលេងគ្រប់ៗគ្នា រួចទើបបន្តទៅសកម្មភាពបន្ទាប់ទៀត។ |
| ៥ | មេរៀនថ្មី៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (១) | គោលការណ៍ និងធាតុផ្សំនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន (១០នាទី) | ▪ ប្រាប់អ្នកចូលរួមថា យើងនឹងពិនិត្យមើលអំពីរបៀបនានា ដែលអាចជួយយើងក្នុងការប្រៀនប្រដៅកូនតាមបែបវិជ្ជមាន និងប្រកបដោយគុណភាព។ នៅក្នុងថ្ងៃនេះ យើងនឹងពិភាក្សាគ្នាអំពីមេរៀនថ្មីមួយទៀតគឺ **ការប្រៀនប្រដៅកូនបែបវិជ្ជមាន**។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួល បិទរូបភាពទី១ បង្ហាញពី ការប្រៀនប្រដៅកូនបែបវិជ្ជមាន រួចសួរសំណួរទៅក្រុមធំថា៖<br>☞ តើការប្រៀនប្រដៅកូនបែបវិជ្ជមាន មានន័យដូចម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ មិនវាយកូន មិនជេរកូន ស្រឡាញ់កូន។ល។<br>▪ អ្នកសម្របសម្រួល បិទរូបភាពទី២ បង្ហាញពីគោលការណ៍ទាំង ៥ និងរូបភាពទី៣ បង្ហាញពីធាតុផ្សំទាំង៤ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន រួចពន្យល់ថា ការប្រៀនប្រដៅកូនបែបវិជ្ជមានគឺជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សា រួមទាំងការមិនអើពើ ដោយផ្តោតលើគោលការណ៍សំខាន់ចំនួន ៥ និងធាតុផ្សំចំនួន ៤។ សូមពន្យល់ពីអត្ថន័យនៃគោលការណ៍នីមួយៗតាមខ្លឹមសារមេរៀន។<br>▪ សួរអ្នកចូលរួមពីអត្ថន័យនៃពាក្យ **ការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សា** បើពួកគាត់មិនយល់ សូមពន្យល់ថា ដូចអ្វីៗដែលលោកអ្នកបានពិភាក្សាកាលពីមេរៀនមុន (**ការការពារកុមារ**) មានដូចជា៖ ការមិនស្តីបន្ទោស ជេរ សំឡុត គំរាម ដាក់ងារ វាយដំ ទះ ក្តិចម្ជូល ទាត់ ធាក់ ដុត បំពុល ការដាក់ទណ្ឌកម្ម ឬទុកចោលឱ្យគាត់នៅតែម្នាក់ឯង។ល។<br>▪ អ្នកសម្របសម្រួលបន្ត ដោយសួរ<br>☞ តើការប្រៀនប្រដៅកូនបែបណា ទើបបង្ហាញថា ជាការប្រៀនប្រដៅកូនបែបវិជ្ជមាន?<br>🗣 ចម្លើយរំពឹងទុក៖ ប្រើសម្តីទន់ភ្លន់ ផ្អែមល្ហែម មិនស្តីបន្ទោស មិនជេរ មិនវាយ។ល។<br>▪ ដើម្បីឆ្លើយតបនឹងសំណួរខាងលើសូមប្រាប់ពួកគាត់ថា យើងនឹងពិភាក្សាបន្តពីរបៀបនានា ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការប្រៀនប្រដៅកូនបែបវិជ្ជមាន ដែលផ្តោតសំខាន់លើធាតុផ្សំចំនួន៤។ នៅក្នុងវគ្គនេះ យើងនឹងពិភាក្សាគ្នាអំពីធាតុផ្សំ ២ ក្នុងការប្រៀនប្រដៅកូនបែបវិជ្ជមានគឺ៖ ធាតុផ្សំទី១៖ គោលដៅយូរអង្វែង និង ធាតុផ្សំទី២៖ ភាពកក់ក្តៅ និងដែនកំណត់។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **ធាតុផ្សំទី១៖ គោលដៅយូរអង្វែង** (២០នាទី) | ▪ ដើម្បីនាំអ្នកចូលរួមឱ្យភ្ជាប់ជាមួយនឹងប្រធានបទនេះ អ្នកសម្របសម្រួលចាប់ផ្ដើមដោយសួរ<br>☞ តើកសិករមានការរំពឹងទុកអ្វីខ្លះ នៅពេលដែលពួកគាត់ធ្វើស្រែម្ដងៗ?<br>☞ ដើម្បីសម្រេចបាននូវអ្វីដែលពួកគេរំពឹងទុកនោះ តើពួកគេត្រូវធ្វើអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចបិទរូបភាពទី៤ បង្ហាញពី គោលដៅយូរអង្វែង រួចសួរ<br>☞ តាមការយល់ឃើញរបស់លោកអ្នក តើរូបភាពនេះមានន័យយ៉ាងដូចម្ដេច?<br>🗣 ចម្លើយរំពឹងទុក៖ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបញ្ជាក់ពាក្យគន្លឹះនៃពាក្យ គោលដៅយូរអង្វែង ដូចខ្លឹមសារមេរៀនខាងលើ។ បន្ទាប់អ្នកសម្របសម្រួលលើកគោលដៅយូរអង្វែងមួយ ដើម្បីធ្វើការពិភាក្សា។<br>*ឧទាហរណ៍៖ លោកអ្នកចង់ឱ្យកូនអ្នកធំឡើងក្លាយជាមនុស្សម្នាក់ដែលមាន □ការទទួលខុសត្រូវ□*<br>▪ បន្ទាប់មក សូមឱ្យអ្នកចូលរួមធ្វើការស្រមៃថា នៅពេលព្រឹកមួយដល់ពេលដែលកូនត្រូវទៅសាលារៀន អ្នកចង់ឱ្យកូនទៅសាលាទាន់ពេលវេលា ប៉ុន្តែកូនរបស់អ្នកមិនព្រមក្រោកពីដំណេកសោះ ពេលនោះអ្នកបានគិតថា កូនអ្នកនឹងទៅរៀនយឺតហើយ។<br>▪ សួរទៅអ្នកចូលរួមថា៖<br>☞ តើលោកអ្នកនឹងធ្វើដូចម្ដេចចំពោះកូន នៅពេលនោះ?<br>🗣 **សកម្មភាពទី១៖** ស្រែកហៅម្ដងហើយម្ដងទៀត ប្រើសម្លេងខ្លាំងឡើងៗ រួមទាំងការបង្ហាញអារម្មណ៍ខឹង ឬអាចចាប់ទាញកូនខ្លាំងៗ ឬអាចក្ដិច មួល ជេរ ស្ដីបន្ទោសកូន ។ល។ បន្ទាប់មក បង្ខំឱ្យដុសធ្មេញ ងូតទឹក ញ៉ាំ ស្លៀកពាក់លឿនៗ និងជូនកូនទៅសាលារៀនលឿនៗ ។ល។<br>▪ បើលោកអ្នកប្រើសកម្មភាពទី១នេះ អ្វីដែលអ្នកសម្រេចគឺ គោលដៅរយៈពេលខ្លី ព្រោះកូនអ្នកនឹងអាចទៅរៀនទាន់ពេលក្នុងថ្ងៃនេះ ប៉ុន្តែកូនអ្នកនឹងរៀនបានពីអាកប្បកិរិយាដូចជា (ស្រែក |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ខ្លាំងៗ ពាក្យសម្តីមិនពិរោះ ការក្តិចមួល ជេរ ឬអាកប្បកិរិយាលឿនៗ នៅពេលដែលគេធំឡើងជាមិនខាន)។<br>● **សកម្មភាពទី២៖** (សុខចិត្តឱ្យយឺតពេល១ថ្ងៃ និងរៀនគ្រប់គ្រងអារម្មណ៍ឱ្យបានស្ងប់) ប៉ុន្តែត្រូវជួយ និងពិភាក្សាជាមួយកូនរកហេតុផលអ្វីខ្លះ ដែលធ្វើឱ្យគាត់ទៅរៀនមិនទាន់ពេល?<br>*ឧទាហរណ៍៖ ដោយសារ ក្រចូលគេង រវល់មើលទូរទស្សន៍យប់ជ្រៅពេក មិនបានរៀបចំសំពៀតរៀនទុកជាមុន គេងជ្រុលមិនមាននរណាដាស់ឱ្យភ្ញាក់ សាលារៀននៅឆ្ងាយ ការស្លៀកពាក់ងូតទឹក ដុសធ្មេញ និងញ៉ាំអាហារយឺត ។ល។*<br>■ ប្រសិនបើលោកអ្នកប្រើសកម្មភាពទី២នេះវិញ លោកអ្នកនឹងមិនអាចសម្រេចគឺគោលដៅរយៈពេលខ្លីបានទេ ព្រោះកូនអ្នកអាចទៅរៀនយឺតពេល ឬខកខានមិនបានទៅរៀនទៀតផងក្នុងថ្ងៃនោះ ប៉ុន្តែនៅពេលលោកអ្នកជួយ ឬពិភាក្សាជាមួយគាត់ឱ្យរកឃើញពីហេតុផលដែលនាំឱ្យយឺត ហើយបន្ទាប់មកជួយឱ្យគាត់ រៀបចំផែនការដូចជា ឆាប់ចូលគេង រៀបចំកាតាបរៀន និងសម្លៀកបំពាក់ទុកជាមុន គួរភ្ញាក់នៅម៉ោងប៉ុន្មានដើម្បីរៀបចំខ្លួនទាន់ពេល និងមានអ្នកណាជួយដាស់ឱ្យភ្ញាក់ ឬដាក់ម៉ោងរោទិ៍ជាដើម ។ល។<br>☞ តើកូនលោកអ្នកនឹងរៀនបានអ្វី?<br>● ចម្លើយរំពឹងទុក៖ ការប្រាស្រ័យទាក់ទងល្អ មានទំនុកចិត្ត អាកប្បកិរិយាវិជ្ជមាន មានភាពកក់ក្តៅជាមួយឪពុកម្តាយ យល់និងចេះស្វែងរកហេតុផល ដឹងពីរបៀប ឬវិធីដោះស្រាយបែបវិជ្ជមាន មានផែនការច្បាស់លាស់។ល។<br>☞ តើកូនលោកអ្នកនឹងក្លាយជាមនុស្សបែបណានៅពេលដែលគេធំឡើង?<br>● ចម្លើយរំពឹងទុក៖ ចេះដោះស្រាយបញ្ហាដោយអាកប្បកិរិយាវិជ្ជមាន មានការប្រាស្រ័យទាក់ទងល្អ ចេះរៀបចំផែនការ ។ល។<br>☞ តើលោកអ្នកទទួលបានការរំពឹងទុកដូចម្តេចខ្លះ៖ នៅពេលដែលកូនអ្នកធំឡើង?<br>● ចម្លើយរំពឹងទុក៖ ចេះរៀបចំផែនការ ចេះដោះស្រាយបញ្ហាពិសេសគឺសម្រេចការរំពឹងទុក និងគោលដៅយូរអង្វែងនៅពេលដែលគេធំឡើងនោះគឺ ការទទួលខុសត្រូវ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួល ជួយឱ្យអ្នកចូលរួមយល់ថា ដើម្បីសម្រេចបានការរំពឹងទុក ឬគោលដៅយូរអង្វែងសម្រាប់កូន ឬកុមារក្រោមការថែទាំរបស់ពួកគាត់បាននោះ វាអាស្រ័យលើការជួយ ឬភាពជា គំរូរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។<br>**គួរចងចាំ៖**<br>**ទង្វើរបស់អ្នកវាជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់កូន ឬកុមារ ពីព្រោះនៅពេលគេឃើញ អ្នកធ្វើអ្វីមួយ គេនឹងអាចធ្វើតាមអ្នក! អាកប្បកិរិយារបស់អ្នកដែលបានធ្វើចំពោះកូន នឹងជះឥទ្ធិពលលើកូន!** |
| | | ធាតុផ្សំទី២៖ ភាពកក់ក្តៅ និង ដែនកំណត់ (២៥នាទី) | ▪ ឥឡូវនេះយើងនឹងពិនិត្យមើលធាតុផ្សំទី២ បន្តទៀតដែលជួយយើងក្នុងការប្រៀនប្រដៅកូនតាមបែបវិជ្ជមានបានប្រកបដោយគុណភាព គឺ **ភាពកក់ក្តៅ និងដែនកំណត់**។<br>▪ អ្នកសម្របសម្រួលបិទរូបភាពទី៥ បង្ហាញពី **ភាពកក់ក្តៅ និងដែនកំណត់** រួចសួរម្តងមួយៗ<br>☞ តាមការយល់ឃើញរបស់លោកអ្នក តើរូបភាពនេះមានន័យយ៉ាងដូចម្តេចខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖<br>១) ឪពុកកំពុងរំរបួសឱ្យកូនពេលកូនជិះកង់ដួល<br>២) ម្តាយកំពុងលួងលោម ឬប្រាប់ឱ្យកូនធ្វើអ្វីមួយ និងកុមារកំពុងអង្គុយលេងរបស់របរ។ល។<br>▪ បន្ទាប់មក អ្នកសម្របសម្រួល សួរចម្លើយរំពឹងទុកទី១<br>☞ នៅពេលដែលកូន ឬកុមារកំពុងឈឺ ឬភ័យខ្លាចហើយមានឪពុកធ្វើបែបនេះ តើកូន ឬកុមារ នោះមានអារម្មណ៍ដូចម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ សប្បាយ រំភើប ពេញចិត្ត ឬ **កក់ក្តៅ** ។ល។<br>☞ តើភាពកក់ក្តៅមានន័យដូចម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ ការថ្នាក់ថ្នម មិនធ្វើឱ្យខឹង ការនិយាយលួងលោម ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចសួរបន្ត<br>☞ តើសកម្មភាពអ្វីខ្លះ ដែលបង្ហាញថាលោកអ្នកផ្តល់ភាពកក់ក្តៅដល់កូន ឬកុមារ? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | • ចម្លើយរំពឹងទុកៈ ពរ ឱប ថើប បំពេរ នៅជិតកូន លេងជាមួយកូន និយាយផ្អែមល្ហែម ប្រើពាក្យលើកទឹកចិត្ត ជូនកូនទៅសាលារៀន មើលថែទាំនៅពេលកូនឈឺ ផ្ដល់ចំណីអាហារ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងពន្យល់បន្ថែមតាមខ្លឹមសារមេរៀន<br>▪ បន្ទាប់អ្នកសម្របសម្រួល សួរបន្តទៅចម្លើយរំពឹងទុកទី២<br>☞ នៅពេលដែលលោកអ្នកចង់ ឬមិនចង់ឱ្យកូន ឬកុមារធ្វើអ្វីមួយ តើលោកអ្នកធ្លាប់ធ្វើអ្វីខ្លះជាមួយពួកគេកន្លងមក?<br>• ចម្លើយរំពឹងទុកៈ ប្រាប់ ពន្យល់ លើកហេតុផល បង្រៀន ដាក់**កំណត់** ឬធ្វើឱ្យគេមើល។ល។<br>☞ តើដែន**កំណត់** មានន័យដូចម្ដេច?<br>• ចម្លើយរំពឹងទុកៈ ការដាក់ព្រំដែន ការហាមប្រាម ការឱ្យធ្វើតាម។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារមេរៀន រួចសួរ<br>☞ តើឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចផ្ដល់ដែនកំណត់ទៅកូនយ៉ាងដូចម្ដេច?<br>• ចម្លើយរំពឹងទុកៈ ប្រាប់កូនឱ្យធ្វើអ្វីមួយ បង្រៀនកូនឱ្យចេះគួរសម ចេះសុំទោសនៅពេលដែលពួកគេធ្វើអ្វីមួយខុសឆ្គង និងពន្យល់ហេតុផល។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងពន្យល់បន្ថែមតាមខ្លឹមសារមេរៀន។ |
| | | **ភាពកក់ក្ដៅ និង ដែនកំណត់ រួមបញ្ចូលគ្នា (១៥នាទី)** | ▪ បន្ទាប់មកអ្នកសម្របសម្រួលធ្វើការពន្យល់ និងជួយឱ្យអ្នកចូលរួមយល់ច្បាស់ថា ការផ្ដល់ភាពកក់ក្ដៅដល់កូនគឺត្រូវធ្វើឡើងទន្ទឹមគ្នាជាមួយនិងការផ្ដល់ដែនកំណត់ផងដែរ ដោយសួរ<br>☞ ហេតុអ្វីបានជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំចាំបាច់ត្រូវផ្ដល់នូវភាពកក់ក្ដៅ និងដែនកំណត់ក្នុងពេលតែមួយ?<br>• ចម្លើយរំពឹងទុកៈ កុំឱ្យកូនឬកុមារបានចិត្ត កុំឱ្យកូន ឬកុមារធ្វើអ្វីៗតាមទំនើងចិត្ត ឱ្យកូនមានច្បាប់ទម្លាប់ត្រឹមត្រូវ និងឱ្យកូនគិតថាយើងយកចិត្តទុកដាក់ និងស្រឡាញ់ពួកគេ។ល។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងពន្យល់បន្ថែមតាមខ្លឹមសារមេរៀន និងលើសពីនេះទៀតគឺជួយឱ្យពួកគេយល់រួមទាំងទទួលស្គាល់ថា ៖<br>*កុមារគ្រប់រូប (កុមារា កុមារី និងកុមារពិការ) ត្រូវការភាពកក់ក្តៅ និងដែនកំណត់ទាំងអស់គ្នា ប៉ុន្តែការផ្តល់ភាពកក់ក្តៅ និងដែនកំណត់ដល់កូន ឬកុមារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីផ្តល់ឱ្យពួកគេទៅតាមកម្រិតអាយុ ដំណាក់កាលលូតលាស់និងអភិវឌ្ឍ និងប្រភេទពិការភាពទើបមានប្រសិទ្ធភាពពិសេស គឺអាចសម្រេចនូវគោលដៅយូរអង្វែងរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលបានរំពឹងទុកថានៅពេលដែលពួកគេធំឡើងក្លាយជាមនុស្សបែបណានោះ*<br>*នៅពេលដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបមានការរំពឹងទុកច្បាស់លាស់ និងការផ្តល់ភាពកក់ក្តៅ រួមទាំងដែនកំណត់សមស្របតាមកម្រិតអាយុ ដំណាក់កាលលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារបានពេញលេញ គឺវាអាចជួយឱ្យមានការទំនាក់ទំនង ការប្រាស្រ័យទាក់ទង ភាពស្និទ្ធស្នាល ភាពចុះសម្រុង ការគោរពឱ្យតម្លៃ ការយល់អធ្យាស្រ័យ និងចំណងចិត្តរវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបជាមួយនឹងកូន ឬកុមារក្រោមការថែទាំរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព ដែលជាការបញ្ចៀសបានយ៉ាងស័ក្តិសិទ្ធពីការបំបែកកូនចេញពីគ្រួសារផងដែរ។*<br>**ត្រូវចងចាំ៖** គ្រប់សំណួរទាំងអស់អ្នកសម្របសម្រួល ត្រូវលើកទឹកចិត្តឱ្យពួកគាត់ឆ្លើយតាមបទពិសោធន៍នៃការចិញ្ចឹមកូនពិតៗរបស់ពួកគាត់។ |
| | | **សង្ខេបមេរៀន**<br>**(១៥នាទី)** | ▪ ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីធាតុផ្សំទី១គឺ គោលដៅយូរអង្វែង និងទី២គឺ ការផ្តល់ភាពកក់ក្តៅ និងដែនកំណត់ដល់កូន ឬកុមារក្រោមការថែទាំរបស់យើង និងរួមទាំងបានធ្វើការឆ្លុះបញ្ចាំងអំពីខ្លួនយើងកាលនៅជាកុមារភាព និងពេលដែលខ្លួនយើងក្លាយជាឪពុកម្តាយតាមរយៈបទពិសោធន៍របស់រៀងៗខ្លួនទាំងនេះ ហើយវាអាចជួយឱ្យយើងមើលឃើញនូវអ្វីដែលយើងគួរធ្វើ និងអ្វីដែលមិនគួរធ្វើជាមួយកូន ឬកុមារចាប់ពីពេលនេះតទៅ ដើម្បីជួយឱ្យកូន ឬកុមារក្រោមការថែទាំរបស់យើងក្លាយជាមនុស្សល្អទាំងផ្លូវកាយ និងផ្លូវចិត្តនៅពេលដែលពួកគេធំឡើង។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ☞ តើលោកអ្នករៀនបានអ្វីខ្លះពីការពិភាក្សាអំពីជាតុផ្សំទាំងនេះ?<br>🗣 ចម្លើយរំពឹងទុក៖<br>• ការចិញ្ចឹមកូនបែបវិជ្ជមាន គឺមិនប្រើអំពើហិង្សាដូចជា វាយ ក្តិច ជេរ គំរាមកំហែង ស្តីបន្ទោស ឬទុកកូនចោល។ល។<br>• ឪពុកម្តាយត្រូវធ្វើអ្វីខ្លះជាមួយកូន ដើម្បីសម្រេចគោលដៅយូរអង្វែង នៅពេលដែលកូនធំឡើងមានដូចជា ពន្យល់ បង្រៀន ប្រាប់ ជួយគាំទ្រ ឬធ្វើជាគំរូ។ល។<br>• ដឹងពីរបៀបនានាសម្រាប់ផ្តល់ភាពកក់ក្តៅ និងដែនកំណត់ជាមួយកូន។<br>• ដឹងថាភាពកក់ក្តៅ និងដែនកំណត់ត្រូវផ្តល់ដល់កូនទន្ទឹមគ្នាក្នុងពេលតែមួយ។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបញ្ជាក់បន្ថែមតាមខ្លឹមសារគោលបំណងនៃមេរៀន។<br>▪ បន្ទាប់មកអ្នកសម្របសម្រួលសួរបន្ត<br>☞ បើយើងគិត និងឆ្លើយដោយស្មោះត្រង់អំពីខ្លួនឯងថា នៅមុនពេលរៀន និងក្រោយពេលរៀន តើមាន «ប្រតិកម្ម» ខុសគ្នាដូចម្តេចខ្លះ ? ដូច្នេះអ្នកទាំងអស់គ្នាត្រូវតែចងចាំថា៖<br><br>**ទង្វើរបស់អ្នកវាជាកត្តាជះឥទ្ធិពលយ៉ាងខ្លាំងដល់កូន ឬកុមារ ពីព្រោះនៅពេលគេឃើញអ្នកធ្វើអ្វីមួយ គេនឹងអាចធ្វើតាមអ្នក!**<br><br>**កុមារគ្រប់រូប (កុមារា កុមារី និងកុមារពិការ) ត្រូវការដែនកំណត់ទាំងអស់គ្នា ប៉ុន្តែការផ្តល់ដែនកំណត់ដល់កូន ឬកុមារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីផ្តល់ឱ្យពួកគេទៅតាមកម្រិតអាយុ និងដំណាក់កាលនៃការអភិវឌ្ឍ ទើបមានប្រសិទ្ធភាព។** |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៦ | <u>ការឆ្លុះបញ្ចាំង</u> | **ការឆ្លុះបញ្ចាំងមេរៀន (៥នាទី)** | ▪ អ្នកសម្របសម្រួលសួរ៖<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្ដេចដែរទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្ដេចនៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ (៥នាទី)** | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្ដើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង<br>▪ ធ្វើឱ្យប្រសើរឡើងនូវការបង្កើតគោលដៅយូរអង្វែង ការផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់សម្រាប់កូន ឬកុមារ និងគ្រប់គ្រងអាកប្បកិរិយារួមទាំងកាត់បន្ថយហិង្សាក្នុងខ្លួនដែលតែងតែកើតមាន ដើម្បីអាចអនុវត្តនូវធាតុផ្សំទាំងនេះសម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមានទៅអនាគត។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

# រូបភាពទី ១



# ការប្រៀនប្រដៅកូនបែបវិជ្ជមាន

# រូបភាពទី ២

## គោលការណ៍ទាំង ៥
## នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន

គោលការណ៍ទី ១ ៖ ភាពអហិង្សា

គោលការណ៍ទី ២ ៖ ផ្តោតទៅលើការរកដំណោះស្រាយ

គោលការណ៍ទី ៣ ៖ ការគោរព

គោលការណ៍ទី ៤ ៖ ផ្អែកលើដំណាក់កាលលូតលាស់
និងអភិវឌ្ឍកុមារ

គោលការណ៍ទី ៥ ៖ ផ្អែកលើអនុសញ្ញា
អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

# រូបភាពទី ៣

## តើអ្វីទៅជាការប្រៀនប្រដៅកូនបែបវិជ្ជមាន ?

ការប្រៀនប្រដៅកូនបែបវិជ្ជមាន គឺជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សា រួមទាំងការមិនអើពើ ដោយផ្តោតទៅលើគោលការណ៍សំខាន់ ៥ និងធាតុផ្សំចំនួន ៤ ដូចខាងក្រោម៖



១) គោលដៅយូរអង្វែង



២) ភាពកក់ក្តៅ និងដែនកំណត់



៣) យល់អំពីការគិត និងអារម្មណ៍



៤) ដោះស្រាយបញ្ហា

# រូបភាពទី ៤



# គោលដៅយូរអង្វែង

# រូបភាពទី ៥



# ភាពកក់ក្ដៅ និងដែនកំណត់

# វគ្គទី៨
# មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (២)

## សេចក្ដីផ្ដើម

យោងទៅតាមលទ្ធផលស្រាវជ្រាវឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការ UNICEF ស្ដីពីអំពើហិង្សាលើកុមារ បានបញ្ជាក់ថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតមានដូចជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ ដូចនេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគួរសិក្សាស្វែងយល់ពីអំពើហិង្សា ការមិនអើពើ និងផលប៉ះពាល់លើកុមារ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការបញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ ដែលកន្លងមកពួកគាត់តែងតែគិតថាការអប់រំប្រដៅកូនមានរបៀបពីរគឺ **ត្រជាក់** (អហិង្សា) **និងក្ដៅ** (ហិង្សា) ពិសេសគឺយោងទៅលើនិស្ស័យរបស់កូន ឬកុមារ។ ការអប់រំប្រដៅកូនដោយបែបក្ដៅដូចជាការស្ដីបន្ទោស ជេរ គំរាម សំឡុត ដាក់ទណ្ឌកម្ម វាយដំគឺគ្រាន់តែចង់ឱ្យកូនៗ ឬកុមារ មានអាកប្បកិរិយាល្អតែប៉ុណ្ណោះ។ ដូច្នេះពួកគាត់គិតថាការធ្វើបែបនេះវាមិនមែនជាការរំលោភបំពាននោះទេ ដោយសារមានការគិត ឬទម្លាប់បែបនេះហើយទើបនាំឱ្យមានការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាបន្តកើតមានលើកូន ឬកុមារ នៅក្នុងគ្រួសារមួយចំនួនធំ។

ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគិត ឬទម្លាប់ខាងលើ យើងក៏បានរៀបចំចងក្រងប្រធានបទនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន ដែលជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដែលផ្ដោតទៅលើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន៤ ក្នុងគោលបំណង ជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកំណត់បានពីរបៀបនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន និងការដោះស្រាយបញ្ហាជាមួយកូន ឬកុមារតាមដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍកុមារ ព្រមទាំងជ្រើសរើស និងអនុវត្តនូវវិធីសាស្ត្រ ឬរបៀបចិញ្ចឹមកូនបែបវិជ្ជមាន ដោយប្រើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន ៤។

# ១. គោលការណ៍ទាំង៥

គោលការណ៍
**ទី១**

## ភាពអហិង្សា

គឺជាការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកូន ឬកុមារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

---

គោលការណ៍
**ទី២**

## ផ្ដោតទៅលើការរកដំណោះស្រាយ

គឺជាការស្ដាប់ និងការបង្ហាញហេតុផល រួមទាំងការពិភាក្សា និងការស្វែងរកវិធី ឬរបៀបណាមួយដើម្បីដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ឬបែបវិជ្ជមានដែលមានការចូលរួមយល់ព្រម និងការចរចាគ្នា។

---

គោលការណ៍
**ទី៣**

## ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នា ក្នុងភាពជាមនុស្ស ដោយគ្មានការរើសអើង និងវិនិច្ឆ័យ។

---

គោលការណ៍
**ទី៤**

## ផ្ដោតលើដំណាក់កាលលូតលាស់ និងអភិវឌ្ឍកុមារ

គ្រប់កុមារទាំងអស់ □កុមារា កុមារី ឬកុមារដែលមានពិការភាព□ មានការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ទៅតាមកម្រិតអាយុរបស់ពួកគេ ដូចជាការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈ ការគិត និងអារម្មណ៍ ដូច្នេះការបំពេញទៅនឹងតម្រូវការរបស់ពួកគេ គឺមានភាពខុសៗគ្នា។

---

គោលការណ៍
**ទី៥**

## ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

សិទ្ធិកុមារ គឺជាអ្វីៗដែលកុមារមាន និងអ្វីដែលមនុស្សទទួលខុសត្រូវចំពោះកុមារ។ ពួកគេត្រូវធានាថា កុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំ និងនិយាយនូវអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ។ កុមារទាំងអស់ រួមទាំងកុមារដែលមានពិការភាពទទួលបាននូវសិទ្ធិទាំងនេះ មិនថាពួកគេជានរណា មានពណ៌សម្បុរអ្វី ភាសាអ្វី សាសនាណា ក្មេងប្រុស ឬក្មេងស្រី អ្នកក្រ ឬអ្នកមានឡើយ។ ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក បានចុះហត្ថលេខាលើឯកសារនេះ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មានន័យថា ពួកគេបានសន្យានឹងធ្វើអ្វីៗទាំងអស់ដើម្បីធានាថា កុមារទាំងអស់ទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។

# ២. ធាតុផ្សំទាំង៤

| ធាតុផ្សំទី១៖ | ធាតុផ្សំទី២៖ | ធាតុផ្សំទី៣៖ | ធាតុផ្សំទី៤៖ |
|---|---|---|---|
| គោលដៅយូរអង្វែង | ភាពកក់ក្ដៅ និងដែនកំណត់ | យល់អំពីការគិត និងអារម្មណ៍ | ដោះស្រាយបញ្ហា |

កាលពីវគ្គមុន លោកអ្នកបានធ្វើការពិភាក្សាគ្នារួចមកហើយអំពីគោលការណ៍សំខាន់ចំនួន ៥ និងធាតុផ្សំចំនួន ២ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន។ នៅក្នុងវគ្គនេះ យើងនឹងលើកយកធាតុផ្សំទី៣ **យល់អំពីការគិត និងអារម្មណ៍** សម្រាប់កូន ឬកុមារ ដែលមានអាយុពី ០ឆ្នាំដល់១២ឆ្នាំ មកធ្វើការពិភាក្សាគ្នា និងហាត់អនុវត្ត។ ដោយឡែកធាតុផ្សំចំនួន ១ ទៀតនឹងត្រូវសិក្សានៅវគ្គបន្ទាប់។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• ស្វែងយល់ពីការគិត និងអារម្មណ៍របស់កុមារ តាមរយៈ ការលូតលាស់ និងអភិវឌ្ឍ របស់កុមារ ដែលមានអាយុពី ០ឆ្នាំ ដល់ ១២ឆ្នាំ។<br>• ទទួលយកនូវរបៀបផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់សម្រាប់កូន ឬកុមារទៅតាម តម្រូវការនានារបស់ពួកគេនៅតាមដំណាក់កាលផ្សេងៗ នៃការលូតលាស់ និង អភិវឌ្ឍ។<br>• ទទួលស្គាល់អំពីការគិត និងអារម្មណ៍នានា ដែលបណ្ដាលឱ្យកូន ឬកុមារមាន អាកប្បកិរិយាប្រឆាំងនឹងអ្វីៗដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបាន រំពឹងទុក។ |
| **រយៈពេល** | **១៥០ នាទី** |
| **សម្ភារៈ ដែលត្រូវការ** | • រូបភាពទី ១ បង្ហាញពី ការអភិវឌ្ឍកុមារ<br>• រូបភាពទី ២ បង្ហាញពី ការលូតលាស់ និងអភិវឌ្ឍគភ៌ក្នុងផ្ទៃ<br>• រូបភាពទី ៣ បង្ហាញពី ការចុះសំបុត្រកំណើត<br>• រូបភាពទី ៤ បង្ហាញពី កុមារចេះមើល និងស្ដាប់ឮសំឡេង<br>• រូបភាពទី ៥ បង្ហាញពី កុមារចេះក្រឡាប់<br>• រូបភាពទី ៦ បង្ហាញពី កុមារចេះលូន<br>• រូបភាពទី ៧ បង្ហាញពី កុមារចេះតោងឈរ និងដើរតេះតះ |

- រូបភាពទី ៨ បង្ហាញពី កុមាររៀនប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ
- រូបភាពទី ៩ បង្ហាញពី កុមាររៀនពីការអនាម័យ
- រូបភាពទី ១០ បង្ហាញពី កុមារចេះលេង និងចែករំលែកជាមួយមិត្តភក្តិ
- រូបភាពទី ១១ បង្ហាញពី គេងឱ្យបានគ្រប់គ្រាន់
- រូបភាពទី ១២ បង្ហាញពី ញ៉ាំឱ្យទៀងពេលវេលា
- រូបភាពទី ១៣ បង្ហាញពី ការមានជម្លោះច្រើនជាមួយបងប្អូន
- រូបភាពទី ១៤ បង្ហាញពី ធ្វើអ្វីមួយមិនបានគិតពីគ្រោះថ្នាក់
- រូបភាពទី ១៥ បង្ហាញពី អាកប្បកិរិយាផ្ដើន
- រូបភាពទី ១៦ បង្ហាញពី ការត្រាប់តាមមនុស្សធំ
- រូបភាពទី ១៧ បង្ហាញពី ចាប់ផ្ដើមមានទំនាក់ទំនងខាងក្រៅ
- រូបភាពទី ១៨ បង្ហាញពី ការចង់ដឹង និងឆ្ងល់ច្រើន
- រូបភាពទី ១៩ បង្ហាញពី ការគ្មានសណ្ដាប់ធ្នាប់
- រូបភាពទី ២០ បង្ហាញពី ការចូលរៀន
- រូបភាពទី ២១ បង្ហាញពី ការមិនចុះសម្រុងជាមួយភេទផ្ទុយគ្នា
- រូបភាពទី ២២ បង្ហាញពី អាកប្បកិរិយាប្រថុយប្រថាន
- រូបភាពទី ២៣ បង្ហាញពី ធ្វើអ្វីតាមមិត្តភក្តិ
- រូបភាពទី ២៤ បង្ហាញពី ផលប៉ះពាល់ នៃការរំលោភបំពានលើការអភិវឌ្ឍខួរក្បាលកុមារ
- រូបភាពទី ២៥ បង្ហាញពី ធាតុផ្សំទី៣៖ យល់អំពីការគិត និងអារម្មណ៍
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ
- កម្រាល សម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀម សម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រា អំពីគោលការណ៍ដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

## ខ្លឹមសារលម្អិត

# I. ធាតុផ្សំទី៣៖ យល់អំពីការគិត និងអារម្មណ៍

## ១. និយមន័យ

ការយល់អំពីការគិត និងអារម្មណ៍គឺជាការយល់ដឹងពីសេចក្ដីត្រូវការរបស់កូនឬកុមារដែលផ្ដោតលើដំណាក់កាល នៃការលូតលាស់ និងអភិវឌ្ឍ រួមទាំងការគោរពឱ្យតម្លៃពួកគេជាមនុស្សម្នាក់ ដែលមានភាពសំខាន់ដោយឡែកៗពីគ្នា។

*ឧទាហរណ៍ កុមារម្នាក់ពូកែខាងគូរគំនូរ ប៉ុន្តែកុមារម្នាក់ទៀតពូកែច្រៀង។ល។*

### ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាចស្វែងយល់អំពីការគិត និងអារម្មណ៍របស់កូន ឬកុមារ តាមរយៈ

- ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គួរព្យាយាមស្វែងយល់អំពីហេតុផលនានាដែលធ្វើឱ្យកូនរបស់លោកអ្នកមានអាកប្បកិរិយាបែបនោះ។
- កុមារគ្រប់រូប (កុមារា កុមារី និងកុមារ ដែលមានពិការភាព) ត្រូវការឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ស្វែងយល់អំពីការគិត និងអារម្មណ៍របស់ពួកគេ ដោយផ្ដល់ឱ្យមានភាពស្មើគ្នារវាងកូនស្រី និងកូនប្រុស ព្រោះកុមារមានការលូតលាស់ និងអភិវឌ្ឍផ្នែកបញ្ញាស្មារតី អារម្មណ៍ និងសង្គម ដោយមានការប្រែប្រួលទៅតាមកម្រិតអាយុ ជីវសាស្ត្រ និងរៀនពីមជ្ឈដ្ឋានជុំវិញ ដែលពួកគេរស់នៅ។ ក្នុងន័យនេះ ប្រសិនបើឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ មានការយល់ដឹងអំពីបម្រែបម្រួលរបស់កូន ឬកុមារ អាចនាំឱ្យពួកគាត់ងាយស្រួលបត់បែន និងទទួលយកនូវអាកប្បកិរិយានានារបស់ពួកគេ ហើយនឹងអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនឯង ហើយអាចជៀសវាង និងកាត់បន្ថយភាពមិនចុះសម្រុងគ្នាជាមួយកូន ឬកុមារ។

*ឧទាហរណ៍*

*១) កូន ឬកុមារអាយុពី ៣-៥ឆ្នាំ មានការសួរសំណួរច្រើន (ប្រើសំណួរប្រដេញ) ដែលពេលខ្លះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ មានការធុញទ្រាន់ និងមិនបានធ្វើការឆ្លើយតបដ៏សមរម្យផងដែរ។ ក្នុងដំណាក់កាលនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវតែឆ្លើយតបទៅនឹងការគិត និងអារម្មណ៍របស់កូន ព្រោះការឆ្លើយតបនេះ អាចកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការរៀនសូត្ររបស់ពួកគេ ដោយផ្ដល់នូវភាពកក់ក្ដៅរួមទាំងដែនកំណត់ តាមរយៈការឆ្លើយតបដោយការគោរពទៅកាន់សំណូមពរពួកគេ។*

*២) កូន ឬកុមារអាយុពី ៦-១២ឆ្នាំ ចង់ជួយធ្វើការងារផ្ទះដូចជា៖ បោសផ្ទះ បោកខោអាវ ឬដាំស្ល។ល។ ពួកគេអាចរៀន និងអនុវត្តបំណិនជីវិតដែលមានសារៈសំខាន់ដោយការសង្កេតមើល និងការជួយធ្វើការងារផ្សេងៗទាំងអស់នោះ។ នៅពេលកូន ឬកុមារជួយធ្វើការពួកគេអាចធ្វើខុសច្រើន ព្រោះពួកគេមិនអាចធ្វើអ្វីៗបានល្អឥតខ្ចោះនៅឡើយ ដោយសារពួកគេមានបទពិសោធន៍តិចតួចចំពោះកិច្ចការទាំងនោះ។ ដូច្នេះ ពួកគេមិនអាចធ្វើតាមតម្រូវចិត្តយើងបាននោះទេ ប៉ុន្តែនេះជារបៀបដែលកូន ឬកុមារមានឱកាសរៀនសូត្រពីកំហុសនោះ។*

**គួរចងចាំ**

- **កូនៗ ឬកុមារតូចមិនមែនធ្វើអ្វីៗ ដើម្បីឆាឆៅ រំខាន ឬធ្វើឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំខឹងនោះទេ។**
- **ជាធម្មតាកូនៗ ឬកុមារក្នុងវ័យជំទង់ព្យាយាមបំពេញតម្រូវការរបស់ខ្លួនទៅតាមអាយុ ឬដំណាក់កាលនៃការលូតលាស់ ការអភិវឌ្ឍ និងមជ្ឈដ្ឋានដែលពួកគេរស់នៅ។**

- មានតែការផ្តល់ភាពកក់ក្តៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់អំពីការគិត និងអារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីៗ ដែលពួកគេគួរធ្វើ និងមិនគួរធ្វើ។

## II. ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ

### ១. និយមន័យ

ការលូតលាស់ និងអភិវឌ្ឍរបស់កុមារគឺ សំដៅលើដំណើរការ ដែលកុមារមានលទ្ធភាពអាចធ្វើកិច្ចការ កាន់តែលំបាក និងស្មុគស្មាញទៅៗ នៅពេល ដែលកុមារមានអាយុកាន់តែច្រើនឡើង។ ការអភិវឌ្ឍខុសប្លែកពីការលូតលាស់ ដែលការលូតលាស់សំដៅលើកុមាររីកធំធាត់ផ្នែកទំហំរាងកាយ។

### ២. ដំណាក់កាល នៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ (អាយុពី ០ឆ្នាំ រហូតដល់ ១២ឆ្នាំ)

#### ២.១. ការលូតលាស់ និងការអភិវឌ្ឍគភ៌ក្នុងផ្ទៃ

- នៅពេលរួមភេទ មេជីវិតឈ្មោលចូលទៅជួបមេជីវិតញី។ ៥០% របស់ម្តាយ ៥០% របស់ឪពុកបង្កើតបានជាគភ៌ ១០០% នៃជីវិតថ្មីមួយ។ ពេលនោះគភ៌ចាប់ផ្តើមធ្វើការបំបែកខ្លួន (មីតូស) ៥០% ជាកូន ៥០% ជាសុក។ គភ៌ធ្វើដំណើរមកកាច់សំបុកក្នុងស្បូន។
- **គភ៌មានអាយុ ២១ថ្ងៃ៖** បេះដូងចាប់ផ្តើមលោត និងមានទំហំ ៣ សង់ទីម៉ែត្រ។
- **គភ៌មានអាយុ ៣ខែ៖** គភ៌លូតលាស់ពេញលក្ខណៈជាមនុស្ស។ ប្រព័ន្ធប្រសាទ (ខួរក្បាល) ចាប់ផ្តើមផ្សារភ្ជាប់គ្នា គភ៌អាចកម្រើកបានតិចៗ និងអាចកំណត់ភេទបាន។
- **គភ៌មានអាយុ ៤ខែ៖** ការកំណត់ភេទបានកាន់តែច្បាស់ គភ៌អាចស្តាប់ឮសម្លេងបេះដូងម្តាយ និងសំលេងខាងក្រៅ។ គភ៌អាចដឹងពីស្ថានភាព ដែលបានកើតឡើងនៅខាងក្រៅតាមរយៈម្តាយ ព្រោះកូនអាចស្មានពីសំឡេងខាងក្រៅជាមួយនឹងអារម្មណ៍របស់ម្តាយ។ ដូចនេះម្តាយត្រូវមានសុខភាពផ្លូវកាយ និងផ្លូវចិត្តល្អ ដើម្បីឱ្យគភ៌លូតលាស់ និងអភិវឌ្ឍបានល្អ ហើយក៏ត្រូវការការយកចិត្តទុកដាក់ពីឪពុកក្នុងការថ្នាក់ថ្នមម្តាយ ថែរក្សាម្តាយឱ្យមានសុខភាពល្អ និយាយទៅកាន់គភ៌ក្នុងផ្ទៃ ដើម្បីកូនបានទទួលស្គាល់សំឡេងឪពុកម្តាយ និងមានអារម្មណ៍កក់ក្តៅ។
- **គភ៌មានអាយុ ៧ខែ៖** ផ្នែកនៃរូបកាយរបស់គភ៌ត្រូវបានបំពេញគ្រប់លក្ខណៈដូចជាមានដុះក្រចកដៃជើង សក់ ភ្នែកអាចបិទបើក ម្រាមដៃមានចលនាអាចចាប់ មាត់បិទបើក និងរៀនភ្លក្សទឹកភ្លោះ។ បើមានការសម្រាលពេលគភ៌ក្នុងអាយុនេះ កូនអាចរស់តែសុខភាពមិនទាន់រឹងមាំដូចគភ៌ដែលគ្រប់ខែទេ (៩ខែ១០ថ្ងៃ)។ ចាប់ពីចន្លោះខែទី៧ទៅខែទី៨ គភ៌បង្វិលក្បាលចុះក្រោម។
- **គភ៌មានអាយុ ៩ខែ៖** ត្រៀមខ្លួនកើតចេញមក (សម្រាល)។

នៅពេល ដែលកូនចាប់កំណើត ស្ត្រីជាម្ដាយយកចិត្តទុកដាក់ថែបំប៉នសុខភាពខ្លួនឯង ដោយគិតទៅដល់របបអាហារដែលមានសុខភាពល្អដល់គភ៌ក្នុងផ្ទៃ និងជៀសវាងការប្រើប្រាស់គ្រឿងញៀន បារី និងគ្រឿងស្រវឹង ព្រោះវាអាចប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍរបស់គភ៌ក្នុងផ្ទៃផងដែរ។ ម្យ៉ាងទៀតព្យាយាមនិយាយលេងជាមួយគភ៌ដោយក្ដីស្រឡាញ់ និងស្វែងរកកន្លែងសម្រាលកូន ដែលមានសុវត្ថិភាព (មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ជាដើម)។ ពិគ្រោះយោបល់អំពីការថែទាំមុនពេលសម្រាលឱ្យបានយ៉ាងតិច៤ដង និងចាក់ថ្នាំបង្ការ ដើម្បីជួយធានានូវការមានផ្ទៃពោះដែលមានសុខភាពល្អ ដោយមានការចូលរួមរបស់ឪពុកផងដែរ។

## ២.២. ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារអាយុពី ០ឆ្នាំ ដល់អាយុក្រោម ៣ឆ្នាំ

ក្រោយពេលសម្រាលភ្លាម ទារកឃំ ដើម្បីឱ្យសួតមានដំណើរការ។ អំឡុងពេលនៅក្នុងផ្ទៃទារកស្គាល់តែសំឡេងបេះដូងម្ដាយ ក្រោយពេលសម្រាល ទារកប៉ះនឹងបរិយាកាសខាងក្រៅ ហើយគេត្រូវការពេលវេលាដើម្បីសាំ។ ដូចនេះ ដើម្បីជួយផ្នែកផ្លូវចិត្តរបស់ទារក គេត្រូវដាក់ទារកលើទ្រូងរបស់ម្ដាយដើម្បីជួយឱ្យទារកមានអារម្មណ៍កក់ក្ដៅ និងយល់ថាម្ដាយរបស់គេមិនបានបោះបង់គេទេ។ ផ្នែកចិត្តសាស្ត្ររបស់កូនគិតថារូបគេ និងម្ដាយជាមនុស្សតែមួយ ព្រោះអ្វីៗទាំងអស់កូនត្រូវពឹងម្ដាយ និងត្រូវការម្ដាយដើម្បីជួយគេក្នុងការចម្រើនវ័យ។ ពេលនោះដែលទារកអាចបៅដោះភ្លាម ដើម្បីទទួលបានទឹកដោះដំបូង ដែលមានសារៈសំខាន់ក្នុងការជួយបង្កើនភាពសាំ និងប្រព័ន្ធការពាររបស់ទារកក្នុងមួយជីវិត ហើយអាចជួយដល់ប្រព័ន្ធផលិតទឹកដោះរបស់ម្ដាយ ព្រមទាំងកាត់បន្ថយជំងឺមហារីកដោះរបស់ម្ដាយនាពេលអនាគត។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក៏គួរយកចិត្តទុកដាក់ក្នុងការថែទាំទារក និងបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់យ៉ាងតិចបំផុតរយៈពេល៦ខែ។

- **ការចុះសំបុត្រកំណើត៖** ត្រូវទៅចុះសំបុត្រកំណើតឱ្យកូន ឱ្យបានមុន ៣០ថ្ងៃបន្ទាប់ពីសម្រាលរួច និងអនុវត្តការថែទាំសុខភាពឱ្យបានត្រឹមត្រូវ ដូចជា ការចាក់ថ្នាំបង្ការតាមការកំណត់អាយុរបស់ក្រសួងសុខាភិបាល ព្យាបាលជំងឺ ស្វែងរកសេវាត្រួតពិនិត្យការលូតលាស់ និងអភិវឌ្ឍរបស់កូន។
- **កុមារចាប់ផ្ដើមចេះមើល ស្ដាប់ឮសំឡេង និងងាកទៅរកសំឡេងនោះ៖** សម្រាប់កូនស្រីអាចមើលឃើញក្នុងអាយុប្រហែល ១ខែកន្លះ ហើយគេចាប់អារម្មណ៍លើពណ៌។ ឯកូនប្រុសអាយុប្រហែល ៣ខែ មានការចាប់អារម្មណ៍លើវត្ថុដែលមានចលនា។ ដូចនេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាចរៀបចំឱ្យមានពណ៌ផ្សេងៗ (ពិសេសពណ៌ស និងខ្មៅ) ឬវត្ថុ ដែលមានចលនា ដើម្បីជួយកូន ឬកុមារទទួលបានការលូតលាស់ និងការអភិវឌ្ឍ។

សំខាន់ណាស់សម្រាប់ទារកក្នុងការរៀននិយាយតាមរយៈការស្តាប់សូរ ហើយកកែកករតាម។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរនិយាយទៅកាន់ទារកក៏ដូចជានិទានរឿងឱ្យពួកគេស្តាប់ជាទៀងទាត់។ កូន ឬកុមារក៏រៀនពីសេចក្តីស្រឡាញ់ និងស្រឡាញ់ខ្លួនឯង តាមរយៈការទទួលសេចក្តីស្រឡាញ់ពីឪពុកម្តាយ ព្រោះគេគិតថា ខ្លួនគេមានតម្លៃ។ ដូចនេះ ទារកយំ ដើម្បីប្រាប់ទៅឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំថា គេកំពុងមានបញ្ហា ហើយការយំរបស់ទារក បង្ហាញពីមូលហេតុ និងតម្រូវការខុសៗគ្នាដូចជា៖ ឃ្លាន សត្វទិច ឈឺពោះ ឬទាមទារការចាប់អារម្មណ៍។ល។ ទារកក៏យល់ផងដែរពីកាយវិការ និងពាក្យសម្តី ដែលបង្ហាញពីសេចក្តីស្រឡាញ់។

- **កុមាររៀនក្រឡាប់៖** ចាប់ពីអាយុបីខែ កូន ឬទារកអាចរៀន និងប្រឹងក្រឡាប់។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរៀបចំកន្លែងសម្រាប់ទារក និងមិនត្រូវដាក់ទារកនៅកន្លែង ដែលមានទីទួល ឬខ្ចស់ដែលអាចបណ្តាលឱ្យកូន ឬទារកមានគ្រោះថ្នាក់។
    - **អាយុពី៤ទៅ៦ខែ៖** ទារកចាប់ផ្តើមធ្វើត្រាប់តាម និងស្គាល់ឈ្មោះវត្ថុ សត្វខ្លះៗ។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ព្យាយាមពន្យល់ និងផ្តល់ព័ត៌មានពិត។ ឪពុកម្តាយ អាណាព្យាបាល ឬ អ្នកថែទាំសូមធ្វើសកម្មភាពជាមួយកូន ឬកុមារដូចជា៖ លេង ច្រៀង និយាយ អាន និងនិទានរឿង។ ការធ្វើសកម្មភាពទាំងនេះជាមួយគាត់ នឹងជំរុញឱ្យមានការលូតលាស់ និងអភិវឌ្ឍ។
    - **ទារកចាប់ពីអាយុ៦ខែ៖** ក្រោយរយៈពេល៦ខែ កូន ឬកុមារចាប់ផ្តើមញ៉ាំអាហារ ដូចជា ស៊ុត ត្រី សាច់ បន្លែ ផ្លែឈើ។ល។ សូមសួរបុគ្គលិកមណ្ឌលសុខភាពដែលនៅជិតអ្នក ពីវិធីបន្ថែមអាហារទាំងនេះទៅក្នុងរបបអាហារប្រចាំថ្ងៃរបស់កូន និងស្នើឱ្យពួកគាត់តាមដាន និងកត់ត្រាពីការកើនទម្ងន់កូនអ្នកនៅក្នុងប័ណ្ណលឿង។

| បរិមាណអាហារដែលត្រូវផ្តល់ឱ្យ | | | |
|---|---|---|---|
| **អាយុកុមារ** | **សណ្ឋានអាហារ** | **ចំនួនពេល** | **បរិមាណក្នុង១ពេល** |
|  **៦ខែ** | ផ្តើមពីបបរខាប់ គ្រប់គ្រឿងកិនឱ្យម៉ត់ និងអាហារបន្ថែម។ *ឧទាហរណ៍៖ ចេក ដំឡូងផ្ទា ល្ពៅ។ល។* | ផ្តល់អាហារ ២ពេលក្នុង ១ថ្ងៃ ជាមួយការបំបៅដោះម្តាយ ឱ្យបានញឹកញាប់ យ៉ាងហោច ៨ដងក្នុង១ថ្ងៃ | ២-៣ ស្លាបព្រាបាយពេញ ក្នុង១ពេល |
|  **៧-៨ខែ** | បន្តការផ្តល់បបរខាប់ កិនលាយជាមួយអាហារ | បង្កើនដល់ ៣ដងក្នុង១ថ្ងៃ ជាមួយការបំបៅដោះម្តាយឱ្យបានញឹកញាប់ យ៉ាងហោច | បង្កើនបន្តិចម្តងៗ រហូតដល់ ១/២នៃចានចង្កឹះក្នុង១ពេល |

| បរិមាណអាហារដែលត្រូវផ្តល់ឱ្យ | | | |
|---|---|---|---|
| **អាយុកុមារ** | **សណ្ឋានអាហារ** | **ចំនួនពេល** | **បរិមាណក្នុង១ពេល** |
|  ៩-១១ខែ | កិន ឬចិញ្ច្រាំ អាហារឱ្យម៉ត់ និងអាហារដែលកុមារអាចកាន់បាន | អាហារពេល ៣ពេល និងអាហារក្រៅពេល ១ពេល នៅចន្លោះពេលបាយ និងជាមួយការបំបៅដោះម្តាយ យ៉ាងហោច ៦ដងក្នុង ១ថ្ងៃ | បង្កើនបន្តិចម្តងៗ រហូតដល់ពេញ ១ចានចង្កឹះ |
|  ១២-២៤ខែ | អាហារគ្រួសារ កិន ឬ ចិញ្ច្រាំ បើចាំបាច់ បបរខាប់ | អាហារពេល ៣ពេល និង អាហារក្រៅពេល ២ពេល នៅចន្លោះពេលបាយ និងជាមួយការបំបៅដោះម្តាយយ៉ាងហោច ៦ដងក្នុង ១ថ្ងៃ | ពេញ១ចានចង្កឹះ |

**អាហារ ដែលខាប់ គឺនៅជាប់ជាមួយនឹងស្លាបព្រាមិនធ្លាក់ចុះនៅពេលផ្អៀង។ អាហារខាប់ គួរកិនលាយជាមួយ**

- **ត្រី ស៊ុត ឈាម សាច់ចិញ្ច្រាំឱ្យល្អិត តៅហ៊ូ និងសណ្តែក**
- **បន្លែ៖ ស្លឹកត្រកួន ស្លឹកផ្ទី ល្ពៅ ដំឡូងផ្វាពណ៌លឿង និងបន្លែផ្សេងៗទៀត។**

**អាហារក្រៅពេល មានដូចជា ផ្លែឈើទុំ (ចេក ស្វាយ ល្ហុង) ចេកចៀន ដំឡូងផ្វា នំអន្សម ស៊ុបសណ្តែក ឬល្ពៅ។ល។**

- **កុមារចេះលូន វារ និងតោងឈរ៖**
  - **កូនអាយុ ៧ខែដល់ ១២ខែ៖** ចេះអង្គុយ វារ តោង ឈរ ដើរតតេះតតះ។ ឪពុកម្តាយ ឬអាណាព្យាបាលបន្តប្រាប់កូនពីឈ្មោះវត្ថុផ្សេងៗ និងជួយគាំទ្រ សរសើរ លើកទឹកចិត្តកូន និងថែទាំកូនដោយយកចិត្តទុកដាក់បំផុតព្រោះក្នុងអាយុនេះកូនមានឱកាសស្វែងយល់នូវអ្វីៗដែលថ្មី ដើម្បីលូតលាស់ និងអភិវឌ្ឍខួរក្បាល ហើយក៏ជាពេលដែលអាចមានគ្រោះថ្នាក់ដែរ។ ដូចនេះឪពុកម្តាយគួរទុកដាក់វត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផុតពីដៃ និងឆ្ងាយពីកុមារ រៀបចំផ្ទះ ដែលអាចផ្តល់ឱ្យកុមារអាចបំពេញតម្រូវការនៃការលូតលាស់ និងការអភិវឌ្ឍរបស់គេបានដូចជា៖ មានកន្លែងលេង កំសាន្ត សម្រាក ហើយការពារនូវកន្លែង ដែលអាចមានគ្រោះថ្នាក់ ដូចជា សម្ភារៈអគ្គីសនី សត្វខាំ ឬទិច និងសត្វចិញ្ចឹម ដោយធ្វើទ្វារជណ្តើរ ឬរនាំងបាំងជាដើម។

- **អាយុ ១ឆ្នាំ ដល់ក្រោម ៣ឆ្នាំ៖**
  - ផ្នែករាងកាយ៖ ចេះរត់ ចេះលោតឡើងកាំជណ្ដើរ
  - ផ្នែកខួរក្បាល៖ ចេះនិយាយ ភាសាកាយវិការ ស្គាល់ផ្នែកនៃរាងកាយ ស្គាល់ឈ្មោះ និងសមាជិកក្នុងគ្រួសារ ចំណាំផ្លូវ ដឹងពីសញ្ញា ពាក្យផ្ទុយខ្លះៗ ដឹងពីហេតុផល សួរសំណួរ ចេះប្រាប់ពេលបន្ទោរបង់ អនាម័យ (មាត់ធ្មេញ លាងដៃមុនញ៉ាំអាហារ) ស្លៀកពាក់ ងូតទឹក។ល។
  - ផ្នែកអារម្មណ៍៖ ចូលចិត្តឱ្យគេសរសើរ រៀនខ្មាស់ ខឹង ងរ ច្រណែន។ល។

ដូចនេះឪពុកម្ដាយបន្តការពារកូនពីគ្រោះថ្នាក់ផ្សេងៗ ផ្ដល់ឱកាសឱ្យកូនលេង ផ្ដល់ភាពកក់ក្ដៅ ជួយគាំទ្រកូនក្នុងការធ្វើអ្វីមួយ ស្ដាប់ សង្កេត ឆ្លើយតប សួរសំណួរ សរសើរ លើកទឹកចិត្ត ចៀសវាងបន្លាច ឬបំភ័យកុមារ គំរាមកំហែង និងព្យាយាមពន្យល់ហេតុផល និងផ្ដល់ព័ត៌មានជាក់លាក់ដល់កុមារ បង្រៀន និងតាមដានពីការថែទាំអនាម័យប្រចាំថ្ងៃ។

## ២.៣. ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារអាយុពី ៣ឆ្នាំ ដល់អាយុ ៥ឆ្នាំ

### ក. ការលូតលាស់ផ្នែករាងកាយ

- រាងកាយមានការលូតលាស់យឺតៗ
- ការលូតលាស់ផ្នែកទម្លាប់ដូចជា៖ ញ៉ាំ និងចូលគេងទៀងម៉ោង។

### ខ. ការលូតលាស់ផ្នែកចរិតលក្ខណៈ

ក្នុងវ័យនេះ កុមារមានបញ្ហាខ្លះៗដូចជា ចាប់ផ្ដើមចង់ធ្វើអ្វីៗដោយខ្លួនឯង ចូលចិត្តប្រឆាំង តបតគ្នា តន្ត្រំ ច្រណែន រពឹស មិនស្ដាប់បង្គាប់ដោយសារតែពួកគេចាប់ផ្ដើមកសាងនូវ អត្តសញ្ញាណផ្ទាល់ខ្លួន។

- ចូលចិត្តបង្កើតសកម្មភាពថ្មីៗ
- ស្វែងយល់បទពិសោធន៍ថ្មីៗតាមរយៈការលេង
- ត្រៀមខ្លួន ដើម្បីចូលរៀននៅសាលា
- មានចម្ងល់ច្រើន។ល។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវមានភាពអត់ធ្មត់ក្នុងការឆ្លើយ និងផ្ដល់ព័ត៌មានពិត ជាក់លាក់ដល់កូន ឬកុមារ។ ជួនពេលខ្លះ មានសំណួរមួយចំនួនដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក៏មិនបានដឹងចម្លើយដែរ សូមមានភាពក្លាហានប្រាប់ទៅកូនថា អត់ដឹង និងសូមឱ្យពួកគេចាំលោកអ្នកស្វែងរកព័ត៌មានបន្ថែមទៀតសិន ដើម្បីឱ្យកូន ឬកុមារទទួលស្គាល់ថា យើងមិនអាចដឹងរឿងគ្រប់បែបយ៉ាងនោះទេ។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគួរចំណាយពេលធ្វើសកម្មភាពជាមួយកូនៗ ឬកុមារដូចជា លេង ច្រៀង និយាយ អាន និងនិទានរឿងប្រាប់កូនរបស់អ្នក។ ការធ្វើសកម្មភាពទាំងនេះជាមួយកុមារ វានឹងជំរុញឱ្យមានការលូតលាស់ និងមានការអភិវឌ្ឍ។

## គ. ការលូតលាស់ផ្នែកអារម្មណ៍

- មានអារម្មណ៍ពុះកញ្ជ្រោល ខឹងច្រើន ចង់មានភាពឯករាជ្យ មានការប្រឆាំងជាមួយនឹងការហាមឃាត់របស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ នៅពេលដែលពួកគាត់មិនឱ្យពួកគេធ្វើអ្វី ដែលគេចង់បាន។ *ឧទាហរណ៍៖ កុំឡើងដើមឈើ កុំលេងរបស់នេះ! តែកូននៅតែធ្វើដដែល។*
- នៅក្នុងដំណាក់កាលនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានតួនាទីរៀបចំកន្លែងឱ្យមានបរិយាកាសល្អ និងសុវត្ថិភាពសម្រាប់កុមារ ហើយមិនគួរហាមឃាត់ពួកគេរហូតនោះទេ ព្រោះការហាមនេះអាចនាំឱ្យពួកគេគិតថា ពិភពលោកនេះនឹងមិនមានសុវត្ថិភាពសម្រាប់ពួកគេ។
- ការច្រណែន ប្រឆាំងជាមួយប្អូនប្រុស ឬប្អូនស្រី និងការនោមដាក់ខោនៅពេលយប់មានន័យថា ពួកគេកំពុងស្វែងរកការចាប់អារម្មណ៍ពីអ្នកដទៃ ជាពិសេសពីសំណាក់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំរបស់ពួកគេ។ តែចំពោះគ្រួសារដែលមានសមាជិកតិច កូនមិនសូវមានចិត្តច្រណែនគ្នានោះទេ។
- មានអារម្មណ៍ភ័យខ្លាចច្រើន ខ្លាចឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបោះបង់ពួកគេចោល។
- ចេះស្គាល់ពីអារម្មណ៍ និងមានអារម្មណ៍កាន់តែច្រើនដូចជា ភ័យ ឈឺចាប់ ស្រឡាញ់ រីករាយ ឬខ្លាចជាដើម។

## ឃ. ការលូតលាស់ផ្នែកភារកិច្ច

- ក្នុងវ័យនេះ កុមាររៀបចំមូលដ្ឋានគ្រឹះ នៃទំនាក់ទំនងសម្រាប់អនាគត ដូចនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានតួនាទីសំខាន់ ដើម្បីជួយពួកគេក្នុងការរៀបចំមូលដ្ឋានគ្រឹះនៃទំនាក់ទំនងនេះ។
- ពង្រឹងជំនាញរបស់ខ្លួនទៅរកភាពស្ទាត់ជំនាញ។ *ឧទាហរណ៍៖ ញ៉ាំបាយល្អជាងមុន តែវាក៏អាស្រ័យទៅលើភេទផងដែរ។ កូនប្រុស ឬកុមារាចូលចិត្តដើរលេង កូនស្រី ឬកុមារីចូលចិត្តធ្វើការងារផ្ទះ តាមរយៈលេងបាយឡុកបាយឡជាដើម។*
- ភាសានិយាយកាន់តែរីកចម្រើន ជួយគាំទ្រភាពឯករាជ្យ យល់ចិត្តគ្នា និងលើកទឹកចិត្តពួកគេសម្រាប់ធ្វើការទំនាក់ទំនងក្នុងសង្គម។ ដំណាក់កាលនេះ មនុស្សធំគួរតែនិយាយយឺតៗ មួយៗ ច្បាស់ៗ ទៅកាន់កុមារ បើមិនដូច្នេះទេ កូន ឬកុមារនឹងមានការយល់ច្រឡំ។

**ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរធ្វើ**

- ទទួលស្គាល់នូវបទពិសោធន៍ និងអាកប្បកិរិយាមិនសូវល្អរបស់កូន ឬកុមារ
- ថ្នាក់ថ្នម និងផ្តល់សេចក្តីស្រឡាញ់
- ផ្តល់នូវសេរីភាព ឯករាជ្យភាព ដែលជាកត្តានាំឱ្យពួកគេមានការផ្តួចផ្តើមគ្រប់វិស័យ
- ផ្តល់នូវសុវត្ថិភាព និងបំពេញតម្រូវការមូលដ្ឋានរបស់កូន ឬកុមារ នាំឱ្យពួកគេមានភាពរីករាយ និងគ្មានភាពតានតឹងចិត្ត
- មានផែនការ និងវិន័យល្អ សម្រាប់អនុវត្តនៅក្នុងគ្រួសារ
- បង្ហាញពីការរំពឹងទុកចំពោះកូន ឬកុមារ តែមិនគួរធ្វើច្រើនពេក ដែលហួសពីសមត្ថភាពកូន ឬកុមារទេ
- បង្កើតបរិយាកាសរីករាយនៅក្នុងគ្រួសារ
- បង្រៀនកូន ដែលមានអាយុចាប់ពី ៣ ឆ្នាំឡើងទៅឱ្យចេះប្រើបង្គន់អនាម័យ និងអនាម័យខ្លួនប្រាណ ដោយលាងដៃជាមួយនឹងសាប៊ូជានិច្ចមុនពេល និងក្រោយពេលញ៉ាំអាហារ ឬពេលបន្ទោរបង់រួច។
- ត្រូវលាងដៃជាមួយសាប៊ូមុនពេល និងក្រោយពេលញ៉ាំអាហារ ពេលបញ្ចុកអាហារកូនបន្ទាប់ពីប្រើបង្គន់ ឬក្រោយពេលលាងគូទកូន។

ចុះឈ្មោះកូន ឬកុមារទាំងអស់ឱ្យបានចូលរៀនមត្តេយ្យនៅពេលគេឈានចូលដល់អាយុ៣ ឆ្នាំភ្លាម។ ការចុះឈ្មោះឱ្យកូនចូលរៀននៅមត្តេយ្យ និងជួយពួកគេឱ្យត្រៀមខ្លួនសម្រាប់ថ្នាក់បឋមសិក្សា។ ប្រសិនបើកូនរបស់លោកអ្នកមានពិការភាព សូមលើកទឹកចិត្តឱ្យមានការលូតលាស់ និងអភិវឌ្ឍ ច្រើនបំផុតតាមដែលអាចធ្វើបាន ដោយអនុញ្ញាតឱ្យកុមារបានលេងជាមួយកុមារដទៃទៀត ចូលរៀន និងស្វែងរកជំនួយពីបុគ្គលិកបម្រើសេវាសុខាភិបាល ឬសេវាសង្គមកិច្ច។

## ២.៤- ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារអាយុពី ៦ឆ្នាំ ដល់អាយុ ១២ឆ្នាំ

### ក. ការលូតលាស់ផ្នែករាងកាយ

- រាងកាយលូតលាស់លឿន ខ្ពស់ ធាត់ ឬស្គម។ល។
- ប្រព័ន្ធបន្តពូជកូនស្រីអាចចាប់ផ្តើមលូតលាស់។

### ខ. ការលូតលាស់ផ្នែកចរិតលក្ខណៈ

- ចូលរៀន និងមានទំនាក់ទំនងជាមួយមិត្តភក្តិ
- មានបញ្ហាខ្លះៗដែលអាចកើតឡើងមកពីឥទ្ធិពលក្រុមមិត្តភក្តិ ដែលមានវ័យប្រហាក់ប្រហែលគ្នា ដូចជា លេងហ្គេមអេឡិចត្រូនិច ការជក់បារី ។ល។
- គ្មានសណ្តាប់ធ្នាប់ (ឬកខ្វក់)
- មានជម្លោះខ្លះៗ ជាពិសេសជាមួយមនុស្ស ដែលមានភេទផ្ទុយគ្នា

- កុមារារៀនអំពីភាពជោគជ័យ រីឯកុមារីរៀនអំពីបែបសម្រប និងដាក់ខ្លួន
- កុមារចូលចិត្តប្រមូលជាមួយគ្នា ស្របតាមគ្នាជាមួយច្បាប់របស់ក្រុម។
- លេងច្រើន និងមានភាពច្នៃប្រឌិតក្នុងការធ្វើអ្វីមួយ

## គ. ការលូតលាស់ផ្នែកអារម្មណ៍

- មានការដាស់តឿនខ្លួនឯងជាខ្លាំង ដើម្បីគ្រប់គ្រងអារម្មណ៍មិនល្អចំពោះអ្នកដទៃ។ ពេលតានតឹងចិត្ត កុមារីយំហើយដកថយ ចំណែកកុមារាធ្វើឱ្យរបស់របរបែកបាក់ ឬបដិសេធក្នុងការប្រឈមមុខជាមួយអ្នកដទៃ ក៏ប៉ុន្តែពេលដែលគេគ្រប់គ្រងអារម្មណ៍នេះបាន សង្គមជុំវិញកោតសរសើរយ៉ាងខ្លាំងចំពោះពួកគេ។
- ទន្ទឹមជាមួយការគ្រប់គ្រងអារម្មណ៍ដែលមិនសប្បាយ ពួកគេក៏រៀនបន្ធូរអារម្មណ៍តានតឹងចិត្ត តាមរយៈការលេងល្បែង ធ្វើការងារប្រើកម្លាំងខ្លាំងៗ ការសើចសប្បាយ ការយំ ទាំងអស់នេះ អាចធ្វើឱ្យអារម្មណ៍តានតឹងចិត្តរបស់កុមារមានការថយចុះ ប៉ុន្តែសម្រាប់កុមារាមិនងាយឱ្យខ្លួនយំនោះទេ។
- ការចែករំលែកទទួលបានការគាំទ្រយ៉ាងខ្លាំង
- ឥទ្ធិពលនៃក្រុម៖ ក្រុមផ្តល់ភាពរីករាយនៅពេលលេងល្បែង ជួយឱ្យកុមារចូលរួម (កុមារសម្រប ទៅតាមក្រុម ពីព្រោះខ្លាចក្រុមបោះបង់គេចោល)។
- មានការទាស់ទែងជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ (ពិសេសអំពីភារកិច្ច និងពេលវេលា)។
- មានការប្រឆាំងជាមួយមនុស្ស ដែលមានភេទផ្ទុយគ្នា ប៉ុន្តែនេះជារបៀបក្នុងការកសាងបុគ្គលិកលក្ខណៈឱ្យកាន់តែមានភាពច្បាស់លាស់។

## ឃ. ការលូតលាស់ផ្នែកភារកិច្ច

- រៀនចុះសម្រុងចំពោះក្រុមមិត្តភក្តិ
- ជំនាញរាងកាយដូចជា៖ កីឡា សិល្បៈជាដើម។
- មានបុគ្គលិកលក្ខណៈកាន់តែច្បាស់ យល់ពីទិសដៅរបស់ខ្លួន និងក្លាយទៅជាមនុស្សដែលមានឯករាជ្យភាព
- យល់ពីតួនាទីភេទរបស់ខ្លួន តែមិនទាន់ចូលចិត្តប្រមូលគ្នានៅឡើយ។
- ការសិក្សា គិត សរសេរ និង អាន (គ្រូ និងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ មានកាតព្វកិច្ចក្នុងការជួយគេ)។
- រៀនពីសាសនា ច្បាប់ និងទម្លាប់សង្គម
- កុមារីមានភាពពេញវ័យលឿនជាងកុមារា ពីព្រោះកុមារីទទួលបានការណែនាំពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំច្រើនជាងកុមារា។
- គេរៀនជំនាញផ្សេងៗពីមជ្ឈដ្ឋានជុំវិញ ដូចជា មិត្តភក្តិ បរិបទសង្គម សេដ្ឋកិច្ច និងសាលារៀន។ល។

- កុមារផ្តាច់ខ្លួនពីឪពុកម្តាយ ទើបពួកគេអាចមានភាពចាស់ទុំ និងអាចនិយាយជាមួយអ្នកដទៃបានច្រើន។
- គ្រប់គ្រងការនិយាយរបស់ខ្លួន ដោយសារខ្លាចក្រុមមិនទទួលស្គាល់ពួកគេ។

**ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរធ្វើ**

- ផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួន ដើម្បីទទួលការគោរពពីកូន ឬកុមារ។ គុណភាពនៃទំនាក់ទំនងនេះអាចនឹងមានឥទ្ធិពលខ្លាំងទៅលើអត្តសញ្ញាណរបស់កុមារនាពេលអនាគត។
- ជ្រើសរើសមិត្តភក្តិ គ្រូ ឬជនណាម្នាក់ ដែលគេពេញចិត្តតាមទូរទស្សន៍ ដើម្បីត្រាប់តាម ឬជាគំរូ។
- ទទួលស្គាល់ខ្លួនឯង ដែលនឹងនាំពួកគេឱ្យមានសេចក្តីសុខផ្ទាល់ខ្លួន។ បើសិនជាមិនទទួលស្គាល់ខ្លួនឯងទេ ពួកគេនឹងរកវិធីផ្សេងៗក្នុងការការពារខ្លួនឯងកុំឱ្យមានការឈឺចាប់។
- មិនគួរតឹងរឹងពេក ព្រោះអាចនាំឱ្យកូនមានការអន់ចិត្ត ហើយប្រឆាំងទៅនឹងវិន័យ ឬការណែនាំរបស់លោកអ្នក ឬច្បាប់សង្គម។
- ប្រសិនបើគ្មានការថ្នាក់ថ្នម អាចនាំឱ្យកុមារមានការដកថយ គិតថាខ្លួនឯងជាមនុស្សធំ មានសកម្មភាពហួសហេតុ ឬមានភាពអាត្មានិយម។
- ការណែនាំមានសារៈសំខាន់ណាស់ ព្រោះនឹងជួយឱ្យកុមាររៀនសូត្រអំពីអ្វីដែលគួរធ្វើ ឬអ្វីដែលមិនគួរធ្វើ ហើយក៏អាចជួយឱ្យកុមារស្វែងយល់អំពីទង្វើរបស់ពួកគេ ដោយជួយឱ្យពួកគេអាចវិភាគ ពិចារណា និងធ្វើការសម្រេចចិត្តបានកាន់តែប្រសើរនៅពេលក្រោយ។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ តែងមានទម្លាប់ថាការអប់រំកូនដោយប្រើអំពើហិង្សា វាជាវិធីត្រឹមត្រូវក្នុងការអប់រំកូន។ ការប្រើអំពើហិង្សាមិនបានជួយឱ្យមានការផ្លាស់ប្តូរនូវអាកប្បកិរិយារបស់កូន ឬដោះស្រាយបញ្ហាទេ ផ្ទុយទៅវិញវាអាចបង្រៀនកូនឱ្យចេះប្រើអំពើហិង្សា នៅពេលដែលមាននរណាម្នាក់ធ្វើអ្វីមួយ ដែលគេមិនពេញចិត្តតែប៉ុណ្ណោះ។

គួររក្សាកូន ឬកុមារឱ្យស្ថិតក្នុងគ្រួសារ ឬសហគមន៍ ដើម្បីឱ្យពួកគេមានឱកាសលូតលាស់ និងអភិវឌ្ឍទៅតាមដំណាក់កាល និងពេញលេញ ហើយគួរជៀសវាងការបំបែកកូន ឬកុមារចេញពីគ្រួសារដោយមិនចាំបាច់។

## III. ផលប៉ះពាល់នៃការរំលោភបំពានលើការលូតលាស់ និងអភិវឌ្ឍខួរក្បាល

នៅក្នុងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ ខួរក្បាលក៏មានការលូតលាស់ និងអភិវឌ្ឍផងដែរ។ បើសិនជានៅក្នុងដំណាក់កាលនីមួយៗមានការរំលោភបំពាន មានអំពើហិង្សា ឬការមិនអើពើកើតឡើង ធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍខួរក្បាលរបស់កុមារទៀតផង។

រូបខាងក្រោមបង្ហាញពី ផលប៉ះពាល់ នៃការរំលោភបំពានលើការអភិវឌ្ឍខួរក្បាលរបស់កុមារ។




មួយផ្នែក នៃខួរក្បាលមានតួនាទីគ្រប់គ្រងអារម្មណ៍របស់យើង ហើយវាជា □ប្រព័ន្ធប្រកាសដំណឹង□។ ប្រសិនបើការរំជួលអារម្មណ៍នេះកើតឡើងច្រើនពេក ឬខ្លាំងពេក នោះការឆ្លើយតបធម្មតា ដែលត្រូវកើតឡើង។

ទាំងនោះនឹងមិនអាចឆ្លើយតបបានទេ។ ដូច្នេះខួរក្បាលកុមារត្រូវជាប់គាំង □ក្នុងតំបន់គ្រោះថ្នាក់□ ដែលកុមារបង្ហាញភាពជាសត្រូវ កាចដាក់គេឯងហើយកុមារមានការពិបាកគិតឱ្យបានច្បាស់លាស់ និងពិបាករីករាយជាមួយនឹងក្តីស្រឡាញ់ ឬការទុកចិត្ត។

ផ្នែកមួយទៀតរបស់ខួរក្បាលមានតួនាទីក្នុងការចងចាំថ្មីបំផុត។ នៅពេលដែលកុមារធ្លាប់ឆ្លងកាត់បទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរត្រូវបានគេរកឃើញថា ផ្នែកនេះតូចជាងកុមារដទៃទៀត ដែលនាំឱ្យមានការចងចាំខ្សោយ ហើយពេលខ្លះនាំឱ្យមានការកាត់ផ្តាច់ពីសតិចងចាំ។ បែបនេះក៏នាំឱ្យមានជំងឺថប់បារម្ភ និងរហូតដល់ជំងឺចិត្តវិកលទៀតផង។

ផ្នែកមួយទៀត នៃខួរក្បាលមានតួនាទីពិចារណាហេតុផល ដើម្បីមានការសម្រេចចិត្តផ្សេងៗពីការឆ្លើយតបផ្នែកអារម្មណ៍ និងគំនិតកើតឡើងមានដូចជា ការធ្វើផែនការតាមដាន ផ្លាស់ប្តូរផែនការ គ្រប់គ្រង និងផ្តោតការយកចិត្តទុកដាក់ គ្រប់គ្រងអាកប្បកិរិយាតក់ក្រហល់ អភិវឌ្ឍសមត្ថភាពសម្រេចចិត្តសមហេតុផល។ នៅពេលដែលកុមាររងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ សមត្ថភាពសម្រេចចិត្តសមហេតុផល ការគ្រប់គ្រងអាកប្បកិរិយាសមត្ថភាពគ្រប់គ្រងផែនការ និងការផ្តោតអារម្មណ៍របស់ពួកគេត្រូវបានបំផ្លាញ។

## ខ្លឹមសារបន្ថែម

អ្នកសម្របសម្រួលត្រូវបញ្ចូលខ្លឹមសារស្តីពី **ពិការភាព និងភាពខុសគ្នាក្នុងការចិញ្ចឹមកូនស្រី និងកូនប្រុស** ផងដែរ។ អ្នកសម្របសម្រួលគួរសួរបំផុសខ្លះៗអំពីកុមារដែលមានពិការភាព។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) អំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀត អាចមានច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការ

ភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួន៖

- **ថ្លង់ ឬខ្សោយការស្តាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អ តែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺ ខ្សោយការស្តាប់ (មិនអាចស្តាប់បាន ឬស្តាប់បានមិនល្អ)។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើលមិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍ ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្តាប់នោះអាចឱ្យពួកគាត់មានឱកាសរៀនភាសាបានល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទទួលបានការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមាររបស់គាត់ដែលមានពិការភាពនេះ ដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាពទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍ ការប្រាស្រ័យទាក់ទង មានភាពកក់ក្តៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្នមានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការគ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។
- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយសតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់ បានចប់បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹក

គេង និងហូបចុក ជាដើម។ មានកុមារមួយចំនួនទៀត មានបញ្ហាខ្សោយសតិបញ្ញាប្រភេទធ្ងន់ធ្ងរ។ ពួកគាត់មិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការអ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេសថែមទៀត ពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឳពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ច ដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវានៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។

- **ខ្សោយកាយសម្បទា ឬពិការកាយ៖** កុមារមួយចំនួនទៀត មានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាចដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឳពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល មជ្ឈមណ្ឌលស្តារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលស្តារនីតិសម្បទានៅតាមខេត្ត។
- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះអាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយលំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឳពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារ ដែលមានបញ្ហាភ្នែកតាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិនឈោងចាប់របស់របរលេង មិនលូន ឬវារ ទារកលេងកំសាន្តតិចតួច នៅតែម្នាក់ឯងច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះឳពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារកដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការថែទាំ និងការគាំទ្រ ពីសេវាសង្គមកិច្ច ដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

| ភាពខុសគ្នារវាងកុមារា និងកុមារី | |
|---|---|
| កុមារា | កុមារី |
| • រាងកាយមានភាពរហ័សរហួន និងសកម្ម<br>• មានជំនាញវិភាគ ក្នុងលំហ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយនឹងការធ្វើឱ្យអ្វីៗផ្លាស់ទី<br>• រៀនតាមរយៈ ការមើល<br>• តក់ក្រហល់ក្នុងការធ្វើអ្វីមួយ<br>• បែងចែកការងារច្បាស់ ដោយផ្តោតអារម្មណ៍ម្តងមួយៗ<br>• ត្រូវការពេលវេលាដើម្បីផ្ចង់អារម្មណ៍ក្នុងការធ្វើអ្វីមួយ<br>• រុករក ឬស្វែងយល់ និងចង់ដឹងពី អ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តបង្ហាញសកម្មភាពជាងនិយាយពីអារម្មណ៍របស់គេ | • រាងកាយមានភាពទន់ភ្លន់<br>• មិនសូវមានជំនាញវិភាគ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយពណ៌<br>• រៀនតាមរយៈ ការស្តាប់<br>• គិតច្បាស់លាស់មុននឹងធ្វើអ្វីមួយ<br>• មិនមានការបែងចែកច្បាស់ អាចធ្វើការច្រើនមុខក្នុងពេលតែមួយ<br>• អាចធ្វើបានភ្លាមៗ<br>• ស្តាប់ ដើម្បីដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តនិយាយ ដើម្បីបង្ហាញពីអារម្មណ៍របស់ខ្លួន |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួម ចែករំលែកបទពិសោធន៍នៃការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងផ្ទះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយសួរ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំផ្តល់<br>▪ និងពិភាក្សាដើម្បីស្វែងរកវិធីដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែង ថាមពល ខ្ញុំស្រឡាញ់ អ្នក (១៥នាទី) | ▪ ចូរនិយាយថា៖ មុននឹងយើងបន្តទៅមេរៀនថ្មី យើងនឹងចាប់ផ្តើមដោយការលេងល្បែងមួយហៅថា **ខ្ញុំស្រឡាញ់អ្នក**។ ឱ្យអ្នកចូលរួមឈរជារង្វង់ រីឯអ្នកសម្របសម្រួលឈរនៅកណ្តាល ហើយពន្យល់ថា<br>☞ ខ្ញុំនឹងចង្អុលទៅចំនរណាម្នាក់ ដែលខ្ញុំពេញចិត្ត ហើយនិយាយ **ខ្ញុំស្រឡាញ់អ្នក**។<br>☞ រីឯអ្នកដែលត្រូវខ្ញុំចង្អុល ត្រូវសួរមកវិញថា **ហេតុអ្វីបានអ្នកស្រឡាញ់ខ្ញុំ?** បន្ទាប់មកខ្ញុំនឹងឆ្លើយតប<br>☞ វិញថា **ព្រោះអ្នកពាក់អាវដៃខ្លី**។<br>☞ នៅពេលអ្នកទាំងអស់គ្នាឮពាក្យនេះ អ្នកដែលមានពាក់អាវដៃខ្លី នឹងត្រូវប្តូរទីតាំងឈរឱ្យបាន អំឡុងពេលនេះបើមាននរណាម្នាក់រកកន្លែងឈរមិនបាន ឬមិនទាន់គេទេនោះ គឺជាអ្នកចាញ់ហើយត្រូវចូលទៅខាងក្នុងរង្វង់ដើម្បីសម្របសម្រួលម្តង។<br>☞ បន្តលេងរហូតអ្នកចូលរួមបានលេងគ្រប់គ្នា មុននឹងបន្តទៅសកម្មភាពបន្ទាប់។ |
| ៥ | មេរៀនថ្មី៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (២) | ការលូតលាស់ និង អភិវឌ្ឍ របស់កុមារ (២៥នាទី) | ▪ សូមប្រាប់អ្នកចូលរួមថា ឥឡូវនេះយើងនឹងពិនិត្យមើល តើមានរបៀបអ្វីខ្លះដែលជួយយើងក្នុងការចិញ្ចឹមកូនបែបវិជ្ជមានបានប្រកបដោយគុណភាព ដំបូងយើងនឹងពិភាក្សាអំពីការលូតលាស់ និងអភិវឌ្ឍកុមារ និងបន្ទាប់យើងនឹងមើលទៅលើធាតុផ្សំទី៣ គឺ **យល់អំពីការគិត និងអារម្មណ៍** របស់កូនក្នុងកម្រិតអាយុចាប់ពីពេលមានផ្ទៃពោះរហូតដល់១២ឆ្នាំ។<br>▪ ដើម្បីនាំអ្នកចូលរួមឱ្យភ្ជាប់ជាមួយនឹងប្រធានបទនេះបាន អ្នកសម្របសម្រួលចាប់ផ្តើមដោយសំណួរ៖<br>☞ តើការលូតលាស់ និងអភិវឌ្ឍកុមារមានន័យដូចម្តេច?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារមេរៀន<br>▪ បន្ទាប់មកអ្នកសម្របសម្រួល បិទរូបភាពទី១ បង្ហាញពី ការអភិវឌ្ឍកុមារ ហើយសួរ<br>☞ តើលោកអ្នកគិតថា កុមារទាំងអស់នេះមានអាយុប្រហែលប៉ុន្មានឆ្នាំ?<br>🗣 ចម្លើយរំពឹងទុក៖ ៦ឆ្នាំ ៨ឆ្នាំ ១០ឆ្នាំ ១២ឆ្នាំ។ល។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងសុំឱ្យពួកគាត់ស្រមើស្រមៃពីដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារ ចាប់តាំងពីករកំណើតទម្រាំពួកគេបានចម្រើនវ័យដូចក្នុងរូបភាពនេះ ដោយសួរ<br>☞ តើកូន ឬកុមារបានឆ្លងកាត់ដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍអ្វីខ្លះ?<br>🗣 ចម្លើយរំពឹងទុក៖ ចេះយំ សើច ក្រឡាប់ លូន ដើរ រត់ និយាយ ញ៉ាំ ផឹក ប្រាប់រឿងរ៉ាវផ្សេងៗ ស្គាល់សមាជិកគ្រួសារ ខឹង ច្រណែន ស្អប់ ស្រឡាញ់ បារម្ភ ចេះអានអក្សរ គិតលេខ ឆ្ងល់ច្រើន មានសំឡេងធំ(គ្រលរ) ចូលចិត្តធ្វើការងារផ្ទះ ស្តាប់បង្គាប់ លេងច្រើន រាងកាយលូតលាស់លឿន បង្ហាញថាខ្លួនធំហើយ មានភាពស្រមើស្រម៉ៃ ស្អប់ភេទផ្ទុយគ្នា។ល។<br>▪ អ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមឆ្លើយអ្វីក៏បានទៅតាមបទពិសោធន៍នៃការចិញ្ចឹមកូនដែលពួកគាត់ធ្លាប់ជួបប្រទះ និងចងចាំកន្លងមក បន្ទាប់មកគឺជួយឱ្យគាត់ទទួលស្គាល់ថាកូន ឬកុមារមានភាពខុសប្លែកគ្នាពី ១ឆ្នាំទៅ ១ឆ្នាំ ទាំងការលូតលាស់ផ្នែករាងកាយ និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី សង្គម និងអារម្មណ៍ សំខាន់គឺជួយឱ្យពួកគាត់បាននឹកឃើញ និងឆ្លុះបញ្ចាំងពីខ្លួនគាត់ផ្ទាល់ ឬកូនៗនៅវ័យមុនជំទង់ និងវ័យជំទង់មានសភាពខុសប្លែកយ៉ាងណាខ្លះ ពិសេសផ្នែកអារម្មណ៍ និងសង្គមដែលនាំឱ្យពួកគាត់ មានអាកប្បកិរិយាប្លែកៗ និងលំបាកៗកើតឡើង ដូចជា៖ មិនសូវស្តាប់បង្គាប់ដូចមុន ចូលចិត្តចេញក្រៅផ្ទះ និងមានមិត្តភក្តិច្រើន ឬស្តាប់មិត្តភក្តិជាងគ្រួសារ ចូលចិត្តនៅម្នាក់ឯង តុបតែងខ្លួនប្លែកៗ ប្រើពាក្យសម្តី និងមានអាកប្បកិរិយាមិនសមរម្យ។ល។ ទង្វើទាំងអស់នេះហើយហៅថាដំណាក់កាល នៃការអភិវឌ្ឍរបស់កុមារនោះ។<br>▪ អ្នកសម្របសម្រួលលើករូបភាព និងពន្យល់ទៅតាមរូបភាពនិមួយៗ តាមខ្លឹមសារមេរៀន និងពន្យល់អំពីរបៀបគាំទ្ររបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងដំណាក់កាលនិមួយៗដូចខាងក្រោម៖<br>• ការលូតលាស់ និងអភិវឌ្ឍគភ៌ក្នុងផ្ទៃ (រូបភាពទី ២) |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | • ការលូតលាស់ និងអភិវឌ្ឍកុមារពី ០ឆ្នាំ ដល់ក្រោម ៣ឆ្នាំ (រូបភាពទី៣ រហូតដល់រូបភាពទី១០)<br>• ការលូតលាស់ និងអភិវឌ្ឍកុមារពី ៣ឆ្នាំ ដល់ ៥ឆ្នាំ (រូបភាពទី១១ រហូតដល់រូបភាពទី១៨)<br>• ការលូតលាស់ និងអភិវឌ្ឍកុមារពី ៦ឆ្នាំ ដល់ ១២ឆ្នាំ (រូបភាពទី១៩ រហូតដល់រូបភាពទី ២៣)<br>▪ អ្នកសម្របសម្រួលបង្ហាញរូបភាពទី២៤ អំពីផលប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍខួរក្បាលរបស់កុមារ ដោយពន្យល់ដល់អ្នកចូលរួម នឹងជួយឱ្យពួកគាត់យល់ថា ការរំលោភបំពានគ្រប់ទម្រង់ និងអំពើហិង្សាដែលកើតមានលើកុមារញឹកញាប់ ឬបន្តកើតឡើងនោះ នឹងមានផលប៉ះពាល់ដល់ការលូតលាស់ និងការអភិវឌ្ឍខួរក្បាលរបស់កុមារ ។ |
| | | **ធាតុផ្សំទី៣៖ យល់អំពីការគិត និងអារម្មណ៍ រយៈពេល (៣៥នាទី)** | ▪ ឥឡូវនេះលោកអ្នកបានយល់ដឹងខ្លះៗហើយអំពីការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ ដូច្នេះយើងនឹងពិភាក្សាលម្អិតអំពីធាតុផ្សំទី៣បន្តទៀតដោយសួរ<br>☞ តើការគិត និងអារម្មណ៍ មានន័យដូចម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារមេរៀន<br><br>**កំណត់សម្គាល់៖**<br><br>**ការគិត** គឺជាទស្សនៈ ឬជាគំនិតយោបល់។ ការគិតគឺជាដំណើរការនៃខួរក្បាលរបស់យើងស្របពេលដែល បានទទួលពីញ្ញាណទាំង៥របស់យើង ដូច្នេះការគិតគឺជាអ្វីៗដែលយើងវិភាគ វែកញែកពិចារណារកហេតុផល។ ការគិតគឺជាការឆ្លើយតបដោយប្រើហេតុផល និងបញ្ហាទៅនឹងបញ្ហាផ្សេងៗដែលកើតឡើងនៅជុំវិញខ្លួនយើង។ អារម្មណ៍ផ្សេងៗតែងតែជាលទ្ធផលនៃការគិត។<br><br>*ឧទាហរណ៍ ខ្ញុំកំពុងតែគិតថា តើនឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំសួរសំណួរនេះ* |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | **អារម្មណ៍** គឺជាញ្ញាណដឹង ប្រតិកម្មនានា និងការឆ្លើយតបនានា ដែលកើតឡើងនៅក្នុងខ្លួនរបស់យើង។ អារម្មណ៍ គឺជាចំណាប់អារម្មណ៍ទូទៅ និងអព្ភន្តរញ្ញាណ (ការយល់ច្បាស់ដោយមិនបាច់ពិចារណា)។ ជារឿយៗអារម្មណ៍មិនមានលក្ខណៈសមហេតុផលទេ។ ជាធម្មតាអារម្មណ៍តែងតែជាការឆ្លើយតបដែលរហ័សជាងការគិត។<br><br>*ឧទាហរណ៍ ខ្ញុំមានអារម្មណ៍ថាខ្លួនឯងឆោតដែលសួរសំណួរនេះ ឬ ខ្ញុំខ្មាសគេណាស់ ។*<br>▪ អ្នកសម្របសម្រួលបន្តសួរទៀតថា<br>☞ តើការយល់អំពីការគិត និងអារម្មណ៍របស់កូនគឺជាអ្វី ?<br>🗣 ចម្លើយរំពឹងទុកៈ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបញ្ជាក់ពីអត្ថន័យនៃពាក្យ យល់អំពីការគិត និងអារម្មណ៍ របស់កូន គឺជាការយល់ដឹងពីសេចក្តីត្រូវការរបស់កូន ឬកុមារដែលផ្តោតលើដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ រួមទាំងការគោរពឱ្យតម្លៃពួកគេជាមនុស្សម្នាក់ដែលមានភាពសំខាន់ និងដោយឡែកៗពីគ្នា។<br>▪ បន្ទាប់ពីអ្នកចូលរួមបានយល់អំពីអត្ថន័យនៃពាក្យនេះរួចហើយ អ្នកសម្របសម្រួលធ្វើការបិទរូបភាពទី៦ បង្ហាញពីការយល់អំពីការគិត និងអារម្មណ៍ ហើយសួរសំណួរ<br>☞ តាមការយល់ឃើញរបស់លោកអ្នក តើរូបភាពនេះមានន័យយ៉ាងដូចម្តេច ?<br>🗣 ចម្លើយរំពឹងទុកៈ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចសួរបន្ត<br>☞ តើការយល់អំពីការគិត និងអារម្មណ៍របស់កូន មានន័យដូចម្តេច ?<br>🗣 ចម្លើយរំពឹងទុកៈ យល់ពីអ្វីដែលកូនចង់បាន ដឹងពីអារម្មណ៍របស់កូនដូចជា ការខឹង និងសប្បាយ។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយរបស់អ្នកចូលរួម និងបន្ថែមខ្លឹមសារ រួចសួរបន្ត<br>☞ តើអ្នកអាចដឹងអំពីការគិត និងអារម្មណ៍របស់កូន ឬកុមារដោយរបៀបណា ? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | 🗣 ចម្លើយរំពឹងទុកៈ ដឹងតាមពាក្យសម្ដី និងអាកប្បកិរិយាផ្សេងៗដូចជា ភាសាកាយវិការ ទឹកមុខ ការតុបតែងខ្លួន និងការស្លៀកពាក់។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយរបស់អ្នកចូលរួម និងបន្ថែមខ្លឹមសារមេរៀន និងខ្លឹមសាររូបភាព។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងជួយឱ្យពួកគេយល់អំពីខ្លឹមសាររបស់រូបភាពនីមួយៗ ដូចជា<br>• រូបផ្នែកខាងលើ □**ម្ដាយមិនសប្បាយចិត្តជាមួយកូនស្រីជំទង់ដែលស្លៀកពាក់សិចស៊ី និងមានមិត្តភក្ដិបែបហ្នឹង**□<br>តាមការស្រាវជ្រាវក្នុងកម្រិតអាយុនេះក៏ដូចជាក្នុងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍគឺ □ក្មេងស្រីជំទង់ចាប់ផ្ដើមចង់ធ្វើអ្វីៗតាមចិត្តរបស់គាត់ចង់ទាំងការស្លៀកពាក់ ការតុបតែងខ្លួន ការសេពគប់មិត្ត និងជាការរៀនតាម ឬធ្វើតាមនរណាម្នាក់ដែលគាត់ពេញចិត្តគោរពឱ្យតម្លៃ (មាននៅក្នុងចិត្ត) ឬចង់ប្រាប់ពិភពលោកថាខ្លួនគេធំហើយ ឬចង់បង្កើតអត្តសញ្ញាណថ្មីសម្រាប់ខ្លួនគេ។ល។□ពិសេសវ័យនេះគឺចង់បានឯករាជ្យភាព។<br>• រូបផ្នែកខាងក្រោម □**ឪពុកគិតថាកូនរបស់ខ្លួនចង់លេងបាល់ជាមួយបងៗដែរ តែគាត់នៅតូចបែបនេះមិនទាន់អាចលេងដូចបងៗបានទេ ដូច្នេះគាត់ត្រូវតែរកកូនបាល់ណាដែលសក្ដិសមនឹងគាត់ ហើយត្រូវជួយបង្ហាត់ ឬនាំគាត់លេង**□<br>តាមការស្រាវជ្រាវនៅក្នុងកម្រិតអាយុ និងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍកុមារនេះ □ចូលចិត្តលេងច្រើន មានចំណង់ខ្លាំង ចង់សាកល្បង ភ្លក្ស ធ្វើតាម ត្រូវការការជួយណែនាំ ការផ្ដល់ក្ដីស្រឡាញ់ និងភាពកក់ក្ដៅពីមនុស្សធំ□ ។ល។<br>▪ អ្នកសម្របសម្រួលបន្តសួរសំណួរ<br>☞ តើការយល់ដឹងពីការគិត និងអារម្មណ៍របស់កូន មានភាពខុសគ្នាយ៉ាងណាខ្លះសម្រាប់<br>ក. កូនតូច ?<br>ខ. កូនមុនវ័យជំទង់ ?<br>គ. កូនដែលមានពិការភាព?<br>ឃ.ក្មេងប្រុស និង ក្មេងស្រី? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងជួយឱ្យពួកគេយល់ថា ពីដំណាក់កាលមួយទៅដំណាក់កាលមួយនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារពិតជាមានភាពខុសប្លែកគ្នាទៅតាមកម្រិតអាយុ វ័យ ភាពឆ្លាតវៃរបស់កុមារ (មានពីធម្មជាតិ និងរៀនពីបរិស្ថានជុំវិញ) ទំនោរផ្នែកភេទ និងប្រភេទនៃពិការភាព។ ដូច្នេះឪពុកម្ដាយ ឬអ្នកថែទាំគ្រប់រូបត្រូវតែយកចិត្តទុកដាក់ស្វែងយល់អំពីការគិត និងអារម្មណ៍ រួមទាំងការលូតលាស់ និងអភិវឌ្ឍវ័យ (អាយុ) របស់កូន ឬកុមារក្រោមការថែទាំរបស់ខ្លួន ដើម្បីជួយបំពេញនូវតម្រូវការរបស់កូន (ភាពកក់ក្ដៅ) ឬជួយឱ្យកូនយល់ពីអ្វីដែលគេគួរធ្វើ និងមិនគួរធ្វើ (ដែនកំណត់)។ នៅពេលដែលលោកអ្នកមានការយល់ដឹងបែបនេះវាជួយឱ្យលោកអ្នកយល់យ៉ាងច្បាស់ថា ហេតុអ្វីបានជាកូន ឬកុមារក្នុងវ័យនេះ និងក្នុងដំណាក់កាលនេះមានអាកប្បកិរិយាលំបាកបែបនេះ? និងជួយឱ្យលោកអ្នកអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាពដែលមិនបង្កឱ្យមានជម្លោះ ឬអំពើហិង្សាផ្លូវចិត្ត និងផ្លូវកាយរួមទាំងការមិនអើពើផងដែរ។ លើសពីនេះទៀតគឺជួយឱ្យគ្រួសារមានការប្រាស្រ័យទាក់ទងល្អ មានភាពស្និទស្នាល មានការយល់ចិត្ត និងសុភមង្គលក្នុងគ្រួសារ ដែលជាការទប់ស្កាត់ពីការបំបែកកូនចេញពីគ្រួសារផងដែរ និងជាពិសេសគឺសម្រេចបាននូវការរំពឹងទុក ឬគោលដៅយូរអង្វែងសម្រាប់កូន ឬកុមារក្រោមការថែទាំរបស់ខ្លួនបានយ៉ាងសក្ដិសិទ្ធ។<br><br>**ចំណាំ៖**<br><br>កូនៗ ឬកុមារតូចមិនមែនធ្វើអ្វីៗ ដើម្បីឆាឆៅ រំខាន ឬធ្វើឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំខឹងនោះទេ។<br><br>ជាធម្មតាកូនៗ ឬកុមារមុនវ័យជំទង់ ព្យាយាមបំពេញតម្រូវការរបស់ខ្លួនទៅតាមអាយុ ឬដំណាក់កាលនៃការលូតលាស់ ការអភិវឌ្ឍ និងបរិស្ថានដែលនៅជុំវិញពួកគេ។<br><br>មានតែការផ្ដល់ភាពកក់ក្ដៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់ពីការគិត និងអារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីដែលពួកគេគួរធ្វើ និងមិនគួរធ្វើ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **សង្ខេបមេរៀន** **(១៥នាទី)** | ▪ ថ្ងៃនេះយើងបានពិភាក្សាគ្នាលម្អិតអំពីធាតុផ្សំទី៣គឺ **យល់អំពីការគិត និងអារម្មណ៍** របស់កូន ឬកុមារក្រោមការថែទាំរបស់យើង និងរួមទាំងបានធ្វើការឆ្លុះបញ្ចាំងអំពីខ្លួនឯងកាលនៅជាកុមារភាព និងនៅពេលដែលខ្លួនយើងក្លាយជាឪពុកម្តាយតាមរយៈបទពិសោធន៍របស់យើងផ្ទាល់ខ្លួន ទាំងអស់នេះហើយដែលជួយឱ្យយើងអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនបានដើម្បីបញ្ចៀសនូវការប្រព្រឹត្តអំពើហិង្សានានា (ផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើ) ចំពោះកូន និងរួមទាំងយល់ច្បាស់អំពីអ្វីដែលយើងគួរធ្វើ និងអ្វីដែលមិនគួរធ្វើដូចជា ការបំពេញតម្រូវការ ការផ្តល់ភាពកក់ក្តៅនិងដែនកំណត់ ការរំពឹងទុក(គោលដៅយូរអង្វែង) ជាមួយកូន ឬកុមារចាប់ពីពេលនេះតទៅ។ ម្យ៉ាងវិញទៀតគឺជួយឱ្យយើងយល់បានកាន់តែច្បាស់ពីដំណាក់កាលនានានៃការលូតលាស់ និងអភិវឌ្ឍរបស់កូន ក៏ដូចជាកត្តាបរិស្ថាន ឬមូលហេតុអ្វីខ្លះ ដែលបណ្តាលឱ្យកូនយើងមានអាកប្បកិរិយាលំបាកៗ ទាំងអស់នោះទៀតផង។<br><br>១) **គោលដៅយូរអង្វែង៖** គឺជាការរំពឹងទុករបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទៅលើកូន ឬកុមារ នៅពេលដែលគេធំឡើង។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគប្បីប្រព្រឹត្តឡើងដោយយុត្តិធម៌ និងភាពស្មើគ្នាចំពោះកូន ឬកុមារ ក្រោមការថែទាំរបស់ខ្លួន ទោះជា កុមារា កុមារី និងកុមារដែលមានពិការភាពក៏ដោយ។<br><br>២) **ភាពកក់ក្តៅ** គឺជាការគាំទ្រតាមរយៈការផ្តល់ក្តីស្រឡាញ់ ដូចជា ឱប ថើប លួងលោម បំពេរ នៅជិតកូន លេងជាមួយកូន ការប្រើពាក្យសរសើរ និងលើកទឹកចិត្ត ការយកចិត្តទុកដាក់ ការខ្វាយខ្វល់ ការឱ្យតម្លៃ ជឿជាក់ ការយល់ចិត្ត និងយល់ពីតម្រូវការ រួមទាំងការបីបាច់ថែរក្សារាងកាយកូនឱ្យបានល្អ។ រីឯ **ដែនកំណត់** គឺជាការផ្តល់ព័ត៌មានពីសេចក្តីណែនាំ ល័ក្ខខ័ណ្ឌ គោលការណ៍ច្បាស់លាស់ ការចរចា និងយល់ពីហេតុផលនានា នូវអ្វីដែលគួរធ្វើ និងមិនគួរធ្វើ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ត្រូវផ្តល់ភាពកក់ក្តៅ និងដែនកំណត់ដល់កូនក្នុងពេលតែមួយ។ កូនអ្នកអាចក្លាយជាមនុស្សបែបណា អាស្រ័យលើការជួយគាំទ្រ និងការផ្តល់នូវព័ត៌មានពីអ្នក។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ៣) ការយល់អំពីការគិត និងអារម្មណ៍របស់កូន គឺជាការយល់ដឹងពីសេចក្តីត្រូវការរបស់កូន ឬកុមារដែលផ្តោតលើដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ កត្តាបរិស្ថានជុំវិញរួមទាំងការគោរព ឱ្យតម្លៃពួកគេ ជាមនុស្សម្នាក់ដែលមានភាពសំខាន់ដោយឡែកៗពីគ្នា។<br>**មានតែការផ្តល់ភាពកក់ក្តៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់អំពីការគិត និង អារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីដែលពួកគេ គួរធ្វើ និងមិនគួរធ្វើ។** |
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន** (១០នាទី) | ▪ អ្នកសម្របសម្រួលសួរៈ<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្តេចដែរទៅលើទង្វើរបស់ខ្លួនកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្តេចនៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ** (១០នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្តើមធ្វើការកត់សម្គាល់ ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយា ដែលអាចដោះស្រាយភាពតានតឹងចិត្ត ដើម្បីជួយខ្លួនឯង ព្រមទាំងគ្រួសារទាំងមូលទទួលបានសុភមង្គល។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

## រូបភាពទី ១



# ការអភិវឌ្ឍកុមារ

# រូបភាពទី ២



## រូបភាពទី ៣



# ការចុះសំបុត្រកំណើត

## រូបភាពទី ៤



# កុមារចេះមើល និងស្តាប់ឮសំឡេង

## រូបភាពទី ៥



# កុមារចេះក្រឡាប់

## រូបភាពទី ៦



# កុមារចេះលូន

# រូបភាពទី ៧



# កុមារចេះតោងឈរ និង ដើរតតេះតតះ

# រូបភាពទី ៨



# កុមាររៀនប្រាស្រ័យទាក់ទង ជាមួយមិត្តភក្តិ

# រូបភាពទី ៩



# កុមាររៀនពីការអនាម័យ

# រូបភាពទី ១០



# កុមាររៀនប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ

## រូបភាពទី ១១



# គេងឱ្យបានគ្រប់គ្រាន់

## រូបភាពទី ១២



# ញុំាឱ្យទៀងពេលវេលា

## រូបភាពទី ១៣



# ការមានជម្លោះច្រើន
# ជាមួយបងប្អូន

## រូបភាពទី ១៤



# ធ្វើអ្វីមួយមិនបានគិតពីគ្រោះថ្នាក់

## រូបភាពទី ១៥



# អាកប្បកិរិយាផ្ដើន

## រូបភាពទី ១៦



# ការគ្រាប់តាមមនុស្សធំ

# រូបភាពទី ១៧




# ចាប់ផ្ដើមមានទំនាក់ទំនងខាងក្រៅ

## រូបភាពទី ១៨



# ការចង់ដឹង និងឆ្ងល់ច្រើន

## រូបភាពទី ១៩



# ការគ្មានសណ្ដាប់ធ្នាប់

## រូបភាពទី ២០



# ការចូលរៀន

## រូបភាពទី ២១



# ការមិនចុះសម្រុងជាមួយ
# ភេទផ្ទុយគ្នា

# រូបភាពទី ២២



# អាកប្បកិរិយាប្រថុយប្រថាន

## រូបភាពទី ២៣



# ធ្វើអ្វីតាមមិត្តភក្តិ

# រូបភាពទី ២៤


ផលប៉ះពាល់នៃការរំលោភបំពានលើការអភិវឌ្ឍខួរក្បាលកុមារ
ខួរក្បាលដែលមាន
ស្ថានភាពផ្លូវចិត្តល្អ
ខួរក្បាលដែលរង
ការរំលោភបំពានធ្ងន់ធ្ងរ

# រូបភាពទី ២៥



៣) យល់អំពីការគិត និងអារម្មណ៍

# វគ្គទី៩
# មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៣)

## សេចក្តីផ្តើម

យោងទៅតាមលទ្ធផលស្រាវជ្រាវឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការ UNICEF ស្តីពីអំពើហិង្សាលើកុមារ បានបញ្ជាក់ថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតមានដូចជា ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ ដូចនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគួរសិក្សា ស្វែងយល់ពីអំពើហិង្សា ការមិនអើពើ និងផលប៉ះពាល់លើកុមារ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការបញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ ដែលកន្លងមកពួកគាត់ តែងតែគិតថាការអប់រំប្រដៅកូនមានរបៀបពីរគឺ **ត្រជាក់** (អហិង្សា) **និងក្តៅ** (ហិង្សា) ពិសេសគឺយោងទៅលើនិស្ស័យ របស់កូន ឬកុមារ។ ការអប់រំប្រដៅកូនដោយបែបក្តៅដូចជាការស្តីបន្ទោស ជេរ គំរាម សំឡុត ដាក់ទណ្ឌកម្ម វាយដំ គឺគ្រាន់តែចង់ឱ្យកូនៗ ឬកុមារមាន អាកប្បកិរិយាល្អតែប៉ុណ្ណោះ។ ដូច្នេះពួកគាត់គិតថាការធ្វើបែបនេះវាមិនមែនជា ការរំលោភបំពាននោះទេ ដោយសារមានការគិត ឬទម្លាប់បែបនេះហើយទើបនាំឱ្យមានការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាបន្តកើតមានលើកូន ឬកុមារ នៅក្នុងគ្រួសារមួយចំនួនធំ។

ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគិត ឬទម្លាប់ខាងលើ យើងក៏បានរៀបចំចងក្រងប្រធានបទនៃការប្រៀន ប្រដៅកូនបែបវិជ្ជមាន ដែលជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើដែលផ្តោត ទៅលើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន៤ ក្នុងគោលបំណង ជួយដល់ឪពុកម្តាយ អាណាព្យាបាល ឬ អ្នកថែទាំ កំណត់បានពីរបៀបនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន និងការដោះស្រាយបញ្ហាជាមួយកូន ឬកុមារតាម ដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍកុមារ ព្រមទាំងជ្រើសរើស និងអនុវត្តនូវវិធីសាស្ត្រ ឬរបៀបចិញ្ចឹម កូនបែបវិជ្ជមាន ដោយប្រើគោលការណ៍សំខាន់ចំនួន៥ និងធាតុផ្សំចំនួន ៤។

# ១. គោលការណ៍ទាំង៥

គោលការណ៍ ទី១

## ភាពអហិង្សា

គឺជាការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកូន ឬកុមារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

គោលការណ៍ ទី២

## ផ្ដោតទៅលើការរកដំណោះស្រាយ

គឺជាការស្ដាប់ និងការបង្ហាញហេតុផល រួមទាំងការពិភាក្សា និងការស្វែងរកវិធី ឬរបៀបណាមួយដើម្បីដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ឬបែបវិជ្ជមានដែលមានការចូលរួមយល់ព្រម និងការចរចាគ្នា។

គោលការណ៍ ទី៣

## ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នា ក្នុងភាពជាមនុស្ស ដោយគ្មានការរើសអើង និងវិនិច្ឆ័យ។

គោលការណ៍ ទី៤

## ផ្ដោតលើដំណាក់កាលលូតលាស់ និងអភិវឌ្ឍកុមារ

គ្រប់កុមារទាំងអស់ □កុមារា កុមារី ឬកុមារដែលមានពិការភាព□ មានការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ទៅតាមកម្រិតអាយុរបស់ពួកគេ ដូចជាការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈ ការគិត និងអារម្មណ៍ ដូច្នេះការបំពេញទៅនឹងតម្រូវការរបស់ពួកគេ គឺមានភាពខុសៗគ្នា។

គោលការណ៍ ទី៥

## ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

សិទ្ធិកុមារគឺជាអ្វីៗដែលកុមារមាន និងអ្វីដែលមនុស្សទទួលខុសត្រូវចំពោះកុមារ។ ពួកគេត្រូវធានាថា កុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំ និងនិយាយនូវអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ។ កុមារទាំងអស់ រួមទាំងកុមារដែលមានពិការភាពទទួលបាននូវសិទ្ធិទាំងនេះ មិនថាពួកគេជានរណា មានពណ៌សម្បុរអ្វី ភាសាអ្វី សាសនាណា ក្មេងប្រុស ឬក្មេងស្រី អ្នកក្រ ឬអ្នកមានឡើយ។ ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក បានចុះហត្ថលេខាលើឯកសារនេះ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មានន័យថា ពួកគេបានសន្យានឹងធ្វើអ្វីៗទាំងអស់ដើម្បីធានាថា កុមារទាំងអស់ទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។

# ២. ធាតុផ្សំទាំង៤

| ធាតុផ្សំទី១៖ | ធាតុផ្សំទី២៖ | ធាតុផ្សំទី៣៖ | ធាតុផ្សំទី៤៖ |
|---|---|---|---|
| គោលដៅយូរអង្វែង | ភាពកក់ក្ដៅ និងដែនកំណត់ | យល់អំពីការគិត និងអារម្មណ៍ | ដោះស្រាយបញ្ហា |

កាលពីវគ្គមុន លោកអ្នកបានធ្វើការពិភាក្សាគ្នារួចមកហើយអំពីគោលការណ៍សំខាន់ចំនួន ៥ និង ធាតុផ្សំចំនួន ២ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន។ នៅក្នុងវគ្គនេះ យើងនឹងលើកយកធាតុផ្សំទី៣ **យល់អំពីការគិត និងអារម្មណ៍** សម្រាប់កូន ឬកុមារដែលមានអាយុពី ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មកធ្វើការពិភាក្សាគ្នា និងហាត់អនុវត្ត។ ដោយឡែកធាតុផ្សំចំនួន ១ទៀតនឹងត្រូវសិក្សានៅវគ្គបន្ទាប់។

## គោលបំណង

**នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**

- ស្វែងយល់អំពីការគិត និងអារម្មណ៍របស់កុមារ តាមរយៈការលូតលាស់ និងអភិវឌ្ឍ របស់កុមារ ដែលមានអាយុពី១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។
- ទទួលយកនូវរបៀបផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់សម្រាប់កូន ឬកុមារទៅតាមតម្រូវការនានារបស់ពួកគេនៅតាមដំណាក់កាលផ្សេងៗ នៃការលូតលាស់ និងអភិវឌ្ឍ។
- ទទួលស្គាល់អំពីការគិត និងអារម្មណ៍នានាដែលបណ្ដាលឱ្យកូន ឬកុមារមានអាកប្បកិរិយាប្រឆាំងនឹងអ្វីៗដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបានរំពឹងទុក។

## រយៈពេល

**១៥០ នាទី**

## សម្ភារៈដែលត្រូវការ

- រូបភាពទី ១ បង្ហាញពី ការប្រែប្រួលប្រព័ន្ធបន្តពូជ
- រូបភាពទី ២ បង្ហាញពី អារម្មណ៍មិនពេញចិត្តនឹងខ្លួនឯង
- រូបភាពទី ៣ បង្ហាញពី បង្ហាញពីអត្តសញ្ញាណរបស់ខ្លួន
- រូបភាពទី ៤ បង្ហាញពី រាងកាយលូតលាស់ជាមនុស្សពេញវ័យ
- រូបភាពទី ៥ បង្ហាញពី ធ្វើអ្វីមួយមិនបានគិតអំពីលទ្ធផល
- រូបភាពទី ៦ បង្ហាញពី ការរៀនបំណិនជីវិត
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ

- កម្រាល សម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រា អំពីវិន័យដែលក្រុមបានចងក្រងកាលពីជំនួបដំបូង

**ខ្លឹមសារលម្អិត**

## I. ធាតុផ្សំទី៣៖ យល់អំពីការគិត និងអារម្មណ៍

### ១. និយមន័យ

ការយល់អំពីការគិត និងអារម្មណ៍គឺជាការយល់ដឹងពីសេចក្តីត្រូវការរបស់កូន ឬកុមារដែលផ្តោតលើដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ រួមទាំងការគោរពឱ្យតម្លៃពួកគេជាមនុស្សម្នាក់ដែលមានភាពសំខាន់ដោយឡែកៗពីគ្នា។

*ឧទាហរណ៍ កុមារម្នាក់ពូកែខាងគូរគំនូរ ប៉ុន្តែកុមារម្នាក់ទៀតពូកែច្រៀង។ល។*

**ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចស្វែងយល់អំពីការគិត និងអារម្មណ៍របស់កូន ឬកុមារតាមរយៈ**

- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គួរព្យាយាមស្វែងយល់អំពីហេតុផលនានាដែលធ្វើឱ្យកូនរបស់លោកអ្នកមានអាកប្បកិរិយាបែបនោះ។
- កុមារគ្រប់រូប (កុមារា កុមារី និងកុមារដែលមានពិការភាព) ត្រូវការឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំស្វែងយល់អំពីការគិត និងអារម្មណ៍របស់ពួកគេ ដោយផ្តល់ឱ្យមានភាពស្មើគ្នារវាងកូនស្រី និងកូនប្រុស ព្រោះកុមារមានការលូតលាស់ និងអភិវឌ្ឍផ្នែកបញ្ញាស្មារតី អារម្មណ៍ និងសង្គម ដោយមានការប្រែប្រួលទៅតាមកម្រិតអាយុ ជីវសាស្ត្រ និងរៀនពីមជ្ឈដ្ឋានជុំវិញដែលពួកគេរស់នៅ។ ក្នុងន័យនេះ ប្រសិនបើឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ មានការយល់ដឹងអំពីបម្រែបម្រួលរបស់កូន ឬកុមារ អាចនាំឱ្យពួកគាត់ងាយស្រួលបត់បែន និងទទួលយកនូវអាកប្បកិរិយានានារបស់ពួកគេ ហើយនឹងអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនឯង ហើយអាចជៀសវាង និងកាត់បន្ថយភាពមិនចុះសម្រុងគ្នាជាមួយកូន ឬកុមារ។

*ឧទាហរណ៍*

*កូន ឬកុមារចាប់ពីអាយុ ១៣-១៨ឆ្នាំ ពួកគេឈប់សួរសំណួរច្រើន និងចង់ធ្វើការងារផ្ទះដូចមុនទៀតហើយ។*

*ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវតែស្វែងយល់ឱ្យបានស៊ីជម្រៅពីការគិត និងអារម្មណ៍នានាដែលនាំឱ្យពួកគេមានតម្រូវការអ្វីមួយ ឬមានអាប្បកិរិយាលំបាកៗកើតឡើង ព្រោះដោយសារតែនៅក្នុងដំណាក់កាលនេះ ទាំងការលូតលាស់ និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី អារម្មណ៍ និងសង្គម មានការប្រែប្រួលយ៉ាងខ្លាំងទៅតាមអាយុ ឬការចម្រើនវ័យរបស់ពួកគេ លើផ្នែកជីវសាស្ត្រ (អ័រម៉ូន) និងអ្វីដែលពួកគេរៀនតាម ឬអ្វីដែលពួកគេចម្លងតាមពីបរិស្ថានជុំវិញដែលគេរស់នៅ។ ក្នុងន័យនេះប្រសិនបើ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ*

*មានការយល់ដឹងពីកត្តានានាដែលនាំឱ្យកូន ឬកុមារមានបម្រែបម្រួលបែបនេះ បានច្បាស់ នោះពួកគាត់ពិតជាទទួលស្គាល់ និងរិះរកវិធីនានា ដើម្បីជួយដល់កូន ឬកុមារបានយ៉ាងមានប្រសិទ្ធភាព ពិសេសគឺអាចគ្រប់គ្រងអារម្មណ៍ រួមទាំងអាកប្បកិរិយារបស់ពួកគាត់ប្រកបដោយភាពអហិង្សាបានជាក់ជាមិនខាន។*

**គួរចងចាំ**

**ជាធម្មតាកូនៗ ឬកុមារក្នុងវ័យជំទង់ ព្យាយាមបំពេញតម្រូវការរបស់ខ្លួនទៅតាមអាយុ ឬដំណាក់កាលនៃការលូតលាស់ ការអភិវឌ្ឍ និងបរិស្ថានដែលនៅជុំវិញពួកគេ។**

**មានតែការផ្តល់ភាពកក់ក្តៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់អំពីការគិត និងអារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីដែលពួកគេគួរធ្វើ និងមិនគួរធ្វើ។**

## II. របៀបដែលកុមារគិត និងមានអារម្មណ៍

### សម្រាប់អាយុ១៣ឆ្នាំ ដល់១៨ឆ្នាំ

- នេះជាដំណាក់កាលលូតលាស់មិនគួរឱ្យជឿ។ ឥឡូវនេះកុមារបានឈានជិតដល់វ័យមនុស្សធំ កុមារត្រូវប្រើជំនាញរបស់ពួកគេដោយខ្លួនឯង ពួកគេអាចគិតពីគំនិតថ្មីៗ អភិវឌ្ឍនូវឧត្តមគតិដោយផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើដំណើរដោយខ្លួនឯង។ ជួនកាលដំណាក់កាលនេះជាការលំបាកសម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទៀតផង។ ដោយសារតែមានការលំបាកបែបនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវតែយកចិត្តទុកដាក់ ផ្តល់ឱកាស ឬបង្រៀនកូន ឬកុមារពីរបៀបនានាក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានល្អក្នុងការដោះស្រាយជម្លោះ និងការតស៊ូយកឈ្នះនូវភាពបរាជ័យផងដែរ។
- នៅក្នុងដំណាក់កាលនេះកិច្ចការជាបឋមរបស់កូន ឬកុមារ គឺស្វែងរកអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ។ ទាំងនេះអាចត្រូវបានបង្ហាញតាមរយៈ ការផ្លាស់ប្តូរភ្លាមៗនៅក្នុងជម្រើសរបស់ពួកគេដូចជា៖
  - → ការស្តាប់បទភ្លេង
  - → ការស្លៀកពាក់
  - → ម៉ូដសក់
  - → មិត្តភក្តិ
  - → ការចូលចិត្តចំណីអាហារ
  - → សកម្មភាពក្រៅសាលា

→ ការចាប់អារម្មណ៍លើការសិក្សាស្រាវជ្រាវ

→ ផែនការសម្រាប់ពេលអនាគត ។ល។

- ជួនកាលដើម្បីបានទទួលនូវអត្តសញ្ញាណថ្មី ពួកគេត្រូវតែបោះបង់ចោលរបៀបរបបចាស់របស់ពួកគេខ្លះ។ ពួកគេប្រៀបដូចជាសត្វដង្កូវនាងដែលកំពុងបោះបង់ចោលនូវសំបុករបស់វា។ ជួនកាលគំនិតថ្មីទាំងនេះមានលក្ខណៈខុសគ្នាទាំងស្រុងពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំរបស់ពួកគេ ហើយប្រហែលជានឹងជួបការលំបាកខ្លាំងថែមទៀត។

- នៅក្នុងដំណាក់កាលនេះមនុស្សជំទង់មានការលំបាកនឹងយល់ថា រឿងអាក្រក់អាចកើតមានចំពោះពួកគេ ព្រោះពួកគេមិនទាន់យល់ច្បាស់នៅឡើយទេពេលគឺកង្វះនូវបទពិសោធន៍។ ជួនកាលពួកគេអាចធ្វើរឿងដែលអាចមានហានិភ័យ (គ្រោះថ្នាក់) ខ្ពស់ ពីព្រោះពួកគេជឿជាក់ថាគ្មានរឿងអាក្រក់អាចកើតមានចំពោះពួកគេនោះឡើយ ពួកគេចង់ធ្វើនូវអ្វីដែលពួកគេតែងតែធ្លាប់បានឃើញមនុស្សចាស់ធ្វើ។

- ការជឿទុកចិត្តបានក្លាយជារឿងសំខាន់ណាស់ក្នុងដំណាក់កាលនេះ ដូច្នេះកូន ឬកុមារត្រូវតែមានឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដើម្បីជួយគាំទ្រ ផ្ដល់ព័ត៌មាន និងដំបូន្មានដល់ពួកគេ ប៉ុន្តែពួកគេក៏មិនចង់ឱ្យអ្នកណាត្រួតត្រានោះដែរ។

- ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវការផ្ដល់ដែនកំណត់ ដូចជាព័ត៌មានពីអ្វីដែលគួរធ្វើ ឬមិនគួរធ្វើឱ្យបានច្បាស់លាស់ និងដោយស្មោះត្រង់ រួមទាំងសេចក្ដីរំពឹងទុកដ៏ច្បាស់លាស់ និងបរិស្ថានដ៏មានសុវត្ថិភាព។ កូន ឬកុមារកំពុងតែសាកល្បងស្លាបរបស់ពួកគេ ដើម្បីរៀនហើរ ជួនកាលពួកគេអាចហើរធ្លាក់ ប៉ុន្តែពួកគេរៀនហោះហើរដោយមានជំនួយរបស់អ្នក។

- ចំណុចដែលសំខាន់ជាងគេនោះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់នៅក្នុងដំណាក់កាលនេះចាំបាច់បំផុតគឺ៖

  ▪ ការពង្រឹងទំនាក់ទំនងគ្នារវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងកូន ដូចជា៖

    → ភាពកក់ក្ដៅ សណ្ដានចិត្តល្អ សេចក្ដីស្រឡាញ់ និងយល់ចិត្ត

    → ភាពនឹងន ភាពម៉ឺងម៉ាត់ ច្បាស់លាស់ប្រាកដ និងភាពស្មោះត្រង់

នៅពេលដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំប្រព្រឹត្តចំពោះកូន ឬកុមាររបស់ពួកគាត់ប្រកបដោយការគោរព និងដោយសណ្ដានចិត្តល្អ កូន ឬកុមាររបស់ពួកគាត់នឹងប្រព្រឹត្តចំពោះពួកគាត់វិញដោយការគោរព និងដោយសណ្ដានចិត្តល្អដូចគ្នា។

- ការតាមដានសកម្មភាពរបស់កូន ឬកុមារ៖

កិច្ចការរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគឺផ្ដល់ផែនទីដើម្បីណែនាំផ្លូវកូន ឬកុមារ គឺត្រូវបង្ហាញពួកគេនូវទីកន្លែងដែលមានផ្លូវរលាក់ និងផ្លូវដែលមានសុវត្ថិភាពជាងគេបំផុត ឆ្ពោះទៅកាន់គោលដៅណាមួយ។ ប៉ុន្តែត្រូវផ្ដល់ឱកាសឱ្យកូន ឬកុមារ បានធ្វើសេចក្ដីសម្រេចចិត្តដោយខ្លួនឯងថាត្រូវដើរផ្លូវណាមួយ។

- ការតាមដាន មានន័យថា ដឹងពីអ្វីដែលកូនឬកុមារ កំពុងតែធ្វើនៅក្នុងផ្លូវមួយ ដែលគោរពនូវសេចក្ដីត្រូវការសម្រាប់អ្វីមួយ និងសិទ្ធិធ្វើអ្វីមួយរបស់ពួកគេនូវភាពលាក់កំបាំង ភាពឯកជន និងភាពឯករាជ្យម្ចាស់ការ។

- ឪពុកម្ដាយអាណាព្យាបាលឬអ្នកថែទាំអាចតាមដានកូនឬកុមាររបស់ពួកគាត់ដោយ៖
    - → សង្កេតពីសកម្មភាពរបស់ពួកគេ
    - → ស្ដាប់ និងនិយាយជាមួយពួកគេឱ្យបានញឹកញាប់
    - → នៅជាមួយពួកគេឱ្យបានច្រើនបំផុតប៉ុន្តែមិនមែនក្នុងលក្ខណៈរំលោភបំពានភាពឯកជន
    - → ចូលរួមព្រឹត្តិការណ៍ផ្សេងៗជាមួយពួកគេ
    - → ដឹងថាអ្នកណាខ្លះជាមិត្តភក្តិរបស់ពួកគេ
    - → ស្វាគមន៍មិត្តភក្តិរបស់ពួកគេឱ្យមកលេងផ្ទះ
    - → អញ្ជើញមិត្តភក្តិរបស់ពួកគេព្រមទាំងក្រុមគ្រួសារទៅដើរកំសាន្តជាមួយគ្នា
    - → ដឹងពីចំណង់ចំណូលចិត្តរបស់ពួកគេចូលចិត្តធ្វើអ្វីខ្លះនៅពេលទំនេរ
    - → រកមើលសកម្មភាពដែលពួកគេទាំងពីរសប្បាយ និងធ្វើរឿងនោះរួមគ្នា
    - → គាំទ្រពួកគេឱ្យសម្រេចនូវគោលបំណង។ល។

- ការបណ្ដុះឱ្យមានភាពឯករាជ្យម្ចាស់ការរបស់កូន ឬកុមារដោយ៖
    - → ការគោរពដោយពិតប្រាកដនូវគំនិតរបស់កូន ឬកុមារ សូម្បីតែរឿងនោះខុសពីគំនិតខ្លួនឯងក៏ដោយ
    - → ជំរុញលើកទឹកចិត្តកូន ឬកុមារឱ្យធ្វើសេចក្ដីសម្រេចពីអ្វីខ្លះដែលជាតម្លៃរបស់ពួកគេ
    - → បង្ហាញនូវសេចក្ដីស្រលាញ់ដែលគ្មានល័ក្ខខ័ណ្ឌ
    - → ជំរុញលើកទឹកចិត្តក្នុងការពិភាក្សាជាមួយកូន ឬកុមារក្នុងឋានៈស្មើគ្នា
    - → បង្ហាញនូវការជឿជាក់លើសមត្ថភាពរបស់កូន ឬកុមារដើម្បីធ្វើសេចក្ដីសម្រេច និងលៃលកដោះស្រាយជាមួយលទ្ធផលនៃសេចក្ដីសម្រេចរបស់ពួកគេ
    - → គោរពនូវអារម្មណ៍របស់កូន ឬកុមារ
    - → គាំទ្រ និងជំរុញលើកទឹកចិត្តកូន ឬកុមារឱ្យព្យាយាមម្ដងទៀតបន្ទាប់ពីបរាជ័យ
    - → ពិចារណាពីទស្សនៈរបស់កូន ឬកុមារនៅពេលដែលពួកគេមានអារម្មណ៍ថាស្រលាញ់មិនស្មើគ្នា

→ ដំណោះស្រាយដោយការចរចាចំពោះភាពមិនចុះសម្រុងគ្នា

ភាពឯករាជ្យគឺជួយលើកទឹកចិត្តកូន ឬកុមារខណៈពេលដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបានបង្ហាញពួកគេថា ពួកគាត់គោរព និងជឿជាក់លើពួកគេ។

## III. ដំណាក់កាលលូតលាស់ និងអភិវឌ្ឍរបស់កុមារ (អាយុពី ១៣ឆ្នាំ រហូតដល់ ១៨ឆ្នាំ)

### ១. ការលូតលាស់ផ្នែករាងកាយ

- ប្រព័ន្ធបន្តពូជមានការលូតលាស់ពេញលេញ។
- ការលូតលាស់នៃរាងកាយមិនស្មើ (ម្ដងលឿន ម្ដងយឺត) ហើយលទ្ធផលនៃការលូតលាស់មិនស្មើនេះធ្វើឱ្យគេមានភាពអស់កម្លាំង ឈឺពេញដងខ្លួន ឈឺពោះ (ការរំលាយអាហារមិនបានល្អ) បរិភោគអាហារមិនទៀងទាត់។ កុមារីឧស្សាហ៍ឈឺក្បាល ហើយជួនកាលសន្លប់បាត់ស្មារតី ក្អួត ធ្លាក់ទឹកចិត្ត ឆាប់ខឹង ច្របូកច្របល់ក្នុងចិត្ត មានអារម្មណ៍ខុសប្លែកពីគេ ឆាប់ខ្លាច និងមានអាកប្បកិរិយាឆ្គាំឆ្គងជាដើម។
- រាងកាយបានលូតលាស់ជាមនុស្សពេញវ័យ ហើយមានកម្លាំងខ្លាំង។ ប៉ុន្តែបើមានការលូតលាស់ ផ្នែកណាមួយនៃរាងកាយខុសពីការរំពឹងទុក គេអាចមានគំនិតអវិជ្ជមានចំពោះខ្លួនឯង។

*ឧទាហរណ៍៖ មានកម្ពស់ទាប ធាត់ពេក ស្គមពេកដែលនាំឱ្យពួកគេពិបាកចិត្តជាខ្លាំង។*

### ២. ការលូតលាស់ផ្នែកអារម្មណ៍

- មានការធ្លាក់ទឹកចិត្តខ្លាំង (អាចសម្លាប់ខ្លួន) ដោយសារគេមិនពេញចិត្តនឹងអ្វីៗដែលគេមានផ្ទាល់ខ្លួន និងខ្វះការគាំទ្រពីបរិស្ថានជុំវិញ។
- អារម្មណ៍មានការលូតលាស់ផ្ទុយពីរាងកាយ (ភេទស្រី មានអារម្មណ៍ជាមនុស្សប្រុស ឬភេទប្រុស មានអារម្មណ៍ជាមនុស្សស្រី)
- ការពារខ្លួនឯងហួសហេតុ អារម្មណ៍ឆេវឆាវ ចង់សងសឹក ដកខ្លួនចេញពីគេ ដែលជាហេតុធ្វើឱ្យពួកគេខឹងជាមួយខ្លួនឯង។
- អាចបង្កជម្លោះជាមួយឪពុកម្ដាយ ឬអ្នកជុំវិញខ្លួន។
- មានការខ្វល់ខ្វាយច្រើន ព្រោះមានការប្រែប្រួលរាងកាយច្រើន។
- ជ្រើសរើសមិត្តភក្តិល្អៗ ២ ទៅ ៣នាក់យ៉ាងច្រើនបំផុត សម្រាប់ជីវិតរបស់គេ។

## ៣. ការលូតលាស់ផ្នែកចរិតលក្ខណៈ

- វ័យនេះជាវ័យមួយដ៏សំខាន់សម្រាប់ការលូតលាស់សរីរាង្គកាយ និងប្រព័ន្ធបន្តពូជ។ ដូចនេះអាកប្បកិរិយាមានការប្រែប្រួលខ្លាំងទៅតាមអារម្មណ៍ និងបរិស្ថានជុំវិញ។

*ឧទាហរណ៍៖ មិនសូវយកចិត្តទុកដាក់នូវការណែនាំ ចេះកុហក ឆេវឆាវ ផ្តាច់ខ្លួនពីគ្រួសារ ខ្មាសអៀន ស្រងូតស្រងាត់ ក្រៀមក្រំ រំភើប ឬសង្ស័យថាគេសម្លឹង និងនិយាយពីខ្លួនឯងជាដើម។*

- ការលូតលាស់ និងអភិវឌ្ឍនេះគឺបណ្តាលមកពីអ័រម៉ូន។

*ឧទាហរណ៍៖ កុមារីចាប់ផ្តើមមានរដូវ កុមារាមានទឹកកាមលើកដំបូង។*

- អំឡុងពេលនេះ ជាពេលនៃការផ្លាស់ប្តូរ និងឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ទៀតដែលនាំឱ្យមានវិបត្តិខាងកសាងបុគ្គលិកលក្ខណៈរបស់ខ្លួន។ ប៉ុន្តែរចនាសម្ព័ន្ធនៃចិត្តមានការផ្តុំឡើងតាំងពីកុមារមកម្ល៉េះ មិនអាចផ្លាស់ប្តូរបានទេ។ ខណៈពេលនេះមានការផ្លាស់ប្តូរច្រើនដូចជា បាត់តុល្យភាពនៃគោលបំណង និងរំជួលអារម្មណ៍ ច្រានចោលនូវគុណសម្បត្តិនៃវ័យកុមារ ចង់បានឯករាជ្យភាព ប្រឈមជាមួយនឹងទំនួលខុសត្រូវ។
- ធ្វើអ្វីមួយមានសន្ទុះចិត្ត និងប្រថុយប្រថានខ្ពស់ ពីព្រោះពួកគេមានបទពិសោធន៍តិចតួចក្នុងជីវិត។
- បង្ហាញពីអត្តសញ្ញាណរបស់ខ្លួន ដោយត្រាប់តាមទង្វើរបស់មនុស្សធំណាដែលពួកគេពេញចិត្ត ឬទុកចិត្ត។

**គួរចងចាំ**

**កុមារត្រូវទទួលស្គាល់ការលូតលាស់ផ្នែករាងកាយ និងតួនាទីប្រព័ន្ធបន្តពូជរបស់ខ្លួនជាមនុស្សពេញវ័យ ព្រោះពួកគេឈានដល់វ័យជំទង់ ហើយចាប់ផ្តើមមានទំនាក់ទំនងជាមួយមនុស្សដែលមានភេទផ្ទុយគ្នា ឬមួយចំនួនតូចដែលមានទំនោរទៅរកភេទដូចគ្នា និងមានឯករាជ្យភាពខ្លះៗ ពីឪពុកម្តាយ។**

### ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរធ្វើ

- ជួយកូន ឬកុមារឱ្យស្រលាញ់ខ្លួនឯងក្នុងផ្លូវវិជ្ជមានដូចជា៖
  - → សរសើរពីភាពស្អាតដែលពួកគេមាន
  - → ទទួលស្គាល់សមត្ថភាពរបស់កូន ឬកុមារ
  - → ជួយកូន ឬកុមារឱ្យស្គាល់ពីភេទរបស់ខ្លួន ជាការសំខាន់ដែលឪពុកគួរសរសើរកូនស្រី ម្តាយសរសើរកូនប្រុស។

→ ទទួលស្គាល់ ឬយល់ពីលក្ខណៈធម្មជាតិរបស់កូន (ភេទស្រី មានទំនោរជាភេទប្រុស ឬភេទប្រុស មានទំនោរជាភេទស្រី) ដោយជម្រុញ និងលើកទឹកចិត្តពួកគាត់ឱ្យទទួលបានការអប់រំ និងចូលរួមដូចកូនផ្សេងទៀត។

→ ទទួលស្គាល់ ជំរុញ ឬពង្រឹងចំពោះអត្តចរិតល្អ។

→ ផ្តល់ឱកាសឱ្យពួកគេមានសេរីភាព និងការទទួលខុសត្រូវ។

- ជួយកូន ឬកុមារឱ្យយល់ដឹងពីខ្លួនឯងដូចជា៖

→ ផ្តល់ព័ត៌មានពីការថែទាំសុខភាព និងអនាម័យខ្លួនប្រាណ។

→ រៀនកត់សម្គាល់ គិត និងប្រតិកម្មផ្សេងៗនៃរាងកាយ ដែលនាំឱ្យកើតមានអារម្មណ៍នានា និងរៀនគ្រប់គ្រងអាកប្បកិរិយារបស់ខ្លួនដែលបណ្តាលមកពីការប្រែប្រួលរាងកាយ ឬស្ថានភាពជុំវិញខ្លួន។

- ជួយកូន ឬកុមារ គ្រប់គ្រងបំណងប្រាថ្នា និងការច្នៃប្រឌិតដូចជា៖

→ ទទួលស្គាល់ និងគាំទ្របំណងប្រាថ្នាល្អរបស់ពួកគេ

→ ជៀសវាងស្តីបន្ទោសពីបំណងប្រាថ្នាដែលពួកគេមាន

→ ជួយគេឱ្យចេះគ្រប់គ្រងអារម្មណ៍

→ ចូលរួមពិភាក្សា និងចរចា

→ ចេះអត់ធ្មត់ជាមួយគេ

→ បង្រៀនគេឱ្យចេះទទួលយកកំហុស និងរៀនពីកំហុស

→ ជួយពួកគេឱ្យដឹងនូវអ្វីដែលនាំឱ្យមានការឈឺចាប់ដល់ខ្លួនឯង និងអ្នកដទៃ

→ រីករាយជាមួយនឹងអ្វីដែលកូនមាន

→ បង្រៀនគេឱ្យចេះរង់ចាំ

→ ជួយពួកគេឱ្យមានគំនិត ឬបង្កើតបំណងប្រាថ្នាថ្មី

→ បដិសេធដោយម៉ឺងម៉ាត់ចំពោះសកម្មភាពដែលនាំឱ្យមានគ្រោះថ្នាក់ ដោយធ្វើការពិភាក្សា និងពន្យល់ពីហេតុផលជាក់លាក់។

- បង្រៀនកូន ឬកុមារឱ្យមានចិត្តទូលាយដូចជា៖

→ បង្រៀនពួកគេឱ្យចេះចែករំលែក មានទំនាក់ទំនង និងគោរពអ្នកដទៃ ទាំងរូបកាយ គំនិត និងអារម្មណ៍។

→ ជួយពួកគេឱ្យយល់ថា មនុស្សម្នាក់ៗមានភាពសំខាន់ខុសៗគ្នា។

→ ជួយពួកគេឱ្យចេះទទួលយកការពិត និងទទួលខុសត្រូវចំពោះខ្លួនឯង

→ ជួយឱ្យពួកគេគោរពសេចក្តីណែនាំ និងច្បាប់ទម្លាប់សង្គមនានា។

- ជួយកូន ឬកុមារឱ្យចេះដោះស្រាយបញ្ហាដូចជា៖

→ ស្តាប់ពីហេតុផលនានា ការលំបាក និងជួយពួកគេឱ្យរកឃើញនូវជម្រើស។

→ អត់ធ្មត់ ស្វែងយល់ពីវិធីដែលវិជ្ជមាន និងទទួលយកគំនិត យោបល់ពីអ្នកដទៃ។

→ ជឿលើសមត្ថភាព និងសក្តានុពលរបស់ពួកគេ នោះគេនឹងអាចមានគំនិតច្នៃប្រឌិត។

- បង្ហាញការយល់ចិត្តកូន ឬកុមារដូចជា៖

→ ស្តាប់៖ ដោយឱ្យពួកគេបញ្ចេញ ឬនិយាយពីអារម្មណ៍របស់ខ្លួន ស្វែងយល់ពីការគិត អារម្មណ៍ និងអាកប្បកិរិយារបស់ពួកគេ។

→ ឆ្លើយតប៖ ដោយបង្ហាញពីអារម្មណ៍របស់យើងចំពោះរឿងរបស់កូន ឬកុមារ ពោលពាក្យសរសើរ និងលើកទឹកចិត្ត ផ្តល់ព័ត៌មាននានាដើម្បីបំពេញតម្រូវការរបស់ពួកគេ។

## IV. អនុសាសន៍មួយចំនួនសម្រាប់អនុវត្តសកម្មភាពនានា និងណែនាំកូនវ័យជំទង់

- មនុស្សវ័យជំទង់មានតម្រូវការសំខាន់ ៣យ៉ាង ៖

១. ឱ្យគេស្រលាញ់ និងយកចិត្តទុកដាក់

២. មានដែនកំណត់ ឬច្បាប់ច្បាស់លាស់ និងយុត្តិធម៌

៣. ការពន្យល់ និងស្តាប់ហេតុផលជាជាងការប្រាប់ ឬបង្គាប់បញ្ជាឱ្យធ្វើអ្វីមួយ

- ជំនឿទុកចិត្តគឺជាការសំខាន់។ ទោះបីជាគេត្រូវការអភិវឌ្ឍភាពឯករាជ្យក៏ដោយ ក៏មនុស្សវ័យជំទង់នៅតែត្រូវការដឹងថាមានឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅតែគាំទ្រគេ។

- គោរពនូវភាពឯកជនរបស់មនុស្សវ័យជំទង់ ប៉ុន្តែត្រូវរក្សាត្រឹមព្រំដែនដែលមានសុវត្ថិភាពដល់គេ

- សូមឱ្យស្មោះត្រង់ និងនិយាយត្រង់ៗនៅពេលដែលនិយាយអំពីប្រធានបទដែលរសើប ដូចជាការប្រើគ្រឿងញៀន ផឹកស្រា ជក់បារី ឬបញ្ហាភេទ និងការរួមភេទជាដើម។

- លើកទឹកចិត្តឱ្យមានការហាត់ប្រាណ និងលេងកីឡា គឺជារឿងល្អសម្រាប់លំហាត់ប្រាណ និងការងារក្រុម។

- ជួប និងស្គាល់ ឬស្វែងយល់នូវមិត្តភក្តិរបស់មនុស្សវ័យជំទង់

- គោរពនូវយោបល់របស់មនុស្សវ័យជំទង់ និងស្វែងយល់អំពីការគិត និងអារម្មណ៍នានារបស់គេ។ វាជារឿងសំខាន់ណាស់ដែលគេដឹងថាមាននរណាម្នាក់ស្តាប់គេ។

- កុំរិះគន់អំពីសក់ សម្លៀកបំពាក់ របស់របរផ្ទាល់ខ្លួន ប៉ុន្តែសូមលើកជាការស្នើរឡើងដែលឈរលើផលប៉ះពាល់នៃរបស់ទាំងនោះទៅលើពួកគេ។

*ឧទាហរណ៍៖ ខ្ញុំដឹងថាអ្នកចូលចិត្ត និងស្រលាញ់សក់ពណ៌ក្រហម និងខោខូវប៊យរហែក ប៉ុន្តែវានឹងងាយក្នុងការទទួលបានការងារធ្វើប្រសិនបើអ្នកមាន សក់ពណ៌ខ្មៅ ឬស្លៀកពាក់របៀបផ្លូវការជាងនេះបន្តិចពេលអ្នកទៅធ្វើសម្ភាសន៍រកការងារ។*

- សូមព្យាយាមនិយាយជាមួយមនុស្សវ័យជំទង់ទោះបីជាទទួលចម្លើយបានតែមួយម៉ាត់ក៏ដោយ។
- សូមធ្វើអ្វីៗជាមួយគេ ហើយរក្សាការអញ្ជើញគេឱ្យធ្វើអ្វីៗជាមួយអ្នក ប៉ុន្តែកុំទទូចខ្លាំងពេក ដូច ជាទៅដើរលេង ដើរទិញអីវ៉ាន់ ឬអ្វីផ្សេងទៀត។
- សូមមានលក្ខណៈវិជ្ជមាន និងលើកទឹកចិត្តតាមតែអ្នកអាចធ្វើទៅបាន។ សូមកត់សម្គាល់ទៅលើស្នាដៃទាំងអស់ទោះតូចតាចក៏ដោយ។
- មនុស្សវ័យជំទង់ចូលចិត្តរៀនអ្វីដែលថ្មី។

*ឧទាហរណ៍៖ គេចង់រៀននូវគំនិតថ្មីក្នុងការចម្អិនម្ហូបថ្មីៗ ជាពិសេសម្ហូបដែលគេចូលចិត្តដូចជា របៀបធ្វើភីហ្សា ឬក៏គេអាចចូលចិត្តសកម្មភាពច្នៃធ្វើវត្ថុអ្វីមួយដោយដៃដែលគេអាចប្រើបានដូចជាស៊ុម្របភាពជាដើម។ល។*

- មនុស្សវ័យជំទង់ក៏ចូលចិត្ត លេងកីឡាដែលមានមនុស្សច្រើនចូលរួម ដូចជា ជិះកង់ បាល់ទាត់ ទៅស្ទូចត្រី លេងដើរតួជាដើម។

*ឧទាហរណ៍: គេអាចសម្តែងតួនូវក្នុងកម្មវិធីទូរទស្សន៍ដែលគេចូលចិត្ត*

- មនុស្សវ័យជំទង់អាចចូលចិត្តគេងយូរ និងនៅហូតដល់យប់ជ្រៅទើបចូលគេង។ សូមព្យាយាមអនុញ្ញាតឱ្យគេធ្វើដូចនេះ ជាពិសេសនៅចុងសប្តាហ៍។
- សូមរកពេលដើម្បីសប្បាយជាមួយមនុស្សវ័យជំទង់ក្នុងសកម្មភាពលំហែរកម្សាន្ត និងសកម្មភាពសប្បាយរីករាយជាមួយគេដូចជា លេងសើចជាមួយពួកគេ មើលភាពយន្តជាមួយគ្នា និងពិភាក្សាអំពីខ្លឹមសារភាពយន្តនោះ ស្វែងរកភ្លេង និងចម្រៀងដែលអ្នកចូលចិត្ត ហើយស្តាប់ទាំងអស់គ្នា និងពិភាក្សាអំពីបទចម្រៀងនោះ។
- មនុស្សវ័យជំទង់មិនសូវចាប់អារម្មណ៍ក្នុងការចំណាយពេលជាមួយគ្រួសារទេ ប៉ុន្តែវាជាការសំខាន់ដែលអ្នកចាំជួយគេ នៅពេលដែលគេត្រូវការការគាំទ្រពីអ្នក។
- សូមរកអ្វីដែលគេចូលចិត្តធ្វើ ហើយអ្នកអាចចូលរួមធ្វើជាមួយពួកគេ (ប្រសិនបើគេចង់ឱ្យអ្នកធ្វើជាមួយ)។
- និយាយជាមួយមនុស្សវ័យជំទង់អំពីការព្រួយបារម្ភរបស់អ្នក និងព្យាយាមយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរអាកប្បកិរិយារបស់គេ។
- បង្ហាញការចាប់អារម្មណ៍ចំពោះការរៀនសូត្ររបស់គេ សកម្មភាពនានា និងចំណាប់អារម្មណ៍ផ្សេងៗទៀតក្រៅពីការងារសាលា។ លើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងសកម្មភាពផ្សេងៗដូចជាកីឡា និងសិល្បៈជាដើម។

- លើកទឹកចិត្តមនុស្សវ័យជំទង់ អបអរសាទរ និងគោរពនូវការខំប្រឹងប្រែង និងលទ្ធផលសម្រេចបានរបស់ពួកគេ។
- គោរពនូវមតិយោបល់របស់មនុស្សវ័យជំទង់។ ស្តាប់គេ និងកុំបដិសេធនូវការព្រួយបារម្ភរបស់ពួកគេ។
- លើកទឹកចិត្តកូនឱ្យបង្កើតនូវដំណោះស្រាយចំពោះបញ្ហា និងទំនាស់ និងជួយឱ្យគេរៀនក្នុងការធ្វើការសម្រេចចិត្តឱ្យបានល្អ។ បង្កើតឱកាសឱ្យគេប្រើនូវការវិនិច្ឆ័យរបស់ខ្លួនឯងផ្ទាល់ និងធ្វើខ្លួនឱ្យទំនេរ ដើម្បីគេអាចសុំនូវដំបូន្មាន ឬក៏ការគាំទ្រផ្សេងៗបាន។
- ប្រសិនបើគេលេងល្បែងនៅតាមអ៊ិនធឺណេត ការជជែកនៅតាមអ៊ិនធឺណេត និងការផ្ញើសារ សូមលើកទឹកចិត្តឱ្យគេមានវិន័យ និងគោរពពេលវេលា រួមទាំងកំណត់ពេលវេលាត្រឹមត្រូវដែលគេត្រូវប្រើពាក់ព័ន្ធចំពោះរឿងនោះ។
- ពិភាក្សានិងរៀបផែនការជាមុនចំពោះការលំបាកផ្សេងៗនិងស្ថានភាពមិនងាយស្រួល។ ពិភាក្សាអំពីអ្វីដែលគេអាចធ្វើបាន នៅពេលដែលគេនៅក្នុងក្រុមដែលមានអ្នកប្រើប្រាស់គ្រឿងញៀន ឬទទួលសម្ពាធអ្វីមួយដូចជា ការបង្ខំឱ្យជក់ ហិត លេប ចាក់ ការស្ទាបអង្អែល ការរួមភេទ ឬការហៅឱ្យជិះកង់ ម៉ូតូជាមួយ ។ល។

---

## ខ្លឹមសារបន្ថែម

អ្នកសម្របសម្រួលត្រូវបញ្ចូលខ្លឹមសារស្តីពី **ពិការភាព** និង**ភាពខុសគ្នាក្នុងការចិញ្ចឹមកូនស្រី និងកូនប្រុស** ផងដែរ។ អ្នកសម្របសម្រួលគួរសួរបំផុសខ្លះៗអំពីកុមារដែលមានពិការភាព។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គួរផ្តល់ការថែទាំជាពិសេសដើម្បីការពារកុមារដែលមានពិការភាព ពីការរំលោភបំពានគ្រប់ប្រភេទ។ កុមារទាំងនោះនឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរដូចជា ចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេ នឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យ យ៉ាងហោចណាស់មួយឆ្នាំមុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តការគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពនានានៅក្នុងសង្គមផងដែរ។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) កំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀត អាចមានច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួន៖

- **ថ្លង់ ឬខ្សោយការស្ដាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អ តែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺ ខ្សោយការស្ដាប់ (មិនអាចស្ដាប់បាន ឬស្ដាប់បានមិនល្អ)។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើល មិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្ដាប់នោះអាចជួយឱ្យពួកគាត់មានឱកាសរៀនភាសាបានល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំទទួលបានការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមាររបស់គាត់ដែលមានពិការភាពនេះ ដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាពទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍ ការប្រាស្រ័យទាក់ទង មានភាពកក់ក្ដៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្នមានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការគ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។

- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយសតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់ បានចប់បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹកគេង និងហូបចុក ជាដើម។ មានកុមារមួយចំនួនទៀត មានបញ្ហាខ្សោយសតិបញ្ញាប្រភេទធ្ងន់ធ្ងរ។ ពួកគេមិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការអ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេសថែមទៀតពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវានៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្ដាល។

- **ខ្សោយកាយសម្បទា ឬរាងកាយ៖** កុមារមួយចំនួនទៀត មានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាចដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្ដាល មជ្ឈមណ្ឌលស្ដារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលស្ដារនីតិសម្បទានៅតាមខេត្ត។

- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះអាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយលំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារ ដែលមានបញ្ហាភ្នែកតាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិនឈោងចាប់របស់របរលេង មិនលូន ឬវារ ទារកលេងកំសាន្តតិចតួច នៅតែម្នាក់ឯងច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារក ដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការថែទាំ និងការគាំទ្រ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

**ភាពខុសគ្នារវាងកុមារា និងកុមារី**

| កុមារា | កុមារី |
|---|---|
| • រាងកាយមានភាពរហ័សរហួន និងសកម្ម<br>• មានជំនាញវិភាគ ក្នុងលំហ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយនឹងការធ្វើឱ្យអ្វីៗផ្លាស់ទី<br>• រៀនតាមរយៈ ការមើល<br>• តក់ក្រហល់ក្នុងការធ្វើអ្វីមួយ<br>• បែងចែកការងារច្បាស់ ដោយផ្តោតអារម្មណ៍ម្តងមួយៗ<br>• ត្រូវការពេលវេលាដើម្បីផ្ចង់អារម្មណ៍ក្នុងការធ្វើអ្វីមួយ<br>• រុករក ឬស្វែងយល់ និងចង់ដឹងពី អ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តបង្ហាញសកម្មភាពជាងនិយាយពីអារម្មណ៍របស់គេ | • រាងកាយមានភាពទន់ភ្លន់<br>• មិនសូវមានជំនាញវិភាគ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយពណ៌<br>• រៀនតាមរយៈ ការស្តាប់<br>• គិតច្បាស់លាស់មុននឹងធ្វើអ្វីមួយ<br>• មិនមានការបែងចែកច្បាស់ អាចធ្វើការច្រើនមុខក្នុងពេលតែមួយ<br>• អាចធ្វើបានភ្លាមៗ<br>• ស្តាប់ ដើម្បីដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តនិយាយ ដើម្បីបង្ហាញពីអារម្មណ៍របស់ខ្លួន |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្ដើម អ្នកសម្របសម្រួលសំណេះសំណាល ហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកទាក់ទងនឹងការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្ដេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមធំផ្ដល់ និងពិភាក្សាដើម្បីស្វែងរកការបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | **ល្បែង ចាមពល កំប្រុកប្តូរទ្រុង (១៥នាទី)** | ▪ ចូរនិយាយថា មុននឹងយើងបន្តទៅមេរៀនថ្មី យើងនឹងចាប់ផ្តើមដោយការលេងល្បែងមួយហៅថា ល្បែង **កំប្រុកប្តូរទ្រុង** រួចធ្វើការពន្យល់ថា៖<br>☞ យើងនឹងចាប់ជាក្រុម ដែលមានគ្នាបីៗនាក់។ ក្នុងនោះ ពីរនាក់នឹងឈរទល់មុខគ្នា រួចស្រាក់ដៃគ្នា បង្កើតបានជារង្វង់ដោយលើកដៃឡើងត្រឹមស្មាឱ្យឈ្មោះថា **ទ្រុង** និងរីឯម្នាក់ទៀតត្រូវឈរនៅចំកណ្តាលរង្វង់ដៃឱ្យឈ្មោះថា **កំប្រុក**។<br>☞ នៅពេលដែលអ្នកសម្របសម្រួល ឬអ្នកដែលនៅក្រៅទ្រុងស្រែកថា **កំប្រុកប្តូរទ្រុង** អ្នកដែលឈរ នៅចំកណ្តាល (កំប្រុក) ទាំងអស់ត្រូវរត់ចេញពីទ្រុងរបស់ខ្លួន ទៅចូលក្នុងទ្រុងផ្សេងមួយទៀត រីឯទ្រុងត្រូវឈរស្ងៀម ចំណែកអ្នកសម្របសម្រួលនឹងធ្វើជាកំប្រុកហើយរត់រកទ្រុងនឹងគេដែរ។<br>☞ ឬពេលដែលអ្នកសម្របសម្រួលស្រែកថា **ទ្រុងប្តូរកំប្រុក** ពីរនាក់ដែលស្រាក់ដៃគ្នាធ្វើជាទ្រុងនោះត្រូវរត់ (ដៃមិនឱ្យរបូតចេញពីគ្នាទេ) ទៅរកកំប្រុកផ្សេងទៀត ចំណែកឯកំប្រុកត្រូវឈរនៅស្ងៀមកន្លែងដដែល។ រីឯអ្នកសម្របសម្រួលក៏ឈរស្ងៀមដែរដើម្បីឱ្យទ្រុងរត់មករក ដូចកំប្រុកផ្សេងៗទៀតដែរ។<br>☞ ឬពេលដែលអ្នកសម្របសម្រួលស្រែកថា **ខ្យល់ព្យុះ** អ្នកទាំងអស់គ្នាត្រូវរត់ទៅកសាងទ្រុងថ្មី កំប្រុកថ្មី (ចាប់ក្រុម៣នាក់ផ្សេង) សាឡើងវិញម្តងទៀត ហើយរីឯអ្នកសម្របសម្រួលក៏ត្រូវរត់ទៅចាប់ក្រុមជាមួយគេដែរ។<br>☞ ប្រសិនបើមានសមាជិកណាម្នាក់ មិនគោរពតាមរបៀបនៃការលេងដូចជា កំប្រុករកទ្រុងមិនបាន ទ្រុងរកកំប្រុកមិនបាន ឬមិនអាចកសាងទ្រុងថ្មីកំប្រុកថ្មីបានទេគឺជាអ្នកចាញ់ ហើយត្រូវឈរ ដើម្បីសម្របសម្រួលម្តង។<br>▪ បន្តលេងរហូតដល់អ្នកចូលរួមបានសប្បាយរីករាយ ទើបបន្តទៅសកម្មភាពបន្ទាប់។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៥ | <u>មេរៀនថ្មី៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៣)</u> | **ការលូតលាស់ និងអភិវឌ្ឍ របស់កុមារ (២៥នាទី)** | ■ សូមប្រាប់អ្នកចូលរួមថា កាលពីជំនួបកន្លងទៅនេះយើងបានពិនិត្យមើលពីរបៀបនានាដែលជួយយើង ក្នុងការប្រៀនប្រដៅកូនបែបវិជ្ជមានប្រកបដោយគុណភាព ហើយយើងក៏បានរៀបរាប់ពីបទពិសោធន៍នៃការចិញ្ចឹមកូន ការលូតលាស់ និងអភិវឌ្ឍកុមារ និងរួមទាំងពិភាក្សាអំពីធាតុផ្សំទី៣ **យល់អំពីការគិត និងអារម្មណ៍**របស់កូនក្នុងកម្រិតអាយុចាប់ពី មានផ្ទៃពោះ ដល់១២ឆ្នាំ។ ដូច្នេះនៅក្នុងវគ្គនេះយើងនឹងមើលលើធាតុផ្សំទី៣ដដែល ប៉ុន្តែយើងធ្វើការស្វែងយល់ទៅលើកូនជំទង់របស់យើងវិញម្តងគឺចាប់ពីអាយុ **១៣ឆ្នាំ ដល់១៨ឆ្នាំ។**<br>■ អ្នកសម្របសម្រួលបន្ត ដោយសុំឱ្យអ្នកចូលរួមធ្វើការស្រមៃអំពីកូន ឬប្អូន ឬខ្លួនគាត់នៅពេលដែលពួកគាត់មានអាយុចន្លោះពី ១៣ ដល់ ១៨ឆ្នាំ ដោយសួរម្តងមួយៗ ដូចខាងក្រោម៖<br>☞ តើរាងកាយរបស់កុមារនៅក្នុងចន្លោះអាយុនេះមានការលូតលាស់ និងអភិវឌ្ឍអ្វីខ្លះ?<br>• ចម្លើយរំពឹងទុក៖ ក្មេងប្រុសមានសាច់ដុំ លូតកម្ពស់ខ្លាំង បំពង់សំឡេងរបស់ក្មេងប្រុសរីកធំ ហើយបែកសំឡេង លូតលាស់រោមក្លៀក និងរោមត្រង់ប្រដាប់ភេទ ក្មេងប្រុសបញ្ចេញទឹកកាមលើកដំបូង និងអាចមានបញ្ហាសើរស្បែកដូចជាកើតមុន ឬស្រែង សុដន់ក្មេងស្រីលូតលាស់ខ្លាំង ភេទទាំងពីរធំធាត់យ៉ាងឆាប់រហ័ស ជាពិសេសក្មេងប្រុស ។ល។<br>☞ តើចរិក និងអាកប្បកិរិយា មានសភាពដូចម្តេចខ្លះ?<br>• ចម្លើយរំពឹងទុក៖ ទង្វើភាគច្រើនតែងនាំទៅរកជម្លោះ ប្រថុយនឹងគ្រោះថ្នាក់ ក្តីស្រលាញ់ចំពោះក្រុមគ្រួសារថយចុះ និងច្រើនប្រើពាក្យមិនគប្បីញឹកញាប់ចំពោះគ្រួសារ អួតអាង ចង់ឈ្នះចាញ់ បង្ហាញការព្រួយបារម្ភចំពោះអ្នកដទៃ ចង់មានអត្តសញ្ញាណផ្ទាល់ខ្លួន អាចនឹងចូលរួមក្នុងទង្វើដែលប្រកបដោយការប្រថុយប្រថាន មិនសូវស្តាប់បង្គាប់ ការនិយាយស្តីមានលក្ខណៈដូចទៅនឹងមិត្តភក្តិ និងមនុស្សដែលពួកគេកោតគោរពជាងក្រុមគ្រួសារ រាប់ទាំងការប្រើពាក្យមិនពិរោះស្តាប់ ចេះសម្រុះសម្រួល និងធ្វើការសម្រេចចិត្តដោយឯករាជ្យ និងចង់បានភាពឯកជន។ល។<br>☞ តើពួកគេមានការគិត និងអារម្មណ៍បែបណា?<br>• ចម្លើយរំពឹងទុក៖ មានអារម្មណ៍ញ៉ាំញ៉ូវ ឆាប់អន់ចិត្តជាមួយឪពុកម្តាយ បារម្ភច្រើនអំពីសម្រស់ រាងកាយ រូបរាង និងសំលៀកបំពាក់ ចាប់អារម្មណ៍តែចំពោះខ្លួនឯង និងសកម្មភាពរបស់ខ្លួន "មនោសញ្ចេតនាអណ្តែតអណ្តូង" គិតអំពីគោលបំណងក្នុងជីវិត និងអនាគតច្រើនជាងមុន មានក្តីបារម្ភអំពីទំនាក់ទំនងស្នេហាពិត។ល។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលលើករូបភាព និងពន្យល់រូបភាពនិមួយៗ តាមខ្លឹមសារមេរៀន (រូបភាពទី១ ដល់រូបភាពទី៦) និងពន្យល់អំពីរបៀបគាំទ្ររបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងដំណាក់កាលនិមួយៗ។<br>▪ បន្ទាប់មក អ្នកសម្របសម្រួលជួយឱ្យពួកគាត់ទទួលស្គាល់ថា កូន ឬកុមារមានភាពខុសប្លែកគ្នាពីវ័យមួយទៅវ័យមួយទៀត អាស្រ័យទៅតាមដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ ក្នុងនោះរួមមាន ផ្នែករាងកាយ ចរិតលក្ខណៈ បញ្ញាស្មារតី សង្គម និងអារម្មណ៍។ ពិសេសគឺជួយឱ្យពួកគាត់យល់កាន់តែច្បាស់ថា កត្តាខាងលើនេះហើយដែលធ្វើឱ្យចរិក អាកប្បកិរិយា ការគិត អារម្មណ៍ និងរូបរាងកាយរបស់កូន ឬកុមារមានភាពប្រែប្រួល រីឯកត្តាបរិស្ថានជុំវិញក៏រួមចំណែកផងដែរ។ សូមមើលដំណាក់កាលលូតលាស់ និងអភិវឌ្ឍកុមារ (ក្រុមអាយុ ១៣ឆ្នាំ ដល់១៨ឆ្នាំ)។ |
| | | **ធាតុផ្សំទី៣៖ យល់អំពីការគិត និងអារម្មណ៍ (អាយុពី ១៣ឆ្នាំ ដល់ ១៨ឆ្នាំ)**<br>**(៣៥នាទី)** | ▪ ឥឡូវនេះលោកអ្នកបានយល់ដឹងខ្លះៗហើយអំពីការលូតលាស់ និងអភិវឌ្ឍកុមារក្នុងវ័យជំទង់ (អាយុពី ១៣ឆ្នាំ ដល់១៨ឆ្នាំ)។ បន្ទាប់ទៅទៀតនេះ យើងនឹងពិភាក្សាលម្អិតអំពីធាតុផ្សំទី៣ ស្ដីពី **យល់អំពីការគិត និងអារម្មណ៍** របស់កុមារដែលមានអាយុពី **១៣ឆ្នាំ ដល់១៨ឆ្នាំ** បន្តទៀតដោយសួរពួកថា<br>☞ តើការយល់អំពីការគិត និងអារម្មណ៍របស់កូនគឺជាអ្វី?<br>🗣 ចម្លើយរំពឹងទុក៖ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម និងបន្ថែមខ្លឹមសារបើខ្វះខាត។ **យល់អំពីការគិត និងអារម្មណ៍** របស់កូន *គឺជាការយល់ដឹងពីសេចក្ដីត្រូវការរបស់កូន ឬកុមារដែលផ្ដោតលើដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ រួមទាំងការគោរពឱ្យតម្លៃពួកគេជាមនុស្សម្នាក់ដែលមានភាពសំខាន់ និងដោយឡែកៗពីគ្នា។*<br>▪ សកម្មភាពបន្ទាប់ ចែកអ្នកចូលរួមជាដៃគូដោយសុំឱ្យពួកគាត់គិតរួមគ្នា ដើម្បីឆ្លើយនឹងសំណួរខាងក្រោម (រយៈពេលនៃការឆ្លើយសំណួរគឺ ១ ទៅ ២នាទី)៖<br>☞ តាមបទពិសោធន៍ ឬអ្វីដែលអ្នកធ្លាប់ដឹង តើក្មេងជំទង់ច្រើនមានអាកប្បកិរិយាលំបាកៗអ្វីខ្លះ? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ◆ ចម្លើយរំពឹងទុក៖ ដើរលេងច្រើន បង្ហោះម៉ូតូ មិនសូវស្តាប់បង្គាប់ លាបសក់ពណ៌ ចង់បានសម្ភារៈទំនើបៗ ខឹងឪពុកម្តាយនៅពេលដែលមិនបានបំពេញបំណងរបស់ខ្លួន រឹងរូស មានះ ស្លៀកសំលៀកបំពាក់មិនសមរម្យ តុបតែងខ្លួនប្លែកៗ និយាយទូរស័ព្ទច្រើន មានសង្សារ ប្រើពាក្យសំដីមិនពីរោះ មិនចង់ជួយធ្វើការងារផ្ទះ ជក់បារី ផឹកស្រា។ល។<br>▪ អ្នកសម្របសម្រួលប្រមូលគំនិតពីអ្នកចូលរួម រួចលើកឡើងគំនិតមួយចំនួនដើម្បីបង្ហាញអំពីការយល់អំពីការគិត និងអារម្មណ៍របស់ពួកគាត់ ហើយសួរបន្ត<br>☞ តើមានហេតុផលអ្វីខ្លះ ដែលនាំឱ្យក្មេងជំទង់មានអាកប្បកិរិយាបែបនេះ ?<br>◆ ចម្លើយរំពឹងទុក៖ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលប្រមូលគំនិតអ្នកចូលរួម និងជួយឱ្យពួកគាត់ឆ្លុះបញ្ចាំងចម្លើយរបស់ពួកគាត់ទៅនឹង *ដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍកុមារក្នុងកម្រិតអាយុ ១៣ឆ្នាំ ទៅ ១៨ឆ្នាំ* និងរួមទាំងបរិស្ថានជុំវិញផងដែរ។<br>▪ បន្ទាប់មកសួរសំណួរបន្តទៀត<br>☞ ក្នុងនាមលោកអ្នកជាឪពុកម្តាយ អាណាព្យាបាល និងអ្នកថែទាំ តើលោកអ្នកត្រូវជួយគាំទ្រ និងផ្តល់អ្វីខ្លះដល់ពួកគេនៅក្នុងដំណាក់កាលនេះ សម្រាប់៖<br>ក. កូនប្រុស ?<br>ខ. កូនស្រី ?<br>គ. កូនដែលមានពិការភាព ?<br>◆ ចម្លើយរំពឹងទុក៖ ចម្លើយបែបណាក៏បានទៅតាមការយល់ឃើញរបស់ពួកគាត់។<br>▪ អ្នកសម្របសម្រួលទទួលយកគំនិតអ្នកចូលរួម និងជួយឱ្យពួកគេយល់ពីវិធីនានា ដើម្បីជួយគាំទ្រដល់កូន ឬកុមារក្នុងកម្រិតអាយុនេះ ដូចមាននៅក្នុងខ្លឹមសារមេរៀន។<br>**គួរចងចាំ**<br>**ជាធម្មតាកូន ឬកុមារក្នុងវ័យជំទង់ ព្យាយាមបំពេញតម្រូវការរបស់ខ្លួនទៅតាមអាយុ ឬដំណាក់កាល នៃការលូតលាស់ ការអភិវឌ្ឍ និងបរិស្ថានដែលនៅជុំវិញពួកគេ។** |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | **មានតែការផ្តល់ភាពកក់ក្តៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់អំពីការគិត និងអារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូន ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីដែលពួកគេគួរធ្វើ និងមិនគួរធ្វើ។** |
| | | សង្ខេបមេរៀន<br>(១៥នាទី) | ថ្ងៃនេះយើងបានពិភាក្សាគ្នាលម្អិតអំពីជាតុជុំទី៣គឺ **យល់ដឹងអំពីការគិត និងអារម្មណ៍** របស់កូន វ័យជំទង់ក្រោមការថែទាំរបស់យើង និងរួមទាំងបានធ្វើការឆ្លុះបញ្ចាំងអំពីខ្លួនឯងកាលនៅជាកុមារ និងវ័យជំទង់ និងនៅពេលដែលខ្លួនយើងក្លាយជាឪពុកម្តាយ តាមរយៈបទពិសោធន៍របស់យើងផ្ទាល់ៗខ្លួន ទាំងអស់នេះហើយដែលជួយឱ្យយើងអាចយល់អំពីចរិត និងអាកប្បកិរិយាប្រែប្រួលរបស់ក្មេងជំទង់បានកាន់តែច្បាស់រួមទាំងអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនបានដើម្បីបញ្ចៀសនូវភាពហិង្សានានាជាមួយកូន (ផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើ) ពិសេសគឺការបំបែកកូនចេញពីគ្រួសារ និងរួមទាំងយល់ច្បាស់អំពីអ្វីដែលយើងគួរធ្វើ និងអ្វីដែលមិនគួរធ្វើដូចជា ការរំពឹងទុក (គោលដៅយូរអង្វែង) ការបំពេញតម្រូវការ (ផ្តល់ភាពកក់ក្តៅ និងដែនកំណត់) ដែលមានភាពខុសប្លែកគ្នារវាងកូនតូច និងកូនធំចាប់ពីពេលនេះតទៅ។ ម្យ៉ាងវិញទៀត គឺជួយឱ្យយើងយល់បានកាន់តែច្បាស់ពីដំណាក់កាលនានានៃការលូតលាស់ និងអភិវឌ្ឍរបស់កូនវ័យជំទង់ ក៏ដូចជាកត្តាបរិស្ថានជុំវិញ ឬមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យកូនយើងមានអាកប្បកិរិយាលំបាកៗទាំងអស់នោះទៀតផង។ ដូច្នេះការយល់អំពីការគិត និងអារម្មណ៍របស់កូន គឺជាការយល់ដឹងពីសេចក្តីត្រូវការរបស់កូន ឬកុមារដែលផ្តោតលើដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ កត្តាបរិស្ថានជុំវិញ រួមទាំងការគោរពឱ្យតម្លៃពួកគេជាមនុស្សម្នាក់ដែលមានភាពសំខាន់ដោយឡែកៗពីគ្នា។<br>▪ បើយើងគិត និងឆ្លើយដោយស្មោះត្រង់អំពីខ្លួនឯងថា នៅមុនពេលរៀន និងក្រោយពេលរៀន តើមាន □ប្រតិកម្ម□ ខុសគ្នាដូចម្តេចខ្លះ ?<br>▪ ដូច្នេះអ្នកទាំងអស់គ្នាត្រូវតែចងចាំថា<br>**មានតែការផ្តល់ភាពកក់ក្តៅ ដែនកំណត់ ការប្រាស្រ័យទាក់ទងល្អ រួមទាំងយល់អំពីការគិត និង អារម្មណ៍របស់កូនទេ ដែលអាចជួយឱ្យកូន ឬកុមារមានអាកប្បកិរិយាល្អ ឬយល់ពីអ្វីដែលពួកគេគួរធ្វើ និងមិនគួរធ្វើ។**<br>▪ សូមសួរអ្នកចូលរួមថា មានសំណួរទៀតដែរឬទេ ? |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៦ | <u>ការឆ្លុះបញ្ចាំង</u> | **ការឆ្លុះបញ្ចាំងមេរៀន** (១០នាទី) | ▪ អ្នកសម្របសម្រួលសួរ៖<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះ មានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្តេចដែរទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្តេច នៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ** (១០នាទី) | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្តើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយា ដោយយល់ពីការគិត និងអារម្មណ៍របស់កូនទៅតាមដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារ<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |

# រូបភាពទី ១



# ការប្រែប្រួលប្រព័ន្ធបន្តពូជ

## រូបភាពទី ២



# អារម្មណ៍មិនពេញចិត្តនឹងខ្លួនឯង

## រូបភាពទី ៣



# បង្ហាញពីអត្តសញ្ញាណរបស់ខ្លួន

# រូបភាពទី ៤



# រាងកាយលូតលាស់ជាមនុស្សពេញវ័យ

## រូបភាពទី ៥



# ធ្វើអ្វីមួយមិនបានគិតអំពីលទ្ធផល

## រូបភាពទី ៦



# ការរៀនបំណិនជីវិត

# វគ្គទី១០
# មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៤)

## សេចក្ដីផ្ដើម

យោងទៅតាមលទ្ធផលស្រាវជ្រាវឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការ UNICEF ស្ដីពីអំពើហិង្សាលើកុមារបានបញ្ជាក់ថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតមានដូចជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ ដូចនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគួរសិក្សាស្វែងយល់ពីអំពើហិង្សា ការមិនអើពើ និងផលប៉ះពាល់លើកុមារ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការ បញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ ដែលកន្លងមកពួកគាត់តែងតែគិតថាការអប់រំប្រដៅកូនមានរបៀបពីរគឺ **ត្រជាក់** (អហិង្សា) **និងក្ដៅ** (ហិង្សា) ពិសេសគឺយោងទៅលើនិស្ស័យរបស់កូន ឬកុមារ។ ការអប់រំប្រដៅកូនដោយបែបក្ដៅដូចជាការស្ដីបន្ទោស ជេរ គំរាម សំឡុត ដាក់ទណ្ឌកម្ម វាយដំ គឺគ្រាន់តែចង់ឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អតែប៉ុណ្ណោះ។ ដូច្នេះពួកគាត់គិតថាការធ្វើបែបនេះវាមិនមែនជាការរំលោភបំពាននោះទេ ដោយសារមានការគិត ឬទម្លាប់បែបនេះហើយទើបនាំឱ្យមានការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាបន្តកើតមានលើកូន ឬកុមារ នៅក្នុងគ្រួសារមួយចំនួនធំ។

ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគិត ឬទម្លាប់ខាងលើ យើងក៏បានរៀបចំចងក្រងប្រធានបទនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន ដែលជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដែលផ្ដោតទៅលើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន៤ ក្នុងគោលបំណង ជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ កំណត់បានពីរបៀបនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន និងការដោះស្រាយបញ្ហាជាមួយកូន ឬកុមារតាមដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍកុមារ ព្រមទាំងជ្រើសរើស និងអនុវត្តនូវវិធីសាស្ត្រ ឬរបៀបចិញ្ចឹមកូនបែបវិជ្ជមាន ដោយប្រើគោលការណ៍សំខាន់ចំនួន៥ និងធាតុផ្សំចំនួន ៤។

# ១. គោលការណ៍ទាំង៥

គោលការណ៍

ទី១

## ភាពអហិង្សា

គឺជាការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកូន ឬកុមារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

គោលការណ៍

ទី២

## ផ្ដោតទៅលើការរកដំណោះស្រាយ

គឺជាការស្ដាប់ និងការបង្ហាញហេតុផល រួមទាំងការពិភាក្សា និងការស្វែងរកវិធី ឬរបៀបណាមួយដើម្បីដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ឬបែបវិជ្ជមានដែលមានការចូលរួមយល់ព្រម និងការចរចាគ្នា។

គោលការណ៍

ទី៣

## ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នា ក្នុងភាពជាមនុស្ស ដោយគ្មានការរើសអើង និងវិនិច្ឆ័យ។

គោលការណ៍

ទី៤

## ផ្ដោតលើដំណាក់កាលលូតលាស់ និងអភិវឌ្ឍរបស់កុមារ

គ្រប់កុមារទាំងអស់ □កុមារា កុមារី ឬកុមារដែលមានពិការភាព□ មានការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ទៅតាមកម្រិតអាយុរបស់ពួកគេ ដូចជាការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈ ការគិត និងអារម្មណ៍ ដូច្នេះការបំពេញទៅនឹងតម្រូវការរបស់ពួកគេ គឺមានភាពខុសៗគ្នា។

គោលការណ៍

ទី៥

## ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

សិទ្ធិកុមារ គឺជាអ្វីៗដែលកុមារមាន និងអ្វីដែលមនុស្សទទួលខុសត្រូវចំពោះកុមារ។ ពួកគេត្រូវធានាថា កុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំ និងនិយាយនូវអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ។ កុមារទាំងអស់ រួមទាំងកុមារដែលមានពិការភាពទទួលបាននូវសិទ្ធិទាំងនេះ មិនថាពួកគេជានរណា មានពណ៌សម្បុរអ្វី ភាសាអ្វី សាសនាណា ក្មេងប្រុស ឬក្មេងស្រី អ្នកក្រ ឬអ្នកមានឡើយ។ ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក បានចុះហត្ថលេខាលើឯកសារនេះ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មានន័យថា ពួកគេបានសន្យានឹងធ្វើអ្វីៗទាំងអស់ដើម្បីធានាថា កុមារទាំងអស់ទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។

# ២. ធាតុផ្សំទាំង៤

**ធាតុផ្សំទី១៖**
គោលដៅយូរអង្វែង

**ធាតុផ្សំទី២៖**
ភាពកក់ក្តៅ
និងដែនកំណត់

**ធាតុផ្សំទី៣៖**
យល់អំពីការគិត
និងអារម្មណ៍

**ធាតុផ្សំទី៤៖**
ដោះស្រាយបញ្ហា

កាលពីវគ្គមុន លោកអ្នកបានធ្វើការពិភាក្សាគ្នារួចមកហើយអំពីគោលការណ៍សំខាន់ចំនួន ៥ និងធាតុផ្សំចំនួន ៣ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន។ នៅក្នុងវគ្គនេះ យើងនឹងលើកយកធាតុផ្សំទី៤ **ដោះស្រាយបញ្ហា** សម្រាប់កូន ឬកុមារដែលមានអាយុពី ០ឆ្នាំ ដល់១២ឆ្នាំ មកធ្វើការពិភាក្សាគ្នា និងហាត់អនុវត្ត។ ដោយឡែកសម្រាប់កុមារដែលមានអាយុពី ១៣ឆ្នាំ ដល់១៨ឆ្នាំនឹងត្រូវសិក្សានៅវគ្គបន្ទាប់។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• ទទួលស្គាល់ពីមូលហេតុនានានៃអាកប្បកិរិយាដែលពិបាកៗ តាមរយៈការអនុវត្តចំណេះដឹងនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។<br>• ទទួលស្គាល់ថាកូន ឬកុមារមានអាកប្បកិរិយាពិបាកនានា នៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ហើយថែមទាំងរកឱ្យឃើញនូវមូលហេតុនៃអាកប្បកិរិយានោះ ដើម្បីជួយគាំទ្រដល់កូន ឬកុមាររួមទាំងជួយឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងអារម្មណ៍ដែលប្រតិកម្មក្នុងខ្លួនផងដែរ។<br>• ហាត់អនុវត្តដោះស្រាយបញ្ហាជាមួយកូន ឬកុមារដែលមានអាយុពី ០ឆ្នាំ ដល់១២ឆ្នាំ ដោយប្រើគោលការណ៍សំខាន់ៗ និងធាតុផ្សំទាំង៤ នៃការចិញ្ចឹមកូនបែបវិជ្ជមាន។ |
| **រយៈពេល** | **១៥០ នាទី** |
| **សម្ភារៈដែលត្រូវការ** | • ករណីសិក្សា (ក) បង្ហាញពី កុមារនៅចន្លោះអាយុក្រោម ៣ឆ្នាំ<br>• ករណីសិក្សា (ខ) បង្ហាញពី កុមារនៅចន្លោះអាយុ ៣ ដល់ ៥ឆ្នាំ<br>• ករណីសិក្សា (គ) បង្ហាញពី កុមារនៅចន្លោះអាយុ ៦ ដល់ ៩ឆ្នាំ<br>• ករណីសិក្សា (ឃ) បង្ហាញពី កុមារនៅចន្លោះអាយុ ១០ ដល់ ១២ឆ្នាំ<br>• រូបភាពទី១ បង្ហាញពី ធាតុផ្សំទី៤៖ ដោះស្រាយបញ្ហា<br>• ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កៃស្ត្រ<br>• កម្រាល ស្រមាប់អ្នកចូលរួមអង្គុយ |

- ត្រៀម សម្ភារៈសម្រាប់លេងជាមួយកុមារ
- ក្រដាសផ្ទាំងធំដែលកត់ត្រា អំពីគោលការណ៍ក្រុមដែលបានចងក្រងកាលពីជំនួបដំបូង

**ខ្លឹមសារលម្អិត**

## I. ធាតុផ្សំទី៤៖ ដោះស្រាយបញ្ហា

ដោះស្រាយបញ្ហា គឺជាការបង្រៀនកូន ឬជួយកូនឱ្យចេះធ្វើការដោះស្រាយបញ្ហា ដោយសន្តិវិធី ឬមិនប្រើអំពើហិង្សា តាមរយៈការប្រាស្រ័យទាក់ទងល្អជាមួយអ្នកដទៃ ការរៀនពីភាពបរាជ័យ និងជោគជ័យ កំហុស ដោយការយោគយល់អធ្យាស្រ័យ និងចេះបត់បែន។

នៅក្នុងគ្រួសារនីមួយៗ តែងតែកើតមានបញ្ហាដូចជា៖ ការខ្វែងគំនិតគ្នា ជម្លោះ ឬការមិនសប្បាយចិត្ត។ល។ រវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ ដែលមានករណីស្រដៀងៗ គ្នាពីគ្រួសារមួយទៅគ្រួសារមួយ។ សូមចងចាំថា៖

- កូនអ្នកនឹងមានតម្រូវការ ឬភាពសំខាន់ៗ និងភាពប៉ិនប្រសព្វផ្សេងៗគ្នាទៅតាមកម្រិត នៃអាយុរបស់ពួកគេ។
- កូន ឬកុមារដែលមានអាកប្បកិរិយាមិនសមរម្យដូចជា យំ កាច កុហក ឬមិនស្ដាប់បង្គាប់ មិនមែនដោយសារតែគេ □មិនល្អ□ នោះទេ គេមានអាកប្បកិរិយាបែបនោះ គឺដើម្បីព្យាយាមបំពេញតម្រូវការដែលគេចង់បាន និងសុវត្ថិភាពសម្រាប់ខ្លួនគេតែប៉ុណ្ណោះ។
- ភារកិច្ចរបស់យើង គឺត្រូវជួយកូន ឬកុមារឱ្យបំពេញតម្រូវការតាមបែបវិជ្ជមាន ដោយត្រូវជួយពួកគេឱ្យមើលឃើញ និងកែតម្រូវនូវអាកប្បកិរិយាមិនសមរម្យទាំងនោះ។
- ការស្រែកគំហក ស្ដីបន្ទោស គំរាមកំហែង ឬវាយដំកូនមិនបានជួយដោះស្រាយបញ្ហាទេ វាគ្រាន់តែបង្រៀនកូនឱ្យចេះស្រែកគំហក ចាប់កំហុស និងចេះប្រើអំពើហិង្សា នៅពេលដែលមាននរណាម្នាក់ធ្វើអ្វីមួយដែលគេមិនពេញចិត្តតែប៉ុណ្ណោះ។
- កុមារគ្រប់រូប (រួមទាំងកុមារដែលមានពិការភាព) ត្រូវការឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំរបស់ពួកគេយកចិត្តទុកដាក់ គោរព ឱ្យតម្លៃ ស្ដាប់ហេតុផល យល់ពីការគិត និងអារម្មណ៍ ដឹងពីតម្រូវការ ទទួលស្គាល់ពីភាពសំខាន់ៗ ភាពប៉ិនប្រសព្វ និងប្រព្រឹត្តស្មើភាពគ្នារវាងកូនស្រី និងកូនប្រុស ស្របទៅតាមកម្រិតអាយុ និងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់ពួកគេ។
- មានគ្រួសារខ្លះជួបបញ្ហាជាមួយនឹងរបៀបនៃការដោះស្រាយបញ្ហា ពិសេសជាមួយអាកប្បកិរិយាលំបាកៗរបស់កូន ឬកុមារដែលអាចបង្កឱ្យមានជម្លោះ ឬអំពើហិង្សានៅក្នុងគ្រួសារ ពេលខ្លះឈានដល់ការទុកកូន ឬកុមារចោលលែងយកចិត្តទុកដាក់ (ការមិនអើពើ) បោះបង់ចោល (ក្លាយជាកុមារអនាថា) ឬការបំបែកកូនចេញពីគ្រួសារ (យកកូនទៅដាក់មណ្ឌល ឬឱ្យគ្រួសារផ្សេងចិញ្ចឹម) ។ល។

- ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវធ្វើជាមនុស្សគំរូល្អសម្រាប់កូន ឬកុមារ ពិសេសគឺការផ្តល់ភាពកក់ក្តៅ និងដែនកំណត់ រួមទាំងយល់ដឹងពីការគិត និងអារម្មណ៍ដល់កូន ឬកុមារទៅតាមកម្រិតអាយុ និងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់ពួកគេ។

បញ្ហាទូទៅដែលតែងតែកើតមានក្នុងគ្រួសាររវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារមានដូចជា៖

- ចង់ឱ្យកូនស្តាប់បង្គាប់ (ដោយការប្រើអំណាច)
- មិនយល់ (មិនខ្វល់) ពីអារម្មណ៍ និងការគិតរបស់កូន
- ប្រើពាក្យសំដីមិនសមរម្យដូចជា ពាក្យអសុរស សំឡុត គំរាមកំហែង ស្តីបន្ទោស ជេរ ។ល។
- ដោះស្រាយបញ្ហាដោយហិង្សាជាមួយកូន ឬកុមារ
- ដោះស្រាយបញ្ហាជាមួយកូន ដោយមិនពន្យល់ហេតុផលនានា
- គិតថាខ្លួនជាមនុស្សពេញវ័យ និងអាងមានបទពិសោធន៍ច្រើនជាងកូន ឬកុមារ
- មិនប្រាប់អំពីអ្វីដែលគាត់ចង់បានទៅកូនឱ្យបានច្បាស់លាស់ ។ល។

នៅក្នុងសង្គមខ្មែរឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចដោះស្រាយបញ្ហាជាមួយកូនដោយមានរបៀបជាច្រើន។

### អវិជ្ជមាន

- ប្រើអំណាចជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដើម្បីដោះស្រាយបញ្ហា។
- ធ្វើតាមទម្លាប់ ឬអ្វីដែលខ្លួនធ្លាប់ឆ្លងកាត់ និងបទពិសោធន៍។
- មិនស្តាប់ហេតុផល ដាក់កំហុស ស្តីបន្ទោស និងដាក់ទណ្ឌកម្មចំពោះកូន ឬកុមារ។
- បំពេញតែតម្រូវការរបស់ខ្លួន ដោយមិនគិតអំពីផលប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍកុមារ។
- មិនឱ្យកូន ឬកុមារធ្វើអ្វីមួយដែលខ្លួនមិនពេញចិត្ត តែមិនពន្យល់ហេតុផល។

### វិជ្ជមាន

- ប្រើការស្តាប់ អំពីហេតុផលនានារបស់កូន ឬកុមារ រួមទាំងពន្យល់ ឬផ្តល់ជាយោបល់ទូន្មាន។
- គោរព ឱ្យតម្លៃ ជឿជាក់ និងទទួលស្គាល់មតិយោបល់ ទស្សនៈ និងអារម្មណ៍របស់កូន ឬកុមារ។
- យល់ពីដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។
- ស្វែងយល់ពីហេតុផលសម្រាប់អាកប្បកិរិយា ឬពាក្យសម្តីរបស់កូន ឬកុមារ ដែលយើងគិតថា មិនត្រឹមត្រូវ ឬ មិនល្អ ។ល។

- ប្រាប់ ឬពន្យល់ហេតុផលទៅកូន ឬកុមារអំពីអ្វីដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមិនចូលចិត្ត និងអ្វីដែលអាចទទួលយកបាន ឬអ្វីដែលអាចធ្វើជំនួស។

## II. ស្វែងយល់ពីបញ្ហា និងស្ថានភាពលំបាកៗរបស់កុមារ

### ០១. ករណីសិក្សា (ក)៖ កុមារនៅចន្លោះអាយុក្រោម ៣ឆ្នាំ

នៅក្នុងដំណាក់កាលនេះកូនអ្នកកំពុងរៀនដើរ ហើយពួកគេចូលចិត្តរើកកាយ និងរុករកការលំបាកៗ។ អ្វីដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវធ្វើ គឺការរក្សាសុវត្ថិភាពពួកគេ។ សូមអ្នកធ្វើការស្រមៃថា៖

**ក.** កូនអ្នកចេះដើរតេះតះ និងកំពុងតែរពឹសខ្លាំងណាស់។ កូនអ្នកកំពុងដើរយ៉ាងលឿនលេងនៅក្នុងផ្ទះ ហើយកំពុងតែកាន់របស់ដែលនាំឱ្យគ្រោះថ្នាក់ដូចជា កាំបិតស្រួច កន្ត្រៃ កែវទឹក។ល។ អ្នកមានការព្រួយបារម្ភខ្លាចកូនមានរបួសដោយការមុតប្រសិនគេនៅបន្តលេងតទៅទៀត។

*តើមានមូលហេតុអ្វីខ្លះដែលធ្វើឱ្យកូនអ្នកធ្វើរឿងនេះ?*

### ០២. ករណីសិក្សា (ខ)៖ កុមារនៅចន្លោះអាយុ ៣ ទៅ ៥ឆ្នាំ

នៅក្នុងដំណាក់កាលនេះ កូនអ្នកមានការចង់ដឹងច្រើន ហើយពួកគេចង់ដឹងថាវត្ថុទាំងឡាយមានដំណើរការទៅតាមរបៀបយ៉ាងដូចម្តេច និងមកពីមូលហេតុអ្វី? ដូច្នេះពួកគេចូលចិត្តសាកល្បងជាមួយវត្ថុទាំងនោះ។ សូមអ្នកធ្វើការស្រមៃថា៖

**ខ.** អ្នកកំពុងស្ថិតនៅខាងក្រៅនៃទីធ្លាមុខផ្ទះ។ កូនអ្នកកំពុងលេងបាល់នៅទីនោះយ៉ាងសប្បាយ។ រំពេចនោះបាល់ក៏បានរមៀលទៅលើផ្លូវថ្នល់ ស្របពេលដែលមានរថយន្តមួយគ្រឿងកំពុងបើកសំដៅមក កូនអ្នកក៏រត់ចូលទៅក្នុងផ្លូវថ្នល់ដើម្បីរើសបាល់។ អ្នកភ័យស្លន់ស្លោ ព្រោះខ្លាចរថយន្តនោះបុកកូន។ ពេលនោះអ្នកក៏បានរត់យ៉ាងលឿនដើម្បីទៅចាប់គេ។ អ្នកដឹងថាកូនអ្នកត្រូវរៀនសូត្រពីព្រឹត្តិការណ៍នោះ ហើយនឹងមិនធ្វើរឿងនេះម្តងទៀតទេ។

*តើមានមូលហេតុអ្វីខ្លះដែលធ្វើឱ្យកូនអ្នកធ្វើរឿងនេះ?*

### ០៣. ករណីសិក្សា (គ)៖ កុមារនៅចន្លោះអាយុ ៦ ទៅ ៩ឆ្នាំ

នៅក្នុងដំណាក់កាលនេះ កូនអ្នកចូលចិត្តលេងរបស់ប្លែក ឬថ្មីៗ និងចង់បានជារបស់ខ្លួន (ភាពជាកម្មសិទ្ធិ) ពិសេសគឺពេញចិត្តនឹងជ័យជំនះ ស្អប់នូវភាពបរាជ័យពោលគឺចង់ឈ្នះចង់ចាញ់។ សូមអ្នកធ្វើការស្រមៃថា៖

**គ.** កូនទាំងពីររបស់អ្នកកំពុងលេងជាមួយតុក្កតារូបសត្វ ក្នុងចំណោមតុក្កតាសត្វ

ទាំងនោះមានតុក្កតារូបសេះតែមួយទេ កូនទាំងពីរនាក់នោះចង់បានរូបសេះដូចគ្នា។ ពេលនោះកូនម្នាក់បានដណ្ដើមយករូបសេះនោះពីកូនម្នាក់ទៀត បន្ទាប់មកកូនទាំងពីរនាក់បានឈ្លោះវាយដណ្ដើមគ្នា។ មុននេះកូនទាំងពីរលេងយ៉ាងសប្បាយ តែពេលនេះបែរជាឈ្លោះប្រកែកគ្នា និងយំព្កកងរំពង។ អ្នកចង់បញ្ឈប់ការឈ្លោះប្រកែកគ្នានេះ ហើយក៏ចង់បង្រៀនពួកគេលើកក្រោយកុំឱ្យឈ្លោះប្រកែក និងវាយគ្នាទៀត។ មុននឹងធ្វើការឆ្លើយតបអ្នកត្រូវពិចារណាអំពីអ្វីដែលអ្នកបានរៀន និងយល់ដឹងពីកម្រិតនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ និងចរិករបស់ពួកគេ។

*តើអ្វីដែលបណ្ដាលឱ្យគេមានអាកប្បកិរិយាបែបនេះ ?*

### ០៤. ករណីសិក្សា (ឃ)៖ កុមារនៅចន្លោះអាយុ ១០ ទៅ ១២ឆ្នាំ

នៅក្នុងដំណាក់កាលនេះ កូនអ្នកមានទំនាក់ទំនងនឹងសង្គមកាន់តែច្រើន និងគិតថាវាមានសារៈសំខាន់បន្តិចម្ដងៗ។ ពួកគេបានដកពិសោធន៍ក្នុងការបង្កើតមិត្តភាព ក៏ដូចជាបង្កើនជម្លោះជាមួយមិត្តភក្តិរបស់គេដែរ។ ពួកគេបានកំពុងរៀនអំពីខ្លួនឯងថាពួកគេជានរណា ហើយពួកគេចង់ក្លាយជាអ្វី។ សូមអ្នកធ្វើការស្រម៉ៃថា៖

**ឃ.** កូនអ្នកបានធ្វើដំណើរត្រឡប់មកផ្ទះវិញជាមួយអារម្មណ៍មិនល្អ។ គេមិនចង់និយាយរកអ្នកទេ មិនតែប៉ុណ្ណោះគេក៏បានបញ្ចេញអាកប្បកិរិយា និងសម្លេងដោយកំហឹងដាក់អ្នកទៀតផង។ អ្នកមានអារម្មណ៍ថាកូនអ្នកមានសម្ដី និងចរិកឈ្លើយ ដែលកំពុងមើលងាយដល់អ្នក។ អ្នកចង់បង្រៀនដល់កូនអ្នកកុំឱ្យគេនិយាយ ឬមានអាកប្បកិរិយាបែបនេះ ព្រោះវាមិនសមរម្យ។

*តើអ្វីដែលបណ្ដាលឱ្យគេមានអាកប្បកិរិយាបែបនេះ ?*

## III. ដោះស្រាយបញ្ហា ចំពោះករណីសិក្សា

### ០១. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា (ក)៖ កុមារនៅចន្លោះអាយុក្រោម ៣ឆ្នាំ

- ត្រូវការស្ទាប និងកាន់ដើម្បីរៀន
- មានចំណង់ខ្លាំងក្នុងការស្វែងយល់ពីវត្ថុ
- កង្វះបទពិសោធន៍ក្នុងការរស់នៅ និងមិនដឹងអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយវត្ថុទាំងនោះ
- កង្វះចំណេះដឹងអំពីថា តើវត្ថុណាខ្លះដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់
- កម្រិតនៃការយល់ដឹងពីការស្ដាប់ ការព្រមាន ការពន្យល់ និងភាសា នៅមានកម្រិតនៅឡើយ

- ការរំជួលចិត្តចង់ដឹងចង់ឃើញការបញ្ចេញអារម្មណ៍និងការសាកល្បងជាមួយនឹងវត្ថុថ្មីៗ
- ភាពទុកចិត្ត និងជឿជាក់ចំពោះសុវត្ថិភាពរបស់ខ្លួន នៅក្នុងរង្វង់បរិស្ថានជុំវិញ
- ស្រឡាញ់ការរៀនសូត្រ និងស្វែងយល់ជានិច្ច

### សកម្មភាព និងរបៀបគាំទ្រ

- ផ្តល់របស់របរឱ្យកុមារលេងដែលមានសភាពទន់ អាចចាប់កាន់បានស្រួល មិនបង្កឱ្យស្លាក់ ឬ មានជាតិពុលពេលកុមារបៀម
- នៅជិតកុមារ នាំកុមារលេង និងជួយគាត់នៅពេលលេង រួមទាំងនិយាយពាក្យផ្អែមល្ហែមនៅពេលដែលធ្វើសកម្មភាពជាមួយគាត់
- ពន្យល់ ឬណែនាំកុមារអំពីវត្ថុមួយចំនួនដែលបង្កឱ្យមានគ្រោះថ្នាក់ រួមទាំងផលប្រយោជន៍របស់វត្ថុនោះផងដែរ ដោយប្រើពាក្យផ្អែមល្ហែម និងភាសាសាមញ្ញបំផុតជាមួយគាត់ ទោះបីជាពួកគាត់មិនទាន់ចេះស្តាប់ ឬយល់បានពេញលេញក៏ដោយ
- ទុកដាក់វត្ថុមុតស្រួច ឬវត្ថុដែលបង្កឱ្យគ្រោះថ្នាក់ដល់កុមារឱ្យឆ្ងាយ ឬផុតពីដៃកុមារ
- ធ្វើរនាំងបាំង សម្រាប់ទីកន្លែងដែលបង្កគ្រោះថ្នាក់ដូចជា៖ កន្លែងដែលមានចរន្តអគ្គិសនី ភ្នក់ភ្លើង ចង្ក្រាន ស្រះ ឬប្រឡាយទឹក មាត់ទ្វារ ។ល។
- ផ្តល់ភាពកក់ក្តៅ និងផ្តល់ឱកាសឱ្យកុមារបានលេង សំរាក(គេង) ញុំា ដើម្បីជួយឱ្យកុមារមានការលូតលាស់ និងអភិវឌ្ឍ

**គួរចងចាំ**

- **កូន ឬកុមារដែលចេះដើរតេះតះនោះមិនមែនគាត់ចង់ធ្វើ ចង់កាន់ ស្ទាប ភ្លក់រសជាតិ ឬទម្លាក់ចោលរបស់របរ វត្ថុ ដើម្បីធ្វើឱ្យខូចខាត បាក់បែក ឬធ្វើឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកមើលថែខឹងសម្បារនោះទេ។ ពួកគេមិនយល់អ្វីទាំងអស់ថា តើវត្ថុណាខ្លះដែលបង្កឱ្យពួកគេមានការឈឺចាប់ ឬវត្ថុណាខ្លះមានតម្លៃ ជាកម្មសិទ្ធិ ឬវត្ថុណាខ្លះដែលអាចបែក ឬបាក់នោះឡើយ។**

## ២. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា (ខ)៖ កុមារនៅចន្លោះអាយុ ៣ ទៅ ៥ឆ្នាំ

- កង្វះបទពិសោធន៍ជាមួយនឹងការទទួលរងនូវការបុក ឬការប៉ះទង្គិចដោយវត្ថុ ឬដោយកម្លាំងខ្លាំង ខ្សោយជាមួយនឹងគ្រឿងម៉ាស៊ីន ។ល។
- កង្វះការយល់ដឹងពីទំហំ និងកម្លាំងរថយន្តធៀបទៅនឹងរាងកាយរបស់ខ្លួន
- កង្វះការយល់ដឹងអំពីផលប៉ះពាល់នៃរយៈចម្ងាយ ល្បឿននៃការជួបរបស់យានយន្តដែលកំពុងបើកលឿន ឬយឺតដែលអាចប៉ះ ឬបុកមកលើរាងកាយខ្លួន។
- អសមត្ថភាពក្នុងការយល់ពីទស្សនៈរបស់អ្នកបើកបរ
- កង្វះការយល់ដឹងថា តើការរងរបួសស្រាល ឬធ្ងន់មានន័យយ៉ាងដូចម្តេច?

- កង្វះការយល់ដឹងអំពីសេចក្តីស្លាប់ និងអចិន្ត្រៃភាពរបស់វា (ការមិនវិលត្រឡប់វិញ)
- និន្នាការចាញ់នៅក្នុងការលេង មិនបានដឹងពីគ្រោះថ្នាក់អ្វីផ្សេងៗទៀតដែលនៅជុំវិញខ្លួនពួកគេ។

### សកម្មភាព និងរបៀបគាំទ្រ

- ពន្យល់ ឬណែនាំកុមារអំពីរបៀបឆ្លងផ្លូវ និងការទទួលរងនូវការបុក ឬការប៉ះទង្គិចជាមួយវត្ថុ ឬគ្រឿងម៉ាស៊ីន
- ជួយឱ្យកុមាររៀនគិតថា នៅពេលដែលខ្លួនគាត់មិនមានទំនុកចិត្ត ឬលទ្ធភាពធ្វើអ្វីមួយដោយ ខ្លួនឯងបាន គាត់ត្រូវសុំជំនួយពីមនុស្សធំដែលនៅជិតគាត់
- រៀបចំទីកន្លែងដែលកុមារលេងឱ្យមានសុវត្ថិភាពតាមដែលអាចធ្វើទៅបាន ដូចជា៖ ឆ្ងាយពីផ្លូវធំនិងទីកន្លែងដែលមានភាពងាយស្រួលក្នុងការលេង (វាលស្មៅ ឬទីកន្លែងដែលមិនមានរបងលួស បន្លា ឬដីគ្រួស ។ល។)
- ព្យាយាមនៅជិតកុមារ ឬលេងជាមួយកុមារ
- ផ្តល់ភាពកក់ក្តៅតាមរយៈពាក្យសម្តី អាកប្បកិរិយា លេងជាមួយ និងពន្យល់ណែនាំអំពី និន្នាការចាញ់ឈ្នះក្នុងពេលលេងអ្វីមួយ ព្រមទាំងគ្រោះថ្នាក់ផ្សេងៗទៀតដែលអាចកើតមាននៅជុំវិញខ្លួនរបស់គាត់។

## ៣. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា (គ)៖ កុមារនៅចន្លោះអាយុ ៦ ទៅ ៩ឆ្នាំ

- កង្វះបទពិសោធន៍ក្នុងការដោះស្រាយបញ្ហា ឬជម្លោះ
- ពិបាកក្នុងការយល់ពីទស្សនៈ របស់អ្នកដទៃ
- កង្វះបទពិសោធន៍ក្នុងការបង្ហាញពីអារម្មណ៍របស់ខ្លួន ជាពាក្យសម្តី។
- និស្ស័យដែលនាំឱ្យពួកគេមានប្រតិកម្មខ្លាំងក្លា ចំពោះការមិនសប្បាយចិត្តរឿងអ្វីមួយ។
- អាចធ្វើត្រាប់តាមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ នៅពេលដែលពួកគាត់ខឹង ឬមិនសប្បាយចិត្ត។

### សកម្មភាព និងរបៀបគាំទ្រ

- ពន្យល់ ឬណែនាំកុមារអំពីនិន្នាការចាញ់ឈ្នះក្នុងពេលលេងអ្វីមួយ របៀបនៃការចែករំលែកការអនុគ្រោះ និងការចេះអធ្យាស្រ័យគ្នាទៅវិញទៅមក ព្រមទាំងចេះទទួលកំហុសនៅពេលខ្លួនធ្វើអ្វីមួយខុសឆ្គង
- ជួយឱ្យកុមារហ៊ាននិយាយ និងបង្ហាញអារម្មណ៍របស់ខ្លួនពីការមិនពេញចិត្តអ្វីមួយតាមបែបវិជ្ជមាន រួមទាំងរៀនយល់ពីអារម្មណ៍នានា របស់អ្នកដទៃ។
- ចូលរួមធ្វើការដោះស្រាយបញ្ហាជាមួយពួកគេ ដោយស្តាប់ហេតុផល សួរសំណួរ និងជួយឱ្យពួកគេបង្កើតជម្រើសនានាដែលសមស្រប និងធ្វើការសម្រេចចិត្ត

- ធ្វើគំរូក្នុងការដោះស្រាយបញ្ហាតូច ឬធំដែលមានក្នុងជីវិតប្រចាំថ្ងៃតាមបែបវិជ្ជមាន ដើម្បីឱ្យពួកគេរៀន និងស្វែងយល់ពីរបៀបនៃការដោះស្រាយបញ្ហា។

## ៤. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា (ឃ)៖ កុមារនៅចន្លោះអាយុ ១០ ទៅ ១២ឆ្នាំ

- ការតានតឹងចិត្តក្នុងការដោះស្រាយបញ្ហាជាមួយនឹងស្ថានភាពដ៏ស្មុគស្មាញពេញមួយថ្ងៃ
- ការថប់បារម្ភក្នុងការធ្វើតាមការរំពឹងទុករបស់គ្រូ ទាក់ទងនឹងសកម្មភាព ឬអាកប្បកិរិយាអ្វីមួយ ឬកិច្ចការសាលាពេញមួយថ្ងៃ។
- មានការពិបាកក្នុងការរៀនសូត្រសម្រាប់មុខវិជ្ជាខ្លះ ដោយសារតែមានពិការភាពក្នុងការរៀនសូត្រ ឬដោយសារការបង្រៀនគ្មានប្រសិទ្ធភាព។
- ព្រួយបារម្ភខ្លាចធ្វើលំហាត់ប្រឡងមិនបានល្អ
- ភ័យខ្លាចថា គ្រូនឹងខឹងនូវពេលដែលខ្លួនធ្វើកិច្ចការសាលាមិនបានល្អ
- ត្រូវកុមារដទៃធ្វើបាប ឬមិត្តរួមថ្នាក់មិនរាប់រក
- មានការពិបាកក្នុងការបង្ហាញពីការភ័យខ្លាច និងក្ដីបារម្ភរបស់គាត់
- មានអារម្មណ៍ថាត្រូវបានកុមារដទៃទៀតដាក់សម្ពាធឱ្យធ្វើអ្វីដែលគាត់មិនយល់ព្រម
- មិនចែករំលែកអារម្មណ៍ ព្រោះចង់ដោះស្រាយបញ្ហាដោយខ្លួនឯង
- មិនមានអារម្មណ៍សុវត្ថិភាពក្នុងការបង្ហាញពីអារម្មណ៍មិនសប្បាយចិត្តរបស់ខ្លួន
- មិនបានសម្រាកគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់ខ្លួន
- ខ្វះអាហារូបត្ថម្ភសម្រាប់ការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ
- ការផ្លាស់ប្ដូរផ្នែកអ័រម៉ូនដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់គាត់។

### សកម្មភាព និងរបៀបគាំទ្រ

- រកពេលដែលសមស្របដើម្បីជួបពិភាក្សាជាមួយកូន និងស្ដាប់ហេតុផល
- ប្រើការស្ដាប់ដោយយកចិត្តទុកដាក់ និងការយល់ចិត្ត
- ជួយឱ្យកូនឆ្លុះបញ្ចាំងពីទង្វើ ឬសកម្មភាពរបស់ខ្លួន និងចេះទទួលកំហុសនៅពេលខ្លួនធ្វើអ្វីមួយខុសឆ្គង
- ជួយ និងផ្ដល់ឱកាសឱ្យកូននិយាយពីតម្រូវការរបស់ខ្លួន និងបង្ហាញពីអារម្មណ៍នានាដែលខ្លួនមាន
- ផ្ដល់ភាពកក់ក្ដៅ តាមរយៈពាក្យសម្ដី អាកប្បកិរិយា ការយកចិត្តទុកដាក់ និងគាំទ្រពួកគេគ្រប់ពេល
- ទទួលស្គាល់ថា កូនមានការប្រែប្រួលផ្នែកអ័រម៉ូន ដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់ពួកគាត់។

## ខ្លឹមសារបន្ថែម

អ្នកសម្របសម្រួលត្រូវបញ្ចូលខ្លឹមសារស្ដីពី **ពិការភាព** និង **ភាពខុសគ្នាក្នុងការចិញ្ចឹមកូនស្រី និងកូនប្រុស** ផងដែរ។ អ្នកសម្របសម្រួលគួរសួរបំផុសខ្លះៗអំពីកុមារដែលមានពិការភាព។

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គួរផ្ដល់ការថែទាំជាពិសេសដើម្បីការពារកុមារដែលមានពិការភាព ពីការរំលោភបំពានគ្រប់ប្រភេទ។ កុមារទាំងនោះនឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរដូចជា ចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេ នឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យ យ៉ាងហោចណាស់មួយឆ្នាំមុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តការគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពនានានៅក្នុងសង្គមផងដែរ។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) កំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀត អាចមានច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួន៖

- **ថ្លង់ ឬខ្សោយការស្ដាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អ តែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺ ខ្សោយការស្ដាប់ (មិនអាចស្ដាប់បាន ឬស្ដាប់បានមិនល្អ)។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើល មិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្ដាប់នោះអាចឱ្យពួកគាត់មានឱកាសរៀនភាសាបានល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ទទួលបានការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមាររបស់គាត់ដែលមានពិការភាពនេះ ដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាពទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍការប្រាស្រ័យទាក់ទង មានភាពកក់ក្ដៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្នមានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការគ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។
- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយសតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់ បានចប់បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹកគេង និងហូបចុក ជាដើម។ មានកុមារមួយចំនួនទៀត មានបញ្ហាខ្សោយសតិបញ្ញា

ប្រភេទធ្ងន់ធ្ងរ។ ពួកគេមិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការអ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេសថែមទៀត ពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។

- **ខ្សោយកាយសម្បទា ឬរាងកាយ៖** កុមារមួយចំនួនទៀត មានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាចដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល មជ្ឈមណ្ឌលស្តារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលស្តារនីតិសម្បទានៅតាមខេត្ត។
- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះអាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយលំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារ ដែលមានបញ្ហាភ្នែកតាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិនឈោងចាប់របស់របរលេង មិនលូន ឬវារ ទារកលេងកំសាន្តតិចតួច នៅតែម្នាក់ឯងច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារក ដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការថែទាំ និងការគាំទ្រ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

| ភាពខុសគ្នារវាងកុមារា និងកុមារី | |
|---|---|
| កុមារា | កុមារី |
| • រាងកាយមានភាពរហ័សរហួន និងសកម្ម<br>• មានជំនាញវិភាគ ក្នុងលំហ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយនឹងការធ្វើឱ្យអ្វីៗផ្លាស់ទី<br>• រៀនតាមរយៈ ការមើល<br>• តក់ក្រហល់ក្នុងការធ្វើអ្វីមួយ<br>• បែងចែកការងារច្បាស់ ដោយផ្តោតអារម្មណ៍ម្តងមួយៗ<br>• ត្រូវការពេលវេលាដើម្បីផ្ទង់អារម្មណ៍ក្នុងការធ្វើអ្វីមួយ<br>• រុករក ឬស្វែងយល់ និងចង់ដឹងពី អ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តបង្ហាញសកម្មភាពជាងនិយាយពីអារម្មណ៍របស់គេ | • រាងកាយមានភាពទន់ភ្លន់<br>• មិនសូវមានជំនាញវិភាគ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយពណ៌<br>• រៀនតាមរយៈ ការស្តាប់<br>• គិតច្បាស់លាស់មុននឹងធ្វើអ្វីមួយ<br>• មិនមានការបែងចែកច្បាស់ អាចធ្វើការច្រើនមុខក្នុងពេលតែមួយ<br>• អាចធ្វើបានភ្លាមៗ<br>• ស្តាប់ ដើម្បីដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តនិយាយ ដើម្បីបង្ហាញពីអារម្មណ៍របស់ខ្លួន |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែក ការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br><br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមជំផ្តល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្រ្ត |
|---|---|---|---|
| ៤ | ការកសាងក្រុម | **ល្បែងថាមពលក្តាមកៀប (១០នាទី)** | ▪ ប្រាប់អ្នកចូលរួមថា មុននឹងបន្តទៅមេរៀនថ្មី យើងនឹងលេងល្បែងមួយហៅថា ល្បែងក្តាមកៀប។ សុំឱ្យអ្នកចូលរួមអង្គុយជារង្វង់ រួចពន្យល់ថា នៅពេលខ្ញុំនិយាយថា៖<br>• □**លេខ១**□ អ្នកទាំងអស់គ្នាលើកដៃស្តាំចង្អុលឡើងលើត្រឹមស្មា<br>• □**លេខ២**□ អ្នកទាំងអស់គ្នាលាបាតដៃឆ្វេងដាក់នៅលើក្បាលជង្គង់ឆ្វេងរបស់គាត់<br>• □**លេខ៣**□ អ្នកទាំងអស់គ្នា យកដៃស្តាំ ដែលលើកចង្អុលត្រឹមស្មាអម្បាញ់មិញដាក់ទៅលើ និងដាក់ឱ្យចំកណ្តាលបាតដៃខាងឆ្វេងអ្នកដែលនៅក្បែរ<br>• នៅពេលដែលខ្ញុំនិយាយថា □**ក្តាមកៀប**□ បាតដៃដែលលាប្រញាប់ក្តោបចាប់ចង្អុលដៃឱ្យជាប់ ចំណែកចង្អុលដៃប្រញាប់ដកចេញ កុំឱ្យគេចាប់បាន។<br>▪ នៅពេលដែលពួកគាត់យល់ពីដំណើរការលែងល្បែងនេះហើយ អ្នកសម្របសម្រួលចាប់ផ្តើមរាប់ ១ ២ ៣ និងនិយាយពាក្យថា ក្តាមកៀប បន្តធ្វើដូចនេះចំនួន៥ទៅ៦ដង។<br>▪ ឥឡូវនេះលោកអ្នកមានអារម្មណ៍ប្រសើរហើយ បន្តទៅទៀតនេះ យើងនឹងពិភាក្សាលើប្រធានបទថ្មីមួយទៀតគឺ (ធាតុផ្សំទី៤) □**ការដោះស្រាយបញ្ហា**□ ជាមួយកូន ឬកុមារ ។ |
| ៥ | មេរៀនថ្មី៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៤) | **ធាតុផ្សំទី៤៖ ដោះស្រាយបញ្ហា (អាយុ 0ឆ្នាំ រហូតដល់ ១២ឆ្នាំ)**<br>**ឆ្លុះបញ្ចាំងអំពីរបៀប និងបទពិសោធន៍នៃការដោះស្រាយបញ្ហា (២០នាទី)** | ▪ សូមប្រាប់អ្នកចូលរួមថា យើងបានធ្វើដំណើរឆ្លងកាត់ធាតុផ្សំនានានៃការចិញ្ចឹមកូនបែបវិជ្ជមាន ឥឡូវនេះយើងមកដល់ធាតុផ្សំទី៤ដែលជាធាតុផ្សំចុងក្រោយគឺ □**ការដោះស្រាយបញ្ហា**□ ដោយផ្តោតសំខាន់លើអាកប្បកិរិយាលំបាកៗរបស់កូន ឬកុមារដែលមានចន្លោះអាយុ 0ឆ្នាំ រហូតដល់ ១២ឆ្នាំ។<br>☞ អ្នកសម្របសម្រួល ចាប់ផ្តើមដោយសួរសំណួរ៖<br>☞ តើការដោះស្រាយបញ្ហាជាមួយកូនមានន័យដូម្តេច?<br>🗣 ចម្លើយរំពឹងទុក៖ ជាការប្រាប់ ឬការបង្ខិតបង្ខំឱ្យកូនធ្វើអ្វីមួយដោយប្រើអំណាចជាមនុស្សធំដូចជា បង្ខំឱ្យធ្វើតាម ហាមមិនឱ្យធ្វើ ការស្តីបន្ទោស ជេរ សំឡុត ដាក់កំហិត ឬវាយជាដើម។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចបន្ថែមថា ការដោះស្រាយបញ្ហា គឺជាការបង្រៀនកូន ឬជួយកូនឱ្យចេះធ្វើការដោះស្រាយបញ្ហាដោយសន្តិវិធី ឬមិនប្រើអំពើហិង្សា តាមរយៈការប្រាស្រ័យទាក់ទងល្អជាមួយអ្នកដទៃ ការរៀនពីភាពបរាជ័យ និងជោគជ័យ កំហុស ដោយការយោគយល់ អធ្យាស្រ័យ និងចេះបត់បែន។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសួរសំណួរបន្ត<br>☞ តើឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ តែងប្រើការដោះស្រាយបញ្ហានានាជាមួយកូន ឬកុមារ តាមរបៀបណាខ្លះ ?<br>🗣 ចម្លើយរំពឹងទុក៖ ប្រាប់ឱ្យធ្វើតាម ពិភាក្សារកដំណោះស្រាយ ស្ដាប់ពីហេតុផល ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតរបស់អ្នកចូលរួម។ ប្រសិនបើរបៀបដោះស្រាយបញ្ហាដែលពួកគាត់លើកឡើង បែបហិង្សា ឬបែបអវិជ្ជមាន អ្នកសម្របសម្រួលត្រូវតែលើកយកចំណុចនោះមកពិភាក្សា ដើម្បីជួយឱ្យពួកគាត់បានឃើញពីចំណុចល្អ ឬមិនល្អ ឬផលប៉ះពាល់នៃដំណោះស្រាយនោះទៅលើ កូន ឬកុមារដូចជា (ប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្ត) ឬក៏ផ្នែកទំនាក់ទំនងជាដើម។ល។ លើសពីនេះទៅទៀតកូនឬកុមារគ្រប់រូបត្រូវការនិងពេញចិត្តទទួលយកនូវរបៀបដោះស្រាយបញ្ហាពី ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបដោយភាពអហិង្សា ភាពកក់ក្ដៅ និងការយល់ចិត្ត។ ដូច្នេះដើម្បីជួយឱ្យកុមារទទួលបាននូវតម្រូវការរបស់ពួកគេបាន ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបត្រូវតែយកចិត្តទុកដាក់ និងស្វែងរកសេវាគាំទ្រផ្សេងៗសម្រាប់ពួកគេ។ អ្នកសម្របសម្រួលអាចបន្ថែមខ្លឹមសារមួយចំនួនទៀត ដូចមាននៅក្នុងមេរៀនខាងលើ។<br>▪ អ្នកសម្របសម្រួល អាចសួរបន្តទៀតថា<br>☞ សម្រាប់កុមារដែលមានពិការភាព តើលោកអ្នកប្រើរបៀបដោះស្រាយបញ្ហាដូចម្ដេចដែរ ?<br>🗣 ចម្លើយរំពឹងទុក៖ ដូចគ្នានឹងកុមារទូទៅដែរ ភាគច្រើនឱ្យគាត់ធ្វើតាមយើងព្រោះគាត់មិនសូវចេះគិត ឬស្ដាប់គ្នាមិនសូវយល់ ។ល។<br>▪ អ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមបានឆ្លើយ និងចូលរួមគ្រប់ៗគ្នារួមទាំងជួយឱ្យអ្នកចូលរួមយល់ថាកុមារា និងកុមារី ដែលមានពិការភាពចាំបាច់ និងពេញចិត្តទទួលយកនូវរបៀបដោះស្រាយបញ្ហាពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបដោយអហិង្សា ផ្ដល់ភាពកក់ក្ដៅ និងការយល់ចិត្តដូចជាកុមារទូទៅដែរ។ ដើម្បីឱ្យពួកគេជួបនឹងតម្រូវការពិសេសនេះបាននោះ គឺទាមទារឱ្យមានការគាំទ្រដោយយកចិត្តទុកដាក់ពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំរបស់គេ។ ដូច្នេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបត្រូវតែស្វែងរកសេវាគាំទ្រផ្សេងៗ ដើម្បីបំពេញតម្រូវការពិសេសទាំងនោះ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | **កំណត់សម្គាល់៖ អ្នកសម្របសម្រួលសូមធ្វើការពន្យល់ថា**<br>▪ ការដោះស្រាយបញ្ហា ជាពិសេសអាកប្បកិរិយាលំបាកៗជាមួយកូន ឬកុមារ តាមរយៈការប្រើអំណាចជាមនុស្សពេញវ័យ ប្រើហិង្សា មិនមែនជាវិធីដែលគាំទ្រ និងជួយឱ្យកូនផ្លាស់ប្តូរអាកប្បកិរិយា ឬបំពេញតម្រូវការដែលគេត្រូវការនោះទេ។ ផ្ទុយទៅវិញពួកគេនឹងទទួលបាននូវភាពភ័យខ្លាច ឈឺចាប់ រងរបួស បាត់បង់ទំនាក់ទំនងជាមួយគ្រួសារ ខ្វះទំនុកចិត្ត និងបាត់បង់ភាពក្លាហាន ។ល។ បទពិសោធន៍ និងផលប៉ះពាល់ទាំងនេះបានធ្វើឱ្យកូន ឬកុមារខ្លះចាកចេញពីផ្ទះ និងគ្រួសារស្របពេលជាមួយមជ្ឈដ្ឋានជុំវិញខ្លួន មានសភាពអាប់អួរ។ ទាំងនេះសុទ្ធតែជាឱកាស និងអំណោយផលដល់ជនខិលខូច ទាក់ទាញពួកគេបានយ៉ាងមានប្រសិទ្ធភាពពិសេសជំរុញឱ្យពួកគេធ្វើសកម្មភាពទំនាស់នឹងច្បាប់។<br>▪ លើសពីនេះទៅទៀតនៅពេលដែលមានបញ្ហាកើតឡើងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំខ្លះបានបង្ខំចិត្តបំបែកកូនចេញពីគ្រួសារ តាមរយៈការបញ្ជូនទៅរស់នៅជាមួយសាច់ញាតិ ឬរស់នៅក្នុងមណ្ឌល គ្រួសារចិញ្ចឹមផ្សេង ខណៈពួកគេគិតថាគ្រួសារកំពុងខ្វះសមត្ថភាព ឬលទ្ធភាពក្នុងការអប់រំណែនាំ និងការចិញ្ចឹមបីបាច់។ គួររំឭកថា ទង្វើទាំងនេះ មិនបានជួយឱ្យកូន ឬកុមារបានទទួល ឬបំពេញនូវតម្រូវការរបស់ពួកគេដូចដែល ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបានគិតនោះទេ តែវាធ្វើឱ្យកូន ឬកុមាររងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងដោយសារពួកគេបាត់បង់នូវភាពកក់ក្តៅ និងក្តីស្រឡាញ់ក្រុមគ្រួសារផ្ទាល់របស់ពួកគេ។ លើសពីនេះទៀតកូន ឬកុមារ ក៏អាចរងនូវការរំលោភបំពានផ្សេងៗដូចជា ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើ ពីអ្នកថែទាំក្នុងមណ្ឌលមួយចំនួនផងដែរ។ ឪពុកម្តាយ អាណាព្យាលបាល ឬអ្នកថែទាំ មិនត្រូវបានការលើកទឹកចិត្តឱ្យមានការបំបែបកូន ឬកុមារចេញពីគ្រួសារឡើយ ព្រោះវាមិនមែនជាជម្រើសទីមួយ នៃការសម្រេចចិត្តយកកុមារដាក់ក្នុងមណ្ឌលទេ វាគឺជាជម្រើសចុងក្រោយបង្អស់។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **ស្វែងយល់ពីបញ្ហា និងស្ថានភាពលំបាកៗរបស់កុមារតាមរយៈករណីសិក្សា (៣០នាទី)** | ▪ ឥឡូវនេះយើងនឹងរៀនពីស្ថានភាពពិបាកៗមួយចំនួនដែលកើតឡើងចំពោះកូន ឬកុមារតាមដំណាក់កាល និងកម្រិតអាយុ។ យើងនឹងប្រើអ្វីដែលយើងបានរៀនអំពីការអភិវឌ្ឍរបស់កុមារ ដើម្បីគិតនូវអ្វីៗដែលអាចបណ្តាលឱ្យកូន ឬកុមារមានអាកប្បកិរិយាលំបាកៗទាំងនោះ។ ការអនុវត្តនេះនឹងជួយឱ្យអ្នកចូលរួមអភិវឌ្ឍការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។<br>▪ អ្នកសម្របសម្រួលបន្តថា យើងនឹងអនុវត្តលើករណីសិក្សា ឬសម្តែងតួអំពីកូន ឬកុមារនៅតាម ដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ដើម្បីស្វែងយល់ពីតម្រូវការ របៀបនៃការបំពេញតម្រូវការ ការគ្រប់គ្រងចិត្ត និងការគ្រប់គ្រងស្ថានភាពពិបាកៗរបស់កុមារ។<br>▪ ចូរបន្តថា យើងនឹងធ្វើការងារជាក្រុមតូចៗ ដើម្បីពិនិត្យមើល និងស្វែងយល់ពីដំណើរការនៃការលូតលាស់ និងអភិវឌ្ឍ ព្រមទាំងមូលហេតុនានាដែលនាំឱ្យកុមារ មានអាកប្បកិរិយាបែបនោះ។<br>▪ ចែកអ្នកចូលរួមជា៤ក្រុម<br>• ចែកករណីសិក្សា ទៅឱ្យក្រុមនីមួយៗ<br>ក្រុមទី១៖ ករណីសិក្សា ក<br>ក្រុមទី២៖ ករណីសិក្សា ខ<br>ក្រុមទី៣៖ ករណីសិក្សា គ<br>ក្រុមទី៤៖ ករណីសិក្សា ឃ<br>• ក្រុមនីមួយៗគិតថា ពេលនេះពួកគាត់កំពុងថែទាំកូនដោយស្រម៉ៃទៅតាមករណីសិក្សាដែលបានចែកជូន ហើយឱ្យពួកគាត់ប្រើប្រាស់ចំណេះដឹងដែលរៀនពីវគ្គមុនៗ ស្តីពីការលូតលាស់ និងអភិវឌ្ឍកុមារ និងធាតុផ្សំនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន ដើម្បីអនុវត្តការដោះស្រាយបញ្ហានេះ។<br>▪ ចាត់តំណាងក្រុមនីមួយៗ ឡើងបង្ហាញដល់ក្រុមធំ។<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រា ពេលក្រុមនីមួយៗធ្វើបទបង្ហាញរួចសរុបខ្លឹមសារ បន្ទាប់ពីក្រុមទាំង ៤ បានបង្ហាញចប់ ដើម្បីជួយឱ្យអ្នកចូលរួមយល់ច្បាស់ថាមានហេតុផលអ្វីដែលធ្វើឱ្យកូន ឬ កុមារមានអាកប្បកិរិយាលំបាកៗបែបហ្នឹង ដោយឆ្លុះបញ្ចាំងទៅនឹងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ រួមទាំងបន្ថែមខ្លឹមសារ និងពន្យល់អំពីសកម្មភាព និងរបៀបគាំទ្រនានា ដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំយកទៅអនុវត្តជាមួយកូន ដូចមាននៅក្នុងខ្លឹមសារមេរៀន។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **ការសម្តែងតួ (៣០នាទី)** | ▪ អ្នកសម្របសម្រួលជ្រើសរើសករណីសិក្សាមួយចេញពីករណីសិក្សាទាំង៤ ខាងលើ ហើយសុំឱ្យសមាជិកម្នាក់ក្នុងក្រុមនោះដើរតួជាកូន ឬកុមារ រីឯអ្នកសម្របសម្រួលដើរតួជាអ្នកថែទាំ ដោយធ្វើការសម្តែងតួ ដើម្បីបង្ហាញដល់ក្រុមធំដោយអនុវត្តនូវធាតុផ្សំទាំង៤ក្នុងការដោះស្រាយបញ្ហា ឬអាកប្បកិរិយាលំបាកៗ។ ក្រោយការសម្តែងតួចប់ អ្នកសម្របសម្រួលសួរសំណួរទៅអ្នកចូលរួម៖<br>☞ តើអ្នកបានកត់សម្គាល់ឃើញអ្វីខ្លះពីការសម្តែងតួនេះ? ដោយធ្វើការឆ្លុះបញ្ចាំងទៅនឹងធាតុផ្សំទាំង៤ ដែលបានរៀន និងចងចាំ?<br>▪ អ្នកសម្របសម្រួលមិនត្រឹមតែប្រមូលគំនិតនោះទេ លើសពីនេះទៀតគឺជួយឱ្យពួកគាត់យល់ច្បាស់ពីសកម្មភាព ឬរបៀបគាំទ្រមួយចំនួនដែលបង្ហាញអំពី គោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់ យល់អំពីការគិត និងអារម្មណ៍ និងការដោះស្រាយបញ្ហា។<br><br>ចំណាំ៖ អ្នកសម្របសម្រួលហាត់សមសម្តែងក្នុងការដោះស្រាយបញ្ហានេះ ដោយប្រើធាតុផ្សំទាំងអស់រួមបញ្ចូលគ្នា។ |
| | | **សង្ខេបមេរៀន (៥នាទី)** | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីការដោះស្រាយបញ្ហាជាមួយកូន ឬកុមារ ដែលមានចន្លោះអាយុពី ០ឆ្នាំ រហូតដល់ ១២ឆ្នាំ ដោយមើលទៅលើមូលហេតុដែលកូន ឬកុមារសម្តែងនូវអាកប្បកិរិយាដែលគេមាន។ ឥឡូវយើងបានមកដល់ធាតុផ្សំចុងបញ្ចប់ហើយ បើយើងគិត និងឆ្លើយដោយស្មោះត្រង់ អំពីខ្លួនឯងថា នៅមុនពេលរៀន និងក្រោយពេលរៀន តើមាន □ប្រតិកម្ម□ ខុសគ្នាដូចម្តេចខ្លះចំពោះឥរិយាបថរបស់យើងជាមួយកូន ឬកុមារដូចក្នុងករណីសិក្សាអម្បាញ់មិញនេះ?<br><br>ការយល់ដឹងអំពីការលូតលាស់ និងអភិវឌ្ឍកុមារមានន័យថា យើងអាចព្យាយាមយល់ពីអ្វីដែលកំពុងកើតឡើងចំពោះកូន ឬកុមារនៅគ្រប់ដំណើរការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ហើយការយល់ដឹងនេះជួយយើងដោះស្រាយបញ្ហា ដែលយើងជួបប្រទះនៅក្នុងការគ្រប់គ្រងអាកប្បកិរិយាលំបាកៗ របស់កូន ឬកុមារបានផងដែរ។ ដូច្នេះដើម្បីធ្វើការដោះស្រាយបញ្ហាដែលតែងតែកើតមានឡើងតាមបែបអហិង្សា ឬបែបវិជ្ជមាន យើងទាំងអស់គ្នាត្រូវតែយល់ដឹងអំពី ការលូតលាស់ និងអភិវឌ្ឍកុមារ ធាតុផ្សំទាំង៤ នៃការប្រៀន |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ប្រដៅកូនបែបវិជ្ជមានឱ្យបានច្បាស់ ព្រោះវាអាចជួយឱ្យលោកអ្នកមានលទ្ធភាពអនុវត្តរួមបញ្ចូលគ្នាយ៉ាងសក្តិសិទ្ធដែលអាចឆ្លើយតប និងបំពេញតម្រូវការរបស់កូន ឬកុមារបានយ៉ាងមានប្រសិទ្ធភាព។<br>**គួរចងចាំ**<br>**ភារកិច្ចរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គឺត្រូវជួយកូន ឬកុមារឱ្យបានជួបនឹងតម្រូវការ តាមបែបវិជ្ជមាន ដោយត្រូវជួយឱ្យកូនមើលឃើញ និងកែតម្រូវនូវអាកប្បកិរិយារបស់គេ។**<br>**ការស្រែកគំហក ជេរ ស្តីបន្ទោស ឬវាយកូនមិនបាន ជួយដោះស្រាយបញ្ហាទេ វាគ្រាន់តែបង្រៀនកូនឱ្យចេះស្រែកគំហក ចាប់កំហុស និងចេះវាយនៅពេលដែលមាននរណាម្នាក់ធ្វើអ្វីមួយដែលគេមិនចូលចិត្ត។**<br>▪ សូមសួរអ្នកចូលរួមថា មានសំណួរទៀតដែរឬទេ? |
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន (១០នាទី)** | ▪ អ្នកសម្របសម្រួលសួរៈ<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្តេចដែរទៅលើទង្វើរបស់យើងកន្លងមក?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្តេចនៅក្នុងគ្រួសាររបស់លោកអ្នក? |
| | | **កិច្ចការផ្ទះ (៥នាទី)** | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្តើមធ្វើការកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយា ដែលអាចជួយកូនក្នុងការដោះស្រាយបញ្ហាទៅតាមដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ ដែលបានមកចូលរួម។ |



# ៤) ដោះស្រាយបញ្ហា

# វគ្គទី១១
# មេរៀនទី៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៥)

## សេចក្តីផ្តើម

យោងទៅតាមលទ្ធផលស្រាវជ្រាវឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និង អង្គការ UNICEF ស្តីពីអំពើហិង្សាលើកុមារ បានបញ្ជាក់ថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុតមានដូចជា ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។ ដូចនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបគួរសិក្សា ស្វែងយល់ពីអំពើហិង្សា ការមិនអើពើ និងផលប៉ះពាល់លើកុមារ។ ការយល់ដឹងពីផលប៉ះពាល់នេះ អាចជួយឱ្យ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំធ្វើការបញ្ឈប់អំពើហិង្សា និងការមិនអើពើលើកុមារ ដែលកន្លងមកពួកគាត់ តែងតែគិតថាការអប់រំប្រដៅកូនមានរបៀបពីរគឺ **ត្រជាក់** (អហិង្សា) **និងក្តៅ** (ហិង្សា) ពិសេសគឺយោងទៅលើនិស្ស័យ របស់កូន ឬកុមារ។ ការអប់រំប្រដៅកូនដោយបែបក្តៅដូចជាការស្តីបន្ទោស ជេរ គំរាម សំឡុត ដាក់ទណ្ឌកម្ម វាយដំ គឺគ្រាន់តែចង់ឱ្យកូនៗ ឬកុមារមានអាកប្បកិរិយាល្អតែប៉ុណ្ណោះ។ ដូច្នេះពួកគាត់គិតថាការធ្វើបែបនេះវាមិនមែនជា ការរំលោភបំពាននោះទេ ដោយសារមានការគិត ឬទម្លាប់បែបនេះហើយទើបនាំឱ្យមានការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាបន្តកើតមានលើកូន ឬកុមារនៅក្នុងគ្រួសារមួយចំនួនធំ។

ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងការគិត ឬទម្លាប់ខាងលើ យើងក៏បានរៀបចំចងក្រងប្រធានបទនៃការប្រៀន ប្រដៅកូនបែបវិជ្ជមាន ដែលជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដែលផ្តោត ទៅលើគោលការណ៍សំខាន់ៗចំនួន៥ និងធាតុផ្សំចំនួន៤ ក្នុងគោលបំណងជួយដល់ឪពុកម្តាយ អាណាព្យាបាល ឬ អ្នកថែទាំ កំណត់បានពីរបៀបនៃការប្រៀនប្រដៅកូនបែបវិជ្ជមាន និងការដោះស្រាយបញ្ហាជាមួយកូន ឬកុមារតាម ដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍកុមារ ព្រមទាំងជ្រើសរើស និងអនុវត្តនូវវិធីសាស្ត្រ ឬរបៀបចិញ្ចឹម កូនបែបវិជ្ជមាន ដោយប្រើគោលការណ៍សំខាន់ចំនួន៥ និងធាតុផ្សំចំនួន ៤។

# ១. គោលការណ៍ទាំង៥

គោលការណ៍
ទី១

## ភាពអហិង្សា

គឺជាការមិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកូន ឬកុមារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ។

គោលការណ៍
ទី២

## ផ្តោតទៅលើការរកដំណោះស្រាយ

គឺជាការស្តាប់ និងការបង្ហាញហេតុផល រួមទាំងការពិភាក្សា និងការស្វែងរកវិធី ឬរបៀបណាមួយដើម្បីដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ឬបែបវិជ្ជមានដែលមានការចូលរួមយល់ព្រម និងការចរចាគ្នា។

គោលការណ៍
ទី៣

## ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នា ក្នុងភាពជាមនុស្ស ដោយគ្មានការរើសអើង និងវិនិច្ឆ័យ។

គោលការណ៍
ទី៤

## ផ្តោតលើដំណាក់កាលលូតលាស់ និងអភិវឌ្ឍរបស់កុមារ

គ្រប់កុមារទាំងអស់ (កុមារា កុមារី ឬកុមារដែលមានពិការភាព) មានការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ទៅតាមកម្រិតអាយុរបស់ពួកគេ ដូចជាការលូតលាស់ និងអភិវឌ្ឍផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈ ការគិត និងអារម្មណ៍ ដូច្នេះការបំពេញទៅនឹងតម្រូវការរបស់ពួកគេ គឺមានភាពខុសៗគ្នា។

គោលការណ៍
ទី៥

## ផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

សិទ្ធិកុមារគឺជាអ្វីៗដែលកុមារមាន និងអ្វីដែលមនុស្សទទួលខុសត្រូវចំពោះកុមារ។ ពួកគេត្រូវធានាថា កុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំ និងនិយាយនូវអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ។ កុមារទាំងអស់ រួមទាំងកុមារដែលមានពិការភាពទទួលបាននូវសិទ្ធិទាំងនេះ មិនថាពួកគេជានរណា មានពណ៌សម្បុរអ្វី ភាសាអ្វី សាសនាណា ក្មេងប្រុស ឬក្មេងស្រី អ្នកក្រ ឬអ្នកមានឡើយ។ ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក បានចុះហត្ថលេខាលើឯកសារនេះ។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មានន័យថា ពួកគេបានសន្យានឹងធ្វើអ្វីៗទាំងអស់ដើម្បីធានាថា កុមារទាំងអស់ទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។

# ២. ធាតុផ្សំទាំង៤

| | | | |
|---|---|---|---|
| **ធាតុផ្សំទី១៖**<br>គោលដៅយូរអង្វែង | **ធាតុផ្សំទី២៖**<br>ភាពកក់ក្តៅ<br>និងដែនកំណត់ | **ធាតុផ្សំទី៣៖**<br>យល់អំពីការគិត<br>និងអារម្មណ៍ | **ធាតុផ្សំទី៤៖**<br>ដោះស្រាយបញ្ហា |

កាលពីវគ្គមុន លោកអ្នកបានធ្វើការពិភាក្សាគ្នារួចមកហើយអំពីគោលការណ៍សំខាន់ចំនួន ៥ និងធាតុផ្សំចំនួន ៣ នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន។ នៅក្នុងវគ្គនេះ យើងនឹងលើកយកធាតុផ្សំទី៤ **ដោះស្រាយបញ្ហា** សម្រាប់កូន ឬកុមារដែលមានអាយុពី ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មកធ្វើការពិភាក្សាគ្នា និងហាត់អនុវត្ត។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាច៖**<br>• ទទួលស្គាល់ពីមូលហេតុនានានៃអាកប្បកិរិយាដែលពិបាកៗ តាមរយៈការអនុវត្តចំណេះដឹងនៃការលូតលាស់ និងអភិវឌ្ឍកុមារ។<br>• ទទួលស្គាល់ថាកូន ឬកុមារមានអាកប្បកិរិយាពិបាកនានា នៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ហើយថែមទាំងរកឱ្យឃើញនូវមូលហេតុនៃអាកប្បកិរិយានោះ ដើម្បីជួយគាំទ្រដល់កូន ឬកុមារ រួមទាំងជួយឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងអារម្មណ៍ដែលប្រតិកម្មក្នុងខ្លួនផងដែរ។<br>• ហាត់អនុវត្តដោះស្រាយបញ្ហាជាមួយកូន ឬកុមារដែលមានអាយុពី ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដោយប្រើគោលការណ៍សំខាន់ៗ និងធាតុផ្សំទាំង៤ នៃការចិញ្ចឹមកូនបែបវិជ្ជមាន។ |
| **រយៈពេល** | **១៥០ នាទី** |
| **សម្ភារៈ ដែលត្រូវការ** | • ករណីសិក្សា ចំនួន២ (ក និងខ) បង្ហាញពី កុមារនៅចន្លោះអាយុ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ<br>• បណ្ណរូបភាព (Poster) ស្តីពីការប្រៀនប្រដៅកូនបែបវិជ្ជមាន<br>• ក្រដាសផ្ទាំងធំ ក្រដាសរ៉ាម (A4) ហ្វឺត ស្កុត កន្ត្រៃ<br>• កម្រាលសម្រាប់អ្នកចូលរួមអង្គុយ<br>• ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ<br>• ក្រដាសផ្ទាំងធំដែលកត់ត្រា អំពីវិន័យដែលក្រុមបានចងក្រងកាលពីជំនួបដំបូង |

**ខ្លឹមសារលម្អិត**

## I. ធាតុផ្សំទី៤៖ ដោះស្រាយបញ្ហា

ដោះស្រាយបញ្ហា គឺជាការបង្រៀនកូន ឬជួយកូនឱ្យចេះធ្វើការដោះស្រាយបញ្ហាដោយសន្តិវិធី ឬមិនប្រើអំពើហិង្សា តាមរយៈការប្រាស្រ័យទាក់ទងល្អជាមួយអ្នកដទៃ ការរៀនពីភាពបរាជ័យ និងជោគជ័យ កំហុស ដោយការយោគយល់អធ្យាស្រ័យ និងចេះបត់បែន។

នៅក្នុងគ្រួសារនីមួយៗ តែងតែកើតមានបញ្ហាដូចជា៖ ការខ្វែងគំនិតគ្នា ជម្លោះ ឬការមិនសប្បាយចិត្ត ។ល។ រវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ ដែលមានករណីស្រដៀងៗគ្នាពីគ្រួសារមួយទៅគ្រួសារមួយ។ **សូមចងចាំថា៖**

- កូនអ្នកនឹងមានតម្រូវការ ឬភាពសំខាន់ៗ និងភាពប៉ិនប្រសព្វផ្សេងៗគ្នាទៅតាមកម្រិតនៃអាយុរបស់ពួកគេ។
- កូន ឬកុមារដែលមានអាកប្បកិរិយាមិនសមរម្យដូចជា យំ កាច កុហក ឬមិនស្តាប់បង្គាប់ មិនមែនដោយសារតែគេ □មិនល្អ□ នោះទេ គេមានអាកប្បកិរិយាបែបនោះ គឺដើម្បីព្យាយាមបំពេញតម្រូវការដែលគេចង់បាន និងសុវត្ថិភាពសម្រាប់ខ្លួនគេតែប៉ុណ្ណោះ។
- ភារកិច្ចរបស់យើង គឺត្រូវជួយកូន ឬកុមារឱ្យបំពេញតម្រូវការតាមបែបវិជ្ជមាន ដោយត្រូវជួយពួកគេឱ្យមើលឃើញ និងកែតម្រូវនូវអាកប្បកិរិយាមិនសមរម្យទាំងនោះ។
- ការស្រែកគំហក ស្តីបន្ទោស គំរាមកំហែង ឬវាយដំកូនមិនបានជួយដោះស្រាយបញ្ហាទេ វាគ្រាន់តែបង្រៀនកូនឱ្យចេះស្រែកគំហក ចាប់កំហុស និងចេះប្រើអំពើហិង្សានៅពេលដែលមាននរណាម្នាក់ធ្វើអ្វីមួយដែលគេមិនពេញចិត្តតែប៉ុណ្ណោះ។
- កុមារគ្រប់រូប (រួមទាំងកុមារដែលមានពិការភាព) ត្រូវការឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរបស់ពួកគេយកចិត្តទុកដាក់ គោរព ឱ្យតម្លៃ ស្តាប់ហេតុផល យល់ពីការគិត និងអារម្មណ៍ ដឹងពីតម្រូវការ ទទួលស្គាល់ពីភាពសំខាន់ៗ ភាពប៉ិនប្រសព្វ និងប្រព្រឹត្តស្មើភាពគ្នារវាងកូនស្រីនិងកូនប្រុសស្របទៅតាមកម្រិតអាយុនិងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់ពួកគេ។
- គ្រួសារខ្លះមានបញ្ហាជាមួយនឹងរបៀបនៃការដោះស្រាយបញ្ហា ពិសេសជាមួយអាកប្បកិរិយាលំបាកៗរបស់កូន ឬកុមារដែលអាចបង្កឱ្យមានជម្លោះ ឬអំពើហិង្សានៅក្នុងគ្រួសារ ពេលខ្លះឈានដល់ការទុកកូន ឬកុមារចោលលែងយកចិត្តទុកដាក់ (ការមិនអើពើ) បោះបង់ចោល (ក្លាយជាកុមារអនាថា) ឬការបំបែកកូនចេញពីគ្រួសារ (យកកូនទៅដាក់មណ្ឌល ឬឱ្យគ្រួសារផ្សេងចិញ្ចឹម) ។ល។
- ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវធ្វើជាគំរូល្អសម្រាប់កូន ឬកុមារពិសេសគឺការផ្តល់ភាពកក់ក្តៅ និងដែនកំណត់ រួមទាំងយល់អំពីការគិត និងអារម្មណ៍របស់កូន ឬកុមារទៅតាមកម្រិតអាយុ និងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់ពួកគេ។

បញ្ហាទូទៅដែលតែងតែកើតមានក្នុងគ្រួសាររវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារមានដូចជា៖

- ចង់ឱ្យកូនស្ដាប់បង្គាប់ (ដោយការប្រើអំណាច)
- មិនយល់ (មិនខ្វល់) ពីអារម្មណ៍ និងការគិតរបស់កូន
- ប្រើពាក្យសំដីមិនសមរម្យដូចជា ពាក្យអសុរស សំឡុត គំរាមកំហែង ស្ដីបន្ទោស ជេរ ។ល។
- ដោះស្រាយបញ្ហាដោយហិង្សាជាមួយកូន ឬកុមារ
- ដោះស្រាយបញ្ហាជាមួយកូន ដោយមិនពន្យល់ហេតុផលនានា
- គិតថាខ្លួនជាមនុស្សពេញវ័យ និងអាងមានបទពិសោធន៍ច្រើនជាងកូន ឬកុមារ
- មិនប្រាប់អំពីអ្វីដែលគាត់ចង់បានទៅកូនឱ្យបានច្បាស់លាស់ ។ល។

នៅក្នុងសង្គមខ្មែរឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចដោះស្រាយបញ្ហាជាមួយកូនដោយមានរបៀបជាច្រើន។

### អវិជ្ជមាន

- ប្រើអំណាចជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ដើម្បីដោះស្រាយបញ្ហា។
- ធ្វើតាមទម្លាប់ ឬអ្វីដែលខ្លួនធ្លាប់ឆ្លងកាត់កន្លងមក។
- មិនស្ដាប់ហេតុផល ដាក់កំហុស ស្ដីបន្ទោស និងដាក់ទណ្ឌកម្មចំពោះកូន ឬកុមារ។
- បំពេញតែតម្រូវការរបស់ខ្លួនដោយមិនគិតអំពីផលប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍកុមារ។
- មិនឱ្យកូន ឬកុមារធ្វើអ្វីមួយដែលខ្លួនមិនពេញចិត្ត តែមិនពន្យល់ហេតុផល។

### វិជ្ជមាន

- ប្រើការស្ដាប់សកម្ម អំពីហេតុផលនានារបស់កូន ឬកុមារ រួមទាំងពន្យល់ ឬផ្ដល់ជាយោបល់ទូន្មាន។
- គោរព ឱ្យតម្លៃ ជឿជាក់ និងទទួលស្គាល់មតិយោបល់ ទស្សនៈ និងអារម្មណ៍របស់កូន ឬកុមារ។
- យល់ពីដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។
- ស្វែងយល់ពីហេតុផលសម្រាប់អាកប្បកិរិយា ឬពាក្យសម្ដីរបស់កូន ឬកុមារ ដែលយើងគិតថា □មិនត្រឹមត្រូវ□ ឬ □មិនល្អ□ ។ល។
- ប្រាប់ ឬពន្យល់ហេតុផលទៅកូន ឬកុមារអំពីអ្វីដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមិនចូលចិត្ត និងអ្វីដែលអាចទទួលយកបាន ឬអ្វីដែលអាចធ្វើជំនួស។

## II. ស្វែងយល់ពីបញ្ហា និងស្ថានភាពលំបាកៗរបស់កុមារ

### ១. ករណីសិក្សា (ក)៖ កុមារនៅចន្លោះអាយុ ១៣ ដល់ក្រោម ១៨ឆ្នាំ

នៅក្នុងដំណាក់កាលនេះ ក្មេងជំទង់កំពុងតែស្វែងយល់អំពីខ្លួនឯងថា តើពួកគេជានរណា? ហើយពួកគេចង់ក្លាយជាអ្វី។ ពួកគេក៏កំពុងតែស្វែងរកនូវអត្តសញ្ញាណពិសេសផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ សូមអ្នកធ្វើការស្រមៃថា៖

**ក.** កូនរបស់អ្នកតែងតែរៀបចំខ្លួន និងស្លៀកពាក់ទៅតាមរបៀបដែលអ្នកបានអនុញ្ញាតឱ្យ។ មានថ្ងៃមួយអ្នកបានឃើញកូនអ្នកលាប និងឆ្កឹះសក់ពណ៌ក្រហម ពាក់អាវយឺតដែលមានសរសេរពាក្យគ្រោតគ្រាតនៅផ្នែកខាងក្រោយខ្នង និងស្លៀកខោខូវប៊យរឹបរាង រួមទាំងដាច់ដុំៗបែបស៊ិចស៊ី។ អ្នកមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង និងមានសេចក្ដីខ្មាសអៀនចំពោះការស្លៀកពាក់របស់ពួកគេ។ អ្នកចង់ឱ្យគេប្ដូរខោអាវ និងកក់សក់ចេញឱ្យបានឆាប់។

*តើអ្វីខ្លះដែលបណ្ដាលឱ្យកូនអ្នកមានអាកប្បកិរិយារបៀបនេះ?*

### ២. ករណីសិក្សា (ខ)៖ កុមារនៅចន្លោះអាយុ ១៣ ដល់ក្រោម ១៨ឆ្នាំ

**ខ.** ច្បាប់ទម្លាប់មួយ នៅក្នុងគ្រួសាររបស់អ្នកគឺ សមាជិកក្នុងគ្រួសារទាំងអស់ត្រូវតែត្រឡប់មកផ្ទះវិញមិនឱ្យហួសពីម៉ោង១០យប់។ឥឡូវនេះម៉ោង១០កន្លះហើយ កូនស្រីជំទង់អាយុ១៧ ឆ្នាំរបស់អ្នកនៅតែមិនទាន់វិលមកផ្ទះវិញនៅឡើយ ទង្វើបែបនេះនាងតែងធ្វើជាញឹកញាប់។ អ្នកកំពុងមានការព្រួយបារម្ភយ៉ាងខ្លាំងពីព្រោះអ្នកដឹងដំណឹងតាមមិត្តភក្តិនាងប្រាប់ថានាងទៅជប់លៀងដោយជិះម៉ូតូជាមួយមិត្តភក្តិដែលមិនទាន់ចេះបើកបរស្ទាត់នៅឡើយ ហើយអ្នកក៏ដឹងផងដែរថា ក្នុងកម្មវិធីនេះមានក្មេងជំទង់ជាច្រើននាក់ទៀតក៏បានទៅចូលរួមក្នុងពិធីនោះដែរ ហើយអ្នកក៏មិនដែលស្គាល់ពួកគេទៀត។ អ្នកបានគិតថាក្នុងពិធីនេះប្រហែលជាមានការផឹកគ្រឿងស្រវឹងទៀតផង។ អ្នកមានការភ័យខ្លាច និងព្រួយបារម្ភយ៉ាងខ្លាំង ស្ទើរតែផ្ទុះកំហឹង ស្រាប់តែភ្លាមនេះ នាងក៏មកដល់ផ្ទះល្មម។

*តើអ្វីខ្លះដែលបណ្ដាលឱ្យកូនអ្នកមានអាកប្បកិរិយារបៀបនេះ?*

## III. ដោះស្រាយបញ្ហា ចំពោះករណីសិក្សា

### ១. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា (ក)៖ កុមារនៅចន្លោះអាយុ ១៣ ដល់ក្រោម ១៨ឆ្នាំ

- គឺជាកម្លាំងដ៏មានឥទ្ធិពលក្នុងការបង្ហាញអំពីបុគ្គលភាពរបស់ខ្លួន

- តម្រូវការក្នុងការបែងចែកខ្លួនគាត់ឱ្យដាច់ពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដើម្បីស្វែងយល់ថាខ្លួនគាត់ជានរណា ?
- ភាពសំខាន់ចំពោះគាត់គឺត្រូវតែធ្វើឱ្យដូចមនុស្សក្នុងក្រុមដែលមានអាយុដូចគ្នាជាជាង ធ្វើតាមតម្រូវការរបស់អ្នកជាឪពុកម្តាយ
- តម្រូវការក្នុងការមានអារម្មណ៍ថា ខ្លួនមានភាពជាម្ចាស់ការជាជាងការត្រួតត្រារបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ
- ចំណង់ខ្លាំងក្នុងការបង្ហាញអំពីរសជាតិ ជំនឿ និងចំណង់ចំណូលចិត្តរបស់ខ្លួន
- តម្រូវការកំណត់នូវអត្តសញ្ញាណរបស់ខ្លួនដូចជា តើខ្លួនឯងជានរណា ? ធ្វើការតុបតែងខ្លួនឱ្យទៅតាមក្រុម ឬមនុស្សដែលខ្លួនចូលចិត្ត ស្រឡាញ់ និងចង់សាកល្បងភាពទាន់សម័យនិយម ទំនើប ឬអ្វីដែលអស្ចារ្យ លេចធ្លោក្នុងចំណោមក្រុមរបស់ពួកគេ។

## ២. ហេតុផលអាកប្បកិរិយា សម្រាប់ករណីសិក្សា ( ខ )៖ កុមារនៅចន្លោះអាយុ ១៣ ដល់ក្រោម ១៨ឆ្នាំ

- មានជំនឿថាគ្មានអ្វីនឹងធ្វើឱ្យនាងមានគ្រោះថ្នាក់ឡើយ
- មានការពិបាកក្នុងការយល់អំពីអារម្មណ៍របស់អ្នកដែលតែងតែបារម្ភពីនាង ពិសេសចំពោះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ
- តម្រូវការភាពជាម្ចាស់ការ និងគ្រប់គ្រងលើការសម្រេចចិត្តរបស់ខ្លួន
- កង្វះខាតការជឿជាក់ខ្លួនឯង និងមិនមានលទ្ធភាពនិយាយថា □ទេ□ ទៅកាន់មនុស្សវ័យក្មេងដូចគ្នា
- តម្រូវការក្នុងការបង្ហាញខ្លួនឯង ទៅកាន់មនុស្សវ័យក្មេងឯទៀត
- នាងមានកង្វះខាតក្នុងការយល់ដឹងពីភាពម្ចាស់ការ និងត្រូវការជួយពីអ្នកដទៃ
- ចង់បង្ហាញឱ្យឃើញថា នាងគឺជាមនុស្សដែលមានភាពម្ចាស់ការម្នាក់
- នាងខ្វះជំនាញក្នុងការពន្យល់ហេតុផលពីតម្រូវការ ទស្សនៈ និងគុណតម្លៃរបស់ខ្លួន។

### សកម្មភាព និងរបៀបគាំទ្រសម្រាប់ករណីសិក្សា ( ក ) និង ( ខ )

- គោរព ឱ្យតម្លៃ និងផ្តល់ឱកាសដល់ពួកគេគ្រប់ពេល
- ជ្រើសរើសពេលដែលសមស្របដើម្បីជួបជជែកពិភាក្សាជាមួយកូន និងស្តាប់ហេតុផលរបស់ពួកគេ
- ប្រាប់អំពីកង្វល់ និងក្តីបារម្ភរបស់យើង ព្រមទាំងអ្នកពាក់ព័ន្ធដែលមានចំពោះពួកគាត់ រួមទាំងជួយឱ្យគាត់ចេះផ្តល់ដំណឹងពេលទៅណាមកណា នៅឯណា ឬរវល់ធ្វើអ្វីមួយ ។ល។
- ប្រើការស្តាប់ដោយយកចិត្តទុកដាក់ និងយល់ចិត្ត តាមរយៈការយល់អំពីការគិត និងអារម្មណ៍របស់កូន

- ណែនាំ និងជួយពួកគេឱ្យនិយាយអំពីផលប្រយោជន៍ និងផលប៉ះពាល់បណ្តាលមកពីការប្រើគ្រឿងស្រវឹង និងការសេពគប់មិត្ត ព្រមទាំងជួយឱ្យពួកគេគិតពីបញ្ហាគ្រោះថ្នាក់ចរាចរ និងសុវត្ថិភាពនៅជុំវិញខ្លួនគ្រប់ពេលទាំងអស់
- លើកទឹកចិត្តឱ្យកូនសុំជំនួយពីនរណាម្នាក់ដែលពួកគេទុកចិត្ត នៅពេលដែលពួកគេជួបបញ្ហា ព្រមទាំងផ្តល់ឱកាសឱ្យពួកគេធ្វើអ្វីមួយប្រកបដោយភាពម្ចាស់ការ
- ជួយឱ្យកូននិយាយពីតម្រូវការរបស់ខ្លួន និងបង្ហាញពីអារម្មណ៍នានាដែលខ្លួនមាន
- អត់ធ្មត់ និងផ្តល់ភាពកក់ក្តៅតាមរយៈពាក្យសម្តី អាកប្បកិរិយា ការយកចិត្តទុកដាក់ និងគាំទ្រដល់ពួកគេគ្រប់ពេល
- ទទួលស្គាល់ថាកូនមានការប្រែប្រួលអ័រម៉ូន (ផ្នែកជីវសាស្ត្រ) នៅក្នុងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍ ដែលធ្វើឱ្យគេមានចរិតលក្ខណៈ និងអាកប្បកិរិយាបែបនេះ។

## ខ្លឹមសារបន្ថែម

អ្នកសម្របសម្រួលត្រូវបញ្ចូលខ្លឹមសារស្តីពី **ពិការភាព** និង **ភាពខុសគ្នាក្នុងការចិញ្ចឹមកូនស្រី និងកូនប្រុស** ផងដែរ។ អ្នកសម្របសម្រួលគួរសួរបំផុសខ្លះៗអំពីកុមារដែលមានពិការភាព។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគួរផ្តល់ការថែទាំជាពិសេសដើម្បីការពារកុមារដែលមានពិការភាព ពីការរំលោភបំពានគ្រប់ប្រភេទ។ កុមារទាំងនោះនឹងទទួលបានគ្រប់យ៉ាងដូចកុមារទូទៅដែរដូចជា ចុះបញ្ជីកំណើត សៀវភៅគ្រួសារ និងចុះឈ្មោះចូលរៀន។ ពួកគេនឹងទទួលបានការគាំទ្រឱ្យបានចូលរៀននៅសាលាមត្តេយ្យ យ៉ាងហោចណាស់មួយឆ្នាំមុនចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ហើយនៅបន្តការគាំទ្រ និងលើកទឹកចិត្តពួកគាត់ឱ្យបន្តរៀនរហូតបញ្ចប់អនុវិទ្យាល័យ វិទ្យាល័យ ឬមហាវិទ្យាល័យដូចកុមារទូទៅដែរ។ ពួកគេក៏អាចចូលរួមសកម្មភាពកីឡា សិល្បៈ សិក្ខាសាលា និងសកម្មភាពនានានៅក្នុងសង្គមផងដែរ។

ប្រភេទនៃពិការភាពរបស់កុមារអាចកើតឡើងផ្សេងៗគ្នា។ ប្រភេទពិការភាពខ្លះអាចកើតមានមុនកំណើត (ក្នុងពេលមានផ្ទៃពោះ) កំឡុងពេលកើត (សម្រាល) ហើយខ្លះទៀតអាចកើតមានក្រោយពីកំណើត។ កុមារមួយចំនួនអាចកើតមកមានពិការភាពតែមួយប្រភេទ តែកុមារមួយចំនួនទៀត អាចមានច្រើនជាងមួយប្រភេទ។ ខាងក្រោមនេះជាប្រភេទពិការភាពផ្សេងៗគ្នាដែលអាចកើតមានលើកុមារមួយចំនួន៖

- **ថ្លង់ ឬខ្សោយការស្តាប់៖** កុមារអាចមានអវៈយវៈ និងសតិបញ្ញាល្អ តែអ្វីដែលជាផលវិបាកសម្រាប់ពួកគាត់គឺ ខ្សោយការស្តាប់ (មិនអាចស្តាប់បាន ឬស្តាប់បានមិនល្អ)។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់ពីប្រភេទពិការភាពនេះនៅពេលដែលកុមារមានអាយុក្រោមបីឆ្នាំដូចជា កូន ឬកុមារមិនងាកមើល មិនភ្ញាក់នៅពេលហៅឈ្មោះ ឬមានសំឡេងខ្លាំងៗ។ ការជួយអន្តរាគមន៍

ទាន់ពេលវេលាដល់កូន ឬកុមារដែលថ្លង់ ឬខ្សោយការស្តាប់នោះអាចឱ្យពួកគាត់មានឱកាសរៀនភាសាបានល្អដូចកុមារដទៃទៀតដែរ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ទទួលបានការជួយគាំទ្រដើម្បីឱ្យពួកគាត់មានកម្លាំង និងទឹកចិត្តបន្តជួយកូន ឬកុមាររបស់គាត់ដែលមានពិការភាពនេះ ដោយជួយជំរុញ ឬធ្វើសកម្មភាពលេងជាមួយពួកគេដូចជា និយាយភាសាកាយវិការ លេងជាមួយកូនដោយប្រើសម្ភារៈមានសំឡេង។ សកម្មភាពទាំងនេះនឹងជួយឱ្យកូន ឬកុមារមានការអភិវឌ្ឍការប្រាស្រ័យទាក់ទង មានភាពកក់ក្តៅ និងមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនានានៅក្នុងសង្គម។ បច្ចុប្បន្នមានសាលាពិសេសសម្រាប់ជួយកុមារដែលមានពិការភាពបែបនេះដូចជា អង្គការគ្រួសារថ្មី អង្គការម៉ារីណុល និងអង្គការ All Ears Cambodia ជាដើម។

- **ខ្សោយសតិបញ្ញា៖** គឺកើតមានតាមកម្រិត។ កុមារមួយចំនួនមានបញ្ហាខ្សោយសតិបញ្ញាប្រភេទស្រាល។ ពួកគាត់អាចទៅរៀនបានយ៉ាងហោចណាស់ បានចប់បឋមសិក្សា ហើយពួកគេក៏អាចមើលថែខ្លួនឯងបានដូចជា ការស្លៀកពាក់ ងូតទឹកគេង និងហូបចុកជាដើម។ មានកុមារមួយចំនួនទៀត មានបញ្ហាខ្សោយសតិបញ្ញាប្រភេទធ្ងន់ធ្ងរ។ ពួកគេមិនអាចមើលថែទាំខ្លួនឯងបាន មិនចេះនិយាយ ហើយត្រូវការអ្នកជួយមើលថែទាំជាពិសេសដូចជា ការបន្ទោរបង់ ការបញ្ចុកអាហារ ការស្លៀកពាក់ និងការរស់នៅប្រចាំថ្ងៃជាដើម។ កុមារទាំងនេះក៏ត្រូវការ ការការពារជាពិសេសថែមទៀតពីការមិនអើពើ ឬការរំលោភបំពានផ្សេងៗ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។
- **ខ្សោយកាយសម្បទា ឬរាងកាយ៖** កុមារមួយចំនួនទៀត មានសតិបញ្ញាធម្មតា ឬស្ទើរតែធម្មតា តែពួកគេមានបញ្ហាក្នុងការធ្វើចលនា ឬបន្លាស់ទី។ ពួកគេអាចដើរបានដោយមានការជួយ ឬឧបករណ៍ជំនួយដូចជា ឈើច្រត់ ឬរទេះរុញ។ល។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចស្វែងរកសេវាការថែទាំកុមារប្រភេទនេះ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន ឬទៅទទួលសេវាមជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ដែលមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល មជ្ឈមណ្ឌលស្តារនីតិសម្បទាបន្ទាយព្រាប ឬនៅគៀនឃ្លាំងក្នុងរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលស្តារនីតិសម្បទានៅតាមខេត្ត។
- **ពិការភ្នែក ឬខ្សោយគំហើញ៖** មានតាមកម្រិតនៃពិការភាព ហើយកុមារទាំងនេះអាចមានសតិបញ្ញាធម្មតាដូចកុមារដទៃទៀតដែរ។ កុមារខ្លះអាចមើលឃើញដោយលំបាក ហើយកុមារមួយចំនួនទៀតមិនអាចមើលឃើញទាំងស្រុងទេ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចកត់សម្គាល់កូន ឬកុមារ ដែលមានបញ្ហាភ្នែកតាំងពីតូចតាមរយៈសកម្មភាពទារកដូចជា មិនសូវមានចលនា មិនងើបក មិនឈោងចាប់

របស់របរលេង មិនលូន ឬវារ ទារកលេងកម្សាន្តតិចតួច នៅតែម្នាក់ឯងច្រើន ឬមិនសូវបានចូលរួមសកម្មភាពសង្គមពេលគេមានវ័យធំឡើង។ ដូចនេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអាចជួយកូន ឬកុមារតាំងពីពួកគេនៅជាទារក ដោយការលេង និយាយ និងចូលរួមសកម្មភាពប្រចាំថ្ងៃ ឬនៅក្នុងសង្គម។ ពួកគេក៏ត្រូវការថែទាំ និងការគាំទ្រ ពីសេវាសង្គមកិច្ចដែលមាននៅមូលដ្ឋាន និងមជ្ឈមណ្ឌលស្តារនីតិសម្បទានានា។

| ភាពខុសគ្នារវាងកុមារា និងកុមារី | |
|---|---|
| **កុមារា** | **កុមារី** |
| • រាងកាយមានភាពរហ័សរហួន និងសកម្ម<br>• មានជំនាញវិភាគ ក្នុងលំហ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយនឹងការធ្វើឱ្យអ្វីៗផ្លាស់ទី<br>• រៀនតាមរយៈ ការមើល<br>• តក់ក្រហល់ក្នុងការធ្វើអ្វីមួយ<br>• បែងចែកការងារច្បាស់ ដោយផ្តោតអារម្មណ៍ម្តងមួយៗ<br>• ត្រូវការពេលវេលាដើម្បីផ្ចង់អារម្មណ៍ក្នុងការធ្វើអ្វីមួយ<br>• រុករក ឬស្វែងយល់ និងចង់ដឹងពី អ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តបង្ហាញសកម្មភាពជាងនិយាយពីអារម្មណ៍របស់គេ | • រាងកាយមានភាពទន់ភ្លន់<br>• មិនសូវមានជំនាញវិភាគ<br>• មានចំណាប់អារម្មណ៍ខ្លាំងជាមួយពណ៌<br>• រៀនតាមរយៈ ការស្តាប់<br>• គិតច្បាស់លាស់មុននឹងធ្វើអ្វីមួយ<br>• មិនមានការបែងចែកច្បាស់ អាចធ្វើការច្រើនមុខក្នុងពេលតែមួយ<br>• អាចធ្វើបានភ្លាមៗ<br>• ស្តាប់ ដើម្បីដឹងពីអ្វីៗដែលនៅជុំវិញខ្លួន<br>• ចូលចិត្តនិយាយ ដើម្បីបង្ហាញពីអារម្មណ៍របស់ខ្លួន |

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួម ចែករំលែកការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុមដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់ និងឆ្លុះបញ្ចាំងពីការអនុវត្ត | (២៥នាទី) | ▪ អ្នកសម្របសម្រួលរំឭកពីអ្វីដែលបានរៀន ឬពិភាក្សាពីជំនួបមុនដោយ<br>☞ តើលោកអ្នករៀនបានអ្វីខ្លះពីវគ្គមុន?<br>☞ តើលោកអ្នកបានចែករំលែកខ្លឹមសារអ្វីខ្លះដែលបានពិភាក្សាកាលពីជំនួបលើកមុន ជាមួយសមាជិកគ្រួសារ និងកូនៗ?<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម បន្ទាប់មកស្នើសុំឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្ត<br>☞ តើលោកអ្នកជួបភាពងាយស្រួល ឬផលលំបាកអ្វីខ្លះ នៅពេលដែលលោកអ្នកយកមេរៀននេះទៅអនុវត្តនៅក្នុងគ្រួសារ?<br>▪ អ្នកសម្របសម្រួលកត់ត្រានូវការលំបាកដែលអ្នកចូលរួមលើកឡើង និងស្នើសុំឱ្យក្រុមជំផ្តល់ និងពិភាក្សាដើម្បីស្វែងរករបៀបដែលអាចជួយដល់ការលំបាកទាំងនោះ រួចអ្នកសម្របសម្រួលបន្ថែមនូវចំណុចខ្វះខាត។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៤ | ការកសាងក្រុម | ល្បែង ចាមពល ក្ដាមគ្រោង (១០នាទី) | ▪ ប្រាប់អ្នកចូលរួមថា មុននឹងបន្តទៅមេរៀនថ្មីយើងនឹងលេងល្បែងមួយហៅថា ល្បែងក្ដាមគ្រោង របៀបលេងមានដូចខាងក្រោម៖<br>☞ សុំឱ្យអ្នកចូលរួមអង្គុយជារង្វង់ និងប្រាប់ពួកគេថាល្បែងនេះស្រដៀងនឹងវគ្គមុនដែរ។<br>☞ ឱ្យអ្នកចូលរួមអង្គុយពេនភ្នែន ឬបត់ជើងក៏បាន ហើយយកដៃឆ្វេងផ្ងារបាតដៃដាក់លើចុងភ្លៅខាងឆ្វេងរបស់ខ្លួន និងយកចង្អុលដៃស្ដាំដាក់ចំកណ្ដាលបាតដៃឆ្វេងអ្នកនៅខាងស្ដាំដៃខ្លួន។<br>☞ ប្រាប់ពួកគេបន្តថា លោកអ្នកទាំងអស់គ្នានឹងស្រែកបន្ទរនូវរសជាតិដូចជា (ផ្អែម ជូរ ប្រៃ...) នៅពេលដែលលោកអ្នកឮឈ្មោះផ្លែឈើ ឬគ្រឿងទេសផ្សេងៗដូចជា (ស្ពៃ ក្រូចឆ្មា អំបិល...) លោកអ្នកស្ដាប់ និងស្រែកបន្ទរហូតដល់ឮពាក្យថាក្ដាមគ្រោង ពេលនោះសុំឱ្យលោកអ្នកប្រញាប់ដកដៃស្ដាំចេញពីបាតដៃអ្នកដែលនៅក្បែរ រីឯដៃខាងឆ្វេងប្រញាប់ក្ដោបដើម្បីចាប់ចង្អុលដៃអ្នកដែលនៅក្បែរម្ខាងទៀតដែរ។ ពេលដែលពួកគាត់យល់ពីដំណើរការលេងល្បែងនេះ ហើយ អ្នកសម្របសម្រួលចាប់ផ្ដើមហៅ ឈ្មោះផ្លែឈើ ឬគ្រឿងទេសជាច្រើនប្រភេទ (មិនយឺត ឬមិនលឿនពេក) និងពាក្យចុងក្រោយថាក្ដាមគ្រោង។ បន្ទាប់មកអាចផ្លាស់ប្ដូរអ្នកហៅឈ្មោះផ្លែឈើ ឬគ្រឿងទេសក៏បានប្រសិនបើមានអ្នកស្ម័គ្រចិត្ត បន្តធ្វើដូចនេះចំនួន៥ទៅ៦ដង។<br>▪ ឥឡូវនេះលោកអ្នកបានស្វាងអារម្មណ៍ហើយ អញ្ចឹងយើងនឹងពិភាក្សាលើប្រធានបទថ្មីមួយទៀតគឺ □ការដោះស្រាយបញ្ហា□ ជាមួយកូនជំទង់បន្តទៀត ។ |
| ៥ | មេរៀនថ្មី៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន (៥) | ឆ្លុះបញ្ចាំង អំពីរបៀប និងបទពិសោធន៍នៃការដោះស្រាយបញ្ហាជាមួយកូនវ័យជំទង់របស់អ្នកចូលរួម (២០នាទី) | ▪ សូមប្រាប់អ្នកចូលរួមថា យើងបានធ្វើដំណើរឆ្លងកាត់ធាតុផ្សំនានានៃការចិញ្ចឹមកូនបែបវិជ្ជមាន ឥឡូវនេះយើងមកដល់ធាតុផ្សំទី៤ដែលជាធាតុផ្សំចុងក្រោយគឺ □ការដោះស្រាយបញ្ហា□ ហើយយើងក៏បានពិភាក្សាគ្នាពីការដោះស្រាយបញ្ហាជាមួយកូន ឬកុមារដែលមានវ័យមុនជំទង់កាលពីជំនួបមុនម្ដងរួចមកហើយ ដោយផ្ដោតសំខាន់លើអាកប្បកិរិយាលំបាកៗរបស់កូន ដូច្នេះពេលនេះយើងនឹងលើកធាតុផ្សំនេះដដែល ប៉ុន្តែយើងនឹងពិភាក្សាអំពីកូន ឬកុមារក្នុងវ័យជំទង់ដែលមានអាយុចន្លោះ ១៣ឆ្នាំ ដល់ក្រោម ១៨ឆ្នាំបន្តទៀត។ អ្នកសម្របសម្រួល នាំអ្នកចូលរួមឱ្យភ្ជាប់ជាមួយនឹងប្រធានបទនេះ ដោយរំឭកឡើងវិញខ្លះៗអំពី៖ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
| --- | --- | --- | --- |
| | | | ☞ តើការដោះស្រាយបញ្ហាជាមួយកូន មានន័យដូចម្ដេច?<br>🗣 ចម្លើយរំពឹងទុកៈ ប្រាប់ពីអ្វីដែលគួរធ្វើ ឬមិនគួរធ្វើ បង្ខំឱ្យធ្វើតាម ហាមមិនឱ្យធ្វើ បង្ខំ ឬវាយ។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយរបស់អ្នកចូលរួម និងបន្ថែមខ្លឹមសារ រួចសួរបន្ត<br>☞ តើបញ្ហាអ្វីខ្លះដែលតែងតែកើតមានឡើងរវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ?<br>🗣 ចម្លើយរំពឹងទុកៈ ប្រើពាក្យសម្ដីមិនសមរម្យ ស្ដីបន្ទោស ជេរប្រមាថ វាយដំ។ល។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចសួរបន្ត<br>☞ នៅពេលមានបញ្ហាកើតឡើង តើលោកអ្នកបានធ្វើអ្វីខ្លះជាមួយកូន ក្នុងការដោះស្រាយបញ្ហាទាំងនោះ?<br>🗣 ចម្លើយរំពឹងទុកៈ និយាយខ្លាំងៗ ស្ដីបន្ទោស ប្រាប់ពីដំណោះស្រាយ ប្រាប់កូនឱ្យឈប់ប្រព្រឹត្តទៀត ។ល។<br>▪ អ្នកសម្របសម្រួលសរុបចម្លើយរបស់អ្នកចូលរួម និងបន្ថែមខ្លឹមសារ។ ប្រសិនបើរបៀបដោះស្រាយបញ្ហាដែលពួកគាត់លើកឡើង បែបហិង្សា ឬបែបអវិជ្ជមាន អ្នកសម្របសម្រួលត្រូវតែលើកយកចំណុចនោះមកពិភាក្សា ដើម្បីជួយឱ្យពួកគាត់មើលឃើញពីចំណុចល្អ ឬមិនល្អ ឬផលប៉ះពាល់នៃដំណោះស្រាយនោះទៅលើកូន ឬកុមារ ដូចជា (ប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្ត) ឬក៏ផ្អែកទំនាក់ទំនងជាដើម។ល។ លើសពីនេះទៅទៀត កូន ឬកុមារគ្រប់រូបត្រូវការ និងពេញចិត្តទទួលយកនូវរបៀបដោះស្រាយបញ្ហាពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបដោយភាពអហិង្សា ភាពកក់ក្ដៅ និងការយល់ចិត្ត។ ដូច្នេះដើម្បីជួយឱ្យកុមារទទួលបាននូវតម្រូវការរបស់ពួកគេបាន ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបត្រូវតែយកចិត្តទុកដាក់ និងស្វែងរកសេវាគាំទ្រផ្សេងៗ សម្រាប់ពួកគេ។<br>▪ អ្នកសម្របសម្រួលសរុបគំនិតអ្នកចូលរួម រួចសួរបន្ត<br>☞ តើសម្រាប់កុមារពិការ លោកអ្នកប្រើរបៀបដោះស្រាយបញ្ហានេះដូចម្ដេចដែរ?<br>🗣 ចម្លើយរំពឹងទុកៈ ទុកចោល និយាយរកហេតុផលក៏ស្ដាប់គ្នាមិនបាន មិនសូវខ្វល់ព្រោះគិតថាពួកគេមិនដឹងអី។ល។<br>▪ អ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមបានឆ្លើយ និងចូលរួមគ្រប់ៗគ្នា។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួលសង្ខេបថាកុមារា កុមារី និងកុមារដែលមានពិការភាព ពេញចិត្តទទួលយកនូវរបៀបដោះស្រាយបញ្ហាពីអ្នកថែទាំគ្រប់រូបដោយភាពអហិង្សា ភាពកក់ក្ដៅ និងការយល់ចិត្តដូចៗគ្នា។ ដើម្បីជួបនឹងតម្រូវការពិសេសនេះបាន គឺទាមទារឱ្យមានការគាំទ្រពីឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំរបស់គេ។ ដូច្នេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូបត្រូវតែយកចិត្តទុកដាក់ និងស្វែងរកសេវាគាំទ្រផ្សេងៗ ដើម្បីបំពេញតម្រូវការពិសេសទាំងនោះរបស់កូន ឬកុមារពិការ។<br><br>**កំណត់សម្គាល់៖** អ្នកសម្របសម្រួលសូមធ្វើការពន្យល់ថា<br>▪ ការដោះស្រាយបញ្ហា ជាពិសេសអាកប្បកិរិយាលំបាកៗជាមួយកូន ឬកុមារតាមរយៈការប្រើអំណាចជាមនុស្សពេញវ័យ ប្រើហិង្សា មិនមែនជាវិធីដែលគាំទ្រ និងជួយឱ្យកូនផ្លាស់ប្ដូរអាកប្បកិរិយា ឬបំពេញតម្រូវការដែលគេត្រូវការនោះទេ។ ផ្ទុយទៅវិញពួកគេនឹងទទួលបាននូវភាពភ័យខ្លាច ឈឺចាប់ រងរបួស បាត់បង់ទំនាក់ទំនងជាមួយគ្រួសារ ខ្វះទំនុកចិត្ត និងបាត់បង់ភាពក្លាហាន ។ល។ បទពិសោធន៍ និងផលប៉ះពាល់ទាំងនេះបានធ្វើឱ្យកូន ឬកុមារខ្លះចាកចេញពីផ្ទះ និងគ្រួសារស្របពេលជាមួយមជ្ឈដ្ឋានជុំវិញខ្លួន មានសភាពអាប់អួរ។ ទាំងនេះសុទ្ធតែជាឱកាស និងអំណោយផលដល់ជនខិលខូចទាក់ទាញពួកគេបានយ៉ាងមានប្រសិទ្ធភាពពិសេសជំរុញឱ្យពួកគេធ្វើសកម្មភាពទំនាស់នឹងច្បាប់។<br>▪ លើសពីនេះទៅទៀត នៅពេលដែលមានបញ្ហាកើតឡើង ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំខ្លះបានបង្ខំចិត្តបំបែកកូនចេញពីគ្រួសារ តាមរយៈការបញ្ជូនទៅរស់នៅជាមួយសាច់ញាតិ ឬរស់នៅក្នុងមណ្ឌល គ្រួសារផ្សេងចិញ្ចឹម ខណៈពួកគេគិតថាគ្រួសារកំពុងខ្វះសមត្ថភាព ឬលទ្ធភាពក្នុងការអប់រំណែនាំ និងការចិញ្ចឹមបីបាច់។ គួររំឭកថា ទង្វើទាំងនេះ មិនបានជួយឱ្យកូន ឬកុមារបានទទួល ឬបំពេញនូវតម្រូវការរបស់ពួកគេដូចដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំបានគិតនោះទេ តែវាធ្វើឱ្យកូន ឬកុមាររងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងដោយសារពួកគេបាត់បង់នូវភាពកក់ក្ដៅ និងក្ដីស្រឡាញ់ពីក្រុមគ្រួសារផ្ទាល់របស់ពួកគេ។ លើសពីនេះទៀតកូន ឬកុមារក៏អាចរងនូវការរំលោភបំពានផ្សេងៗដូចជា ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងការមិនអើពើពីអ្នកថែទាំក្នុងមណ្ឌលមួយចំនួនផងដែរ។ ឪពុកម្ដាយ អាណាព្យាលបាល ឬអ្នកថែទាំមិនត្រូវបានលើកទឹកចិត្តឱ្យមានការបំបែកកូន ឬកុមារចេញពីគ្រួសារឡើយ ព្រោះវាមិនមែនជាជម្រើសទីមួយ នៃការសម្រេចចិត្តយកកុមារដាក់ក្នុងមណ្ឌលនោះទេ។ មណ្ឌលគឺជាជម្រើសចុងក្រោយបង្អស់។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **ធាតុផ្សំទី៤៖ ដោះស្រាយបញ្ហា (អាយុ ១៣ឆ្នាំ រហូតដល់ ១៨ឆ្នាំ)**<br>**ស្វែងយល់ពីបញ្ហា និងស្ថានភាពលំបាកៗរបស់កូនជំទង់តាមរយៈករណីសិក្សា (២៥នាទី)** | ▪ ឥឡូវនេះយើងនឹងរៀនពីស្ថានភាពពិបាកៗ មួយចំនួនដែលកើតឡើងចំពោះកូន ឬកុមារតាមដំណាក់កាលនានា។ យើងនឹងប្រើអ្វីដែលយើងបានរៀនអំពីការអភិវឌ្ឍរបស់កុមារ ដើម្បីគិតពីអ្វីខ្លះដែលអាចនឹងបណ្តាលឱ្យកូនៗយើងមាននូវអាកប្បកិរិយាលំបាកៗបែបនេះ។ ការអនុវត្តនេះនឹងជួយឱ្យអ្នកចូលរួមអភិវឌ្ឍការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ។<br>▪ អ្នកសម្របសម្រួលបន្តថា យើងនឹងអនុវត្តលើករណីសិក្សា ឬសម្តែងតួ អំពីកូន ឬកុមារនៅតាមដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា ដើម្បីស្វែងយល់ពីតម្រូវការ របៀបនៃការបំពេញតម្រូវការ ការគ្រប់គ្រងអារម្មណ៍ និងការគ្រប់គ្រងស្ថានភាពពិបាកៗរបស់កូន ឬកុមារវ័យជំទង់។ យើងនឹងធ្វើការងារជាក្រុមតូចៗ ដើម្បីពិនិត្យមើល និងស្វែងយល់ពីដំណើរការនៃការលូតលាស់ និងអភិវឌ្ឍ រួមទាំងមូលហេតុនានា ដែលនាំឱ្យកូន ឬកុមារវ័យជំទង់មានអាកប្បកិរិយាលំបាកទាំងនោះ។<br>▪ ចែកអ្នកចូលរួមជា៤ក្រុម និងសុំឱ្យពួកគាត់គិតថា ពេលនេះពួកគាត់កំពុងថែទាំកូនដោយស្រម៉ៃទៅតាមករណីសិក្សាដែលបានចែកជូន ហើយក៏សុំឱ្យពួកគាត់ប្រើប្រាស់ចំណេះដឹងកាលពីវគ្គមុនៗ ស្តីពីការអភិវឌ្ឍកុមារ ធាតុផ្សំមួយចំនួនដែលបានរៀនរួចហើយ ដើម្បីអនុវត្តការដោះស្រាយបញ្ហានេះមានរយៈពេល ១០នាទី ដោយកត់ត្រាលើក្រដាសរ៉ាមធំ (A3)។ បន្ទាប់មកឱ្យក្រុមមានឱកាសចែករំលែកហេតុផលទាំងនោះ (រហូតដល់ពួកគាត់អស់ហេតុផល)។<br>• ចែកករណីសិក្សា ទៅឱ្យក្រុមនីមួយៗ<br>ក្រុមទី១ និងទី២៖ ករណីសិក្សា ក<br>ក្រុមទី៣ និងទី៤៖ ករណីសិក្សា ខ<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រា ពេលក្រុមនីមួយៗធ្វើបទបង្ហាញរួចសរុបខ្លឹមសារ បន្ទាប់ពីក្រុមទាំង ៤ បានបង្ហាញចប់ ដើម្បីជួយឱ្យអ្នកចូលរួមយល់ច្បាស់ថាមានហេតុផលអ្វីដែលធ្វើឱ្យកូន ឬកុមារមានអាកប្បកិរិយាលំបាកៗបែបហ្នឹង ដោយឆ្លុះបញ្ចាំងទៅនឹងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ រួមទាំងបន្ថែមខ្លឹមសារ និងពន្យល់អំពីសកម្មភាព និងរបៀបគាំទ្រនានាដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំយកទៅអនុវត្តជាមួយកូន ដូចមាននៅក្នុងខ្លឹមសារមេរៀន។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | **សម្តែងតួដោះស្រាយញ្ហាជាមួយកូនជំទង់** (២០នាទី) | ▪ អ្នកសម្របសម្រួលជ្រើសរើសក្រុមស្ម័គ្រចិត្ត ឬចាត់តាំងក្រុមណាមួយឱ្យសម្តែងតួពីករណីសិក្សាមួយណាក៏បាន។ សុំឱ្យសមាជិកក្នុងក្រុមនោះដើរតួជាឪពុក ឬម្តាយ និងកូនជំទង់ ដោយអនុវត្តការដោះស្រាយបញ្ហា រួមទាំងប្រើធាតុផ្សំទាំងអស់ជាមួយកូនដែលមានអាកប្បកិរិយាលំបាកដូចក្នុងករណីសិក្សានោះ ហើយក៏សុំឱ្យអ្នកចូលរួមផ្សេងទៀតសង្កេត និងកត់ត្រា។ ក្រោយការសម្តែងតួចប់ អ្នកសម្របសម្រួលសួរសំណួរ<br>☞ តើពួកគាត់បានកត់សំគាល់ឃើញអ្វីខ្លះអម្បាញ់មិញ ដោយធ្វើការឆ្លុះបញ្ចាំងទៅនឹងធាតុផ្សំទាំង៤ ដែលបានរៀន និងចងចាំ?<br>▪ អ្នកសម្របសម្រួលប្រមូលគំនិតទាំងអស់ និងរួមទាំងជួយឱ្យពួកគេយល់ច្បាស់ពីសកម្មភាពណាដែលបង្ហាញថា គោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់ យល់ពីការគិត និងអារម្មណ៍ និងការដោះស្រាយបញ្ហា។<br>**គួរចងចាំ**<br>អ្នកសម្របសម្រួលត្រូវសម្រេចចិត្តថា ក្រុមណាដែលមានសមត្ថភាពក្នុងការសម្តែងតួរួមទាំងអាច អនុវត្តនូវការដោះស្រាយបញ្ហានេះដោយប្រើធាតុផ្សំទាំងអស់រួមបញ្ចូលគ្នា ដើម្បីជាគំរូក្នុងការដោះស្រាយបញ្ហាជាមួយកូនជំទង់។ |
| | | **សង្ខេបមេរៀន រយៈពេល** (១០នាទី) | ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីការដោះស្រាយបញ្ហាជាមួយកូនវ័យជំទង់ (អាយុ១៣ ទៅ១៨ឆ្នាំ) ដោយមើលទៅលើមូលហេតុដែលកូន ឬកុមារសម្តែងនូវអាកប្បកិរិយា(លំបាកៗ) ដែលគេមាន រួមទាំងអនុវត្តនូវការដោះស្រាយបញ្ហា ដោយប្រើធាតុផ្សំទាំងអស់រួមបញ្ចូលគ្នា។ មកដល់ធាតុផ្សំចុងបញ្ចប់នេះ បើយើងគិត និងឆ្លើយដោយស្មោះត្រង់អំពីខ្លួនឯងថា នៅមុនពេលរៀន និងក្រោយពេលរៀន តើមាន□ប្រតិកម្ម□ខុសគ្នាដូចម្តេចខ្លះទេ? ចំពោះឥរិយាបថរបស់កូន ឬកុមារ ដូចក្នុងករណីសិក្សាអម្បាញ់មិញនេះ។<br>ការយល់ដឹងអំពីការលូតលាស់ និងអភិវឌ្ឍរបស់កុមារមានន័យថា យើងអាចព្យាយាមយល់ពីអ្វីដែលកំពុងកើតឡើងចំពោះកូន ឬកុមារនៅគ្រប់ដំណាក់កាលផ្សេងៗគ្នា ហើយការយល់ដឹងនេះជួយយើងឱ្យដោះស្រាយបញ្ហាដែលយើងជួបប្រទះនៅក្នុងការគ្រប់គ្រងអាកប្បកិរិយាលំបាកៗរបស់កូន ឬកុមារបាន។ ទោះបីជាយើងយល់ដឹងអំពីធាតុផ្សំនីមួយៗច្បាស់ហើយក៏ដោយ ដើម្បីឱ្យការចិញ្ចឹម និងថែទាំរបស់យើងមានប្រសិទ្ធភាពទៅបាន យើងត្រូវតែដាក់ធាតុផ្សំទាំង៤នេះរួមបញ្ចូលគ្នា សូមសួរអ្នកចូលរួមថា មានសំណួរដែរឬទេ? បើមានសូមឆ្លើយ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ចែកផ្ទាំងរូបភាពស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាន ដល់អ្នកចូលរួម។ បើមានពេលអ្នកសម្របសម្រួលអានរំឭក នូវខ្លឹមសារនៃធាតុផ្សំទាំង ៤នេះផង។<br>▪ សូមសួរអ្នកចូលរួមថា មានសំណួរទៀតដែរឬទេ ? |
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន**<br>**( ១០នាទី )** | ▪ អ្នកសម្របសម្រួលសួរ៖<br>☞ តើលោកអ្នកយល់ថាប្រធានបទនេះមានប្រយោជន៍អ្វីខ្លះចំពោះលោកអ្នក ?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍យ៉ាងដូចម្ដេចដែរ ទៅលើទង្វើរបស់យើងកន្លងមក ?<br>☞ តើត្រូវយកទៅអនុវត្តយ៉ាងដូចម្ដេចនៅក្នុងគ្រួសាររបស់លោកអ្នក ? |
| | | **កិច្ចការផ្ទះ**<br>**( ១០នាទី )** | ▪ លើកទឹកចិត្តឱ្យអ្នកចូលរួម ចាប់ផ្ដើមធ្វើការកត់សម្គាល់ ពីអាកប្បកិរិយារបស់ខ្លួនឯង និង<br>▪ ធ្វើឱ្យប្រសើរឡើងនូវការដោះស្រាយបញ្ហា និងគ្រប់គ្រងអាកប្បកិរិយាលំបាកៗរបស់កូន ជាមួយនឹងការអនុវត្តនូវធាតុផ្សំនៃការចិញ្ចឹមកូនបែបវិជ្ជមានទៅនឹងដំណាក់កាលនៃការលូតលាស់ និងអភិវឌ្ឍកុមារ។<br>▪ ចុងបញ្ចប់សូមថ្លែងអំណរគុណដល់ពួកគាត់ដែលបានមកចូលរួម។ |

# វគ្គទី១២
# ជំនួបចុងក្រោយ

## សេចក្តីផ្តើម

ដូចលោកអ្នកដឹងហើយថា ថ្ងៃនេះគឺវគ្គចុងក្រោយនៃការពិភាក្សា និងឆ្លុះបញ្ចាំងអំពី ការចិញ្ចឹមកូនបែបវិជ្ជមានរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ មកដល់ពេលនេះការពិភាក្សាគឺបានឈានមកដល់វគ្គទី១២ ដែលមានការចូលរួមពីសំណាក់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទាំងអស់ដោយការពេញចិត្ត និងរីករាយក្នុងការពិភាក្សាពីប្រធានបទនានាដែលសុទ្ធតែជាប្រធានបទទាក់ទងទៅនឹងការចិញ្ចឹមកូន ឬកុមារ រួមទាំងកុមារដែលមានពិការភាពផងដែរ។ ដូច្នេះនៅក្នុងវគ្គនេះនឹងជួយដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំបានធ្វើការរំឭក និងឆ្លុះបញ្ចាំងឡើងវិញពីអ្វីដែលបានរៀន ក៏ដូចជាការបញ្ជាក់ឡើងវិញនូវចំណុចផ្សេងៗ ដែលអ្នកចូលរួមមានចម្ងល់ រួមទាំងការពិភាក្សា និងចែករំលែកបទពិសោធន៍នានាពីភាពងាយស្រួល ឬការលំបាកក្នុងការអនុវត្តពីរបៀបនៃការចិញ្ចឹមកូនបែបវិជ្ជមានដែលបានចូលរួម និងពិភាក្សាទាំង១១ជំនួបកន្លងមក។

| | |
|---|---|
| **គោលបំណង** | **នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងអាចៈ**<br>• ឆ្លុះបញ្ចាំង និងរំឭកឡើងវិញនូវមេរៀនទាំងអស់ ដែលបានពិភាក្សាកន្លងមក និងពង្រឹងបន្ថែមនូវចំណុចដែលខ្វះខាត។<br>• ចែករំលែក និងទទួលយកបទពិសោធន៍អំពីការផ្លាស់ប្តូរ និងស្វែងរកដំណោះស្រាយពីការលំបាករបស់ខ្លួនឯងផ្ទាល់ និងសមាជិកផ្សេងទៀតជាមួយក្រុមឪពុកម្តាយ។<br>• ស្ទាបស្ទង់ចំណេះដឹងរបស់អ្នកចូលរួម ក្រោយវគ្គបណ្តុះបណ្តាលបានបញ្ចប់។ |
| **រយៈពេល** | **១៥០ នាទី** |

**សម្ភារៈ ដែលត្រូវការ**

- ស្កុត ហ្វឺត កន្ត្រៃ
- ក្រដាសផ្ទាំងធំ
- កម្រាលសម្រាប់អ្នកចូលរួមអង្គុយ
- ត្រៀមសម្ភារៈសម្រាប់លេងជាមួយកុមារ
- ដំឡូងក្តៅ (បាល់ក្រដាសរៀបចំជាស្រេច ដែលរុំជុំវិញជាមួយនឹងកម្រងសំណួរមួយស្រទាប់ៗ និងបទចម្រៀង)
- ក្រដាសផ្ទាំងធំកត់ត្រាអំពីវិន័យ ដែលក្រុមបានចងក្រងកាលពីជំនួបមុន (វគ្គដំបូង)
- លំហាត់សាកល្បងក្រោយវគ្គបណ្តុះបណ្តាល
- លំហាត់សាកល្បងមុនវគ្គបណ្តុះបណ្តាល (ឯកសារថតចម្លង)

**ខ្លឹមសារលម្អិត**

## ១. សំណួរសម្រាប់ឆ្លុះបញ្ចាំង និងរំឭកមេរៀន

### សំណួរសម្រាប់ដំឡូងក្តៅ

- សូមនិយាយរឿងកំប្លែងមួយ ហើយបងប្អូនចាំចាក់ចង្កេះខ្លួនឯងផង
- រាំបទ បុណ្យភូមិ ទាំងអស់គ្នា
- តើការរំលោភបំពាន មានផលប៉ះពាល់អ្វីខ្លះចំពោះកុមារ?
- តាមអ្វីដែលលោកអ្នកបានរៀន តើអ្នកបានធ្វើអ្វីខ្លះដើម្បីការពារកូន ពីការរំលោភបំពានផ្សេងៗ?
- តើភាពតានតឹងចិត្ត អាចបណ្តាលមកពីកត្តាអ្វីខ្លះ?
- ចាប់ពីពេលលោកអ្នកបានរៀនជាមួយក្រុមឪពុកម្តាយ នៅពេលដែលលោកអ្នកមានអារម្មណ៍តានតឹងចិត្ត តើលោកអ្នកបានធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយភាពតានតឹងនោះ?
- សូមចាប់ដៃគូម្នាក់ រួចរាំជាមួយគ្នា។ (អ្នកសម្របសម្រួលត្រៀមបទចម្រៀង)
- តើលោកអ្នកបានធ្វើអ្វីខ្លះ ដើម្បីឱ្យទំនាក់ទំនងក្នុងគ្រួសារមានលក្ខណៈល្អប្រសើរជាងមុន?
- ដូចដែលលោកអ្នកបានរៀនអំពីកាតព្វកិច្ចរបស់ឪពុកម្តាយ តើកាតព្វកិច្ចណាខ្លះដែលលោកអ្នកបានអនុវត្តជាមួយកូន ឬកុមារនៅក្នុងគ្រួសាររបស់លោកអ្នក?
- សូមឱ្យអ្នកនៅឆ្វេងដៃដើរបង្ហាញម៉ូដ
- តើលោកអ្នកបានធ្វើអ្វីខ្លះ ក្នុងការជួយគាំទ្រកូន ឬកុមារដើម្បីឱ្យពួកគេអាចបំពេញភារកិច្ចរបស់គេបាន?
- តើភារកិច្ចណាខ្លះ ដែលកូន ឬកុមារបានអនុវត្តកន្លងមក?
- តើរបៀបនៃការចិញ្ចឹមកូនមានអ្វីខ្លះ?
- តើការចិញ្ចឹមកូនបែបវិជ្ជមាន មានន័យដូចម្តេច?
- ចូររៀបរាប់ អំពីគោលការណ៍ទាំង៥ នៃការចិញ្ចឹមកូនបែបវិជ្ជមាន?
- សូមញញឹមរកស្នេហ៍ ដាក់អ្នកទាំងអស់គ្នា។ (បញ្ជាក់៖ ញញឹមអត់ឱ្យចេញធ្មេញទេ)

- ចូររៀបរាប់អំពីធាតុផ្សំទាំង៤ នៃការចិញ្ចឹមកូនបែបវិជ្ជមាន?
- តើការកំណត់គោលដៅយូរអង្វែង មានន័យដូចម្ដេច? (ចូរលើកឧទាហរណ៍បញ្ជាក់)
- តើការផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់មានន័យដូចម្ដេច? (សុំឱ្យអ្នកនៅស្ដាំដៃលើកឧទាហរណ៍បញ្ជាក់)
- តើការយល់អំពីការគិត និងអារម្មណ៍មានន័យដូចម្ដេច? (ចូរលើកឧទាហរណ៍បញ្ជាក់)
- តើការដោះស្រាយបញ្ហា សំដៅទៅលើអ្វី? (ចូរលើកឧទាហរណ៍បញ្ជាក់)
- រាំកម្សាន្តទាំងអស់គ្នា១បទ

## ២. សេចក្ដីសង្ខេបមេរៀនធំៗ ទាំង៦

### ខ្លឹមសារសង្ខេប ដែលឆ្លើយតបទៅនឹង គោលបំណងមេរៀន ដែលបានបង្ហាញនៅជំនួបដំបូង

**មេរៀនទី ១៖ ការការពារកុមារ**

ដើម្បីការពារកុមារ សំខាន់យើងត្រូវស្វែងយល់ពីការរំលោភបំពានផ្សេងៗដែលអាចប៉ះពាល់ដល់កុមារ។ ការរំលោភបំពានចែកជាបួនប្រភេទខុសៗគ្នាគឺ ការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពានផ្លូវភេទ និងការមិនអើពើ។ គ្រប់ប្រភេទនៃការរំលោភបំពានទាំងអស់សុទ្ធតែមានផលប៉ះពាល់ដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ ការការពារកុមារមិនមែនផ្ដោតតែលើកុមារដែលមានកាយសម្បទា និងសតិបញ្ញាល្អនោះទេ ហើយក៏ផ្ដោតសំខាន់លើកុមារដែលខ្សោយកាយសម្បទា និងសតិបញ្ញាផងដែរ ព្រោះពួកគេត្រូវការការការពារជាពិសេសដើម្បីទទួលបានការលូតលាស់ និងអភិវឌ្ឍដូចជាកុមារទូទៅដែរ។ ចំណែកកុមារដែលអាចរងការរំលោភបំពានមិនមែនមានតែកុមារីនោះទេ កុមារាក៏ប្រឈមខ្លាំងពីការរំលោភបំពានផងដែរ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ។

**មេរៀនទី ២៖ សុខុមាលភាពឪពុកម្ដាយ**

ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីសុខុមាលភាពរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ហើយយើងបានដឹងពីមូលហេតុដែលធ្វើឱ្យយើងមានភាពតានតឹងចិត្ត ផលប៉ះពាល់ និងវិធីដែលជួយកាត់បន្ថយភាពតានតឹងចិត្តសម្រាប់ដោះស្រាយនៅក្នុងគ្រួសារ។ បើសិនជាយើងមិនបានបន្ធូរភាពតានតឹងចិត្តឱ្យបានត្រឹមត្រូវ នោះវានឹងអាចមានឥទ្ធិពលដល់ការចិញ្ចឹមកូន និងទំនាក់ទំនងក្នុងគ្រួសារ។ ម្យ៉ាងវិញទៀត យើងក៏បាន

ពិភាក្សាដែរអំពីរបៀបដែលអាចកត់សម្គាល់ថា កូន ឬកុមារមានភាពតានតឹងចិត្ត និងជួយឱ្យគាត់ចេះដោះស្រាយភាពតានតឹងចិត្ត ព្រមទាំងធ្វើឱ្យពួកគេកាន់តែមានទំនុកចិត្តលើខ្លួនឯងថែមទៀត។ ដូច្នេះ ដើម្បីជៀសវាងពីផលប៉ះពាល់អវិជ្ជមានចំពោះការចិញ្ចឹមកូនចាំបាច់ឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំ ត្រូវដឹងពីវិធីដែលធ្វើឱ្យមានសុខុមាលភាពល្អ គឺត្រូវមានរបៀបកាត់បន្ថយភាពតានតឹងនោះតាមបែបវិជ្ជមាន។

---

**មេរៀនទី ៣៖ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ**

ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីការប្រាស្រ័យទាក់ទងក្នុងគ្រួសារដែលមានសារៈសំខាន់ណាស់ក្នុងការផ្តល់ និងទទួលព័ត៌មានផ្សេងៗពីសមាជិកនៅក្នុងគ្រួសារ ជាពិសេសជាមួយកូន ឬកុមាររួមទាំងកុមារដែលមានពិការភាព។ ដើម្បីងាយស្រួលក្នុងការទទួលព័ត៌មានពីគ្នា យើងត្រូវគិតពីរបៀបក្នុងការស្ដាប់ដោយយល់ចិត្ត និងសង្កេតដើម្បីជួយសម្រួលដល់ការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាព។បើទោះជាមានសមាជិកក្នុងគ្រួសារណាដែលមានពិការភាព យើងត្រូវស្វែងរកពីរបៀបផ្សេងៗ ដើម្បីឱ្យការប្រាស្រ័យទាក់ទងគ្នាកាន់តែមានភាពជិតស្និទ្ធ។ យើងក៏បានដឹងដែរថា ដើម្បីឱ្យកូន និងកុមាររៀនបានពីការប្រាស្រ័យទាក់ទង ដោយមានប្រសិទ្ធភាព យើងដែលជាឪពុកម្ដាយអាណាព្យាបាល ឬអ្នកថែទាំត្រូវស្ដាប់កូនដោយយកចិត្តទុកដាក់ ហើយក៏ត្រូវធ្វើជាគំរូល្អដល់កូនៗ ឬកុមារផងដែរ។

---

**មេរៀនទី ៤៖ កាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កូន**

ថ្ងៃនេះយើងបានពិភាក្សាគ្នាអំពីកាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កូន ឬកុមារ។ ដូចអ្វីដែលលោកអ្នកបានលើកឡើង និងការបង្ហាញរបស់អ្នកសម្របសម្រួល ហើយមានកាតព្វកិច្ចច្រើនណាស់ ដែលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវបំពេញក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារ និងទាមទារឱ្យមានការជួយគាំទ្រគ្នាទៅវិញទៅមករវាងអ្នកពាក់ព័ន្ធ។ ម្យ៉ាងទៀតយើងក៏អាចជ្រើសរើសនូវទម្លាប់នៃការចិញ្ចឹមកូន ដែលជួយដល់ការសម្រេចបាននូវគោលដៅរយៈពេលវែងដោយមិនមានការរំពឹងការតបស្នងពីកូន ឬកុមារឱ្យមើលថែ ឬចិញ្ចឹមឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំវិញឡើយ។ ចំណែកកូន ឬកុមារក៏មានភារកិច្ចដែលត្រូវធ្វើដើម្បីជួយដល់គ្រួសារ និងអភិវឌ្ឍខ្លួន។ ចំពោះកុមារដែលមានពិការភាពក៏មានភារកិច្ចផងដែរ ហើយភារកិច្ចទាំងនោះគឺ

អាស្រ័យទៅតាមលទ្ធភាព សមត្ថភាព និងប្រភេទនៃពិការភាពរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថា ភារកិច្ចទាំងអស់នោះ មិនមានប៉ះពាល់ដល់សិទ្ធិ ការលូតលាស់ និងអភិវឌ្ឍរបស់កូន ឬកុមារឡើយ។

## មេរៀនទី ៥៖ របៀបនៃការចិញ្ចឹមកូន

- កំណត់បាន និងឆ្លុះបញ្ចាំងអំពីរបៀបនានានៃការចិញ្ចឹមកូនដែលពួកគាត់ទទួលបានពីមនុស្សជំនាន់មុន រួមទាំងបានយកមកអនុវត្តបន្តជាមួយកូន ឬកុមារផ្ទាល់ដូចជាការចិញ្ចឹមកូនបែប
  - ត្រជាក់ (មាត់តូច ឬការផ្តល់សិទ្ធិ)
  - ក្តៅ (មាត់ធំ ឬផ្តាច់ការ)
  - សេរី ឬទំនើង
  - មិនអើពើ
- ទទួលស្គាល់ថាការដាក់ទណ្ឌកម្មដល់កូន ឬកុមារវាបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់កូន ឬកុមារ។ ទណ្ឌកម្មមិនមែនគ្រាន់តែជាអំពើហិង្សាលើរាងកាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាអំពើហិង្សាខាងផ្លូវចិត្ត ឬការមិនអើពើផងដែរ។ ឧទាហរណ៍ដូចជា ការបន្ទុះបង្អាប់ ការទុកចោលឱ្យនៅដោយទៃ្បក ការធ្វេសប្រហែស និងការបង្អត់អាហារដល់កុមារជាដើម។ល។
- កំណត់បានពីរបៀបនានាក្នុងការអនុវត្តនៃការដាក់វិន័យបែបវិជ្ជមានដល់កូន ឬកុមារ ដើម្បីផ្លាស់ប្តូរនូវអាកប្បកិរិយាលំបាកៗមួយចំនួន ដែលរបៀបទាំងអស់នេះមិនបង្កឱ្យមានផលប៉ះពាល់ដល់កូនទាំងផ្លូវកាយ ផ្លូវចិត្ត ការមិនអើពើ រួមទាំងការលូតលាស់ និងអភិវឌ្ឍផងដែរ។ ឧទាហរណ៍ ពួកគេអាចមើលទូរទស្សន៍បាន ប្រសិនបើពួកគេធ្វើលំហាត់ កិច្ចការផ្ទះចប់ពួកគេអាចទៅផ្សារជាមួយបានប្រសិនបើពួកគេមិនទាមទារ ឬអុកឡុកចង់បានរបស់អ្វីមួយ ញុំាអាហារឱ្យអស់ទើបគេអាចរត់លេងបាន។ល។

## មេរៀនទី ៦៖ ការប្រៀនប្រដៅកូនបែបវិជ្ជមាន

- កំណត់បានអំពីនិយមន័យនៃការចិញ្ចឹមកូនបែបវិជ្ជមាន ជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដែលផ្តោតទៅលើគោលការណ៍សំខាន់ៗចំនួន៥ (ភាពអហិង្សា ផ្តោតទៅលើការរកដំណោះស្រាយ ការគោរព ផ្អែកលើដំណាក់កាលលូតលាស់ និងការអភិវឌ្ឍកុមារ និងផ្អែកលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ) និងធាតុផ្សំចំនួន៤គឺ គោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់ យល់អំពីការគិត និងអារម្មណ៍ និងដោះស្រាយបញ្ហា។
- កំណត់ និងជ្រើសរើសនូវវិធីសាស្ត្រក្នុងការអនុវត្តពីរបៀបនៃការចិញ្ចឹមកូនបែបវិជ្ជមាន ដើម្បីធ្វើការដោះស្រាយបញ្ហាដោយផ្អែកលើគោលការណ៍សំខាន់ៗចំនួន៥ និងប្រើប្រាស់ធាតុផ្សំទាំង៤ ឱ្យស្របទៅនឹងដំណាក់កាលផ្សេងៗគ្នា នៃការលូតលាស់ និងការអភិវឌ្ឍកុមារតាមកម្រិតអាយុរបស់ពួកគេដូចជា
    - ចន្លោះអាយុពី ០ឆ្នាំ រហូតដល់អាយុក្រោម ៣ឆ្នាំ
    - ចន្លោះអាយុពី ៣ឆ្នាំ រហូតដល់អាយុ ៥ឆ្នាំ
    - ចន្លោះអាយុពី ៦ឆ្នាំ រហូតដល់អាយុ ១២ឆ្នាំ
    - ចន្លោះអាយុពី ១៣ឆ្នាំ រហូតដល់អាយុក្រោម ១៨ឆ្នាំ
- ទទួលស្គាល់ថាការអនុវត្តនូវគោលការណ៍សំខាន់ៗចំនួន ៥ និងធាតុផ្សំចំនួន៤នៃការចិញ្ចឹមកូនបែបវិជ្ជមាន វាជួយបង្កើតឱ្យមានភាពស្និទ្ធស្នាល ទំនាក់ទំនងល្អ ការជួយគាំទ្រគ្នា ការនឹករឭក និងការយល់អធ្យាស្រ័យ... រវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូន ឬកុមារ ពិសេសកុមារដែលមានពិការភាព។ កត្តាទាំងនេះ ហើយដែលជួយឱ្យគ្រួសារទាំងអស់ទទួលបាននូវភាពសុខដុមរមនា ដែលបញ្ចៀសនូវការបំបែកកូន ឬកុមារចេញពីគ្រួសារផងដែរ។

# លំហាត់សាកល្បងក្រោយវគ្គ
# សម្រាប់ក្រុមឪពុកម្តាយ (Post-Test)
# (បំពេញក្នុងវគ្គចុងក្រោយ)

## លេខសម្គាល់៖..............................

កាលបរិច្ឆេទ ៖ ថ្ងៃទី............ខែ............ឆ្នាំ............

ទីកន្លែង ៖ ភូមិ....................ឃុំ....................

ស្រុក......................ខេត្ត...................................

## គោលការណ៍ណែនាំ

បន្ទាប់ពីយើងបានជួបគ្នាចំនួន១១ជំនួបកន្លងមក យើងនឹងធ្វើលំហាត់មួយ ហើយលំហាត់នេះគឺគ្រាន់តែចង់ដឹងថា តើលោកអ្នកមានចំណេះដឹង ឬបទពិសោធន៍អ្វីខ្លះ ដែលទទួលបានបន្ថែមពីការបណ្តុះបណ្តាល និងការអនុវត្តជាក់ស្តែង សម្រាប់ជួយលោកអ្នកក្នុងការចិញ្ចឹមបីបាច់កូន ឱ្យមានការលូតលាស់ និងអភិវឌ្ឍបានល្អ។ ចម្លើយរបស់លោកអ្នកនឹងត្រូវរក្សាការសម្ងាត់ សូមលោកអ្នកធ្វើការបំពេញតាមបទពិសោធន៍រស់នៅប្រចាំថ្ងៃរបស់លោកអ្នក។

សម្គាល់៖សូមគូសសញ្ញា ( □ ) នៅក្នុងប្រអប់ចម្លើយណាមួយដែលលោកអ្នកយល់ថាត្រឹមត្រូវ។

**១- តើឪពុកម្តាយត្រូវធ្វើអ្វីខ្លះសម្រាប់កូន ឬ កុមារ ?**

- ☐ ចុះសំបុត្រកំណើត និងបញ្ជូនកូនទៅរៀន
- ☐ ផ្តល់អាហារដែលមានជីវជាតិគ្រប់គ្រាន់
- ☐ វាយ ដើម្បីប្រៀនប្រដៅចំពោះកូនដែលមិនស្តាប់បង្គាប់
- ☐ ផ្តល់ភាពកក់ក្តៅ ក្តីស្រឡាញ់ និងធ្វើជាគំរូល្អ

**២- តើកូន ឬកុមារមានភារកិច្ចធ្វើអ្វីខ្លះនៅក្នុងគ្រួសារ ?**

- ☐ ជួយធ្វើការងារផ្ទះ និងខិតខំរៀនសូត្រ
- ☐ លេង និងធ្វើសកម្មភាពតាមអ្វីដែលខ្លួនចង់ធ្វើ
- ☐ ប្រាប់ឪពុកម្តាយពេលមានទុក្ខកង្វល់
- ☐ ស្តាប់ និងធ្វើតាមដំបូន្មានល្អៗ ពីឪពុកម្តាយដើម្បីការពារខ្លួន

**៣- ធ្វើយ៉ាងណាទើបដឹងថា មនុស្សម្នាក់កំពុងស្តាប់ដោយយកចិត្តទុកដាក់ ?**

- ☐ មើលមុខ ងក់ក្បាល បន្ទរពាក្យ សួរបញ្ជាក់
- ☐ សួរសំណួរត្រូវតាមសាច់រឿង
- ☐ សង្ខេបសាច់រឿងបាន
- ☐ ធ្វើការបណ្តើរ ស្តាប់បណ្តើរ

## ៤- តើការប្រាស្រ័យទាក់ទងក្នុងគ្រួសារ មានសារៈសំខាន់អ្វីខ្លះ ?

- ☐ ស្តាប់បង្គាប់ និងធ្វើតាម ទោះបីមិនពេញចិត្តក៏ដោយ
- ☐ ទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក
- ☐ អាចស្វែងរកដំណោះស្រាយតាមតម្រូវការ
- ☐ ការពារកូនពីការរំលោភបំពានផ្សេងៗ ការពារខ្លួន

## ៥- តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថាជា ការរំលោភបំពានលើកុមារ ?

- ☐ វាយកូន ដើម្បីឱ្យកូនស្តាប់ដំបូន្មាន
- ☐ ប៉ះពាល់ប្រដាប់ភេទកុមារ ពេលលាងសម្អាត
- ☐ ចាប់បង្ខំ ឬរំលោភផ្លូវភេទកុមារ
- ☐ ទុកកុមារតូច ឱ្យនៅផ្ទះតែម្នាក់ឯង

## ៦- តើការរំលោភបំពានកុមារ មានផលប៉ះពាល់អ្វីខ្លះ ?

- ☐ ចេះប្រុងប្រយ័ត្ន និងមានការអត់ធ្មត់
- ☐ ភ័យខ្លាច និងយល់សប្តអាក្រក់
- ☐ រាងកាយលូតលាស់មិនបានល្អ និងអាចពិការភាព
- ☐ រៀនមិនចេះ និងមិនចូលសាលា

**៧- តើឪពុកម្តាយគួរធ្វើអ្វីខ្លះ ដើម្បីការពារកូនពីការរំលោភបំពាន?**

- ☐ ណែនាំពីរបៀបការពារខ្លួន និងប្រាប់ពីល្បិចឆបោករបស់ជនខិលខូច
- ☐ ស្តាប់កូន ឬកុមារឱ្យបានច្រើន
- ☐ ចាក់សោរកូនក្នុងផ្ទះ ជាជាងយកទៅផ្ញើសាច់ញាតិ
- ☐ ទុកវត្ថុអាចបង្កគ្រោះថ្នាក់ ឱ្យផុតពីដៃកូន

**៨- នៅពេលដែលលោកអ្នកមានអារម្មណ៍មិនសប្បាយចិត្ត ឬតានតឹងចិត្ត តើលោកអ្នកធ្លាប់បានធ្វើអ្វីខ្លះ?**

- ☐ ដកដង្ហើមឱ្យវែងៗ ឬដើរចេញ
- ☐ ដាំដំណាំ ឬធ្វើការងារផ្ទះផ្សេងៗ
- ☐ ជជែកលេងជាមួយអ្នកដទៃ
- ☐ ផឹកស្រា ឬជក់បារី

**៩- នៅពេលដែលកូន ឬកុមារ មានអាកប្បកិរិយាមិនល្អ តើលោកអ្នកធ្លាប់បានធ្វើអ្វីខ្លះ?**

- ☐ សម្លុត និងវាយកូន
- ☐ សួរ និងស្តាប់ពីហេតុផល
- ☐ ពិភាក្សាជាមួយកូន ដើម្បីរកដំណោះស្រាយ
- ☐ នាំកូនធ្វើសកម្មភាពផ្សេងៗ ដើម្បីបន្ធូរអារម្មណ៍

**១០- តើសកម្មភាពអ្វីខ្លះដែលបង្ហាញថា ជាការផ្ដល់ភាពកក់ក្ដៅដល់កូន ?**

- [ ] វាយ ហើយលួងលោមតាមក្រោយ
- [ ] នៅក្បែរកូន នៅពេលដែលកូនត្រូវការ
- [ ] ស្ដាប់កូននិយាយ ដោយយកចិត្តទុកដាក់
- [ ] ចំណាយពេលលេងជាមួយកូន

**១១- តើការផ្ដល់ភាពកក់ក្ដៅមានសារៈសំខាន់អ្វីខ្លះ ?**

- [ ] បង្កើនភាពស្និទ្ធស្នាលរវាងឪពុកម្ដាយនិងកូន
- [ ] កាត់បន្ថយជម្លោះ ឬអំពើហិង្សាក្នុងគ្រួសារ
- [ ] កូនមានទំនុកចិត្តក្នុងការប្រាប់រឿងកង្វល់របស់ខ្លួន
- [ ] ឪពុកម្ដាយមានអាទិភាព ក្នុងការសម្រេចចិត្តធ្វើអ្វីមួយ

**១២- ពេលកូន ឬកុមារឈានចូលវ័យជំទង់ តើពួកគេមានការប្រែប្រួលអ្វីខ្លះ ?**

- [ ] កុមារី (មានរដូវ ដើមទ្រូង និងត្រគៀករីកធំ) កុមារា (ប្ដូរសម្លេង មានទឹកកាម ស្មារីកធំ)
- [ ] អារម្មណ៍ឆេវឆាវ និងមិនសូវស្ដាប់បង្គាប់
- [ ] ចាប់អារម្មណ៍ជាមួយមិត្តភក្ដិ ច្រើនជាងគ្រួសារ
- [ ] ចូលចិត្តធ្វើការងារផ្ទះ

# ដំណើរការសម្រាប់សម្របសម្រួលមេរៀន

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ១ | ការស្វាគមន៍ | (១០នាទី) | ▪ ជាកិច្ចចាប់ផ្តើមអ្នកសម្របសម្រួលសំណេះសំណាលហើយអាចៈ<br>☞ សួរអំពីសុខទុក្ខ ការធ្វើដំណើរ ឬការរស់នៅរបស់អ្នកចូលរួម<br>☞ លើកទឹកចិត្តឱ្យអ្នកចូលរួម ចែករំលែកការរស់នៅរបស់ពួកគាត់<br>☞ ថ្លែងអំណរគុណដល់អ្នកចូលរួមដែលបានចែករំលែក និងបន្តសកម្មភាពបន្ទាប់។ |
| ២ | រំឭកគោលការណ៍ក្រុម | (៥នាទី) | ▪ អ្នកសម្របសម្រួល ជួយរំឭកពីគោលការណ៍ក្រុមដែលបានបង្កើតរួមគ្នា កាលពីជំនួបដំបូងដោយសួរៈ<br>☞ តើគោលការណ៍ក្រុមរបស់យើងបានកំណត់យ៉ាងដូចម្តេចខ្លះ?<br>▪ បើសិនជាសមាជិកក្រុមមិនបានចាំ អ្នកសម្របសម្រួលអាចរំឭក ឬបង្ហាញទៅលើក្រដាសផ្ទាំងធំ (គោលការណ៍ក្រុម) ដែលបានសរសេរចំណុចដែលពួកគាត់បានព្រមព្រៀងកាលពីវគ្គដំបូង។<br>**កំណត់សម្គាល់ៈ** អ្នកសម្របសម្រួលដាក់ ឬព្យួរគោលការណ៍ក្រុម ដែលអ្នកចូលរួមអាចមើលឃើញ ហើយធ្វើការរំឭកខ្លះៗដូចជា សួរទៅពួកគាត់ជាមួយនឹងការបង្ហាញទៅផ្ទាំងគោលការណ៍នោះ។ |
| ៣ | រំឭកមេរៀនចាស់<br>មេរៀនទី១ ដល់ ទី៦ | **ល្បែង<br>ជំឡុងក្តៅ<br>(៤៥នាទី)** | ▪ អ្នកសម្របសម្រួលត្រូវរៀបចំជំឡុងក្តៅ និងត្រៀមបទចម្រៀងឱ្យបានរួចរាល់ បន្ទាប់មកស្នើឱ្យអ្នកចូលរួមឈរជារង្វង់ ហើយណែនាំពីសកម្មភាព និងរបៀបលេង។<br>• ពន្យល់ថា នេះគឺជាជំឡុងក្តៅ ដែលយើងមិនអាចទុកនៅនឹងដៃ ឬកាន់យូរបានទេ ព្រោះវាធ្វើឱ្យយើងរលាក ដូចនេះនៅពេលដែលយើងទទួលបានជំឡុងក្តៅនេះហើយ អ្នកត្រូវបញ្ជូនជំឡុងនេះទៅឱ្យអ្នកបន្ទាប់ដែលឈរនៅខាងស្តាំជាប់នឹងអ្នក។<br>• ក្នុងអំឡុងពេលបញ្ជូនជំឡុងក្តៅពីម្នាក់ទៅម្នាក់ នឹងមានអមដោយបទភ្លេងដ៏ពិរោះៗ លុះនៅពេលដែលបទភ្លេងឈប់ អ្នកមិនត្រូវបញ្ជូនជំឡុងក្តៅបន្តទៀតទេ គឺអ្នកត្រូវធ្វើការបកសម្បកជំឡុងនោះមួយស្រទាប់ (ម្តងៗបកបានតែមួយស្រទាប់ទេ) បន្ទាប់មកអានន្ទូវការណែនាំដែលមាននៅក្នុងសម្បកជំឡុងនោះ។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកដែលបកសម្បកដំឡូងក្ដៅនេះហើយ ត្រូវឆ្លើយ ឬធ្វើតាមការណែនាំដែលមាននៅលើសម្បកដំឡូងនោះ នឹងបន្ទាប់មកភ្លេងចាប់ផ្ដើម អ្នកត្រូវហុចដំឡូងក្ដៅនោះបន្តទៀត។ សូមធ្វើរបៀបនេះដដែលៗ រហូតដល់អស់សម្បកដំឡូង។<br>**សម្គាល់៖**<br>១) ម្នាក់ៗ អាចមានឱកាសបកសម្បកដំឡូងលើសពីម្ដង<br>២) អ្នកចាក់បទភ្លេងត្រូវស្មោះត្រង់ (មិនបញ្ឈប់ភ្លេងសម្រាប់តែនរណាម្នាក់ៗឡើយ)<br>▪ អ្នកសម្របសម្រួលចាប់ផ្ដើមសកម្មភាព ដោយមានជំនួយការចាក់ភ្លេង អ្នកចូលរួមចាប់ផ្ដើមបញ្ជូនដំឡូងក្ដៅបន្តបន្ទាប់គ្នា។<br>▪ ជំនួយការត្រូវបញ្ឈប់បទភ្លេង រីឯអ្នកសម្របសម្រួលជួយអ្នកដែលមានដំឡូងក្នុងដៃបកសម្បក និងអានសារដែលមាននៅក្នុងសម្បកដំឡូងនោះ<br>▪ ស្នើឱ្យអ្នកដែលបានបកដំឡូង (អ្នកចូលរួម) ឆ្លើយតបតាមសារដែលបានប្រាប់ក្នុងសម្បកដំឡូងនោះ (ឆ្លើយសំណួរ ឬធ្វើសកម្មភាពតាមសារដែលបានប្រាប់ រីឯអ្នកសម្របសម្រួលត្រូវបំពេញបន្ថែមលើចម្លើយដែលខ្វះខាត ទៅតាមខ្លឹមសារមេរៀនគ្រប់សំណួរទាំងអស់)<br>▪ បន្តសកម្មភាពនេះរហូតដល់អស់ ឬតាមពេលវេលាមាន |
| ៤ | <u>ការឆ្លុះបញ្ចាំងអំពីភាពជោគជ័យ និងការលំបាករបស់ឪពុកម្ដាយ</u> | (៤០នាទី) | ▪ អ្នកសម្របសម្រួលថ្លែងអំណរគុណដល់អ្នលចូលរួមដែលបានចែករំលែកនូវការចងចាំពីអ្វីដែលបានរៀនកន្លងមក។ ជាបន្ទាប់អ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមធ្វើការពិភាក្សាជាមួយដៃគូអំពីអ្វីដែលពួកគេបានអនុវត្តនូវវិធីសាស្ត្រនៃការចិញ្ចឹមកូនបែបវិជ្ជមានដោយប្រើសំណួរខាងក្រោម៖<br>☞ តើមានការប្រែប្រួលអ្វីខ្លះសម្រាប់ខ្លួនលោកអ្នកផ្ទាល់ និងក្នុងគ្រួសាររបស់លោកអ្នក?<br>☞ តើមានឧបសគ្គអ្វីខ្លះដែលបានកើតឡើងចំពោះលោកអ្នក និងគ្រួសារ?<br>☞ តើលោកអ្នកបានដោះស្រាយយ៉ាងដូចម្ដេចខ្លះជាមួយនឹងឧបសគ្គទាំងនោះ?<br>▪ ផ្ដល់ពេលឱ្យដៃគូពិភាក្សាគ្នា បន្ទាប់មកលើកទឹកចិត្តឱ្យពួកគាត់ចែករំលែកនៅក្នុងក្រុមធំនូវអ្វីដែលគាត់បានជជែកគ្នា។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| | | | ▪ អ្នកសម្របសម្រួល កត់ត្រានូវអ្វីៗដែលពួកគាត់បានចែករំលែក រួមទាំងជួយដឹកនាំការពិភាក្សាជាមួយក្រុម ដើម្បីស្វែងរកដំណោះស្រាយដែលសមស្របសម្រាប់ឧបសគ្គមួយចំនួនដែលពួកគាត់បានលើកឡើងផងដែរ។ |
| ៥ | <u>លំហាត់សាកល្បងក្រោយវគ្គបណ្តុះបណ្តាល</u> | (៣០នាទី) | ▪ អ្នកសម្របសម្រួលពន្យល់ទៅអ្នកចូលរួមថា កាលពីជំនួបដំបូង លោកអ្នកបានធ្វើលំហាត់នេះរួចម្តងមកហើយ តែឥឡូវនេះ លោកអ្នកនឹងធ្វើម្តងទៀត ដើម្បីដឹងថាមុន និងក្រោយវគ្គបណ្តុះបណ្តាល លោកអ្នកទទួលបានចំណេះដឹងបានកម្រិតណា។<br>▪ ចែកលំហាត់សាកល្បងក្រោយវគ្គបណ្តុះបណ្តាលដល់អ្នកចូលរួម ហើយបន្ទាប់មកអ្នកចូលរួមចាប់ផ្តើមធ្វើលំហាត់។<br>▪ នៅពេលអ្នកចូលរួមធ្វើលំហាត់នេះរួចរាល់ហើយអ្នកសម្របសម្រួលចែកលំហាត់សាកល្បងមុនវគ្គបណ្តុះបណ្តាល (ជាឯកសារថតចម្លង) ដល់អ្នកចូលរួមដើម្បីឱ្យពួកគាត់ធ្វើការប្រៀបធៀបចំណេះដឹងរបស់គាត់ផ្ទាល់ៗខ្លួន នៅពេលពួកគាត់បានពិនិត្យរួចរាល់ហើយ អ្នកសម្របសម្រួលធ្វើការប្រមូលលំហាត់សាកល្បងក្រោយវគ្គបណ្តុះបណ្តាល។<br>**កំណត់សម្គាល់៖**<br>▪ អ្នកចូលរួមដែលអាចធ្វើលំហាត់សាកល្បងក្រោយវគ្គបណ្តុះបណ្តាលនេះបានលុះត្រាណាតែពួកគាត់បានធ្វើលំហាត់សាកល្បងមុនវគ្គបណ្តុះបណ្តាល និងបានចូលរួមបន្តរហូតមក។ |
| | | **សង្ខេបមេរៀន** (៥នាទី) | ▪ យើងទាំងអស់គ្នា ថ្ងៃនេះបានមកដល់វគ្គចុងក្រោយហើយ នៅមុននេះយើងក៏បានរំឭកឡើងវិញអំពីមេរៀននីមួយៗ ដែលយើងបានរៀនជាមួយគ្នា ហើយបន្ទាប់មកយើងក៏បានធ្វើការពិភាក្សាឆ្លុះបញ្ចាំង និងចែករំលែកអំពីភាពជោគជ័យ និងការលំបាកនានាដែលយើងទាំងអស់គ្នាបានជួបប្រទះនៅពេលដែលយើងយកខ្លឹមសារនៃការចិញ្ចឹមកូនបែបវិជ្ជមាន ទៅអនុវត្តជាក់ស្តែងជាមួយកូន ឬកុមាររួមទាំងគ្រួសារផងដែរ។ លើសពីនេះទៅទៀត យើងទាំងអស់គ្នាក៏បានធ្វើលំហាត់សាកល្បងម្តងទៀត ដើម្បីវាស់ស្ទង់ចំណេះរបស់យើងផ្ទាល់ៗខ្លួនថា នៅពេលមុន និងរហូតមកដល់បញ្ចប់វគ្គបណ្តុះបណ្តាលនេះយើងទាំងអស់គ្នាមានការយល់ដឹង និងចងចាំបានក្នុងកម្រិតណាទៀតផង។ |

| ល.រ | សកម្មភាព | រយៈពេល | ដំណើរការ និងវិធីសាស្ត្រ |
|---|---|---|---|
| ៦ | ការឆ្លុះបញ្ចាំង | **ការឆ្លុះបញ្ចាំងមេរៀន (១០នាទី)** | ▪ ក្រោយពេលបញ្ចប់ការសង្ខេបមេរៀន អ្នកសម្របសម្រួលថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ដែលបានលះបង់ពេលវេលា និងព្យាយាមចូលរួម រួមទាំងការចែករំលែកអំពីបទពិសោធន៍ក្នុងការចិញ្ចឹមកូនរបស់ខ្លួននៅក្នុងវគ្គបណ្ដុះបណ្ដាលរហូតដល់វគ្គបញ្ចប់នេះ បន្ទាប់មកសួរសំណួរ៖<br>☞ តើលោកអ្នកទទួលបានប្រយោជន៍អ្វីខ្លះ អំពីការមកចូលរួមរហូតដល់ពេលនេះ?<br>☞ តើលោកអ្នកបានសម្គាល់ពីអាកប្បកិរិយារបស់ខ្លួនមានការផ្លាស់ប្ដូរ ឬប្រែប្រួលអ្វីខ្លះដែលទាក់ទងនឹងការចិញ្ចឹមកូនរបស់លោកអ្នក?<br>☞ តើលោកអ្នកមានការគិត និងអារម្មណ៍ដូចម្ដេចនៅពេលបានឃើញពីលទ្ធផល និងចំណេះដឹងអំពីការចិញ្ចឹមកូនបែបវិជ្ជមានដែលលោកអ្នកទទួលបាននេះ?<br>☞ តាមរយៈការបំពេញសំណួរ ឬលំហាត់អម្សាញ់មិញនេះ តើលោកអ្នកមានការពេញចិត្តចំពោះខ្លួនឯងកម្រិតណាដែរ អំពីអ្វីដែលបានប្រឹងប្រែងយ៉ាងសកម្មក្នុងការផ្លាស់ប្ដូរការចិញ្ចឹមកូនតាមបែបវិជ្ជមាននេះ? |
| | | **បណ្ដាំផ្ញើ និងបិទវគ្គបណ្ដុះបណ្ដាល (៥នាទី)** | ▪ សូមលោកអ្នកបន្តកត់សម្គាល់ពីអាកប្បកិរិយារបស់ខ្លួនឯង<br>▪ សូមបន្តធ្វើឱ្យប្រសើរឡើងនូវការចិញ្ចឹមកូនបែបវិជ្ជមាន និងជួយគាំទ្រដល់កូន ឬកុមារ រួមទាំងកុមារដែលមានពិការភាពផងដែរ ដើម្បីជួយឱ្យពួកគាត់មានការលូតលាស់ និងអភិវឌ្ឍបានប្រសើរ។<br>▪ សូមថ្លែងអំណរគុណដល់ពួកគាត់ដែលបានមកចូលរួម។ |

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

USAID
FROM THE AMERICAN PEOPLE

Save the Children

unicef
ដើម្បីកុមារគ្រប់រូប